**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal university of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# របបគតិយុត្តនៃពាណិជ្ជកម្មតាម ប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **មូរ គីមហុង**

សាស្ត្រាចារ្យណែនាំ
លោក **ជិន វណ្ណារ៉ា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# លិខិតថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ បូរ គឹមហុង ជានិស្សិតថ្នាក់ បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី១៩ ក្រុម $L_4A_1$ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ**

❖ **លោកឪពុក បូរ គឹមសុង នឹងអ្នកម្តាយ ថន ណារិន និងបងប្អូនប្រុស ស្រី** ដែលចិញ្ចឹមបីបាច់ថែរក្សា អប់រំ ប្រៀនប្រដៅ និងផ្គត់ផ្គង់គ្រប់បែបយ៉ាងទាំងស្មារតី ទាំងសម្ភារៈ រហូតដល់រូបខ្ញុំបាទទទួលចំណេះដឹងដ៏ខ្ពង់ខ្ពស់ និងបានទទួលលទ្ធផលផ្លែផ្កាដូចសព្វថ្ងៃ។

❖ **ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស សាស្ត្រាចារ្យ** និងបុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានដឹកនាំពង្រឹងវិន័យ និងខិតខំប្រឹងប្រែងអស់កម្លាំងកាយចិត្ត ក្នុងការបង្ហាត់បង្រៀនដល់ខ្ញុំបាទផ្ទាល់។

❖ លោកសាស្ត្រាចារ្យ **ជិន វណ្ណារ៉ា** ជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀន និងបានចំណាយពេលវេលាដ៏មានតម្លៃរបស់លោក ដើម្បីធ្វើការពន្យល់ណែនាំផ្តល់ចំណេះដឹង និងបទពិសោធន៍ល្អៗក្នុងការស្រាវជ្រាវ ដើម្បីតាក់តែងសារណារនេះ។ ហើយរូបខ្ញុំបាទ ក៏សូមថ្លែងអំណរគុណ ជាពិសេសចំពោះការខិតខំប្រឹងប្រែងរបស់លោកសាស្ត្រាចារ្យ។

ជាទីបញ្ចប់ ខ្ញុំបាទសូមប្រសិទ្ធពរជ័យសិរីមង្គលដល់ លោកអ្នកដែលមានគុណទាំងអស់ខាងលើឱ្យ ទទួលបាននូវពុទ្ធពរទាំង បួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ ព្រមទាំងសម្រេចបាននូវគោលបំណង និងទទួលបាននូវសេចក្តីចម្រើន និងជោគជ័យគ្រប់បែបយ៉ាង ក្នុងការបំពេញ ការងារ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ជាបឋមខ្ញុំបាទសូមគោរពដល់សាស្ត្រាចារ្យណែនាំ និងមិត្តអ្នកអានទាំងអស់ជាទីស្រលាញ់ និងរាប់អាន។ ដើម្បីឆ្លើយតបឱ្យទាន់ពេលវេលា នឹងគោលបំណងបម្រើកិច្ចការស្រាវជ្រាវរបស់និស្សិតផ្នែកនីតិសាស្ត្រជំនាន់ក្រោយៗទៀតឱ្យមានសន្ទុះជឿនលឿន និងអភិវឌ្ឍសមតាមគោលបំណងប្រថ្នាផងនោះ។ ខ្ញុំបាទជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំសិក្សាទី៤ ថ្នាក់បង់ថ្លៃ ជំនាន់ទី១៩ និងនៅក្រុម $L_4A_1$ ឆ្នាំសិក្សា ២០១៨ - ២០១៩ មានសេចក្តីសោមនស្សរីករាយ និងមានមោទនភាពយ៉ាងខ្លាំងដោយបាន ស្រាវជ្រាវរៀបចំចងក្រង នូវអត្ថបទសារណារក្រោមប្រធានបទស្តីអំពី « **របបគតិយុត្តនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា** » ដើម្បីបញ្ជាក់អំពីការស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។ ជាពិសេសដើម្បីទុកឯកសារនេះ ជាជំនួយផ្នែកច្បាប់ ផ្នែកស្មារតី សម្រាប់និស្សិតទាំងឡាយដែលមានគោលបំណង សិក្សាស្រាវជ្រាវ និងចង់ដឹងអំពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឬ E-Commerce ។

ចំពោះខ្លឹមសារនៅក្នុងសារណានេះមានចំណុចខ្លះៗ ដែលមិនបានបន្តវិភាគឱ្យលម្អិតសព្វជ្រុងជ្រោយនោះទេ ប៉ុន្តែខ្ញុំបាទសង្ឃឹមយ៉ាងមុតមាំថាសារណារនេះគឺជាមូលដ្ឋាននៃចំណេះដឹង មួយផ្នែកដើម្បីស្វែងយល់ អំពីការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឬ E-Commerce ដែលមានទាំងផលវិជ្ជមាន និងផលអវិជ្ជមាន ក្នុងពេលកន្លងមក និងពេលអានាគត ដែលអាចឆ្លុះបញ្ចាំងទៅរកការវិវឌ្ឍនៃការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឬ E-Commerce ក្រោយៗទៀតឱ្យមានលក្ខណៈល្អប្រសើរប្រកបដោយចីរភាព។ ម្យ៉ាងវិញទៀតទាក់ទងនឹង ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឬ E-Commerce នេះគឺជាប្រធានបទមួយថ្មី ដែលទាមទារនូវរយៈពេលមួយសមស្រប សម្រាប់ការសិក្សាស្រាវជ្រាវ ដើម្បីទាញយកឯកសារឱ្យបានគ្រប់គ្រាន់យកមកចងក្រងឱ្យមានលក្ខណៈសព្វជ្រុងជ្រោយ។

ដោយមានការព្យាយាមខិតខំប្រឹងប្រែង យ៉ាងយកចិត្តទុកដាក់បំផុតក្នុងការប្រមូលចំណេះដឹងដែលបានសិក្សាអស់រយៈពេល ៤ឆ្នាំ កន្លងមកនេះហើយរួមផ្សំជាមួយការស្រាវជ្រាវឯកសារជាច្រើនពាក់ព័ន្ធវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឬ E-Commerce និងការអនុវត្តន៍នៅក្នុងវិស័យនេះ ធ្វើឱ្យសារណារបស់ខ្ញុំបាទសង្ឃឹមថានឹងទទួលបាននូវលទ្ធផលយ៉ាងល្អប្រសើរ។

ជាចុងក្រោយខ្ញុំបាទមានបេតិសោមនស្សរីករាយជាទីបំផុតដើម្បីរង់ចាំទទួលនូវ ការរិះគន់នូវកំហុសឆ្គងដើម្បីស្ថាបនាពីសំណាក់លោកសាស្ត្រាចារ្យ និស្សិត បញ្ញាវ័ន្ត និងមិត្តអ្នកអានទាំងអស់ក្នុងគោលបំណងស្ថាបនា និងកែរលំអរឱ្យមានភាពល្អប្រសើរជាងនេះថែមទៀត។

# មាតិកា

ទំព័រ

**អារម្ភកថា**

**សេចក្តីផ្តើម**

## ជំពូកទី១ សញ្ញាណនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក


**ផ្នែកទី១ សញ្ញាណនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** ........ ៤

**កថាខណ្ឌទី១ ប្រវត្តិសង្ខេបស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** ........ ៤

១. ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងទសវត្សរ៍ទី៧០ ........ ៤

២. ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងទសវត្សរ៍ទី៨០ ........ ៥

៣. ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងទសវត្សរ៍ទី៩០ ........ ៥

៤. ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងដើមសតវត្សរ៍ទី២១ ........ ៥

**កថាខណ្ឌទី២ បដិវត្តន៍ឧស្សាហកម្មដំណាក់កាល ៤** ........ ៦

**កថាខណ្ឌទី៣ សាយប៊ើស្បេស (CYBERSPACE)** ........ ៧

**កថាខណ្ឌទី៤ និយមន័យនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** ........ ៩

**កថាខណ្ឌទី៥ ទម្រង់នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** ........ ៩

**កថាខណ្ឌទី៦ គោលការណ៍សំខាន់ៗនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** ........ ១០

១.គោលការណ៍នៃភាពស្រុះស្រួលគ្នាជាអន្តរជាតិ ........ ១០

២.គោលការណ៍ក្របខណ្ឌច្បាប់ ........ ១១

៣.គោលការណ៍អព្យាក្រិតភាពនៃបច្ចេកវិទ្យា ........ ១១

៤.គោលការណ៍សមភាពនៃមុខងារ ........ ១១

៥.គោលការណ៍ផ្តល់នូវទំនុកចិត្ត ឬភាពដែលអាចទុកចិត្តបានដល់សាធារណៈជន ........ ១១

៦.គោលការណ៍សុវត្ថិភាពនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ........ ១២

**ផ្នែកទី២ ការបង្កើតកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** ........ ១២

**កថាខណ្ឌ១ សំណើក្នុងកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** ........ ១៤

១. ការបង្កើតសំណើនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ........ ១៥

២. ការអញ្ជើញឱ្យបង្កើតសំណើនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ................. ១៦
៣. ពេលវេលា និងទីកន្លែងនៃការបញ្ជូននូវសំណើរ ................. ១៧
៣.១ ពេលវេលានៃការបញ្ជូននូវសំណើរតាមរយៈប្រព័ន្ធអេឡិចត្រូនិក ................. ១៧
៣.២ ទីកន្លែងនៃការបញ្ជូននូវសំណើរតាមរយៈប្រព័ន្ធអេឡិចត្រូនិក ................. ១៧
**កថាខណ្ឌ២ ស្វីកាក្នុងកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ................. ១៧**
១. លក្ខណៈនៃស្វីការ ................. ១៨
២. អនុភាពនៃស្វីការ ................. ១៩
៣. ពេលវេលា និងទីកន្លែងនៃការទទួលស្វីការ ................. ១៩
៣.១ ពេលវេលានៃការទទួលទំនាក់ទំនងអេឡិចត្រូនិក ................. ១៩
៣.២ ទីកន្លែងនៃការទទួលទំនាក់ទំនងអេឡិចត្រូនិក ................. ២០
**កថាខណ្ឌ៣ ការបង្កើតកិច្ចសន្យាដោយប្រព័ន្ធស្វ័យប្រវត្តិ ................. ២០**
**កថាខណ្ឌ៤ កំហុសឆ្គងក្នុងទំនាក់ទំនងអេឡិចត្រូនិក ................. ២១**
១. ការកែតម្រូវដែលទទួលស្គាល់ដោយច្បាប់ ................. ២១
២. ការកែតម្រូវទំនាក់ទំនងអេឡិចត្រូនិក ................. ២១
**កថាខណ្ឌ៥ អានុភាពគតិយុត្តនៃទំនាក់ទំនងអេឡិចត្រូនិក ................. ២២**
១. លក្ខខណ្ឌតម្រូវជាលាយល័ក្ខអក្សរ ................. ២២
២. លក្ខខណ្ឌតម្រូវស្តីពីភស្តុតាង ................. ២៣
៣. លក្ខខណ្ឌតម្រូវលើការរក្សាទុកកំណត់ត្រា ................. ២៣
៤. លក្ខខណ្ឌតម្រូវស្តីពីទម្រង់បែបបទដែលបានកំណត់ ................. ២៤
៥. លក្ខខណ្ឌតម្រូវចំពោះការរក្សាព័ត៌មានតាមទម្រង់ដើម ................. ២៤
៦. លក្ខខណ្ឌតម្រូវចំពោះហត្ថលេខា ................. ២៤
**កថាខណ្ឌ៦ ការព្រមព្រាងរបស់គូភាគីចំពោះសុពលភាពនៃទំនាក់ទំនងអេឡិចត្រូនិក ................. ២៦**
**ផ្នែកទី៣ សុវត្ថិភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ................. ២៦**
**កថាខណ្ឌ១ សមត្ថកិច្ចរបស់អាជ្ញាធរក្នុងការគ្រប់គ្រង និងផ្តល់នីតិវិធីដើម្បីធានាសុវត្ថិភាព ................. ២៦**
**កថាខណ្ឌ២ សុវត្ថិភាពកំណត់ត្រា ................. ២៧**
**កថាខណ្ឌ៣ សុវត្ថិភាពហត្ថលេខាអេឡិចត្រូនិក ................. ២៧**

**កថាខណ្ឌ៤ ការសន្មតកំណត់ត្រា និងហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព** ............ ២៨
១. ការសន្មតអំពីសុវត្ថិភាពកំណត់ត្រា ............ ២៨
២. ការសន្មតអំពីសុវត្ថិភាពហត្ថលេខាអេឡិចត្រូនិក ............ ២៨
**កថាខណ្ឌ៥ ភស្តុតាងអេឡិចត្រូនិក** ............ ២៩
១. ប្រព័ន្ធអេឡិចត្រូនិកដែលមានសុក្រិតភាព............ ២៩
២. សុក្រឹតភាពនៃព័ត៌មាន ............ ៣០
៣. បទដ្ឋានដែលបញ្ជាក់អំពីសុក្រឹតភាពនៃកំណត់ត្រាអេឡិចត្រូនិក............ ៣១
៤. នីតិវិធីផ្សេងៗទៀតក្នុងការបង្កើតភស្តុតាងអេឡិចត្រូនិក............ ៣១
៤.១. ការទទួលយកភស្តុតាងអេឡិចត្រូនិកពីបណ្តាប្រទេសផ្សេងត្រឹមជាកំណត់ត្រា .... ៣២
៤.២. ការទទួលស្គាល់ភស្តុតាងអេឡិចត្រូនិកពីបណ្តាលប្រទេសផ្សេងៗទៀតត្រឹមជាព័ត៌មានអេឡិចត្រូនិក ............ ៣២
៥. ការបង្ហាញពីយថាភូតភាពនៃភស្តុតាងអេឡិចត្រូនិក ............ ៣២
៥.១. បន្ទុកក្នុងការបង្ហាញពីយថាភូតភាពនៃភស្តុតាងអេឡិចត្រូនិក............ ៣២
៥.២. ការចេញសេចក្តីបញ្ជាក់ពីយថាភូតភាពនៃភស្តុតាងអេឡិចត្រូនិក............ ៣៣
៦. ឯកសារជាភស្តុតាងអេឡិចត្រូនិកដែលបានបោះពុម្ពចេញ ............ ៣៣
**កថាខណ្ឌ៦ កិច្ចការពារអ្នកប្រើប្រាស់នៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** ............ ៣៣
១. ការការពារព័ត៌មាននៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក............ ៣៤
២.ការការពារអ្នកប្រើប្រាស់នៅក្នុងទំនាក់ទំនងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលមិនបានស្នើសុំ............ ៣៥
៣. ការការពារទៅលើទិន្នន័យ............ ៣៥

## ជំពូកទី២ ដំណើរការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

**ផ្នែកទី១ ទំនាក់ទំនងនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** ............ ៣៧
**កថាខណ្ឌ១ ទំនាក់ទំនងពេលវេលា និងទីកន្លែងបញ្ជូនចេញ និងទទួល នៃទំនាក់ទំនងអេឡិចត្រូនិក** ............ ៣៧
**កថាខណ្ឌ២ ទំនាក់ទំនងពេលវេលា និងទីកន្លែងទទួល** ............ ៣៨
**កថាខណ្ឌ៣ ទីតាំងអាជីវកម្ម** ............ ៣៨
**ផ្នែកទី២ សិទ្ធិ និងករណីកិច្ចរបស់ភាគីក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**............ ៣៩

**កថាខណ្ឌ១ សិទ្ធិ និងករណីកិច្ចរបស់អ្នកលក់ទំនិញ ឬសេវា ដោយប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិក** ........ ៣៩

១. ករណីកិច្ចរបស់អ្នកលក់ទំនិញ ឬសេវា ដោយប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិក ........ ៣៩

១-១ ករណីកិច្ចផ្ទេរសិទ្ធិ ........ ៣៩

១-២. ករណីកិច្ចរក្សាទុកដែលជាកម្មវត្ថុ ........ ៣៩

២. សិទ្ធិរបស់អ្នកលក់ទំនិញ ឬសេវា ដោយប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិក ........ ៣៩

២-១. សិទ្ធិទាមទារឱ្យបង់ប្រាក់ថ្លៃទិញ ........ ៣៩

២- ២. ការតវ៉ាឱ្យអនុវត្តព្រមគ្នា ........ ៣៩

**កថាខណ្ឌ២ សិទ្ធិ និងករណីកិច្ចរបស់អ្នកទិញទំនិញ ឬសេវា ដោយប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិក** ........ ៤០

១. ករណីកិច្ចរបស់អ្នកទិញទំនិញ ឬសេវា ដោយប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិក ........ ៤០

១.១. ករណីកិច្ចបង់ថ្លៃទិញ ឬសេវា ........ ៤០

១.២. ករណីកិច្ចទទួលវត្ថុ ឬសេវាដែលខ្លួនបានទិញ ........ ៤០

២. សិទ្ធិរបស់អ្នកទិញទំនិញ ឬសេវា ដោយប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិក ........ ៤១

២-១. សិទ្ធិទទួលទំនិញ ........ ៤១

២-២. សិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នា ........ ៤១

២-៣. ការតវ៉ាដោយមានការបារម្ភ ........ ៤១

**ផ្នែកទី៣ ដំណើការទូទាត់ ឬផ្ទេរប្រាក់ជាអេឡិចត្រូនិកនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** ........ ៤១

**កថាខណ្ឌ១ ការទូទាត់ ឬផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក** ........ ៤២

**កថាខណ្ឌ២ ការទទួលខុសត្រូវរបស់អ្នកផ្ដល់សេវាទូទាត់** ........ ៤២

១. ការត្រួតពិនិត្យអតិថិជនដោយអ្នកផ្ដល់សេវាទូទាត់ ........ ៤២

២. ឧបករណ៍ទូទាត់អេឡិចត្រូនិក ........ ៤៣

៣. ការរួចផុតពីការទទួលខុសត្រូវរបស់អ្នកផ្ដល់សេវាទូទាត់ ........ ៤៣

**កថាខណ្ឌ៣ ការទទួលខុសត្រូវរបស់អតិថិជន** ........ ៤៤

១. ការជូនដំណឹងរបស់អតិថិជនចំពោះការដែលខូចខាត ........ ៤៤

២. ក្នុងករណីមានបន្ទុកគ្រប់គ្រាន់បង្ហាញពីកំហុសអតិថិជន ........ ៤៤

៣. ក្នុងករណីមិនមានបន្ទុកគ្រប់គ្រាន់បង្ហាញពីកំហុសអតិថិជន......................................... ៤៤
**ផ្នែកទី៤ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដោយអន្តរការី និងអ្នកផ្តល់សេវា**......................... ៤៤
**កថាខណ្ឌ១ តួនាទីរបស់អន្តរការី និងអ្នកផ្តល់សេវា**....................................................... ៤៥
១. តួនាទីរបស់អន្តរការី....................................................................................... ៤៥
២. តួនាទីរបស់អ្នកផ្តល់សេវា ................................................................................. ៤៥
**កថាខណ្ឌ២ កាតព្វកិច្ចរបស់អន្តរការី និងអ្នកផ្តល់សេវា** .................................................... ៤៦
**កថាខណ្ឌ៣ ការមិនទទួលខុសត្រូវរបស់អន្តរការី និងអ្នកផ្តល់សេវា**......................................៤៧
១. ការមិនទទួលខុសត្រូវរបស់អន្តរការី និងអ្នកផ្តល់សេវា...................................................៤៧
២. ការមិនអាចរួចផុតពីការទទួលខុសត្រូវរបស់អន្តរការី និងអ្នកផ្តល់សេវា ............................៤៧
៣. ក្រមសីលធម៌សម្រាប់អន្តរការី និងអ្នកផ្តល់សេវា.............................................................. ៤៨
**ផ្នែកទី៥ ការបញ្ចប់នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** ....................................................... ៤៨
**កថាខណ្ឌ១ ការទូទាត់ប្រាក់ទៅលើទំនិញ ឬសេវា**............................................................. ៤៩
**កថាខណ្ឌ២ ការបញ្ជូនចេញដោយជោគជ័យ** ......................................................................... ៤៩
**កថាខណ្ឌ៣ ការបានទទួលដោយជោគជ័យ**........................................................................... ៤៩
**ផ្នែកទី៦ សកម្មភាព និងប្រតិបត្តិការរបស់រដ្ឋាភិបាលលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**..... ៥០
**កថាខណ្ឌ១ ការប្រើប្រាស់ទម្រង់អេឡិចត្រូនិកដោយរដ្ឋាភិបាល**............................................. ៥០
**កថាខណ្ឌ២ តួនាទីរបស់ក្រសួង ឬស្ថាប័ន** ......................................................................... ៥០

## ជំពូកទី៣ ឧក្រិដ្ឋកម្មបច្ចេកវិទ្យាក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងការទប់ស្កាត់តាមបទពិសោធន៍កម្ពុជា

**ផ្នែកទី១ បទល្មើសដែលកើតចេញពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** ................................ ៥២
**កថាខណ្ឌ១ ប្រភេទបទល្មើសដែលកើតមានលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**............ ៥២
**កថាខណ្ឌ២ លក្ខណៈសម្គាល់ប្រភេទបទល្មើសឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យាក្នុងរឿងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**.........................................................................................៥៣
១. ការចូលប្រើប្រាស់ ទាញយក ថតចម្លង ស្រង់យក ឬធ្វើឲ្យបែកធ្លាយទិន្នន័យ ដែលស្ថិតនៅក្រោមការរក្សាទុករបស់បុគ្គលផ្សេងទៀត ...........................................................៥៣
២. ការលួចអត្តសញ្ញាណ..........................................................................................៥៣
៣. ការក្លែងប្រព័ន្ធអេឡិចត្រូនិក...............................................................................៥៣

៤. ការបង្កើតកូដព្យាបាល ...... ៥៤
៥. ការបំពានលើកូដនីយកម្ម ...... ៥៤
៦. ការផ្ញើទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំ ...... ៥៤
៧. ការមិនអនុវត្តកាតព្វកិច្ចការពារទិន្នន័យ ...... ៥៤
៨. បទមិនរាយការណ៍អំពីព័ត៌មានខុសច្បាប់ ...... ៥៤
៩. ការមិនអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈ និងបទប្បញ្ញត្តិពាក់ព័ន្ធ ...... ៥៤
១០. ការបំពានលើការចេញសេចក្តីបញ្ជាក់យថាភូតភាព ...... ៥៤
១១. ការទូទាត់សងប្រាក់ជាអេឡិចត្រូនិកដោយគ្មានការអនុញ្ញាត ...... ៥៤
១២. បទក្លែងបន្លំឧបករណ៍ទូទាត់សងប្រាកជាអេឡិចត្រូនិក ...... ៥៥
**ផ្នែកទី២ ការទប់ស្កាត់រយៈពេលកន្លងមកតាមបទពិសោធន៍កម្ពុជា ...... ៥៥**
**កថាខណ្ឌ១ ភារកិច្ចរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ...... ៥៥**
**កថាខណ្ឌ២ រចនាសម្ព័ន្ធរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ...... ៥៦**
**កថាខណ្ឌ៣ តួនាទីរបស់ការិយាល័យប្រឆាំងបទល្មើសបច្ចេកវិទ្យា ...... ៥៩**
**សេចក្តីសន្និដ្ឋាន ...... ៦០**
**អនុសាសន៍ ...... ៦៣**
**បញ្ជីឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

អស់រយៈពេលជិត៥០០ឆ្នាំមកហើយ រាប់ពីការចាប់កំណើតនៃឧស្សាហកម្មដែលបានធ្វើឱ្យមានការផ្លាស់ប្តូរយ៉ាងច្រើនជាពិសេសការរស់នៅរបស់ប្រជាជនក្នុងពិភពលោកតែម្តង ពោលគឺបដិវត្តន៍ឧស្សាហកម្មនេះហើយដែលបានក្លាយជាផ្នែកមួយដ៏សំខាន់ នៃប្រវត្តិសាស្ត្រមនុស្សជាតិ[1]។ មកដល់បច្ចុប្បន្នបដិវត្តន៍ឧស្សាហកម្មត្រូវបានឆ្លងកាត់ ឬ ត្រូវបានគេបែងចែកជា៤ដំណាក់កាលធំៗ[2]។ ដំណាក់កាលទី១ នៅឆ្នាំ១៧៦៥ ជាពេលចាប់កំណើតរបស់ម៉ាស៊ីនដើរដោយចំហាយទឹក។ ដំណាក់កាលទី២ នៅឆ្នាំ១៨៧០ ជាពេលដែលមានការកកើតនូវភ្លើងអគ្គីសនីដែលមានតម្លៃទាប និងប្រើប្រាស់បានដោយមនុស្សទូទៅ។ ដំណាក់កាលទី៣ នៅឆ្នាំ១៩៦៩ ជាការបង្កើតនូវថាមពលនុយក្លេអ៊ែ ឧបករណ៍អេឡិចត្រូនិច មានដូចជាប្រព័ន្ធទូរគមនាគម៍ ដែលមានទូរស័ព្ទចល័តតំបូង Motorola និងកុំព្យូទ័ររបស់ Apple ក្នុងពេលជាមួយគ្នា ដែលនេះជាពេលវេលាដែលបច្ចេកវិទ្យាមានទំហំតូចទៅៗ សម្រាប់ភាពងាយស្រួលក្នុងការប្រើប្រាស់របស់មនុស្សទូទៅ។ ដំណាក់កាលទី៤ នៅពេលបច្ចុប្បន្ន ជាការចាក់បញ្ចូលគ្នារវាងពិភពឌីជីថល និងពិភពពិត ក្នុងនោះមានជាអាទ៍ដូចជាអ៊ីនធើណែតល្បឿនលឿន ទិន្នន័យអេឡិចត្រូនិកដែលជាបច្ចេកវិទ្យាចុងក្រោយនេះ កំពុងស្ថិតនៅក្នុងជំហានដំបូងនៅឡើយ។

តាមរយៈការរីកលូតលាស់នូវវិស័យឧស្សាហកម្មឥតឈប់ឈរ ដែលគេអាចមើលឃើញតាមរយៈបដិវត្តន៍ឧស្សាហកម្មទាំង៤ដំណាក់កាលខាងលើ ជាពិសេសបដិវត្តន៍ឧស្សាហកម្មទី៣ និងទី៤ ជាបដិវត្តន៍ផ្តោតទៅលើប្រព័ន្ធបច្ចេកវិទ្យាអេឡិចត្រូនិក សាយប៊ើស្ប៉េស (Cyberspace) ឬអ៊ីនធើណែត ដែលធ្វើឱ្យវិស័យឧស្សាហកម្មរីកចម្រើនឡើងៗ ។ ពិសេសនោះគេឃើញមានការប្រើប្រាស់នូវបច្ចេកវិទ្យា ដូចជាប្រព័ន្ធអេឡិចត្រូនិក សាយប៊ើស្ប៉េស (Cyberspace) ឬអ៊ីនធើណែត យកមកប្រើប្រាស់នៅក្នុងវិស័យឧស្សាហកម្ម និង ពាណិជ្ជកម្ម ដូចជាតាមរយៈប្រព័ន្ធបណ្តាញសង្គមនានាដែលរួមមានដូចជា Facebook Tweeter YouTube line Instagram Telegram និងបណ្តាញផ្សេងៗក្នុងការធ្វើជំនួញ ដូចជាការផ្សព្វផ្សាយនូវផលិតផលរបស់ខ្លួនទៅកាន់អតិថិជនរបស់ខ្លួនបានគ្រប់ទីកន្លែងក្នុងការធ្វើពាណិជ្ជកម្ម ដូចជាការទិញទំនិញ ឬសេវា ការលក់ទំនិញ និងសេវា។ នៅពេលដែលពិភពលោកកាន់តែមានការរីកចម្រើនខ្លាំងនោះ បានបង្ហាញថា ការដែលយើងបានយកមធ្យោបាយប្រព័ន្ធ

[1]សូមពិគ្រោះ គី ចំណា, "*តើបដិវត្តន៍ឧស្សាហកម្មទាំងបួនដំណាក់កាលមានអ្វីខ្លះ?*", www.thmeythmey.com, ចុះផ្សាយថ្ងៃទី២០ ខែមករា ឆ្នាំ២០០១៩ , (កថាខណ្ឌទី១) , ចូលទស្សនាថ្ងៃទី ១៥ ខែមេសា ឆ្នាំ២០១៩ វេលាម៉ោង ៣ និង២៥នាទីរសៀល ,៖ "បដិវត្តន៍ឧស្សាហកម្មទាំងបួនដំណាក់កាល"

[2] សូមពិគ្រោះ គី ចំណា, "*តើបដិវត្តន៍ឧស្សាហកម្មទាំងបួនដំណាក់កាលមានអ្វីខ្លះ?*", www.thmeythmey.com, ចុះផ្សាយថ្ងៃទី២០ ខែមករា ឆ្នាំ២០០១៩ , (កថាខណ្ឌទី២) , ចូលទស្សនាថ្ងៃទី ១៥ ខែមេសា ឆ្នាំ២០១៩ វេលាម៉ោង ៣ និង២៥នាទីរសៀល,៖ "បដិវត្តន៍ឧស្សាហកម្មទាំងបួនដំណាក់កាល"

អេឡិចត្រូនិកមកប្រើប្រាស់ ធ្វើជាមធ្យោបាយអាជីវកម្មនៅក្នុងវិស័យពាណិជ្ជកម្មរបស់ខ្លួន បានក្លាចទៅជាមធ្យោបាយដ៏សំខាន់នៅក្នុងយុគសម័យឌីជីថលនេះ។ ជាក់ស្តែងការធ្វើអាជីវកម្មពាណិជ្ជកម្មតាមរយៈប្រព័ន្ធអេឡិចត្រូនិក ដូចជានៅលើបណ្តាញសង្គម និងនៅលើវេបសាយធំៗនានា ដូចជា Alibaba.com ដែលជាវេបសាយដ៏ធំនៅប្រទេសចិន និង Amazon.com របស់សហរដ្ឋអាមេរិច។ មធ្យោបាយពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិចគ្រប់ដណ្តប់ទូទាំងពិភពលោក ទាំងមូលនៅក្នុងពេលបច្ចុប្បន្ននេះ ប្រជាជននៅទីណា កន្លែងណាក៏អាចធ្វើពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិកនេះបានដូចៗគ្នា។ មិនខុសគ្នាអ្វីទៅនឹងបរិបទពិភពលោកដែល កម្ពុជាដែលជាប្រទេសស្ថិតនៅក្នុងដំណាក់ការប្រទេសរីកចម្រើនក៏ដូចគ្នាដែល ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកំពុងតែទទួលបាននូវការគាំទ្រយ៉ាងច្រើនពីប្រជាជន បើទោះបីជារបបពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកជាសញ្ញាណថ្មី សម្រាប់ពួកគាត់ក៏ដោយ។ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវបានផ្តល់និយមន័យដោយយោងតាមមាត្រា១៤ នៃច្បាប់ស្តីពីទំនុកចិត្តនៅក្នុងសេដ្ឋកិច្ចនូមមេរិករបស់ប្រទេសបារាំងឆ្នាំ២០០៤ ថាជាសកម្មភាពសេដ្ឋកិច្ចដែលបុគ្គលម្នាក់បានធ្វើ ឬនឹងធ្វើពីចម្ងាយតាមមធ្យោបាយអេឡិចត្រូនិកដើម្បីផ្តល់នូវទំនិញ ឬសេវាកម្ម[3]។

ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះ ក៏ទាមទារផងដែលនូវច្បាប់ដើម្បីធ្វើការគ្រប់គ្រងនូវរបបគតិយុត្តថ្មីបែបបច្ចេកវិទ្យានេះផងដែល ដែលនៅដំណាក់ការបច្ចុប្បន្នស្ថាប័នដែលមានសមត្ថកិច្ចគឺក្រសួងពាណិជ្ជកម្មកំពុងតែខ្នះខ្នែងតាក់តែងនៅ សេចក្តីព្រាងច្បាប់នេះដើម្បីធ្វើការគ្រប់គ្រងទៅលើដំណើការនៃការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះ ឱ្យដំណើការទៅបានយ៉ាងល្អ ស្របពេលដែលបណ្តាលប្រទេសនៅលើពិភពលោកនេះមានសឹងគ្រប់ប្រទេសទៅហើយ ជាពិសេសប្រទេសក្នុងតំបន់ដូចជា សឹង្ហបុរី ថៃ វៀតណាម ហ្វីលីពីន។ គេរំពឹងទុកថាច្បាប់ស្តីពីការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះនឹងសម្រេចបាននៅពេលខាងមុខនេះផងដែល[4] រួមទាំងច្បាប់ពាក់ព័ន្ធដទៃទៀតដែលបម្រើដល់ការធ្វើប្រតិបត្តិការ លើការធ្វើពាណិជ្ជកម្មតាមបែប្រភេទនេះកាន់តែប្រសើរនាពេលខាងមុខ។ តើការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះមានរបបគតិយុត្តយ៉ាងដូចម្តេចចំពោះការបង្កើត ដំណើការ និងការបញ្ចប់? តើមានធាតុផ្សំសំខាន់ៗអ្វីខ្លះដែល

---

[3] សូមពិគ្រោះ អុន រតនា, អ៊ុត ចាន់លីនណា,សារណាបញ្ចប់ការសិក្សាស្តីពី *ពាណិជ្ជកម្មអេឡិចត្រូនិក* , ឆ្នាំបោះផ្សាយ ២០១២, ទំព័រទី ៣ ៖ "ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវបានផ្តល់និយមន័យដោយយោងតាមមាត្រា១៤ នៃច្បាប់ស្តីពីទំនុកចិត្តនៅក្នុងសេដ្ឋកិច្ចនូមមេរិករបស់ប្រទេសបារាំងឆ្នាំ២០០៤ ថាជាសកម្មភាពសេដ្ឋកិច្ចដែលបុគ្គលម្នាក់បានធ្វើ ឬនឹងធ្វើពីចម្ងាយតាមមធ្យោបាយអេឡិចត្រូនិកដើម្បីផ្តល់នូវទំនិញ ឬសេវាកម្ម"

[4]សូមពិគ្រោះ "រដ្ឋលេខាធិការពាណិជ្ជកម្ម៖ ប្រតិបត្តិការធុរកិច្ច តាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា មានសន្ទុះកើនឡើងខ្លាំង", *www.moc.com.kh, ចុះផ្សាយថ្ងៃទី២៥ ខែមករា ឆ្នាំ២០០១៩ , (កថាខណ្ឌទី៤) , « មិន» , ចូលទស្សនាថ្ងៃទី ១៥ ខែមេសា ឆ្នាំ២០១៩ វេលាម៉ោង ៣ និង៤០នាទីរសៀល,*៖ "ច្បាប់ស្តីពីការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះនឹងសម្រេចបាននៅពេលខាងមុខ"

នាំឱ្យការ ធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះ ដំណើការទៅប្រកបដោយជោគជ័យ?តើការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកយ៉ាងដូចម្ដេចទើបទទួលបានសុវត្ថិភាព? ដើម្បីធ្វើការឆ្លើយតបទៅនឹងសំនួរខាងលើឱ្យបានក្បោះក្បាយជុំវិញប្រធានបទខាងលើនេះ យើងសូមធ្វើការសិក្សាទៅលើ បីជំពូកធំៗ ដោយសិក្សាទៅលើ សញ្ញាណនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក **(ជំពូកទី១)** ដែលជាចំណុចផ្ដើមនាំឱ្យមាននៅដំណើការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងសិក្សាទៅលើ ការដំណើរការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកជា **(ជំពូកទី២)** ដែលជាដំណាក់ការនាំឱ្យមានដំណើការអនុវត្តនៅប្រតិបត្តិការ ស្ដីពីការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និង ជំពូកចុងក្រោយយើងនឹងធ្វើការសិក្សាទៅលើ ឧក្រិដ្ឋកម្មបច្ចេកវិទ្យាក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិក និងការទប់ស្កាត់តាមបទពិសោធន៍កម្ពុជា **(ជំពូកទី៣)** ដែលជាដំណាក់ការចុងក្រោយនាំឱ្យ ប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវបានបញ្ចប់។

# ជំពូកទី១

# សញ្ញាណនៃពាណិជ្ជកម្ម
# តាមប្រព័ន្ធអេឡិចត្រូនិក
# និង កិច្ចសន្យាពាណិជ្ជកម្ម
# តាមប្រព័ន្ធអេឡិចត្រូនិក

## ជំពូកទី១ សញ្ញាណនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

នៅក្នុងជំពូកដំបូងនៃការសិក្សាស្រាវជ្រាវដែលចងក្រងទៅជាសារណា ដើម្បីបញ្ចប់ការសិក្សានេះ យើងនឹងសិក្សាទៅលើដំណាក់កាលដំបូង នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឬ (E-COMMERCE) ដែលស្ដីពីសញ្ញាណនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និង ការបង្កើតនូវកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-COMMERCE) ដែលមានទម្រង់សឹងដូចគ្នា ទៅនឹងកិច្ចសន្យាលក់ទិញដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧ ផងដែរ។ នៅក្នុងជំពូកទីមួយនេះយើងនឹងសិក្សាទៅលើបីផ្នែកសំខាន់ៗ ដែល **(ផ្នែកទី១)** យើងនឹងសិក្សាទៅលើសញ្ញាណនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នឹងការបង្កើតកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក **(ផ្នែកទី២)** និង សុវត្ថិភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក **(ផ្នែកទី៣)** ។

### ផ្នែកទី១ សញ្ញាណនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

នៅក្នុងការសិក្សាអំពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះ ជាដំបូងយើងនឹងធ្វើកាសិក្សាទៅលើសញ្ញាណនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយសិក្សាទៅលើ បដិវត្តន៍ឧស្សាហកម្មដំណាក់កាល៤ **(កថាខណ្ឌ២)** ការរីកចម្រើនសាយបើស្បែស **(កថាខណ្ឌ៣)** នឹងសិក្សាទៅលើនិយមន័យនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក **(កថាខណ្ឌ៤)** ទម្រង់នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក **(កថាខណ្ឌ៥)** នឹងគោលការណ៍សំខាន់ៗដែលមាននៅក្នុងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក **(កថាខណ្ឌ៦)** និងប្រវត្តិសង្ខេបស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក **(កថាខណ្ឌ១)**។

#### កថាខណ្ឌទី១ ប្រវត្តិសង្ខេបស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក[5]

នៅក្នុងកថាខណ្ឌទី១ ដែលសិក្សាទៅលើប្រវត្តិសង្ខេបស្ដីពីការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះយើងនឹងសិក្សាទៅលើ៤ចំណុចសំខាន់ដែលជា ដំណើរនៃការរីកចម្រើនឡើងនៃការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក យើងនឹងសិក្សាទៅលើ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងទស្សវត្សទី៧០ **(ចំណុចទី១)** ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងទស្សវត្សទី៨០ **(ចំណុចទី២)** ពាណិ- ជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងទស្សវត្សទី៩០ **(ចំណុចទី៣)** ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងដើមសតវត្សទី២១ **(ចំណុចទី៤)** ។

#### ១. ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងទស្សវត្សទី៧០

ទម្រង់នៃការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនមែនទើបតែចាប់កំណើត លេចឡើងកកើតមានឲ្យប្រើប្រាស់ឡើង ទើបតែកើតមានឡើងនូវពេលដែលលេចមានឡើងនូវបដិវត្តន៍ឧស្សាហកម្មដំណាក់កាលទី៤ នេះឡើងទេ ក៏ប៉ុន្តែកើតមានឡើងតាំងពីនៅក្នុងសម័យបដិវត្តន៍ឧស្សាហកម្មដំ

[5] សូមពិគ្រោះ: Jenifer Mitra, Introduction E-COMMERCE ចុះថ្ងៃទី ១៤ ខែ មេសា ឆ្នាំ២០១០

ណាក់កាលទី៣ មកម្លេះ។ ក្នុងសម័យទស្សវត្សទី៧០ គេឃើញមាននូវការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកចាប់ផ្តើមកើតមានឡើង ព្រោះថាការកើតមាននៅក្នុងសម័យនោះបដិវត្តន៍ឧស្សាហកម្មដំណាក់កាលទី៣ ដែលជាសម័យបដិវត្តន៍ដោយមានការរីកចម្រើននូវបច្ចេកវិទ្យានៅដំណាក់កាលដំបូង នៅពេលនោះគេឃើញមានការប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យាតិចណូឡូជីដូចជា Electronic Data Interchange (EDI) និង Electronic Fund Transfer (EFT) និងមានការអនុញ្ញាតឲ្យមានការធ្វើជំនួញដោយមានការផ្ញើឯកសារដែលទាក់ទងទៅនឹង ការធ្វើពាណិជ្ជកម្មតាមរយៈប្រព័ន្ធអេឡិចត្រូនិកដូចជា ការបញ្ជាទិញតាមអេឡិចត្រូនិក និងការទូទាត់អេឡិចត្រូនិក ដូចជាការទូទាត់វិក័យបត្រ។

## ២. ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងទស្សវត្សទី៨០

នៅក្នុងទស្សវត្សទី៨០វិញម្តង ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានវិវត្តន៍ខ្លួនឡើងបន្ថែមទៀត ដោយមានការរីកចម្រើនឡើងនូវប្រព័ន្ធបច្ចេកវិទ្យាដែលធ្វើឲ្យការធ្វើពាណិជ្ជកម្មក្រោមទម្រង់អេឡិចត្រូនិកនេះកាន់តែរីកចម្រើនឡើង ដូចជាតាមរយៈការរីចចម្រើនឡើង និងការទទួលស្គាល់ Credit Cards នឹងការទូទាត់ ការបើកប្រាក់តាមរយៈម៉ាស៊ីន (ATM) នឹងការកើតមានឡើងនូវ Telephone Banking និង Airline Reservation System ជាដើម។

## ៣. ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងទស្សវត្សទី៩០

បន្តមកទស្សវត្សទី៩០វិញម្តង ពោលគឺនៅចុងសតវត្សទី២០ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឈានដល់ការរីកចម្រើនមួយកម្រិតទៀត នោះគឺនៅក្នុងទស្សវត្សទី៩០នេះ ទាំងពាណិជ្ជករ និងអ្នកប្រើប្រាស់បានប្រើប្រាស់នូវប្រព័ន្ធអ៊ិនធើណែត ហើយរួមបញ្ចូលគ្នាធ្វើសហប្រតិបត្តិការណ៍ដោយចាប់ផ្តើមប្រើប្រាស់ Dot-coms ឬអ៊ិនធើណេត។ នៅពេលនោះក៏មានការចាប់ផ្តើមកម្មវិធី ឬការអនុវត្តក្រោមគំនិតប្រកបដោយភាពច្នៃប្រឌិតចាប់ផ្តើមមានការលក់ តាមរយៈប្រព័ន្ធអេឡិចត្រូនិកដោយផ្ទាល់តែម្តង។

## ៤. ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងដើមសតវត្សទី២១

នៅដើមឆ្នាំ២០០០ ការធ្វើជំនួញដោយក្រុមហ៊ុននៅសហភាពអឺរ៉ុប នៅសហរដ្ឋអាមេរិច បានចាប់ផ្តើមផ្តត់ផ្គង់នូវសេវារបស់ខ្លួនតាមរយៈបណ្តាញទូទាំងពិភពលោក ដែលគេហៅថា World Wide Web ។ ហើយចាប់ពីពេលនោះហើយបានជាមនុស្សបានចាប់ផ្តើមមូលមាត់គ្នា សហការណ៍គ្នាក្នុងការប្រើប្រាស់ នូវពាក្យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឬ E-Commerce ហើយដែលកាន់តែពេញនិយមនូវពេលដែលកកើតមានឡើងនូវបដិវត្តន៍ឧស្សាហកម្មដំណាក់កាល៤ ដែលយើងនឹងសិក្សានៅផ្នែកខាងក្រោមបន្ទាប់ ដែលការរីកចម្រើននៃបដិវត្តន៍ឧស្សាហកម្ម បានធ្វើឲ្យការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក កាន់តែទទួលបាននូវការចាប់អារម្មណ៍កាន់តែខ្លាំងសម្រាប់មជ្ឈដ្ឋានទូទៅជាពិសេសពីសំណាក់ពាណិជ្ជករដែលធ្វើជំនួញ ឬពាណិជ្ជកម្ម ។

**កថាខណ្ឌទី២ បដិវត្តន៍ឧស្សាហកម្មដំណាក់កាល ៤**[6]

បដិវត្តន៍ឧស្សាហកម្មទី៤ បាននឹងកំពុងតែក្លាយជាប្រធានបទមួយដ៏មានសារៈសំខាន់ ដែលទទួលបានការចាប់អារម្មណ៍ពីសំណាក់មេដឹកនាំពិភពលោក រួមទាំងមេដឹកនាំកម្ពុជា ទាំងអ្នកសិក្សាស្រាវជ្រាវ អ្នកអនុវត្តន៍ អ្នកជំនាញ និងអ្នកបង្កើតគោលនយោបាយ ហើយប្រទេសជាច្រើនបានកំណត់យកបដិវត្តន៍ឧស្សាហកម្មទី៤ ជាអាទិភាពចម្បងក្នុងចំណោមអាទិភាពដទៃសម្រាប់កំណើន និងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួនជាមួយនឹងបច្ចេកវិទ្យា ដូច្នេះកាលដែលចង់សិក្សាទៅលើ ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឬ E-COMMERCE ពិតជាមិនអាចកាត់ផ្តាច់បានឡើយពីការសិក្សា ការលើកឡើង អំពីបដិវត្តន៍ឧស្សាហកម្មទី៤ ដែលជាសញ្ញាណកាន់តែរីកចម្រើនមួយនៃ E-COMMERCE ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចមួយតាមបែបសេដ្ឋកិច្ចឌីជីថល។ ការដែលរីកសាយភាយនៃបដិវត្តន៍ឧស្សាហកម្មទី៤នេះ វាមិនជារឿងមួយដ៏ថ្មីស្រឡាងនោះទេ តាមរយៈលោក Schwab ជឿថា បដិវត្តន៍ឧស្សាហកម្មទី៤នេះ បាននឹងកំពុងតែអភិវឌ្ឍខ្លួនឡើងតាំងពីរដើមសតវត្សទី២១ មកម្លេះ ហើយដំណើរការវិវត្តនេះគឺពឹងផ្អែកលើមូលដ្ឋានគ្រឹះរបស់បច្ចេកវិទ្យា ឌីជីថលក្នុងបដិវត្តន៍ឧស្សាហកម្មទី៣។ ការរីកសាយភាយនៃបដិវត្តន៍ឧស្សាហកម្មទី៤នេះ បានធ្វើឲ្យរាជរដ្ឋាភិបាលកម្ពុជាកំពុងខិតខំយ៉ាងខ្នះខ្នែងក្នុងការពង្រីកខ្លួន ឬដើរឲ្យទាន់ ឲ្យស្របតាមបដិវត្តន៍ឧស្សាហកម្មទី៤នេះ។ នាពេលថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងខិតខំបង្កើតនូវច្បាប់ថ្មីៗ ក៏ដូចជាឲ្យស្ថាប័ននានាធ្វើការសិក្សាទៅលើបញ្ហានានាដែលកើតចេញពីយុគសម័យបច្ចេកវិទ្យានេះ ដូចជា មានការបង្កើតឡើងនូវ សេចក្តីព្រាងច្បាប់នានា ដូចជា សេចក្តីព្រាងច្បាប់ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក សេចក្តីព្រាងច្បាប់ពីកិច្ចការការពារអ្នកប្រើប្រាស់ និងឲ្យធ្វើការសិក្សាទៅលើ ឧក្រិដ្ឋកម្មបច្ចេកវិទ្យា និងព័ត៌មានវិទ្យាជាដើម។ លោក Schwab បានគូសបញ្ជាក់ថារបបគំហើញវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាថ្មីៗមួយចំនួន ដែលបានរួមចំណែកដល់ការកកើតឡើងនៃបដិវត្តន៍ឧស្សាហកម្មទី៤ដោយបានរាប់បញ្ចូលជាក្រុមទៅតាមប្រភេទរូបសាស្ត្រ (ការបោះពុម្ព ៣D បច្ចេកវិទ្យារ៉ូបូតទំនើប-Advanced Robotics និងរថយន្តដំណើរការស្វ័យប្រវត្តិ) ប្រភេទឌីជីថល (ឧបករណ៍តភ្ជាប់ទៅប្រព័ន្ធអ៊ីនធើណែត - Internet of things ឬ IoT និងឧបករណ៍កំណត់សញ្ញា Sensor) និងប្រភេទជីវសាស្ត្រ។ លើសពីនេះទៅទៀតតាមរយៈការរីកចម្រើននៃបដិវត្តន៍ឧស្សាហកម្មទី៤នេះ បានធ្វើឲ្យការធ្វើពាណិជ្ជកម្មកាន់តែមានភាពប្រសើជាងមុន ដូចជា E-COMMERCE ដែលប្រើប្រាស់នូវបច្ចេកវិទ្យា និងប្រព័ន្ធអ៊ីនធើណែត - Internet of things ឬ IoT ប្រើប្រាស់ក្នុងវិស័យពាណិជ្ជកម្ម ហើយកាន់តែមានភាពរហ័ស ជាពិសេសនូវពេលដែលមានការរកឃើញនូវ 5G ដំបូងគេរបស់ក្រុមហ៊ុន Huawei ដែលនឹងមានប្រព័ន្ធអ៊ីនធើណែតកាន់តែមានល្បឿនលឿនបន្ថែមទៀត នេះដោយសារឥទ្ធិពលនៃបដិវត្តន៍ឧស្សាហកម្មទី

[6] សូមពិគ្រោះ តាន់ មុន្នីវិសា, អត្ថបទជំនួយស្មារតីស្តីពី *បដិវត្តន៍ឧស្សាហកម្មទី៤(ឧស្សាហកម្ម៤.០)* ,វ៉ុល១ លេខទី៣, ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៩, ដោយមជ្ឈមណ្ឌលអភិវឌ្ឍកម្ពុជា

៤[7]។ មិនតែប៉ុណ្ណោះវាបានធ្វើឱ្យទីក្រុងកាន់តែឆ្លាតវៃតាមរយៈប្រព័ន្ធបច្ចេកវិទ្យា មានសុវត្ថិភាព ឧត្តមភាព និងមានសន្តិសុខដូចជាតាមរយៈ ទីក្រុងឆ្លាតវៃត្រូវបានបំពាក់ដោយប្រព័ន្ធកាម៉ារាសុវត្ថិភាព។ តាមរយៈបដិវត្តន៍ឧស្សាហកម្មទី៤នេះ នាពេលថ្មីៗនេះនាយករដ្ឋមន្ត្រីកម្ពុជា បានផ្ដល់អនុសាសន៍ដល់គណៈកម្មការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឲ្យបង្កើតក្របខណ្ឌសេដ្ឋកិច្ចឌីជីថលដើម្បីលើកកម្ពស់សេដ្ឋកិច្ច និងសង្គម។ តាមរយៈលើកកម្ពស់សេដ្ឋកិច្ចនេះហើយដែលបានធ្វើកម្ពុជាមានទស្សនៈវិស័យវែងឆ្ងាយក្នុង ការបង្កើតឲ្យមាននូវ ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះឡើងដើម្បីកំណើនសេដ្ឋកិច្ចជាតិ តាមរយៈសេដ្ឋកិច្ចតាមបែបឌីជីថល។ ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដូចជាការទិញទំនិញតាមអនឡាញ ការដឹកជញ្ជូនប្រកបដោយសុវត្ថិភាពប្រសិទ្ធិភាពខ្ពស់ និងការទូទាត់ប្រាក់តាមអេឡិចត្រូនិកជាដើម។ ដូច្នេះតាមរយៈបដិវត្តន៍ឧស្សាហកម្មទី៤នេះ វាមានឥទ្ធិពលខ្លាំងក្លា ទៅដល់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ទាំងការបង្កើតការរួមផ្សំ និងការដំណើការប្រកបដោយប្រសិទ្ធិភាពខ្ពស់ សុវត្ថិភាព ទាំងព័ត៌មាន និងកំណត់ត្រា ឬហត្ថលេខាអេឡិចត្រូនិកផងដែល សុទ្ធតែពឹងផ្អែលលើប្រព័ន្ធបច្ចេកវិទ្យាទាំងអស់។ តាមរយៈរាជរដ្ឋាភិបាលកម្ពុជាដើម្បីដើរឱ្យទាន់ទៅនឹងបដិវត្តន៍ឧស្សាហកម្មទី៤នេះ យ៉ាងហោចណាស់ក៏ប្រើប្រាស់រយៈពេល១០ឆ្នាំទៅមុខដែល ដើម្បីធ្វើការអភិវឌ្ឍខ្លួនឱ្យទាន់សភាពការណ៍នៃការបម្រែបម្រួលនៃសម័យឌីជីថល បច្ចេកកវិទ្យា អ៊ីនធើណែតទាំងអស់នេះ។ អ្វីទៅជាសេដ្ឋកិច្ចឌីជីថល ដែលបានលើកឡើងខាងលើ? សេដ្ឋកិច្ចឌីជីថល គឺជាទម្រង់នៃសកម្មភាព និងដំណើរការសេដ្ឋកិច្ចដែលចរាចរនៅលើប្រព័ន្ធអ៊ីនធើណែតដោយមានជំនួយបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដែលជម្រុញឲ្យមានកការតភ្ជាប់កាន់តែទូលំទូលាយបំផុតរវាងនិងក្នុងចំណោមមនុស្ស ពាណិជ្ជកម្ម ឧបករណ៍ និងទិន្នន័យ[8]។ សេដ្ឋកិច្ចឌីជីថលនេះ ត្រូវបានផ្ដល់និយមន័យផ្សេងពីគ្នា ដូចជាតាមរយៈការផ្ដល់ឲ្យដោយ ADB តាមរយៈ OECD តាមរយៈ UNCTAD និងតាមរយៈ THE WORLD BANK។

**កថាខណ្ឌទី៣ សាយប៊ើស្បេស** ( CYBERSPACE )[9]

សាយប៊ើស្បេស (Cyberspace) កើតឡើងស្របទៅតាមបដិវត្តន៍ឧស្សាហកម្មទី៤ ដែលជាកាលានុវត្តភាព ទន្ទឹមគ្នាថ្មីនៃសម័យបច្ចេកវិទ្យាឌីជីថល។ សាយប៊ើស្បេស សំដៅដល់ការប្រើប្រាស់ពិភពនិមិត្ត ដែលបង្កើតឡើងដោយប្រព័ន្ធកុំព្យូទ័រ បច្ចេកវិទ្យាដើម្បីបង្កើតបណ្ដាញ ទូទាំងពិភពលោក ដើម្បីសម្រួលដល់ការទំនាក់ទំនង ឧទាហរណ៍ដូចជា សម្រួលដល់ការទទួលបានព័ត៌មាន

[7] សូមពិគ្រោះ KLAUS SCHWAB, ស្ដីពីបដិវត្តន៍ឧស្សាហកម្មលើកទី៤

[8] សូមពិគ្រោះ គង់ រតនធីតា, អត្ថបទជំនួយស្មារតីស្ដីពី *ស្វែងយល់ពីសេដ្ឋកិច្ចឌីជីថល* , ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩, ដោយមជ្ឈមណ្ឌលអភិវឌ្ឍកម្ពុជា

[9] សូមពិគ្រោះ រ៉ាវី សុភាវ័ត្ន, អត្ថបទជំនួយស្មារតីស្ដីពី *សារប្រយោជន៍នៃសាយប៊ើស្បេសក្នុងដំណើការអភិវឌ្ឍនៅកម្ពុជា* , ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧, ដោយមជ្ឈមណ្ឌលអភិវឌ្ឍកម្ពុជា

សម្រួលដល់ការសិក្សាស្រាវជ្រាវ សម្រួលដល់ការធ្វើពាណិជ្ជកម្មឥតដែនកំណត់ និងគ្រប់ទីកន្លែង ដូចជា E-COMMERCE។ សាយបើស្បេស (Cyberspace) ជាប្រព័ន្ធអ៊ីនធើណែត ដែលមានប្រជាប្រិយភាពបំផុតនៅលើសកលលោក ជាពិសេសនៅកម្ពុជា។ ដោយយោងទៅតាមគម្រោងរបស់អង្គការអ្នកវាយការណ៍គ្មានព្រំដែន និងជាអង្គការ CCIM បានសម្គាល់ឃើញថា ៣៩% នៃប្រជាជនកម្ពុជាបានចូលទៅក្នុងប្រព័ន្ធផ្សព្វផ្សាយអនឡាញ ដូចជាការធ្វើពាណិជ្ជកម្មក្នុងការលក់ទំនិញ ឬសេវាហើយដែលបានប្រើប្រាស់សាយបើស្បេស (Cyberspace) ឬអ៊ីនធើណែត រឹតតែធ្វើឱ្យប្រព័ន្ធអ៊ីនធើណែត ក្លាយជាវិស័យដែលមានប្រជាប្រិយភាពបំផុតលំដាប់ទី២ នៅក្នុងប្រទេស។ សាយបើស្បេស (Cyberspace) មិនត្រឹមសម្រួលដល់ការធ្វើពាណិជ្ជកម្ម ជាពិសេសការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកប៉ុណ្ណោះទេ តែក៏បានបង្កើតនូវការអភិវឌ្ឍជូនកម្ពុជាផងដែល ជាពិសេសជូនប្រជាជន។ សារៈសំខាន់ចម្បងរបស់សាយបើស្បេស(Cyberspace) ដែលបានចូលរួមចំណែកក្នុងដំណើរការអភិវឌ្ឍដែលរួមមាន បង្កើតច្រកឱកាស វេទិកាសម្រាបធ្វើការរិៈគន់ និង សម្រួលដល់ការសិក្សាស្រាវជ្រាវ។

សាយបើស្បេស (Cyberspace) បង្កើតច្រកឱកាសសម្រាប់ការអភិវឌ្ឍ ដូចជាតាមរយៈការផ្សព្វផ្សាយព័ត៌មានជាច្រើន នៅតាមបណ្តាញសង្គមនានានៅក្នុងសាយបើស្បេស(Cyberspace)ដូចជាព័ត៌មានទាន់ហេតុការណ៍ ព័ត៌មានអន្តរជាតិ ព័ត៌មានអាហារូបករណ៍ ឬ ព័ត៌មានប្រកួតប្រជែងក្នុងឆាកអន្តរជាតិ។

លំហូព័ត៌មានតាមរយៈសាយបើស្បេស (Cyberspace) បានបង្កើតឱកាសឲ្យប្រជាជនកម្ពុជាប្រកបអាជីវកម្ម ពាណិជ្ជកម្ម ការរកស៊ីនៅលើប្រព័ន្ធសាយបើស្បេស (Cyberspace) ឬអនឡាញ ដើម្បីបង្កើនកំណើនសេដ្ឋកិច្ចផ្ទាល់ខ្លួន សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិផងដែល។ ឧទាហរណ៍ អ្នកជំនួញវ័យក្មេងអាចបង្កើតជំនួញថ្មីៗ និងផ្សព្វផ្សាយផលិតផលរបស់ខ្លួន ទៅកាន់អតិថិជនរបស់ខ្លួន តាមរយៈប្រព័ន្ធអនឡាញ ដែលការធ្វើពាណិជ្ជកម្មបែបនេះ ជាក្របខណ្ឌនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ដូច្នោះមានន័យថា ការរីកចម្រើននៃសាយបើស្បេស (Cyberspace) វាជាសញ្ញាណមួយដែលនាំឲ្យកើតមានការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ព្រោះការធ្វើពាណិជ្ជកម្មតាមបែបប្រភេទនេះ វាពិតជាតម្រូវការខ្លាំងឲ្យមាននូវប្រព័ន្ធសាយបើស្បេស (Cyberspace) ឬអ៊ីនធើណែតដែលមានល្បឿនលឿន ដែលអាចងាយស្រួលក្នុងការប្រតិបត្តិការដំណើការនៃការធ្វើពាណិជ្ជកម្មឲ្យមានភាពរលូន ហើយសាយបើស្បេសក៏ជាធាតុផ្សំមួយបន្ទាប់ពីបដិវត្តន៍ឧស្សាហកម្មជំនាន់៤លេចចេញរូបរាងកាន់តែខ្លាំងឡើងៗ។

**កថាខណ្ឌទី៤ និយមន័យនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវបានកំណត់និយមន័យតាមបែបផ្សេងៗគ្នានិងខុសៗគ្នាពីមួយនិយមន័យ ទៅមួយនិយមន័យ តែមិនបានប្រែប្រួលនូវសារជាតុនិយមន័យដើមឡើយពោលគឺមិនបានចាកឆ្ងាយពីគ្នាដាច់ស្រឡះឡើយ។

ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវបានផ្តល់ជានិយមន័យទូទៅថា ជាការផលិត ជាការចែកចាយ ជាការលក់ទំនិញ ឬសេវាកម្ម ទៅតាមមធ្យោបាយអេឡិចត្រូនិក។

ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ជាសកម្មភាពនៃការទិញ ឬលក់ ផលិតផលនៅលើសេវាកម្មអនឡាញ ឬ អ៊ីនធើណែត។

យោងទៅតាមអង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងការអភិវឌ្ឍ បានចាប់ទុកពាណិជ្ជកម្មតាម

ប្រព័ន្ធអេឡិចត្រូនិក សំដៅទៅលើគ្រប់ទម្រង់នៃទាំងអស់នៃប្រតិបត្តិការពាណិជ្ជកម្ម ដែលរួមមានទាំងនីតិបុគ្គល និងរូបវន្តបុគ្គល ដោយផ្អែកលើដំណើរការអេឡិចត្រូនិក និងការបញ្ជូនទិន្នន័យរួមទាំងបញ្ចូលឯកសារ សំឡេង និងរូបភាព។

យោងទៅតាម WTO បានកំណត់និយមន័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកថាជា ការផលិត ការចែកចាយ ការធ្វើទីផ្សារ ការលក់ ការប្រគល់ទំនិញ និងការផ្គត់ផ្គង់សេវាកម្មតាមមធ្យោបាយអេឡិចត្រូនិក[10]។

យោងទៅតាមការកំណត់ដោយក្របខណ្ឌ E-ASEAN បានកំណត់ថា ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក សំដៅទៅលើប្រតិបត្តិការអេឡិចត្រូនិកនៅលើបណ្តាញអ៊ីនធើណែត ឬនៅលើបណ្តាញបើកទូលាយផ្សេងៗទៀត[11]។

**កថាខណ្ឌទី៥ ទម្រង់នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

ទម្រង់នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករួមមាន[12]៖

- ការធ្វើពាណិជ្ជកម្ម ពីពាណិជ្ជករ ទៅ ពាណិជ្ជករ
- ការធ្វើពាណិជ្ជកម្ម ពីពាណិជ្ជករទៅ អ្នកប្រើប្រាស់
- ការធ្វើពាណិជ្ជកម្ម ពីពាណិជ្ជករ ទៅរដ្ឋាភិបាល
- ការធ្វើពាណិជ្ជកម្ម ពីរដ្ឋាភិបាល ទៅ ពាណិជ្ជករ
- ការធ្វើពាណិជ្ជកម្ម ពីអ្នកប្រើប្រាស់ ទៅអ្នកប្រើប្រាស់

[10]សូមពិគ្រោះ ញ៉ឹក ពេជ្រម៉ូលីកា, ឡឹក សីហា,សារណាបញ្ចប់ការសិក្សាស្តីពី *ការរៀបចំច្បាប់ពាណិជ្ជកម្មអេឡិចត្រូនិក*, ឆ្នាំបោះផ្សាយ ២០១៤, ទំព័រទី ៤ ដល់ទី ៣

[11] សូមពិគ្រោះ ញ៉ឹក ពេជ្រម៉ូលីកា, ឡឹក សីហា,សារណាបញ្ចប់ការសិក្សាស្តីពី *ការរៀបចំច្បាប់ពាណិជ្ជកម្មអេឡិចត្រូនិក*, ឆ្នាំបោះផ្សាយ ២០១៤, ទំព័រទី ៤

[12]សូមពិគ្រោះ ញ៉ឹក ពេជ្រម៉ូលីកា, ឡឹក សីហា,សារណាបញ្ចប់ការសិក្សាស្តីពី *ការរៀបចំច្បាប់ពាណិជ្ជកម្មអេឡិចត្រូនិក*, ឆ្នាំបោះផ្សាយ ២០១៤, ទំព័រទី ៤ ដល់ទី ៥

- ការធ្វើពាណិជ្ជកម្ម ពីអ្នកប្រើប្រាស់ ទៅពាណិជ្ជករ
- ការធ្វើពាណិជ្ជកម្ម ពីរដ្ឋាភិបាល ទៅអ្នកប្រើប្រាស់
- ការធ្វើពាណិជ្ជកម្មតាមរយៈឧបករណ៍ឥតខ្សែ។

## កថាខណ្ឌទី៦ គោលការណ៍សំខាន់ៗនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

គោលការណ៍សំខាន់ៗដែលមាននៅក្នុងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ជាពិសេសនៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងនៅក្នុងបទដ្ឋានអន្តរជាតិមួយចំនួនមានដូចជា ៖

- គោលការណ៍នៃភាពស្រុះស្រួលគ្នាជាអន្តរជាតិ
- គោលការណ៍ក្របខណ្ឌច្បាប់
- គោលការណ៍អព្យាក្រឹត្យភាពនៃបច្ចេកវិទ្យា
- គោលការណ៍សមភាពនៃមុខងារ
- គោលការណ៍ផ្តល់នូវទំនុបចិត្ត ឬភាពដែលអាចទុកចិត្តបានដល់សាធារណៈជន
- គោលការណ៍សុវត្ថិភាពនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

### ១.គោលការណ៍នៃភាពស្រុះស្រួលគ្នាជាអន្តរជាតិ

គោលការណ៍នៃភាពស្រុះស្រួលគ្នាជាអន្តរជាតិ[13] ជាគោលការណ៍មួយដែលមានលក្ខខណ្ឌរួមគ្នាដើម្បីភាពស្រុះស្រួលគ្នាក្នុងការធ្វើពាណិជ្ជកម្មរវាងប្រទេសមួយ ទៅនឹងប្រទេសមួយទៀត ឬប្រទេសជាច្រើនទៀត ។ គោលការណ៍នៃភាពស្រុះស្រួលគ្នាជាអន្តរជាតិ ជាគោលការណ៍សុខដុមនីយកម្មនៃច្បាប់ជាតិទាំងឡាយទាក់ទិនទៅនឹងបញ្ហាពាណិជ្ជកម្មអេឡិចត្រូនិក ដែលមានលក្ខណៈផ្សេងៗគ្នាឲ្យមានភាពស្រុះស្រួលគ្នា ស្របគ្នា ក្នុងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

តាមរយៈគោលការណ៍នៃភាពស្រុះស្រួលគ្នាជាអន្តរជាតិ បានរួមផ្តល់ឱកាសឲ្យប្រជាពលរដ្ឋគ្រប់ទីកន្លែង គ្រប់ប្រទេស អាចធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានដោយដោយជោគជ័យ និងគ្មានបញ្ហាក្នុងការធ្វើពាណិជ្ជកម្ម។ ភាពស្រុះស្រួលគ្នាជាអន្តរជាតិនេះដោយហេតុថា មានការចូលរួមពីច្បាប់ ពីអាជ្ញាធរ ឬពីរដ្ឋាភិបាល ពីអង្គការអន្តរជាតិធំៗដូចជា WTO និង WORLD BANK ជាដើម។

[13] សូមពិគ្រោះ ញ៉ឹក ពេជ្រម៉ូលីកា, ឡឹក សីហា,សារណាបញ្ចប់ការសិក្សាស្តីពី *ការរៀបចំច្បាប់ពាណិជ្ជកម្មអេឡិចត្រូនិក* , ឆ្នាំបោះផ្សាយ ២០១៤, ទំព័រទី ១០

### ២.គោលការណ៍ក្របខណ្ឌច្បាប់

គោលការណ៍ក្របខណ្ឌច្បាប់[14] គឺជាគោលការណ៍មួយដែលបង្កើតឡើងក្នុងគោលបំណងដើម្បីធានាឲ្យបាននូវភាពដែលអាចបត់បែនបាននៃការអភិវឌ្ឍន៍ជាបន្តបន្ទាប់នៃ ប្រព័ន្ធបច្ចេកវិទ្យានៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយចាប់ផ្តើមពីវិធានច្បាប់ណែនាំ និងស្តង់ដារច្បាប់ជាមូលដ្ឋានដែលទូលាយហើយមិនមែនជាវិធានច្បាប់ដែលដាក់កម្រិតតឹងរឹងពេកនោះទេ។

### ៣.គោលការណ៍អព្យាក្រិតភាពនៃបច្ចេកវិទ្យា

ជាគោលការណ៍ដែលធានា ផ្តល់នូវភាពដែលអាចទុកចិត្តបានដល់បុគ្គលដែលធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលធានានូវភាពដែលអាចទុកចិត្តបាននៃបច្ចេកវិទ្យា អព្យាក្រិតភាពនៃ ប្រព័ន្ធបច្ចេកវិទ្យាដែលផ្តល់នូវភាពដែលអាចទុកចិត្តបានចំពោះបុគ្គលទាំងឡាយដែលធ្វើប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក អព្យាក្រិតភាពនេះឃើញស្តែងចេញតាមរយៈសុវត្ថិភាពនៃទំ នាក់ទំនងប្រព័ន្ធអេឡិចត្រូនិក សុវត្ថិភាពហត្ថលេខាអេឡិចត្រូនិក រួមទាំង ទៅលើសុវត្ថិភាពភស្តុតាងអេឡិចត្រូនិកដែលមានចែងទុកជាដើម ដូចជាភស្តុតាងអេឡិចត្រូនិក ដែលវាជាបច្ចេកវិទ្យាមួយ ដែលត្រូវបានធានាដោយគោលការណ៍អព្យាក្រិតភាពនៃបច្ចេកវិទ្យា ដែលមានចែងនៅក្នុងច្បាប់អន្តរជាតិ ក៏ដូចជាច្បាប់ជាតិកម្ពុជាជាដើមតួយ៉ាងដូចជា ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

### ៤.គោលការណ៍សមភាពនៃមុខងារ

គោលការណ៍សមភាពនៃមុខងារ[15] គឺជាគោលការណ៍បង្កើតឡើងដើម្បីធានានូវការផ្តល់តម្លៃស្មើគ្នាទៅលើពាណិជ្ជកម្មតាមរយៈការប្រើប្រាស់ឯកសារជាក្រដាស់ និងពាណិជ្ជកម្មអេឡិចត្រូនិកដែលប្រើប្រាស់ព័ត៌មានក្នុងទម្រង់អេឡិចត្រូនិក ដូចជាការបង្កើតកិច្ចសន្យាតាមរយៈអេឡិចត្រូនិក។ គោលការណ៍សមភាពនៃមុខងារនេះ មានន័យថា ត្រូវធ្វើយ៉ាងមិចក៏ដោយឲ្យទំនាក់ទំនង និងកំណត់ត្រាអេឡិចត្រូនិក អាចផ្តល់នូវភាពច្បាស់លាស់ និង សន្តិសុខតាមផ្លូវច្បាប់នៅលើទំនាក់ទំនងអេឡិចត្រូនិក ដូចគ្នាទៅនឹងអ្វីដែលផ្តល់ដោយឯកសារក្រដាស់ផងដែរ។

### ៥.គោលការណ៍ផ្តល់នូវទំនុកចិត្ត ឬភាពដែលអាចទុកចិត្តបានដល់សាធារណៈជន

ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក គ្រប់បុគ្គលចង់បាននូវទំនុកចិត្ត ហើយដែលអាចទុកចិត្តបានសម្រាប់ការធ្វើប្រតិបត្តិការណ៍ពាណិជ្ជកម្មនៅលើប្រព័ន្ធបច្ចេកវិទ្យា។ មិនខុសទេនូវពេល

[14] សូមពិគ្រោះ ញ៉ឹក ពេជ្រម៉ូលីកា, ឡឹក សីហា,សារណាបញ្ចប់ការសិក្សាស្តីពី *ការរៀបចំច្បាប់ពាណិជ្ជកម្មអេឡិចត្រូនិក*, ឆ្នាំបោះផ្សាយ ២០១៤, ទំព័រទី ១១

[15] សូមពិគ្រោះ ញ៉ឹក ពេជ្រម៉ូលីកា, ឡឹក សីហា,សារណាបញ្ចប់ការសិក្សាស្តីពី *ការរៀបចំច្បាប់ពាណិជ្ជកម្មអេឡិចត្រូនិក*, ឆ្នាំបោះផ្សាយ ២០១៤, ទំព័រទី ១១

ដែលមានសញ្ញាណគតិយុត្តមួយឡើង ដូចជាច្បាប់ ចាំបាច់បំផុតត្រូវមានវិធាន ឬគោលការណ៍សម្រាប់អនុវត្តន៍ឲ្យដំណើរការល្អ ដោយសារមានទំនុបចិត្តដែលអាចជាទីទុកចិត្តបាននៃពាណិជ្ជកម្មប្រភេទនេះបាន។ គោលការណ៍នេះមានខ្លឹមសារត្រឹមតែ ផ្តល់នូវទំនុបចិត្តដល់សារធារណ៍ជនក្នុងការប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលអាចទុកចិត្តបានមិនផ្ទុយទៅនឹងច្បាប់ដទៃដែលនាំឲ្យបាត់ទំនុបចិត្តពីបុគ្គលទាំងអស់។

### ៦.គោលការណ៍សុវត្ថិភាពនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

សុវត្ថិភាពនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកជាកត្តាដែរចាំបាច់បំផុត តម្រូវឲ្យមាននៅក្នុងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីបង្កើតទំនុបចិត្តទៅគ្រប់បុគ្គលដែលបានប្រើប្រាស់វា និង បង្កើតនូវសុវត្ថិភាពដល់បុគ្គលទាំងនោះដោយការពារពេញលក្ខណៈច្បាប់។ នៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រង់មាត្រា ២ ចែងថាច្បាប់ស្តីពីការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានគោលដៅ កំណត់អំពីយថាភូតភាព សុក្រិតភាព និងភាពដែលអាចជឿទុកចិត្តបាននៃការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ជាពិសេសនៅក្នុងសេចក្តីព្រាងច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះដដែល ក៏បានចែងផងដែលដែលទាក់ទងទៅនឹងសុវត្ថិភាពក្នុងគោលដៅ ដើម្បីធានាសុវត្ថិភាពជូនបុគ្គលដែលប្រតិបត្តិការនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកផងដែល ដែលមានចែងអំពីសុវត្ថិភាពកំណត់ត្រា សុវត្ថិភាពហត្ថលេខា និងសុត្ថិភាពភស្តុតាង និងទៅលើសុវត្ថិភាពទៅលើលក្ខណផ្សេងៗទៀតដូចដែលមានចែងនៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកជាដើម។

## ផ្នែកទី២ ការបង្កើតកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

បដិវត្តន៍ឧស្សាហកម្មសកល បានធ្វើឱ្យមានការផ្លាស់ប្តូរយ៉ាងខ្លាំង នូវស្ថានភាពសង្គម សេដ្ឋកិច្ចសកល ដោយសារនវានុវត្តន៍ភាពបច្ចេកវិទ្យា ហើយកំពុងស្ថិតក្នុងដំណាក់កាលផ្លាស់ប្តូរថ្មីមួយទៀតគឺបដិវត្តន៍ឧស្សាហកម្មទី៤ ដែលពឹងផ្អែកទៅលើបច្ចេកវិទ្យាចម្បង។ បម្រែបម្រួលខ្លាំងនៃបដិវត្តន៍ឧស្សាហកម្មនេះបានធ្វើឱ្យពិភពលោកពឹងផ្អែកទៅលើ បច្ចេកវិទ្យាស្ទើគ្រប់វិស័យដើម្បីធ្វើការអភិវឌ្ឍន៍នូវប្រព័ន្ធសេដ្ឋកិច្ចតាមបែបឌីជីថល ឬគេហៅថាសេដ្ឋកិច្ចឌីជីថលដែលពឹងផ្អែកទៅលើបច្ចេកវិទ្យាជាចម្បង ជាពិសេសនោះគឺប្រព័ន្ធអេឡិចត្រូចនិកនេះតែម្តង ការដែលយកបច្ចេកវិទ្យា កាលដែលពឹងផ្អែកទៅលើបច្ចេកវិទ្យានេះបានផ្តល់នូវផលវិជ្ជមានច្រើនដល់មនុស្ស ជាពិសេសដល់សេដ្ឋកិច្ច កាលពីមុនបើគេចង់លក់ទំនិញ ឬសេវាទៅកាន់មនុស្ស ១០០ លាននាក់ជាង គេត្រូវការរយៈពេលចំនួនជាង ជិត ៨0ឆ្នាំ សម្រាប់ Telephone 7ឆ្នាំ ពេលមានវត្តមានអ៊ិនធើណែត ៤ឆ្នាំសម្រាប់ Facebook 2ឆ្នាំ នូវពេលដែលមានវត្តមានបណ្តាញសង្គម Instagram និង ត្រឹមតែ ១ខែ លក់បានដល់ទៅជាង ១០០លាននាក់ នូវពេលបដិវត្តន៍ឧស្សាហកម្មដំណាក់កាលទី៤បានផ្ទុះឡើងជាពិសេស

មានការរីកចម្រើននៃប្រព័ន្ធសាយប៊ើស្បេស (Cyberspace) ឬអ៊ិនធើណែត។ បដិវត្តន៍ឧស្សាហកម្មទី ៤ នាំឱ្យពិភពលោកពឹងផ្អែកទៅលើបច្ចេកវិទ្យាជាសំខាន់ ដូចជាការពឹងផ្អែកទៅលើប្រព័ន្ធសាយប៊ើស្បេស (Cyberspace) ឬអ៊ីនធើណែត បច្ចេកវិទ្យា និងជាពិសេសប្រព័ន្ធអេឡិចត្រូចនិក ដែលជាជំហានរីកចម្រើនថ្មីក្នុងការប្រកបរបបក្នុងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូចនិកនេះ។

ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ( E-COMMERCE ) បានចាប់ផ្ដើមរីកលូតលាស់ស្របពេលដែលកម្ពុជាកំពុងតែអភិវឌ្ឍ ហើយបានទទួលស្គាល់ដោយបណ្ដាប្រទេសជាច្រើន ជាពិសេសអង្គការអន្តរជាតិធំៗ ដូចជា WTO និង UNDP ។ ទម្រង់នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ( E-COMMERCE ) មានទម្រង់ខុសពីការធ្វើពាណិជ្ជកម្មធម្មតា ដោយសារការធ្វើនូវពាណិជ្ជកម្មនេះភាគច្រើនវាផ្ដោតសំខាន់ទៅលើបច្ចេកវិទ្យា ពោលគឺយកបច្ចេកវិទ្យាជាស្ពាននាំឱ្យដំណើការពាណិជ្ជកម្មទៅបាន ដូចជាការបង្កើតទម្រង់នៃកិច្ចសន្យា។ ខុសពីកិច្ចសន្យាដទៃដែលមានសរសេរលិខិតស្នាមដោយផ្ទាល់ដៃ ឬចំពោះមុខពាណិជ្ជករ ឬភាគីជាបុគ្គល តែកិច្ចសន្យានៅលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះបង្កើតនៅលើប្រព័ន្ធបច្ចេកវិទ្យាផ្ទាល់តែម្ដងដូចជាតាមរយៈ Website, Smart Phone, Computer ។ នៅក្នុងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ( E-COMMERCE ) ការធ្វើកិច្ចសន្យាពាណិជ្ជកម្មគឺជាស្ពាននាំឱ្យមាននូវពាណិជ្ជកម្មមួយកើតឡើង ដែលអាចគេមើលឃើញថាប្រព័ន្ធកិច្ចសន្យាដែលយកមកប្រើ ជាសំខាន់គឺកិច្ចសន្យាលក់ទិញនេះតែម្ដង ហើយក៏មិនខុសអ្វីពីកិច្ចសន្យាដទៃដែរ ដែលទាមទារឱ្យមានលក្ខខណ្ឌច្បាប់ជាមូលដ្ឋានគ្រឹះដែលនាំឱ្យកិច្ចសន្យាមួយអាចកើតមានឡើង និងអាចអនុវត្តន៍ទៅបាន។

នៅក្នុងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ( E-COMMERCE ) នេះទម្រង់នៃប្រព័ន្ធច្បាប់ក៏ពុំបានឃ្លាតចាកឆ្ងាយពីក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧ នោះឡើយពោលគឺនៅតែប្រើប្រាស់ក្រមរដ្ឋប្បវេណីខ្មែរឆ្នាំ ២០០៧ ជាជំនួយដើម្បីរួមផ្សំគ្នាក្នុងគោលបំណងដើម្បីឲ្យការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដំណើការទៅយ៉ាងរលូន។ ជាក់ស្ដែងដូចដែលមានចែងនៅក្នុងមាត្រា ១ នៃសេចក្ដីព្រាងច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក[16] ដែលបានចែងថា ការបង្កើតច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះ ក្នុងគោលបំណងបង្កើតភាពប្រកដប្រជាផ្នែកគតិយុត្ត ក្នុងប្រតិបត្តិការផ្នែករដ្ឋប្បវេណី និងពាណិជ្ជកម្មដែលទាក់ទងទៅនឹងទំនាក់ទំនងអេឡិចត្រូនិក។ និងមាត្រា៣ ដែលទទួលស្គាល់ថា ច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក អនុ

[16] សូមពិគ្រោះ សេចក្ដីព្រាងច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ១, "គោលបំណងនៃសេចក្ដីព្រាងច្បាប់ ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក"

វត្តលើសកម្មភាពឯកសារ និងប្រតិបត្តិការផ្ទេរករដ្ឋប្បវេណី និងពាណិជ្ជកម្មទាំងអស់[17]។ ដូច្នេះការបង្កើតនូវកិច្ចសន្យាដែលយកទម្រង់តាម ក្រមរដ្ឋប្បវេណីជាគោលក្នុងការបង្កើត វាជាស្ថានភាពគតិយុត្តមួយដែលច្បាប់ទទួលស្គាល់ជាពិសេសទាក់ទងនឹងការបង្កើតសំណើ (**កថាខណ្ឌទី១**) ការបង្កើតស្វីការ (**កថាខណ្ឌទី២**) ហើយនឹងការសិក្សាផ្សេងៗទៀតដូចជា ការបង្កើតកិច្ចសន្យាដោយប្រព័ន្ធស្វ័យប្រវត្តិ (**កថាខណ្ឌទី៣**) កំហុសឆ្គងក្នុងទំនាក់ទំនងអេឡិចត្រូនិក (**កថាខណ្ឌទី៤**) អានុភាពគតិយុត្តនៃទំនាក់ទំនងអេឡិចត្រូនិក (**កថាខណ្ឌទី៥**) ការព្រមព្រាងរបស់គូភាគីចំពោះសុពលភាពនៃទំនាក់ទំនងអេឡិចត្រូនិក (**កថាខណ្ឌទី៦**)។

## កថាខណ្ឌ១ សំណើក្នុងកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

សំណើ ស្វីការ នាំឲ្យមានកិច្ចសន្យា អាចធ្វើឡើងតាមមធ្យោបាយអេឡិចត្រូនិកបាន ហើយដូចគ្នាទៅនឹងកិច្ចសន្យាដទៃដែរ កិច្ចសន្យាមួយមានអានុភាពដោយសារសំណើ និងស្វីការត្រូវគ្នា[18]។ សំណើគឺជាការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយ នឹងចំណងគតិយុត្តក្នុងករណីដែលមានស្វីការរបស់ភាគីម្ខាងទៀតចំពោះសំណើនោះ[19]។ ម្យ៉ាងទៀតនៅក្នុងច្បាប់បានកំណត់ផងដែរថា សំណើត្រូវចាត់ទុកថាមានសុពលភាព អានុភាពគតិយុត្ត និងភាពអាចអនុវត្តបាន គឺនៅពេលដែលសំណើនោះបានទៅដល់ភាគីម្ខាងទៀត ហើយភាគីបានធ្វើស្វីការតបមកវិញចំពោះសំណើនោះ នោះមានន័យថាគឺនូវពេលដែលលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាឱ្យមានសុពលភាពនោះត្រូវរ៉ូវគ្នា[20]។ ចំពោះនៅក្នុងខ្លឹមសារនៃការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ( E-COMMERCE ) នេះចំពោះការបង្កើតកិច្ចសន្យាមួយឡើងនៅក្នុងពាណិជ្ជកម្មអេឡិចត្រូនិកនេះជាពិសេសសំណើ និងស្វីការតែម្តងពោលគឺ អាចត្រូវបានធ្វើឡើងតាមមធ្យោបាយទំនាក់ទំនងអេឡិចត្រូនិក[21] បាន។ ហើយនៅពេលដែលទំនាក់ទំនងអេឡិចត្រូនិកត្រូវបានប្រើប្រាស់ ក្នុងគោលដៅដើម្បីបង្កើតកិច្ចសន្យានោះឡើង នោះកិច្ចសន្យានោះមានសុពលភាពអាចអនុវត្តបាន[22]។ តាមរយៈមាត្រា

[17] សូមពិគ្រោះ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ៣, "វិសាលភាពនៃសេចក្តីព្រាងច្បាប់ស្តីពី ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក"

[18] សូមពិគ្រោះ ក្រមរដ្ឋប្បវេណីកម្ពុជា, នស/រកម/១២០៧/០៣០, ២១ វិច្ឆិកា ឆ្នាំ ២០០៧, មាត្រា ៦៦៨ កថាខណ្ឌ។

[19] សូមពិគ្រោះ ក្រមរដ្ឋប្បវេណីកម្ពុជា, នស/រកម/១២០៧/០៣០, ២១ វិច្ឆិកា ឆ្នាំ ២០០៧, មាត្រា ៦៦៨ កថាខណ្ឌ។

20 សូមពិគ្រោះ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ១១, "ការបង្កើត និងសុពលភាពកិច្ចសន្យាដែលមានចែងនៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក"

21 សូមពិគ្រោះ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃ៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ១១ កថាខណ្ឌទី២, "ការបង្កើត និងសុពលភាពកិច្ចសន្យាដែលមានចែងនៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក"

22 សូមពិគ្រោះ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃ៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ១១ កថាខណ្ឌទី២, "ការបង្កើត និងសុពលភាពកិច្ចសន្យាដែលមានចែងនៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក"

ខាងលើនេះអាចកត់សម្គាល់បានថា សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិកទទួលស្គាល់ការប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកក្នុងការបង្កើតកិច្ចសន្យា គឺទទួលស្គាល់ជាលក្ខណៈផ្លូវច្បាប់នូវការបង្កើតកិច្ចសន្យាដែលអាចមានសុពលភាពអនុវត្តទៅបាន។

ហើយម្យ៉ាងទៀតទំនាក់ទំនងអេឡិចត្រូនិកក៏ត្រូវបានទទួលស្គាល់ជា លក្ខណៈគតិយុត្តផងដែល ដែលជាការទទួលស្គាល់ជាពិសេសនៅក្នុង សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ នៅក្នុងមាត្រា ៥ នៃសេចក្តីព្រាងច្បាប់នេះបានចែងបញ្ជាក់យ៉ាងដូច្នោះថា គ្មានបុគ្គលណាម្នាក់អាចបដិសេធមិនទទួលស្គាល់អានុភាពគតិយុត្ត ឬសុពលភាព ឬភាពអាចទទួលយកបាន ឬភាពដែលអាចយកទៅ អនុវត្តបាននៃទំនាក់ទំនងអេឡិចត្រូនិក ដោយគ្រាន់តែសម្អាងទៅលើមូលហេតុដែលថាវាគ្រាន់តែបានធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិក ឬដែលស្ថិតនៅក្នុងទំនាក់ទំនងអេឡិចត្រូនិកឡើយ[23]។

នៅក្នុងការបង្កើតកិច្ចសន្យាមួយឱ្យមានសុពលភាពមិនមែនត្រឹមតែគោរពទៅលើ លក្ខខណ្ឌសំណើមួយតែប៉ុណ្ណោះទេ ពោលវាត្រូវបានគោរពផងដែលទៅលើលក្ខខណ្ឌផ្សេងៗទៀតមានដូចជាលក្ខខណ្ឌទូទៅទាក់ទងនឹងភាគីដែលមានដូចជា ( មាន ឬ មិនមាន សមត្ថភាពទទួលសិទ្ធិ សមត្ថភាពខាងឆន្ទៈ សមត្ថភាពក្នុងការធ្វើសកម្មភាព និង វិការៈក្នុងការបង្ហាញឆន្ទៈ) និងលក្ខខណ្ឌទូទៅទាក់ទងនឹងខ្លឹមសារ (ភាពច្បាស់លាស់ ភាពស្របច្បាប់ ភាពសមស្របតាមស្ថានភាពសង្គម និងគ្មានការបង្ហាញឆន្ទៈមិនពិត) ដូចដែលមានកំណត់នៅក្នុង **ឧបសម្ព័ន្ធ** នៃសារណានេះ។ នៅក្នុងកថាខណ្ឌនេះ យើងនឹង សិក្សាទៅលើចំណុចលម្អិតបីចំណុចសំខាន់ដែលបន្ថែមទៅការបង្ហាញត្រួសៗខាងលើដោយ (**ចំណុច១**) យើងនឹងសិក្សាទៅលើការបង្កើតសំណើនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងការអញ្ជើញឱ្យបង្កើតសំណើ (**ចំណុចទី២**) ពេលវេលា និង ទីកន្លែងនៃការបញ្ជូននូវសំណើរ **(ចំណុចទី៣)** ។

## ១. ការបង្កើតសំណើនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

នៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក សំណើអាចបង្កើតឡើងតាមរយៈប្រព័ន្ធអេឡិចត្រូនិកបាន ហើយដើម្បីបង្កើតកិច្ចសន្យាមួយឡើង ក៏ត្រូវទទួលបាននូវសុពលភាពគតិយុត្តផងដែល។ នៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកម្ចាស់សំណើត្រូវបានគេហៅថាអ្នកផ្ញើ ចំណែកម្ចាស់ស្វីការគេហៅថា អ្នកទទួល។ សំណើបើយោងទៅតាមក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ មានពីរប្រភេទគឺ សំណើដែលមានកំណត់អំឡុងពេលសម្រាប់ស្វីការ[24] និងសំណើដែលគ្មានកំណត់អំឡុង

---

23 សូមពិគ្រោះ: សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ៥, "ការទទួលស្គាល់លក្ខណៈគតិយុត្តនៃទំនាក់ទំនងគតិយុត្តនៃទំនាក់ទំនង អេឡិចត្រូនិក"

24 សូមពិគ្រោះ: ក្រមរដ្ឋប្បវេណីកម្ពុជា, នស/រកម/១២០៧/០៣០, ២១ វិច្ឆិកា ឆ្នាំ ២០០៧, មាត្រា ៦៦៨ កថាខណ្ឌ។

ពេលសម្រាប់ស្វីការ[25]។ ការបង្កើតសំណើអាចត្រូវបានធ្វើដោយផ្ទាល់មាត់ក៏បាន ឬជាលាយលក្ខណ៍អក្សរក៏បាន ប៉ុន្តែចំពោះនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានកំណត់ថា បើសិនជា ការបង្កើតនូវសុពលភាពនៃទំនាក់ទំនងអេឡិចត្រូនិកជាពិសេសការបង្កើតកិច្ចសន្យាជាអាទិ៍ ឬចំណុចណា មាត្រាណាមួយដែលទាក់ទងទៅនឹងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅក្នុង សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក តម្រូវឱ្យផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរ ឬធ្វើកំណត់ត្រាជាលាយលក្ខណ៍អក្សរ ត្រូវបានចាត់ទុកថាលក្ខណ៍តម្រូវនេះត្រូវបានបំពេញប្រសិនបើព័ត៌មាននោះធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិក ហើយអាចចូលប្រើប្រាស់បាន និងអាចយកទៅប្រើប្រាស់ជាសំអាងនៅពេលក្រោយបាន[26] ជាពិសេសក្រោយពេលបង្កើតកិច្ចសន្យារួចហើយ។

**២. ការអញ្ជើញឱ្យបង្កើតសំណើនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

នៅពេលដែលមានការស្នើសុំចុះកិច្ចសន្យាតាមរយៈប្រព័ន្ធអេឡិចត្រូនិក មិនថាតាមការផ្សព្វផ្សាយរបស់បណ្តាញសង្គមដូចជា Facebook Tweeter YouTube line Instagram Telegram និង Website ដែលបានធ្វើពាណិជ្ជកម្មនៅលើប្រព័ន្ធអេឡិចត្រូនិកនានា ដែលបានធ្វើឡើងដោយទំនាក់ទំនងអេឡិចត្រូនិកទាំងនោះ ហើយដែលមិនសំដៅដល់បុគ្គលណាមួយជាក់លាក់ ត្រូវចាត់ទុកថាជាការអញ្ជើញឱ្យធ្វើសំណើបង្កើតកិច្ចសន្យា លុះត្រាតែសំណើបង្កើតកិច្ចសន្យាមានបង្ហាញឱ្យឃើញច្បាស់អំពីឆន្ទៈរបស់បុគ្គលដែលបានបង្កើតសំណើនោះ ថាខ្លួននឹងត្រូវជាប់កាតព្វកិច្ចលុះត្រាតែមានស្វីការ ហើយនៅពេលដែលមានស្វីការ ការអញ្ជើញនោះត្រូវចាត់ទុកថាជាសំណើ[27]។ ដូច្នេះនៅពេលដែលមានស្វីការតបបានផ្តល់ឱ្យ នោះការអញ្ជើញឱ្យបង្កើតសំណើតាមប្រព័ន្ធព័ត៌មាននឹងមានអានុភាពចំពោះគូភាគី។ ម្យ៉ាងទៀតនៅពេលដែលការអញ្ជើញឱ្យបង្កើតសំណើតាមប្រព័ន្ធអេឡិចត្រូនិកនោះ ហើយទទួលបាននូវស្វីការតបដែលនាំឱ្យកិច្ចសន្យាពាណិជ្ជកម្មមួយបានកើតឡើងទៅហើយនោះ នោះទំនាក់ទំនងអេឡិចត្រូនិកដែលនាំឱ្យមានកិច្ចសន្យាពាណិជ្ជកម្មមួយកើតឡើងមិនត្រូវបដិសេធគតិយុត្ត សុពលភាព និងភាពអាចអនុវត្តបានចំពោះការបង្ហាញឆន្ទៈ ឬសេចក្តីថ្លែងផ្សេងៗរបស់ខ្លួនបានឡើយ[28] ព្រោះថារាល់ការអញ្ជើញឱ្យបង្កើតសំណើក៏ជាទំនាក់ទំនងទៅនឹងការបង្ហាញឆន្ទៈហើយស្វីការដែលមានជារួមវាក៏ជាទំនាក់ទំនងទៅនឹងការបង្ហាញឆន្ទៈដែលបានធ្វើឡើងក្រោមទម្រង់អេឡិចត្រូនិក ដែរច្បាប់បានទទួលស្គាល់ដូចមាននៅក្នុងការបកស្រាយខាងលើដែរ។

---

[25] សូមពិគ្រោះ ក្រមរដ្ឋប្បវេណីកម្ពុជា, នស/រកម/១២០៧/០៣០, ២១ វិច្ឆិកា ឆ្នាំ ២០០៧, មាត្រា ៦៦៨ កថាខណ្ឌ។

[26] សូមពិគ្រោះ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក,ចុះថ្ងៃ៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ៦ កថាខណ្ឌទី១, "លក្ខខណ្ឌតម្រូវជាលាយលក្ខណ៍អក្សរ"

[27] សូមពិគ្រោះ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ១៦ , "ការអញ្ជើញឱ្យបង្កើតសំណើ"

[28] សូមពិគ្រោះ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ១៣

### ៣. ពេលវេលា និងទីកន្លែងនៃការបញ្ជូននូវសំណើរ

#### ៣.១ ពេលវេលានៃការបញ្ជូននូវសំណើរតាមរយៈប្រព័ន្ធអេឡិចត្រូនិក

សំណើនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវបានកំណត់ ពេលវេលារបស់វានៅក្នុងសេចក្ដីព្រាងច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក វាត្រូវបានកំណត់ពីព័ត៌មានអេឡិចត្រូនិកមួយដែលត្រូវបញ្ជូនចេញ (សំណើរ) នៅពេលដែល ព័ត៌មានអេឡិចត្រូនិកនោះចាកចេញពីប្រព័ន្ធព័ត៌មានដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកផ្ញើ ឬរបស់ភាគីដែលបានផ្ញើជំនួសក្នុងនាមអ្នកផ្ញើ[29]។ ម្យ៉ាងទៀតក្នុងករណីដែលព័ត៌មានអេឡិចត្រូនិកនោះមិនទាន់បានចាកចេញពីប្រព័ន្ធព័ត៌មាន ហើយដែលស្ថិតនៅក្រោមការគ្រប់គ្រង របស់អ្នកផ្ញើ ឬរបស់ភាគីដែលផ្ញើជំនួស នោះទំនាក់ទំនងព័ត៌មានអេឡិចត្រូនិកមួយនោះ ត្រូវបានបញ្ជូនចេញនៅពេលដែលព័ត៌មានអេឡិចត្រូនិកនោះត្រូវបានទទួលក្នុងពេលណាមួយ[30] ។

#### ៣.២ ទីកន្លែងនៃការបញ្ជូននូវសំណើរតាមរយៈប្រព័ន្ធអេឡិចត្រូនិក

ទីកន្លែងនៃការបញ្ជូនព័ត៌មានតាមរយៈប្រព័ន្ធអេឡិចត្រូនិក ត្រូវបានសន្មតថាបានបញ្ជូនចេញពីទីតាំងអាជីវកម្មរបស់អ្នកផ្ញើ បើទោះបីជាព័ត៌មានអេឡិចត្រូនិកនោះត្រូវបានផ្ញើចេញពីទីតាំងណាក៏ដោយ[31]។

## កថាខណ្ឌ២ ស្វីការក្នុងកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

កិច្ចសន្យាមួយកើតឡើងលុះត្រាតែមានជំនួបនៃឆន្ទៈកើតឡើង មានន័យថាគឺលុះត្រូវតែវាបានបំពេញនូវលក្ខខណ្ឌរបស់វាដែលលក្ខខណ្ឌគឺមានន័យវាទាល់តែពោលគឺសំណើ និងស្វីការវាត្រូវរូវគ្នា[32] សំណើយើងបានបកស្រាយនៅ កថាខណ្ឌ១ រួចមកហើយ តែស្វីការនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះនឹងត្រូវបកស្រាយនៅខាងក្រោមបន្ទាប់។

ស្វីការមិនត្រូវបានផ្ដល់និយមន័យឡើយនៅក្នុងសេចក្ដីព្រាងច្បាប់ស្ដីពី ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក តែមានកំណត់នៅក្នុងនិយមន័យពាក្យដែលជាឧបសម្ព័ន្ធថា សំដៅដល់ការសម្ដែងឆន្ទៈ ដែលបុគ្គលម្នាក់បានបញ្ចេញការយល់ព្រមរបស់ខ្លួនចំពោះសំណើដែលបុគ្គលដ៏ទៃបានស្នើមកខ្លួនដើម្បីបង្កើតកិច្ចសន្យាមួយឡើង ហើយនិយមន័យនៃស្វីការនេះគេឃើញមានកំណត់នៅក្នុងក្រម

29 សូមពិគ្រោះ សេចក្ដីព្រាងច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ១៥ កថាខណ្ឌទី១ ចំណុច ក "

30 សូមពិគ្រោះ សេចក្ដីព្រាងច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ១៥ កថាខណ្ឌទី១ ចំណុច ខ , "

31 សូមពិគ្រោះ សេចក្ដីព្រាងច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា១៥ កថាខណ្ឌទី ២ ។

32 សូមពិគ្រោះ អុន រតនា, អ៊ុត ចាន់លីនណា, សារណាបញ្ចប់ការសិក្សាស្ដីពី *ពាណិជ្ជកម្មអេឡិចត្រូនិក* ,ឆ្នាំបោះផ្សាយ ២០១២, ទំព័រទី ៣០ ។

រដ្ឋប្បវេណីខ្មែរឆ្នាំ២០០៧ ថាស្វីការ គឺជាការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ[33]។ សញ្ញាណនៃនិយមន័យនៃស្វីការនេះក៏មានដែលនៅក្នុងអត្ថបទសៀវភៅដទៃទៀតដែល ហើយបានកំណត់ថា ស្វីការ គឺជាការសម្តែងឆន្ទៈ ដែលតាមរយៈនេះបុគ្គលម្នាក់ យល់ព្រមទទួលយកសំណើដែលស្នើឡើងដោយម្ចាស់សំណើមកខ្លួន[34]។ តែទោះបីជាគ្មានចែងនៅក្នុងសេចក្តីព្រាងច្បាប់ ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក៏ដោយ ក៏សញ្ញាណនៃក្រមរដ្ឋប្បវេណីត្រូវបានទទួលស្គាល់ដោយ សេចក្តីព្រាងច្បាប់នេះផងដែលដូចដែលបានរៀបរាប់ខាងលើ។ នៅក្នុងកថាខណ្ឌនេះយើងនឹងសិក្សាលម្អិតទៅលើស្វីការនេះដោយសិក្សាទៅលើ លក្ខណៈនៃស្វីការ ( **ចំណុចទី១)** និងអានុភាពស្វីការ (**ចំណុចទី២**) និង (**ចំណុចទី៣**) ពេលវេលា និងទីកន្លែងនៃការទទួលស្វីការក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ជាចំណុចបញ្ចប់ ។

### ១. លក្ខណៈនៃស្វីការ

នៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក បានកំណត់ទៅលើពាក្យអ្នកទទួល (ម្ចាស់ស្វីការ) ថាគឺសំដៅដល់បុគ្គលដែលទទួលទំនាក់ទំនងអេឡិចត្រូនិក ស្របទៅតាមឆន្ទៈរបស់អ្នកផ្ញើ[35](ម្ចាស់សំណើ) ដែលឆន្ទៈរបស់អ្នកផ្ញើនេះក៏បង្កើតឡើងតាមរយៈប្រព័ន្ធអេឡិចត្រូនិកដូចគ្នា។ យោងទៅតាមក្រមរដ្ឋប្បវេណីខ្មែរឆ្នាំ២០០៧ បានកំណត់ថាស្វីការគឺជាលក្ខខណ្ឌដែលនាំឱ្យមានកិច្ចសន្យាមួយកើតឡើង[36]។ លក្ខណៈនៃស្វីការត្រូវបានកំណត់បន្ថែមនៅក្រមរដ្ឋប្បវេណីខ្មែរឆ្នាំ២០០៧ ដោយបន្ថែមថា ស្វីការក៏មានលក្ខណៈយឺតយ៉ាវផងដែល នឹងស្វីការមួយចំនួនក៏មានបន្ថែមការកែប្រែផងដែល និងដែលមានអំឡុងពេលសម្រាប់ស្វីការ។

ការមកដល់យឺតយ៉ាវនៃស្វីការនោះអាចនឹងមិនមានសុពលភាពបើសិនណាភាគីដែល ជាម្ចាស់សំណើ (អ្នកផ្ញើ)នោះធ្វេសប្រហែសពុំបានជូនដំណឹងទៅម្ចាស់ស្វីការ (អ្នកទទួល) ចំពោះការមកដល់យឺតយ៉ាវនៃស្វីការចំពោះសំណើរដែលមានកំណត់អំឡុងពេលសម្រាប់ធ្វើស្វីការ[37]។ តែបើក្នុងករណីដែលភាគីម្ចាស់សំណើបានដឹងអំពីការមកដល់យឺតយ៉ាវនៃស្វីការ នោះម្ចាស់សំណើត្រូវជូនដំណឹងដោយគ្មានការយឺតយ៉ាវទៅម្ចាស់ស្វីការនោះ ដើម្បីមិនបង្កើតសុពលភាពក្រោយពេលផុតអំឡុងពេលសម្រាប់ស្វីការ ជាសំណើថ្មីបានដែរ[38]។

---

33 សូមពិគ្រោះ ក្រមរដ្ឋប្បវេណីកម្ពុជា, នស/រកម/១២០៧/០៣០, ២១ វិច្ឆិកា ឆ្នាំ ២០០៧, មាត្រា ៣៣៧ កថាខណ្ឌទី៣ ។

34 សូមពិគ្រោះ អុន រតនា, អ៊ុត ចាន់លីនណា, សារណាបញ្ចប់ការសិក្សាស្តីពី *ពាណិជ្ជកម្មអេឡិចត្រូនិក* ,ឆ្នាំបោះផ្សាយ ២០១២,ទំព័រទី៣០ ។

35 សូមពិគ្រោះ និយមន័យ ឧបសម្ព័ន្ធ, ក្នុងសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩,

36 សូមពិគ្រោះ ក្រមរដ្ឋប្បវេណីកម្ពុជា, នស/រកម/១២០៧/០៣០, ២១ វិច្ឆិកា ឆ្នាំ ២០០៧, មាត្រា ៣៣៧។

37 សូមពិគ្រោះ ក្រមរដ្ឋប្បវេណីកម្ពុជា, នស/រកម/១២០៧/០៣០, ២១ វិច្ឆិកា ឆ្នាំ ២០០៧, មាត្រា ៣៤១ កថាខណ្ឌទី១

38 សូមពិគ្រោះ ក្រមរដ្ឋប្បវេណីកម្ពុជា, នស/រកម/១២០៧/០៣០, ២១ វិច្ឆិកា ឆ្នាំ ២០០៧, មាត្រា ៣៤១ កថាខណ្ឌទី២

ចំពោះស្ទីការដែលមានបន្ថែមការកែប្រែវិញមានន័យថា បើសិនជាម្ចាស់ស្ទីការបានដាក់លក្ខខណ្ឌ ឬកែប្រែសារធាតុផ្សេងនៃសំណើ នោះស្ទីការនោះនឹងប្រែក្លាចជាសំណើថ្មីវិញ ហើយម្ចាស់សំណើដើម ក្លាយជាអ្នកផ្តល់ស្ទីការនោះវិញម្តង[39]។ ក៏ប៉ុន្តែបើសិនបើលក្ខខណ្ឌ ឬការកែប្រែដែលភ្ជាប់ជាមួយនឹងស្ទីការ មិនឱ្យមានការកែប្រែសារធាតុនៃសំណើទេ ស្ទីការនោះមានសុពលភាពលុះត្រាតែអ្នកស្នើមិនតវ៉ាភ្លាមៗ។

## ២. អានុភាពនៃស្ទីការ

ដូចបានបកស្រាយរៀបរាប់រួចមកហើយ កិច្ចសន្យាមួយមានសុពលភាពលុះត្រាតែសំណើ និងស្ទីការត្រូវរូវគ្នា។ ដូច្នេះដើម្បីឱ្យសំណើ និងស្ទីការឈានទៅត្រូវរូវគ្នា ទាំងសំណើ និងស្ទីការសុទ្ធតែត្រូវការលក្ខខណ្ឌនាំឱ្យបង្កើតសុពលភាព អានុភាពដូចៗគ្នា។ អានុភាពនៃសំណើរមាននៅក្នុងការបកស្រាយខាងលើរួចមកហើយ ដូច្នេះនៅក្នុងចំណុចនេះយើងនឹងសិក្សាទៅលើអានុភាពនៃស្ទីការ។ ស្ទីការមានអានុភាពនៅពេលដែលស្ទីការនោះបានទៅដល់អ្នកស្នើ[40] នេះជាគោលការណ៍នៃការមកដល់នៃស្ទីការ។ ប៉ុន្តែអានុភាពនៃស្ទីការ នឹងមិនត្រូវកើតនោះឡើងឡើយប្រសិនបើដំណឹងអំពីការដកស្ទីការវិញ ដល់អ្នកស្នើ នៅពេលព្រមគ្នា នឹងពេលស្ទីការដល់ ឬមុនពេលស្ទីការដល់។

## ៣. ពេលវេលា និងទីកន្លែងនៃការទទួលស្ទីការ

### ៣.១ ពេលវេលានៃការទទួលទំនាក់ទំនងអេឡិចត្រូនិក

នៅក្នុងចំណុចនេះយើង នឹងធ្វើការសិក្សាទៅលក្ខខណ្ឌនៃពេលវេលាចំពោះការទទួលទំនាក់ទំនងអេឡិចត្រូនិក ដែរមាននៅក្នុងទំនាក់ទំនងប្រព័ន្ធអេឡិចត្រូនិកចំពោះការធ្វើ ឬប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលមានខ្លឹមសារថា៖

ពេលវេលានៃការទទួលព័ត៌មានអេឡិចត្រូនិក គឺជាពេលដែលព័ត៌មានអេឡិចត្រូនិកនោះ អាចទាញយកបានដោយអ្នកទទួលនៅក្នុងអាស័យដ្ឋានអេឡិចត្រូនិក ដែលអ្នកទទួលនោះបានបញ្ជាក់ជាមុន[41]។ ឧទាហរណ៍ ការបញ្ជាក់នៅលើមធ្យោបាយអេឡិចត្រូនិកដែលប្រើប្រាស់សម្រាប់ធ្វើជំនួញពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

ប្រសិនបើអាសយដ្ឋានអេឡិចត្រូនិកមិនត្រូវបានផ្តល់ឱ្យដោយអ្នកទទួល នោះពេលវេលាដែលទទួលបានព័ត៌មានអេឡិចត្រូនិកនោះ គឺជាពេលវេលាដែលអ្នកទទួលបានដឹងអំពីការផ្ញើចេញ និងអាចធ្វើការទាញយកព័ត៌មាននោះតាមរយៈអាសយដ្ឋានអេឡិចត្រូនិកណាមួយ ហើយក៏បានសន្មត

[39] សូមពិគ្រោះ ក្រមរដ្ឋប្បវេណីកម្ពុជា, នស/រកម/១២០៧/០៣០, ២១ វិច្ឆិកា ឆ្នាំ ២០០៧, មាត្រា ៣៨២ កថាខណ្ឌទី១

[40] សូមពិគ្រោះ ក្រមរដ្ឋប្បវេណីកម្ពុជា, នស/រកម/១២០៧/០៣០, ២១ វិច្ឆិកា ឆ្នាំ ២០០៧, មាត្រា ៣៨០

[41] សូមពិគ្រោះ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ១៥ កថាខណ្ឌទី៣

ថាបានទទួលនៅកន្លែងដែលជាទីតាំងអាជីវកម្មរបស់អ្នកទទួល[42]។

ប្រសិនបើអាសយដ្ឋានអេឡិចត្រូនិកត្រូវបានផ្តល់ដោយអ្នកទទួល ព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិកត្រូវបានសន្មត់ថា បានទទួលនៅពេលព័ត៌មាននោះបានទៅដល់អាសយដ្ឋានអេឡិចត្រូនិករបស់អ្នកទទួល ហើយត្រូវបានចាត់ទុកថាបានទទួលនៅទីកន្លែងដែលជាទីតាំងអាជីវកម្មរបស់អ្នកទទួល។

### ៣.២ ទីកន្លែងនៃការទទួលទំនាក់ទំនងអេឡិចត្រូនិក

ទំនាក់ទំនងអេឡិចត្រូនិកត្រូវបានសន្មតថាបានទទួលដោយអ្នកទទួល នៅពេលវាទៅដល់អាស័យដ្ឋានអេឡិចត្រូនិករបស់អ្នកទទួល[43]។ ហើយទំនាក់ទំនងអេឡិចត្រូនិកត្រូវបានសន្មត់ថាបានទទួលនៅទីកន្លែងដែលជាទីតាំងអាជីវកម្មរបស់អ្នកទទួលនោះ[44]។

## កថាខណ្ឌ៣ ការបង្កើតកិច្ចសន្យាដោយប្រព័ន្ធស្វ័យប្រវត្តិ

ទំនើបកម្មផ្នែកបច្ចេកវិទ្យា នាំឱ្យកាន់តែបង្កើតភាពងាយស្រួលដល់អ្នកប្រើប្រាស់ទៅតាមផ្នែកនីមួយៗរបស់វា ហើយទំនើបកម្មផ្នែកបច្ចេកវិទ្យាបានបង្កើតភាពងាយស្រួលដល់មនុស្សក្នុងការប្រកបអាជីវកម្ម ពាណិជ្ជកម្ម ដោយសារការប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យាទាំងអស់នោះ។ ជាក់ស្តែងនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក បានយកប្រព័ន្ធបច្ចេកវិទ្យាជាស្នូលក្នុងការធ្វើពាណិជ្ជកម្មទៅលើទំនិញគ្រប់បែបយ៉ាង រួមទាំងសេវាកម្មថែមទៀត នៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបាន អនុញ្ញាតឱ្យប្រើប្រាស់នូវបច្ចេកវិទ្យាអេឡិចត្រូនិកដើម្បីធ្វើការប្រើប្រាស់ បង្កើតនូវកិច្ចសន្យាមួយឡើង ដោយប្រព័ន្ធស្វ័យប្រវត្តិផងដែល។ ដោយបានកំណត់នៅក្នុងមាត្រា១៧ នៃសេចក្តីព្រាងច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលជាសញ្ញាណថ្មី ដែលមានខ្លឹមសារបញ្ជាក់ថា ៖

កិច្ចសន្យាមួយដែលបង្កើតឡើងដោយអន្តរកម្ម[45] រវាងប្រព័ន្ធសារស្វ័យប្រវត្តិជាមួយរូបវន្តបុគ្គល ឬបុគ្គល ឬជាមួយប្រព័ន្ធសារស្វ័យប្រវត្តិផ្សេងទៀត មិនត្រូវបានជំទាស់ ឬមិនអាចត្រូវបានបដិសេធអំពីសុពលភាព អានុភាពគតិយុត្ត ឬភាពអាចអនុវត្តន៍បាននៃកិច្ចសន្យានោះឡើយ ដោយគ្រាន់សម្អាងលើហេតុផលអវត្តមាននៃរូបវន្តបុគ្គលក្នុងការពិនិត្យ ឬក្នុងការធ្វើសកម្មភាពដោយផ្ទាល់ ក្នុង

[42]សូមពិគ្រោះ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ១៥ កថាខណ្ឌទី៤

[43] សូមពិគ្រោះ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ១៥ កថាខណ្ឌទី៤ វេយ្យខណ្ឌ១

[44] សូមពិគ្រោះ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ១៥ កថាខណ្ឌទី៥

[45] សូមពិគ្រោះ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ១៧

ប្រព័ន្ធសារស្វ័យប្រវត្តិ ឬក្នុងការបង្កើតកិច្ចសន្យានោះ[46]។ មានន័យថាទោះបីជាការបង្កើតកិច្ចសន្យា នៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក៏ដោយ ហើយធ្វើឡើងដោយប្រព័ន្ធស្វ័យប្រវត្តិ នោះ កិច្ចសន្យានោះនឹងមានសុពលភាព អានុភាពគតិយុត្ត មានអានុភាពអាចតតាំងជាមួយតតីយជនបាន ដែលនេះជាសញ្ញាណទទួលស្គាល់ដោយច្បាប់បើតួប្បីជាគ្មានវត្តមានរបស់បុគ្គល ក្នុងការពិនិត្យ ឬ ក្នុងការធ្វើសកម្មភាពដោយផ្ទាល់ក៏ដោយ ក៏កិច្ចសន្យាធ្វើឡើងតាមប្រភេទបែបនេះ ក៏មានអានុភាព សុពលភាព និងភាពដែលអាចតតាំងបានដែរ។

**កថាខណ្ឌ៤ កំហុសឆ្គងក្នុងទំនាក់ទំនងអេឡិចត្រូនិក**

នៅក្នុងទំនាក់ទំនងអេឡិចត្រូនិកមិនអាចជៀសផុតបានឡើយ នូវកំហុសឆ្គងដែលនឹងកើតមាន នូវពេលដែលបុគ្គលទាំងអស់នោះជ្រើសរើសយក បច្ចេកវិទ្យាអេឡិចត្រូនិកមកប្រើប្រាស់។ នៅក្នុង ទំនាក់ទំនងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ផ្តល់ឱកាសឱ្យបុគ្គលដែលបានសាងនូវកំហុស នោះមានលទ្ធភាពក្នុងការកែតម្រូវ ការកែតម្រូវនោះយើងនឹងសិក្សាទៅលើ ការកែតម្រូវដែល ទទួលស្គាល់ដោយច្បាប់ (**ចំណុចទី១**) និងការកែតម្រូវនូវទំនាក់ទំនងអេឡិចត្រូនិក (**ចំណុចទី២**)។

**១. ការកែតម្រូវដែលទទួលស្គាល់ដោយច្បាប់**

នៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះ បានផ្តល់ឱកាសក្នុងការ កែតម្រូវ ហើយដែលបានកំណត់ថា ៖

នៅពេលដែលបុគ្គលបញ្ចូលព័ត៌មានខុសនៅក្នុង ទំនាក់ទំនងអេឡិចត្រូនិកជាមួយប្រព័ន្ធស្វ័យ ប្រវត្តិរបស់ភាគីម្ខាងទៀត ហើយប្រព័ន្ធស្វ័យប្រវត្តិនោះមិនផ្តល់ឱកាសឱ្យបុគ្គលនោះធ្វើការកែប្រែ នូវព័ត៌ដែលខុសនោះទេនោះបុគ្គល ឬ ក៏ភាគីដែលជំនួសមុខឱ្យបុគ្គលដែលធ្វើសកម្មភាពនោះ (សកម្មភាពដែលខុស) មានសិទ្ធិកែតម្រូវ ឬដកចេញនូវ ព័ត៌មានដែលខុសនោះបាន។ ហើយដែល ត្រូវគោរពទៅតាមលក្ខខណ្ឌខាងក្រោម។

**២. ការកែតម្រូវទំនាក់ទំនងអេឡិចត្រូនិក**

គ្រប់បុគ្គលដែលជំនួសមុខឱ្យបុគ្គលដែលធ្វើសកម្មភាពខុសនោះ អាចធ្វើការកែប្រែនូវព័ត៌ដែល ខុស មានសិទ្ធិកែតម្រូវ ឬដកចេញពីទំនាក់ទំនងអេឡិចត្រូនិកនូវព័ត៌មានដែលខុសនោះបានក្នុង ករណីដែល៖

ក. បុគ្គលនោះជូនដំណឹងទៅភាគីម្ខាងទៀតអំពីកំហុសដែលកើតមានឡើងឱ្យបានឆាប់ បំផុត តាមលទ្ធភាពដែលអាចធ្វើទៅបាន ក្រោយពីបានដឹងអំពីកំហុសនោះ ហើយត្រូវបង្ហាញថាខ្លួនបាន បញ្ចូលព័ត៌មាននៅក្នុងទំនាក់ទំនងអេឡិចត្រូនិកនោះ ឬ ដែលធ្វើឡើងបានតែក្នុងករណីមិនទាន់ធ្វើ

[46] សូមពិគ្រោះ: សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ១៧

ស្ទីការ ឬប្រតិបត្តិការមិនទាន់ត្រូវបានអនុវត្ត និង

ខ. បុគ្គលនោះមិនទទួលបានផលប្រយោជន៍ណាមួយ ដោយសារការបញ្ចូលព័ត៌មានខុសនេះ មុនពេលដែលខ្លួនធ្វើការជូនដំណឹងទៅឱ្យភាគីម្ខាងទៀត ហើយមិនបង្កការខូចខាតដល់ផលប្រយោជន៍របស់ភាគីម្ខាងទៀត ឬតតិយជនណាមួយ។

**កថាខណ្ឌ៥ អានុភាពគតិយុត្តនៃទំនាក់ទំនងអេឡិចត្រូនិក**

អានុភាព ឬ សុពលភាពគតិយុត្តនៃទំនាក់ទំនងអេឡិចត្រូនិកត្រូវបានទទួលស្គាល់ដោយច្បាប់ បើតួម្បីជាវាបានបង្កើតឡើងក្រោមរូបភាព ដែលធ្វើនៅក្នុងទម្រង់មួយដោយប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក ឬស្ថិតនៅក្នុងទំនាក់ទំនងអេឡិចត្រូនិកក៏ដោយ។ ការប្រើប្រាស់នូវទំនាក់ទំនងអេឡិចត្រូនិក គ្មានបុគ្គលណាម្នាក់អាចបដិសេធមិនទទួលស្គាល់អានុភាព ឬសុពលភាព ឬភាពអាចទទួលយកបាន និងភាពដែលអាចយកទៅតតាំងជាមួយតតិយជនបានឡើយ។

លក្ខខណ្ឌដើម្បីបង្កើតសុពលភាពនៃទំនាក់ទំនងអេឡិចត្រូនិកមាន ជាអាទិ៍ដូចជា សុពលភាពនៃកិច្ចសន្យាដូចបានបកស្រាយខាងលើ លក្ខខណ្ឌតម្រូវជាលាយលក្ខណ៍អក្សរ (**ចំណុចទី១**) លក្ខខណ្ឌតម្រូវស្តីពីភស្តុតាង (**ចំណុចទី២**) លក្ខខណ្ឌតម្រូវលើការរក្សាទុកកំណត់ត្រា (**ចំណុចទី៣**) លក្ខខណ្ឌស្តីពីទម្រង់បែបបទដែលបានកំណត់ (**ចំណុចទី៤**) លក្ខខណ្ឌតម្រូវដើម្បីរក្សាព័ត៌មានតាមទម្រង់ដើម (**ចំណុចទី៥**) និងលក្ខខណ្ឌតម្រូវចំពោះហត្ថលេខា (**ចំណុចទី៦**)។

**១. លក្ខខណ្ឌតម្រូវជាលាយល័ក្ខអក្សរ**

បើព័ត៌មានមួយធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិក ហើយអាចចូលប្រើប្រាស់បាន និងអាចទាញយកទៅប្រើប្រាស់ជាសំអាងនៅពេលក្រោយបាន ហើយបើមានបទប្បញ្ញត្តិណាមួយ តម្រូវឱ្យផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរ ឬធ្វើកំណត់ត្រាជាលាយលក្ខណ៍អក្សរ ក៏ដោយ ក៏លក្ខខណ្ឌនោះត្រូវចាត់ទុកថាជាលក្ខខណ្ឌតម្រូវហើយត្រូវបានបំពេញ បើទោះបីជាលក្ខខណ្ឌតម្រូវនេះបានធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិកក៏ដោយ[47]។

ហើយបើមានលក្ខខណ្ឌតម្រូវតាមច្បាប់ដែលទាមទារឱ្យបុគ្គលណាមួយ ផ្តល់សំណៅចម្លងច្រើនច្បាប់ក្នុងពេលតែមួយស្តីពី ព័ត៌មានណាមួយ ឬ កិច្ចការណាមួយទៅឱ្យបុគ្គលមួយផ្សេងទៀត បុគ្គលដែលផ្តល់អាចបំពេញលក្ខខណ្ឌនេះគឺដោយគ្រាន់តែផ្តល់ឲ្យក្រោម ទម្រង់ជាអេឡិចត្រូនិកតែមួយច្បាប់[48]ទៅបានហើយ។

[47] សូមពិគ្រោះ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ៦ កថាខណ្ឌទី១

[48] សូមពិគ្រោះ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ៦ កថាខណ្ឌទី២

**២. លក្ខខណ្ឌតម្រូវស្តីពីភស្តុតាង**

នៅក្នុងលក្ខខណ្ឌតម្រូវស្តីពីភស្តុតាងនេះ នៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានកំណត់ថា គ្មានបទប្បញ្ញត្តិណាមួយក្នុងការអនុវត្តវិធានស្តីពីភស្តុតាង អាចជំទាស់ការទទួលស្គាល់ទំនាក់ទំនងអេឡិចត្រូនិកជាភស្តុតាង ដោយគ្រាន់តែឈរលើមូលដ្ឋានដែលថា៖

- ភស្តុតាងនោះជាទំនាក់ទំនងអេឡិចត្រូនិក ឬ
- ភស្តុតាងនោះមិនស្ថិតក្នុងទម្រង់ដើម។

**៣. លក្ខខណ្ឌតម្រូវលើការរក្សាទុកកំណត់ត្រា**

ការរក្សាទុកនៅកំណត់ត្រា ជាសកម្មភាពមួយដែលនាំឱ្យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកទទួលបាននូវសុពលភាពនៃទំនាក់ទំនងអេឡិចត្រូនិក។ នៅក្នុងប្បញ្ញត្តិស្តីលក្ខខណ្ឌតម្រូវលើការរក្សាទុកពីកំណត់ត្រាមានខ្លឹមសារថា ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងទំនាក់ទំនងអេឡិចត្រូនិកបើមានបទប្បញ្ញត្តិណាមួយតម្រូវឱ្យរក្សាទុកនូវឯកសារ កំណត់ត្រា ឬព័ត៌មានជាក់លាក់ណាមួយលក្ខខណ្ឌតម្រូវនោះត្រូវចាត់ទុកថាបានបំពេញប្រសិនបើ ការក្សាទុកនោះគឺបានបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

ក) ព័ត៌មានដែលមាននៅក្នុងទំនាក់ទំនងអេឡិចត្រូនិកនោះអាចចូលប្រើប្រាស់បាន និងសម្រាប់យកទៅប្រើប្រាស់នាពេលអនាគត

ខ) ទំនាក់ទំនងអេឡិចត្រូនិកត្រូវបានរក្សាទុកក្នុងទម្រង់ដើមដែលត្រូវបានបង្កើតឡើង ផ្ញើ ឬទទួលបាន ឬក្នុងទម្រង់ដែលអាចត្រូវបានបង្ហាញពីសុក្រិតភាពនៃព័ត៌មាននោះ

គ) ព័ត៌មានទាំងនោះ ត្រូវរក្សាទុកដើម្បីឱ្យបុគ្គលណាម្នាក់អាចកំណត់បាននូវប្រភពដើម និងគោលដៅនៃទំនាក់ទំនងអេឡិចត្រូនិក កាលបរិច្ឆេទ និងពេលវេលា ដែលទំនាក់ទំនងអេឡិចត្រូនិកនោះត្រូវបាមផ្ញើ ឬទទួល[49]។

តែបើធ្វើឡើងក្នុងគោលបំណងសម្រាប់តែធ្វើការបញ្ជូន ឬទទួលសារ កាតព្វកិច្ចក្នុងការក្សាឯកសារ កំណត់ត្រា ឬព័ត៌មានមិនត្រូវបានរាប់បញ្ចូលព័ត៌មានណាមួយឡើយ[50] ព្រោះវាមិនមែនជាលក្ខខណ្ឌចាំបាច់ដែលត្រូវធ្វើការរក្សាទុកកំណត់ត្រាអ្វីនោះឡើយ ដោយហេតុថាវាគ្រាន់តែជាការបញ្ជូន ឬទទួលសារតែប៉ុណ្ណោះ។

[49] សូមពិគ្រោះ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ១០ កថាខណ្ឌទី១

[50] សូមពិគ្រោះ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ១០ កថាខណ្ឌទី២

**៤. លក្ខខណ្ឌតម្រូវស្តីពីទម្រង់បែបបទដែលបានកំណត់**

នៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក៏បានកំណត់ទម្រង់បែបបទដែលបានកំណត់ផងដែរ ដែលការកំណត់ទម្រង់បែបនេះ វានាំឱ្យទំនាក់ទំនងអេឡិចត្រូនិកនៅក្នុងពាណិជ្ជកម្មអេឡិចត្រូនិកមានសុពលភាព អនុវត្តទៅបានយ៉ាងរលូន។ មានន័យថា នៅក្នុងទំនាក់ទំនងអេឡិចត្រូនិកនៅពេលណាដែលមានបទប្បញ្ញត្តិណាមួយតម្រូវឱ្យផ្តល់ព័ត៌មាន ធ្វើឡើងក្នុងទម្រង់បែបបទណាមួយលក្ខខណ្ឌតម្រូវនោះត្រូវជំនួសដោយការផ្តល់ព័ត៌មានតាមទម្រង់អេឡិចត្រូនិកបាន ប្រសិនបើទម្រង់អេឡិចត្រូនិកនោះត្រូវបំពេញនូវលក្ខខណ្ឌទាំងអស់ខាងក្រោមនេះ ៖

ក) មានផ្ទុកព័ត៌មានដូចគ្នា ឬ ដូចគ្នាភាគច្រើនទៅនឹងទម្រង់បែបបទដែលបានកំណត់

ខ) អាចចូលទៅមើលបាន អាចយល់បាន និងអាចទាញយកមកប្រើប្រាស់បាននៅពេលក្រោយ

គ) អាចឱ្យបុគ្គលដែលទទួលបានព័ត៌មាននោះរក្សាទុកបាន។

**៥. លក្ខខណ្ឌតម្រូវចំពោះការរក្សាព័ត៌មានតាមទម្រង់ដើម**

លក្ខខណ្ឌគតិយុត្តក្នុងការរក្សាព័ត៌មាន ដែលមិនត្រឹមត្រូវបានធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិកអាចត្រូវបានបំពេញដោយការរក្សាព័ត៌មាននោះក្រោមទម្រង់អេឡិចត្រូនិកប្រសិនបើ៖

- ទម្រង់អេឡិចត្រូនិកនោះ ជាមធ្យោបាយដែលអាចជឿទុកចិត្តបានដើម្បីកំណត់ភាពពេញលេញរបស់ព័ត៌មាននោះ និង
- ព័ត៌មាននោះអាចចូលយកបានដោយងាយស្រួល សម្រាប់យកទៅប្រើប្រាស់បាននៅពេលក្រោយបាន។

**៦. លក្ខខណ្ឌតម្រូវចំពោះហត្ថលេខា**

ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលផ្អែកទៅលើកិច្ចសន្យាមួយដែលធ្វើឡើងតាមរយៈទំនាក់ទំនងអេឡិចត្រូនិក សុទ្ធតែត្រូវការលក្ខខណ្ឌមួយបង្កើតឱ្យមានឡើងដើម្បីឱ្យកិច្ចដំណើរពាណិជ្ជកម្មដំណើរការទៅបានដោយសុវត្ថិភាព។ ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឱ្យមានសុពលភាព យោងទៅតាមសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានចែងដើម្បីបង្កើតឱ្យមានសុពលភាពនៅក្នុងទំនាក់ទំនងអេឡិចត្រូនិក ដោយមានចែងតម្រូវឱ្យមានហត្ថលេខាជាដើម។

នៅពេលដែលមានបទប្បញ្ញត្តិណាមួយ លក្ខខណ្ឌណាមួយដែលមានទំនាក់ទំនងទៅលើការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ហើយដែលតម្រូវឱ្យមានហត្ថលេខារបស់បុគ្គលណាមួយក្នុងទំនាក់ទំនងទៅតាមប្រព័ន្ធអេឡិចត្រូនិក លក្ខខណ្ឌតម្រូវនេះត្រូវចាត់ទុកថាបានបំពេញតាមរយៈការចុះហត្ថលេខាតាមប្រព័ន្ធអេឡិចត្រូនិក ប្រសិនបើហត្ថលេខាអេឡិចត្រូនិកដែលបានប្រើនោះត្រូវបានបង្កើតឡើងតាមរយៈមធ្យោបាយដែល៖

ក-អាចកំណត់អត្តសញ្ញាណបុគ្គល និងបង្ហាញការឯកភាពរបស់បុគ្គលនោះលើព័ត៌មាន ឬកំណត់ត្រាដែលមាននៅក្នុងទំនាក់ទំនងអេឡិច្រូនិកនោះ

ខ-អាចជឿជាក់បាន ស្របតាមចរិកលក្ខណៈ គោលបំណង និងកាលៈទេសៈដែលទំនាក់ទំនងអេឡិចត្រូនិកនោះត្រូវបានបង្កើតឡើង ឬត្រូវបានប្រាស្រ័យទាក់ទងផងដែរ[51]។ ហើយហត្ថលេខានោះត្រូវតែ អាចជឿជាក់បាន និងស្របទៅតាមគោលបំណងដែលទំនាក់ទំនងអេឡិចត្រូនិកនោះត្រូវបានបង្កើតឡើង ឬត្រូវបានប្រាស្រ័យទាក់ទង ក្នុងគោលបំណងឆ្លុះបញ្ចាំងគ្រប់កាលៈទេសៈជាក់ស្តែង រួមទាំងរាល់កិច្ចព្រមព្រៀងដែលពាក់ព័ន្ធ។

កាលដូចដែលលើកឡើងខាងលើនេះវាតម្រូវទៅលើគ្រប់លក្ខខណ្ឌបើទោះបីជា មានច្បាប់កំណត់អំពីលក្ខខណ្ឌតម្រូវឱ្យមានចុះហត្ថលេខា ឬ គ្រាន់តែកំណត់ផលវិបាកនៃការមិនចុះហត្ថលេខាក៏ដោយ។ ហត្ថលេខាអេឡិចត្រូនិក ត្រូវបានសន្មតថាអាចជឿជាក់បាន ប្រសិនបើហត្ថលេខាអេឡិចត្រូនិក នោះគោរពទៅតាមលក្ខខណ្ឌដូចខាងក្រោមៈ

ក) អាចផ្សារភ្ជាប់ទៅនឹងហត្ថលេខីតែម្នាក់គត់

ខ) អាចកំណត់បានអត្តសញ្ញាណរបស់ហត្ថលេខី

គ) ត្រូវបានបង្កើតឡើងដោយប្រើប្រាស់មធ្យោបាយ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ហត្ថលេខីនោះ។

ឃ) បញ្ជាក់អំពីពេលវេលា និងកាលបរិច្ឆេទនៃការចុះហត្ថលេខា

ង) បញ្ជាក់ពីស្ថានភាពដើមនៃសារ ឬកំណត់ត្រាអេឡិចត្រូនិកដែលត្រូវបានផ្សាភ្ជាប់ដោយហត្ថលេខានោះបាន[52]។

ហើយម្យ៉ាងវិញទៀត ការសន្មត់ពីភាពដែលអាចជឿជាក់បាន ចំពោះហត្ថលេខាអេឡិចត្រូនិកមិនកម្រិតលើលទ្ធភាពរបស់បុគ្គលណាមួយក្នុងទំនាក់ទំនងអេឡិចត្រូនិកឡើយក្នុងការៈ

ក) កំណត់លក្ខខណ្ឌផ្សេងទៀតពាក់ព័ន្ធ នឹងការបញ្ជាក់ភាពអាចជឿជាក់បានរបស់ហត្ថលេខាអេឡិចត្រូនិក ឬ

ខ) លើកភស្តុតាងអំពីភាពមិនអាចជឿជាក់បាននៃហត្ថលេខាអេឡិចត្រូនិក[53]។

ហត្ថលេខាអេឡិចត្រូនិក មានកំណត់នៅក្នុងច្បាប់ផ្សេងមួយដែល កំណត់ឡើងដោយក្រសួង

51 សូមពិគ្រោះ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ៧ កថាខណ្ឌទី១

52 សូមពិគ្រោះ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ២០ កថាខណ្ឌទី១

53 សូមពិគ្រោះ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ២០ កថាខណ្ឌទី២

ប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជា ជាធានានូវសុវត្ថិភាព។

## កថាខណ្ឌ៦ ការព្រមព្រាងរបស់គូភាគីចំពោះសុពលភាពនៃទំនាក់ទំនងអេឡិចត្រូនិក

ទោះបីជានៅក្នុង កថាខណ្ឌទី៤ ខាងលើដែលលើកឡើងអំពីអានុភាព ឬសុពលភាពនៃទំនាក់ទំនងអេឡិចត្រូនិក នៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលកំណត់អំពីលក្ខខណ្ឌបង្កើតសុពលភាពនៅក្នុងទំនាក់ទំនងអេឡិចត្រូនិកនេះក៏ដោយ ក៏គូភាគីអាចធ្វើការកែប្រែបានដោយមានកិច្ចព្រមព្រាងរវាងគ្នា (គូភាគី) នោះ ហើយដែលចូលរួមក្នុងការបង្កើត ការផ្ញើ ការទទួល ការរក្សាទុក ឬដំណើរការទំនាក់ទំនងអេឡិចត្រូនិកបាន លើកលែងមានចែងផ្សេងពីនេះក្នុងកិច្ចព្រមព្រាងដើម[54]។ មួយវិញទៀតគូភាគីនៃកិច្ចសន្យា ឬប្រតិបត្តិការណាមួយ ក៏អាច[55]៖

ក. ហាមឃាត់មិនឱ្យប្រើប្រាស់កំណត់ត្រាតាមប្រព័ន្ធអេឡិចត្រូនិក ការទំនាក់ទំនងអេឡិចត្រូនិក ឬ ហត្ថលេខាតាមប្រព័ន្ធអេឡិចត្រូនិកក្នុងកិច្ចសន្យា ឬប្រតិបត្តិការណាមួយតាមរយៈកិច្ចព្រមព្រាង។

ខ. ដាក់លក្ខខណ្ឌតម្រូវបន្ថែមផ្សេងៗដែលពាក់ព័ន្ធនឹងទម្រង់ ឬយថាភូតភាពនៃកិច្ចសន្យា ឬប្រតិបត្តិការតាមរយៈកិច្ចព្រមព្រាង។

## ផ្នែកទី៣ សុវត្ថិភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

នៅ ផ្នែកទី៣ ធំនេះយើងនឹងសិក្សាទៅលើ ការកំណត់អំពីការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមួយដែលមានសុវត្ថិភាព ដែលយើងផ្តោតសំខាន់ទៅលើសុវត្ថិភាពនៃ កំណត់ត្រាអេឡិចត្រូនិក (**កថាខណ្ឌ២**) និងហត្ថលេខាអេឡិចត្រូនិក (**កថាខណ្ឌ៣**) និង សមត្ថកិច្ចរបស់អាជ្ញាធរក្នុងការគ្រប់គ្រង និងផ្តល់នីតិវិធីដើម្បីធានាសុវត្ថិភាព (**កថាខណ្ឌ១**) រួមទាំង ការសន្មតទាក់ទងនឹងកំណត់ត្រា និងហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព (**កថាខណ្ឌ៤**) ភស្តុតាងអេឡិចត្រូនិក (**កថាខណ្ឌ៥**) និង កិច្ចការពារអ្នកប្រើប្រាស់នៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (**កថាខណ្ឌ៦**) ។

## កថាខណ្ឌ១ សមត្ថកិច្ចរបស់អាជ្ញាធរក្នុងការគ្រប់គ្រង និងផ្តល់នីតិវិធីដើម្បីធានាសុវត្ថិភាព

អាជ្ញាធរមានសមត្ថកិច្ចជាពិសេសក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រង និងជាអ្នកផ្តល់នីតិវិធីដើម្បីធានាសុវត្ថិភាពដែលកំណត់។ ហើយស្ថាប័ននេះក៏ត្រូវផ្តល់នូវបទប្បញ្ញត្តិដែលទាក់ទង នឹងនីតិវិធីដើម្បីធានាសុវត្ថិភាព ដោយរាប់បញ្ចូលទាំង ៖

១) ការកំណត់លក្ខខណ្ឌដែលតាមរយៈនេះ ហត្ថលេខាអេឡិចត្រូនិកអាចត្រូវបានចាត់ទុកជា

[54] សូមពិគ្រោះ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ១៤ កថាខណ្ឌទី១

[55] សូមពិគ្រោះ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ១៤ កថាខណ្ឌទី២

ហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព

២) ការកំណត់លក្ខខណ្ឌដែលតាមរយៈនេះ កំណត់ត្រាអេឡិចត្រូនិកអាចត្រូវបានចាត់ទុកជាកំណត់ត្រាអេឡិចត្រូនិកដែលបានធានា និង

៣) បទប្បញ្ញត្តិ អាជ្ញាប័ណ្ណ ឬសិទ្ធិអំណាចរបស់អ្នកផ្តល់នីតិវិធីដើម្បីធានាសុវត្ថិភាព។

ការគ្រប់គ្រងនីតិវិធីសុវត្ថិភាពសម្រាប់កំណត់ត្រាអេឡិចត្រូនិក និងហត្ថលេខាអេឡិចត្រូនិកត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែកមួយ ដើម្បីធានាផ្តល់នូវសុវត្ថិភាពជូនអ្នកដែលធ្វើពាណិជ្ជកម្មតាមរយៈប្រព័ន្ធអេឡិចត្រូនិកនេះ។

**កថាខណ្ឌ២ សុវត្ថិភាពកំណត់ត្រា**

កំណត់ត្រា សំដៅដល់ព័ត៌មានដែលត្រូវបានកត់ត្រាចូល រក្សាទុក ឬបញ្ចូលទៅក្នុងទម្រង់រូបិយ ឬដែលត្រូវបានរក្សាទុកក្នុងទម្រង់អេឡិចត្រូនិក ជាក្រដាស ឬទម្រង់ប្រភេទផ្សេងទៀត ហើយដែលអាចទាញយកកំណត់ត្រានោះវិញបានក្នុងទម្រង់ជាក់លាក់ដែលអាចមើលបាន។ អ្នកដែលផ្តល់ និងធានានូវសុវត្ថិភាពចំពោះកំណត់ត្រា គឺអាជ្ញាធរដែលមានសមត្ថកិច្ចពាក់ព័ន្ធ។ កំណត់ត្រាអេឡិចត្រូនិកមួយត្រូវបានចាប់ទុកថាជាកំណត់ត្រាអេឡិចត្រូនិកដែលមានសុវត្ថិភាព គិតចាប់ពីពេលដែលមានភាពជាក់លាក់ រហូតដល់ពេលធ្វើការពិនិត្យបញ្ជាក់ដោយធ្វើការពិនិត្យផ្ទៀងផ្ទាត់[56]។ រាប់ថាជាពេលដែលជាក់លាក់មួយ គឺនូវពេលដែលបញ្ជាក់ថាកំណត់ត្រាអេឡិចត្រូនិកនោះមិនត្រូវបានកែប្រែ ហើយត្រូវបានប្រើប្រាស់ដោយត្រឹមត្រូវចំពោះកំណត់ត្រាអេឡិចត្រូនិកនោះ ទៅតាមនីតិវិធីស្តីពីសុវត្ថិភាព។

**កថាខណ្ឌ៣ សុវត្ថិភាពហត្ថលេខាអេឡិចត្រូនិក**

ហត្ថលេខាអេឡិចត្រូនិក សំដៅដល់រាល់ហត្ថលេខាដែលធ្វើឡើងដោយអាស្រ័យលើដំណើរការអេឡិចត្រូនិក ដែលហត្ថលេខានោះអាចឱ្យគេប្រើដើម្បីកំណត់អត្តសញ្ញាណរបស់ហត្ថលេខីដែលពាក់ព័ន្ធនឹងទំនាក់ទំនងអេឡិចត្រូនិកនោះ ឬដើម្បីបង្ហាញពីការយល់ព្រមរបស់ហត្ថលេខីទៅលើព័ត៌មានដែលមានក្នុងទំនាក់ទំនងអេឡិចត្រូនិកនោះ។ ចាប់ទុកថា ហត្ថលេខាមានមានសុវត្ថិភាពត្រូវបានពិនិត្យបញ្ជាក់បាននៅពេលដែលៈ

១) ផ្សាភ្ជាប់ទៅកាន់ហត្ថលេខីតែម្នាក់គត់

២) ហត្ថលេខានោះមានសមត្ថភាពកំណត់អំពីអត្តសញ្ញាណរបស់ហត្ថលេខី

៣) ហត្ថលេខានោះត្រូវបានបង្កើតតាមរបៀប ឬដោយប្រើប្រាស់មធ្យោបាយមួយដែលស្ថិតនៅក្រោមការត្រួតពិនិត្យគ្រប់គ្រងដោយហត្ថលេខី និង

[56] សូមពិគ្រោះ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ១៩

៤) បញ្ជាក់ពេលវេលា និងកាលបរិច្ឆេទនៃការចុះហត្ថលេខា[57]។

៥) បញ្ជាក់ពីស្ថានភាពដើមនៃសារ ឬកំណត់ត្រាអេឡិចត្រូនិកដែលត្រូវបានផ្សាភ្ជាប់ដោយហត្ថលេខានោះ។ ការដែលបានកំណត់បែបនេះ ពោលគឺមិនកម្រិតលទ្ធភាពរបស់បុគ្គលណាមួយក្នុងទំនាក់ទំនងអេឡិចត្រូនិក ក្នុងការកំណត់លក្ខខណ្ឌបន្ថែមផ្សេងទៀតពាក់ព័ន្ធនឹងភាពអាចជឿជាក់បានរបស់ហត្ថលេខាអេឡិចត្រូនិក និងលើភស្តុតាងអំពីភាពមិនអាចជឿកជាក់បាននៃហត្ថលេខាអេឡិចត្រូនិកនោះ។

**កថាខណ្ឌ៤ ការសន្មតកំណត់ត្រា និងហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព**

នៅក្នុង **កថាខណ្ឌ៤** នេះយើងនឹងសិក្សាទៅលើការសន្មតពីសុវត្ថិភាពកំណត់ត្រា **(ចំណុចទី១)** និង ពីសុវត្ថិភាពហត្ថលេខាអេឡិចត្រូនិក **(ចំណុចទី២)**។

**១. ការសន្មតអំពីសុវត្ថិភាពកំណត់ត្រា**

ត្រូវបានសន្មតថាកំណត់ត្រាមួយមានសុវត្ថិភាព នៅពេលដែលកំណត់ត្រាអេឡិចត្រូនិកនោះមិនត្រូវបានកែប្រែចាប់តាំងពីពេលជាក់លាក់ណាមួយកើតមានឡើង។ ប៉ុន្តែទោះបីជាបានកំណត់ពីការសន្មតបែបនេះក៏ដោយ បើសិនបើរកឃើញនោះភស្តុតាងដែលផ្ទុយបង្ហាញ នោះការសន្មតដែលបានលើកឡើងអំពីសុវត្ថិភាពកំណត់ត្រានោះ ក៏ប្រែប្រួលទៅតាមភស្តុតាងដែលផ្ទុយនោះដែរ។

**២. ការសន្មតអំពីសុវត្ថិភាពហត្ថលេខាអេឡិចត្រូនិក**

ហត្ថលេខាអេឡិចត្រូនិក ត្រូវបានសន្មតនៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកថាជាហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាពលុះត្រាតែ ៖

ក) ហត្ថលេខាអេឡិចត្រូនិកនោះ គឺជាហត្ថលេខារបស់បុគ្គល ដែលពាក់ព័ន្ធ និង

ខ) ហត្ថលេខាអេឡិចត្រូនិកមានសុវត្ថិភាព ត្រូវបានចុះហត្ថលេខាដោយរូបវន្តបុគ្គលដែលមានឆន្ទៈក្នុងការចុះហត្ថលេខា ឬបានយល់ព្រមជាមួយគ្នាដោយធ្វើការឯកភាពលើកំណត់ត្រាតាមរយៈប្រព័ន្ធអេឡិចត្រូនិកនោះ[58]។

តែបើក្នុងករណីដែលគ្មានកំណត់ត្រាអេឡិចត្រូនិកសុវត្ថិភាព ឬ ហត្ថលេខាអេឡិចត្រូនិកសុវត្ថិភាពទេ នោះគេមិនអាចសន្មតជាមុនអំពីយថាភូតភាព ឬសុក្រិតភាពនៃកំណត់ត្រាអេឡិចត្រូនិក ឬហត្ថលេខាអេឡិចត្រូនិកនោះឡើយ[59]។

[57] សូមពិគ្រោះ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ២០

[58] សូមពិគ្រោះ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ២១ កថាខណ្ឌទី២

[59] សូមពិគ្រោះ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ២១ កថាខណ្ឌទី២ វេយ្យខណ្ឌទី៣

## កថាខណ្ឌ៥ ភស្តុតាងអេឡិចត្រូនិក

នៅក្នុងទំនាក់ទំនងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក៏មិនខុសគ្នាអីទៅនឹងដំណើការប្រតិបត្តិការផ្សេងៗទៀតដែរ ពោលគឺវាត្រូវការនូវ លក្ខខណ្ឌដើម្បីបញ្ជាក់ ពី សុពលភាព នៃប្រតិបត្តិការនោះឱ្យដំណើរការទៅបានយ៉ាងរលូន។ នៅក្នុងទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជាវាជាសញ្ញាណមួយថ្មីដែលពឹងផ្អែកទៅលើបច្ចេកវិទ្យាទាំងស្រុង ដែលជាវិបាកក្នុងកាគ្រប់គ្រង រហូតមកដល់បច្ចុប្បន្ន ពិសេសដូចជាហត្ថលេខាអេឡិចត្រូនិក និងលក្ខខណ្ឌដើម្បីបញ្ជាក់ភស្តុតាងក្នុងទម្រង់ជាប្រព័ន្ធអេឡិចត្រូនិកជាអាទិ៍ ហើយយើងនឹងធ្វើការសិក្សាលម្អិតទៅលើ ប្រព័ន្ធអេឡិចត្រូនិកដែលមានសុក្រិតភាព **(ចំណុចទី១)** សុក្រឹតភាពនៃព័ត៌មាន **(ចំណុចទី២)** និងបទដ្ឋានដែលបញ្ជាក់អំពីសុក្រឹតភាពនៃកំណត់ត្រាអេឡិចត្រូនិក **(ចំណុចទី៣)** រួមទាំងនីតិវិធីផ្សេងៗទៀតក្នុងការបង្កើតភស្តុតាងអេឡិចត្រូនិក **(ចំណុចទី៤)** និងបន្តសិក្សាទៅលើ ការបង្ហាញពីយថាភូតភាពនៃភស្តុតាងអេឡិចត្រូនិក **(ចំណុចទី៥)** នឹង ឯកសារជាភស្តុតាងអេឡិចត្រូនិកដែលបានបោះពុម្ពចេញ **(ចំណុចទី៦)**។

### ១. ប្រព័ន្ធអេឡិចត្រូនិកដែលមានសុក្រិតភាព

ភស្តុតាងអេឡិចត្រូនិកត្រូវបានគេទទួលស្គាល់ និងទទួលយកជាទូទៅដើម្បីធ្វើការកំណត់អំពីសុវត្ថិភាពនៃភស្តុតាងអេឡិចត្រូនិក។ គ្មានបុគ្គលណាមួយអាចធ្វើការបដិសេធមិនទទួលយកនូវកំណត់ត្រាអេឡិចត្រូនិកទំនាក់ទំនងអេឡិចត្រូនិកធ្វើជាភស្តុតាង ដោយគ្រាន់តែសម្អាងលើមូលដ្ឋានថាវាជាកំណត់ត្រាអេឡិចត្រូនិកបានទេ បើទោះបីជាភស្តុតាងនោះមិនស្ថិតនៅក្នុងទម្រង់ដើមក៏ដោយ[60]។

សុពលភាពនៃភស្តុតាងអេឡិចត្រូនិកអាចត្រូវបានបញ្ជាក់តាមរយៈសុក្រិតភាព នៃប្រព័ន្ធអេឡិចត្រូនិកដែលបានកត់ត្រា ឬរក្សាទុកនូវទិន្នន័យណាមួយ[61]។

សុក្រិតភាពនៃប្រព័ន្ធអេឡិចត្រូនិកដែលកំណត់ត្រាអេឡិចត្រូនិកត្រូវបានកត់ត្រាទុក ឬរក្សាទុកត្រូវបានគេសន្មតក្នុង នីតិវិធីតាមផ្លូវច្បាប់ដូចខាងក្រោមៈ

ក- នៅពេលដែលមានភស្តុតាងគាំទ្រដល់អង្គហេតុណាមួយដែលបញ្ជាក់ថាប្រព័ន្ធអេឡិចត្រូនិក ឬឧបករណ៍ស្រដៀងគ្នាផ្សេងទៀត បានដំណើរកាជាប្រក្រតីនៅពេលដែលកំណត់ត្រាអេឡិចត្រូនិកនោះត្រូវបានកដត្រា ឬ រក្សាទុក ឬនៅពេលដែលយកធ្វើជាភស្តុតាង ឬក្នុងករណីដែលប្រព័ន្ធអេឡិចត្រូនិក ឬឧបករណ៍ស្រដៀងគ្នាផ្សេងទៀតនោះមិនបានដំណើរការជាប្រក្រតី ឬឈប់ដំណើរការទាំងស្រុង តែមិនធ្វើឱ្យប៉ះពាល់ដល់សុក្រិតភាពនៃកំណត់ត្រាអេឡិចត្រូនិក ហើយគ្មានមូលហេតុសមស្របណាផ្សេង យកមកជំទាស់លើសុក្រឹតភាពនៃកំណត់ត្រានោះឡើយ ឬ

ខ- នៅពេលដែលមានភស្តុតាងអាចបង្ហាញថា កំណត់ត្រាអេឡិចត្រូនិកត្រូវបានកត់ត្រាចូល ឬ

[60] សូមពិគ្រោះ សេចក្ដីព្រាងច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ៣២

[61] សូមពិគ្រោះ សេចក្ដីព្រាងច្បាប់ស្ដីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ៣៣ កថាខណ្ឌទី១

រក្សាទុក ដោយភាគីដែលមានផលប្រយោជន៍ផ្ទុយគ្នាទៅនឹងភាគីម្ខាងទៀតដែលប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិកនោះជាភស្តុតាងក្នុងដំណើការនីតិវិធីតាមផ្លូវច្បាប់

គ- នៅពេលដែលមានភស្តុតាងអាចបង្ហាញបានថា កំណត់ត្រាអេឡិចត្រូនិកត្រូវបានកត់ត្រាចូល ឬរក្សាទុកតាមធម្មតា និងគោលបំណងអាជីវកម្មធម្មតាដោយបុគ្គល ដែលមិនមែនជាភាគីនៅក្នុងនីតិតាមផ្លូវច្បាប់ ហើយ បុគ្គលនោះមិនបានកត់ត្រា ឬរក្សាទុកនូវកំណត់ត្រាអេឡិចត្រូនិកក្រោមការគ្រប់គ្រងរបស់ភាគីដែលមានបំណងប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិកនោះ ជាភស្តុតាងក្នុងដំណើការនីតិវិធីតាមផ្លូវច្បាប់។

**២. សុក្រឹតភាពនៃព័ត៌មាន**

សុក្រឹតភាពនៃព័តិមានជាពិសេសកំណត់ត្រាអេឡិចត្រូនិកដែលបានកត់ត្រា ឬរក្សាទុកនៅក្នុងប្រព័ន្ធអេឡិចត្រូនិក ត្រូវបានសន្មតថាមានសុក្រឹតភាពនៅក្នុងនីតិវិធីតាមផ្លូវច្បាប់ ប្រសិនបើកំណត់ត្រាអេឡិចត្រូនិកនោះ៖

ក- នៅពេញលេញ និងគ្មានការកែប្រែ ក្រៅពីការធ្វើបដិលេខបន្ថែមណាមួយ ឬការផ្លាស់ប្តូដែលមិនសំខាន់ណាមួយដែលកើតឡើងនៅក្នុងដំណើរការជាប្រក្រតីនៃទំនាក់ទំនង ការរក្សាទុក ឬ ការបង្ហាញ។

ខ- ត្រូវបានបញ្ជាក់ ឬចុះហត្ថលេខានៅក្នុងទម្រង់អេឡិចត្រូនិក តាមរយៈមធ្យោបាយដែលផ្តល់ឲ្យដោយអ្នកផ្តល់នីតិវិធីសុវត្ថិភាពដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវ។

គ- មានសុក្រឹតភាព និងមានខ្លឹមសារដែលត្រូវបានបញ្ជាក់ដោយក្រសួង ឬស្ថាប័នមានសមត្ថកិច្ច។

ឃ- ត្រូវបានកត់ត្រាទុកនៅក្នុងឧបករណ៍រក្សាទុកដែលមិនអាចយកទៅធ្វើឡើងវិញជាថ្មី ឬតាមមធ្យោបាយអេឡិចត្រូនិកផ្សេងទៀតដែលមិនអនុញ្ញាតឱ្យមានការកែរប្រែទៅលើកំណត់ត្រាអេឡិចត្រូនិកនោះ។

ង- ត្រូវបានត្រួតពិនិត្យ និងបញ្ជាក់ពីសុក្រឹតភាព ដោយអ្នកជំនាញដែលត្រូវបានតែងតាំងដោយតុលាការ។

ច- នៅពេលដែលមានភស្តុតាងគាំទ្រដល់អង្គហេតុណាមួយ ដែលបញ្ជាក់ថាប្រព័ន្ធអេឡិចត្រូនិក ឬឧបករណ៍ស្រដៀងគ្នាផ្សេង បានដំណើរជាប្រក្រតីនៅគ្រប់រយៈពេលសំខាន់ៗ ឬក្នុងករណីដែលប្រព័ន្ធអេឡិចត្រូនិក ឬឧបករណ៍ស្រដៀងគ្នាផ្សេងទៀតនោះមិនបានដំណើរការជាប្រក្រតី ឬឈប់ដំណើរការទាំងស្រុង តែសុក្រឹតភាពនៃកំណត់ត្រា មិនរងការប៉ះពាល់ដោយសារស្ថានភាពទាំងនោះទេ ហើយគ្មានមូលហេតុសមស្របណាផ្សេងទៀតដែលចោទជា មន្ទិលសង្ស័យលើសុក្រឹតភាពនៃកំណត់ត្រានោះឡើយ ឬ

ឆ- នៅពេលដែលមានភស្តុតាងអាចបង្ហាញបានថា កំណត់ត្រាអេឡិចត្រូនិកត្រូវបានកត់ត្រា ឬរក្សាទុក ដោយភាគីដែលចូលរួមនៅក្នុងនីតិវិធីតាមផ្លូវច្បាប់នោះ ហើយដែលភាគីមានទំនាស់ផលប្រយោជន៍ ទៅនឹងភាគីម្ខាងទៀត ដែលមានបំណងប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិកនោះ[62]។ ឬ នៅពេលដែលមានភស្តុតាងអាចបង្ហាញបានថា កំណត់ត្រាអេឡិចត្រូនិកត្រូវបានកត់ត្រា ឬរក្សាទុកតាមធម្មតា និងក្នុងគោលបំណងអាជីវកម្មធម្មតា ដោយបុគ្គលដែលមិនមែនជាភាគីនៅក្នុងនីតិវិធីតាមផ្លូវច្បាប់ ហើយបុគ្គលនោះមិនបានកត់ត្រា ឬរក្សាទុកនូវកំណត់ត្រាអេឡិចត្រូនិក ក្រោមការគ្រប់គ្រងរបស់ភាគីដែលមានបំណងប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិកនោះ។

នៅពេលដែលរបាយការណ៍ ត្រូវបានកត់ត្រាទុកនៅក្នុងកំណត់ត្រាអេឡិចត្រូនិកដែលត្រូវបានបង្កើតឡើងដោយប្រព័ន្ធអេឡិចត្រូនិក មិនត្រូវបានចាត់ទុកថា ជាពាក្យចចាមអារាមទេនោះ របាយការណ៍ទាំងនោះអាចទទួលយកបាន ប្រសិនបើលក្ខខណ្ឌ ដូចបានរៀបរាប់ខាងលើ ដែលទាក់ទងនឹងកំណត់ត្រាអេឡិចត្រូនិកនោះត្រូវបានបំពេញ។

### ៣. បទដ្ឋានដែលបញ្ជាក់អំពីសុក្រឹតភាពនៃកំណត់ត្រាអេឡិចត្រូនិក

នៅក្នុងសេចក្តីព្រាងច្បាប់កម្ពុជាយើង ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានកំណត់អំពីសុក្រឹតភាពនៃកំណត់ត្រាអេឡិចត្រូននិកថា អាចទទួលយកបាន ឬមិនអាចទទួលយកបាន ដោយគ្រាន់តែបង្ហាញភស្តុតាងពាក់ព័ន្ធទៅនឹងបទដ្ឋាន នីតិវិធីការប្រើប្រាស់ ឬការអនុវត្តនៃកំណត់ត្រាអេឡិចត្រូនិក ឬរក្សាទុកអេឡិចត្រូនិក ដោយត្រូវពិនិត្យពិចារណាអំពីប្រភេទអាជីវកម្មចរិកលក្ខណៈ និងគោលបំណងនៃកំណត់ត្រាអេឡិចត្រូនិកនោះ[63]។

### ៤. នីតិវិធីផ្សេងៗទៀតក្នុងការបង្កើតភស្តុតាងអេឡិចត្រូនិក

ភស្តុតាងអេឡិចត្រូនិកអាចត្រូវបានកំណត់ ឬបង្កើតនៅក្នុងនីតិវិធីផ្សេងៗទៀត ដើម្បីយកមកប្រើប្រាស់នៅក្នុងវិស័យពាណិជ្ជកម្ម ជាពិសេសគឺពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះផ្ទាល់តែម្តង។ ដោយបន្ថែមពីលើការបកស្រាយនូវភស្តុតាងអេឡិចត្រូនិកដែលមានខាងលើ ភស្តុតាងអេឡិចត្រូនិកអាចត្រូវបង្កើតឡើង តាមបច្ចេកទេស និងនីតិវិធីផ្សេងទៀតដូចជា ការបញ្ជាក់ដោយសាការី ឬស្ថាប័នមានសមត្ថកិច្ច កំណត់ត្រាក្នុងមធ្យោបាយអេឡិចត្រូនិកដែលមិនអនុញ្ញាតឲ្យមានការកែប្រែបាន និង លទ្ធផលកោសល្យវិច្ច័យទៅលើប្រព័ន្ធអេឡិចត្រូនិកតាមការរកឃើញរបស់យុត្តាធិការតុលាការ[64]។

---

[62] សូមពិគ្រោះ: សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ៣៥ កថាខណ្ឌទី១

[63] សូមពិគ្រោះ: សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ៣៧

[64] សូមពិគ្រោះ: សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ៣៩

**៤.១. ការទទួលយកភស្តុតាងអេឡិចត្រូនិកពីបណ្តាប្រទេសផ្សេងត្រឹមជាកំណត់ត្រា**

នៅគ្រប់ភស្តុតាងដែលមានការបញ្ជាក់ពីក្រសួង ឬ ស្ថាប័នមានសមត្ថកិច្ចនៃបណ្តារដ្ឋប្រទេសក្រៅពីកម្ពុជា គឺត្រូវបានទទួលស្គាល់ថាជាភស្តុតាងបាន ប្រសិនបើប្រព័ន្ធអេឡិចត្រូនិកដែលកដត្រា ឬ រក្សាទុកកំណត់ត្រាអេឡិចត្រូនិកនោះ មានសុក្រឹតភាពដែលស្របទៅតាមបទដ្ឋានដែលប្រហាក់ប្រហែល ទៅនឹងបទដ្ឋានដែលមានចែងនៅក្នុង ច្បាប់របស់កម្ពុជា[65]។

**៤.២. ការទទួលស្គាល់ភស្តុតាងអេឡិចត្រូនិកពីបណ្តាប្រទេសផ្សេងៗទៀតត្រឹមជាព័ត៌មានអេឡិចត្រូនិក**

ចំពោះភស្តុតាងអេឡិចត្រូនិកចំពោះព័ត៌មាន ដែលជាប្រតិបត្តិការមួយនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ទោះបីវាមាននៅបណ្តាប្រទេសផ្សេងទៀតក៏ដោយត្រូវកំណត់ថាព័ត៌មានក្នុងទម្រង់អេឡិចត្រូនិកមួយអាចទទួលយកបាន ឬមិនអាចទទួលយកបាន ឬអាចទទួលយកបានត្រឹមកម្រិតណា គឺមិនចាំបាច់គិតពីទីតាំងដែលព័ត៌មាននោះត្រូវបានបង្កើតឡើង ឬត្រូវបានប្រើប្រាស់ ឬទីកន្លែងនៃអាជីវកម្មដែលបានបង្កើតឡើងនោះឡើយ ឱ្យតែកំណត់ត្រាអេឡិចត្រូនិកនោះអាចចូល និងទាញយកមកប្រើប្រាស់បាននៅក្នុងដែនសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា[66]។

**៥. ការបង្ហាញពីយថាភូតភាពនៃភស្តុតាងអេឡិចត្រូនិក**

នៅក្នុងផ្នែកនេះយើងនឹងធ្វើការសិក្សាទៅលើពីចំណុចអមសំខាន់ៗ ដោយសិក្សាទៅលើបន្ទុកក្នុងការបង្ហាញពីយថាភូតភាពនៃភស្តុតាង និងការចេញសេចក្តីបញ្ជាក់ យថាភូតភាពនៃភស្តុតាងអេឡិចត្រូនិក។

**៥.១. បន្ទុកក្នុងការបង្ហាញពីយថាភូតភាពនៃភស្តុតាងអេឡិចត្រូនិក**

ភស្តុតាងអេឡិចត្រូនិកត្រូវបានខ្លាចជាបន្ទុកក្នុងការបង្ហាញពីយថាភូតភាពទៅលើបុគ្គលដែលបានបង្ហាញខាងក្រោម៖

១- បុគ្គលដែលស្នើសុំបង្ហាញកំណត់ត្រាអេឡិចត្រូនិក ក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ណាមួយ បុគ្គលនោះត្រូវមានបន្ទុកបង្ហាញពីយថាភូតភាពនៃកំណត់ត្រាអេឡិចត្រូនិកដោយមានភស្តុតាងគាំទ្រដល់កំណត់ត្រាដែលបុគ្គលនោះបានបង្ហាញ។

២- ក្នុងករណីមានបទប្បញ្ញត្តិណាមួយ ការពារបុគ្គលងាយរងគ្រោះដែលរាប់បញ្ចូលទាំងអ្នកប្រើប្រាស់ និងកុមារ ហើយដែលមានកំណត់អំពីបន្ទុកនៃភស្តុតាងដែលមានអត្ថប្រយោជន៍ដល់បុគ្គលទាំងនោះច្រើនជាង ហើយត្រូវតែយក បទប្បញ្ញត្តិនោះជាបទប្បញ្ញត្តិដែលមានអាទិភាពជាងគេក្នុងការអនុវត្ត។

[65] សូមពិគ្រោះ: សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ៥០

[66] សូមពិគ្រោះ: សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ៥១

**៥.២. ការចេញសេចក្ដីបញ្ជាក់ពីយថាភូតភាពនៃភស្តុតាងអេឡិចត្រូនិក**

ក្នុងករណីដែល បុគ្គលណាមួយមានបំណងចង់បង្ហាញយថាភូតភាពនៃកំណត់ត្រាអេឡិចត្រូនិកមួយដើម្បីធ្វើជាភស្តុតាង បុគ្គលនោះអាចស្នើសុំភស្តុតាងនោះពីអ្នកជំនាញពាក់ព័ន្ធនឹងយថាភូតភាពនៃកំណត់ត្រាអេឡិចត្រូនិកនោះក្រោមទម្រង់ជាសេចក្ដីបញ្ជាក់។

សេចក្ដីបញ្ជាក់នោះត្រូវបានបង្កើតឡើងក្រោមទម្រង់ដែលរៀបចំដោយ ៖

ក - ក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬ បុគ្គលដែលមានតួនាទីទទួលខុសត្រូវពាក់ព័ន្ធនឹងប្រតិបត្តិការ ឬការគ្រប់គ្រងអ្នកបង្កើតនីតិវិធីសុវត្ថិភាពជាក់លាក់ណាមួយ ឬ អ្នកបង្កើតនីតិវិធីសុវត្ថិភាពដែលទទួលស្គាល់ដោយតុលាការ ឬ

ខ- អ្នកជំនាញដែលតែងតាំង ឬដែលទទួលស្គាល់ដោយតុលាការ។

**៦. ឯកសារជាភស្តុតាងអេឡិចត្រូនិកដែលបានបោះពុម្ពចេញ**

ភស្តុតាងអេឡិចត្រូនិកជា កំណត់ត្រាហើយដែលបានបោះពុម្ពចេញដោយស្ថិតនៅក្នុងទម្រង់ជាឯកសារ ហើយដែលបានបោះពុម្ពត្រឹមត្រូវស្រប នឹងខ្លឹមសារដើមចេញពីកំណត់ត្រាអេឡិចត្រូនិកអាចយកមកប្រើប្រាស់ជាភស្តុតាងបានក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់។ តែត្រូវអនុវត្តផ្អែកទៅលើ ឬប្រើប្រាស់យ៉ាងច្បាស់លាស់ និងបានស្របទៅនឹងនីតិវិធីតាមផ្លូវច្បាប់ត្រូវចាប់ទុកថាជាកំណត់ត្រាសម្រាប់គោលបំណងប្រើប្រាសជាភស្តុតាងបាន ដែលទទួលស្គាល់ដោយសេចក្ដីព្រាងច្បាប់នេះ។

**កថាខណ្ឌ៦ កិច្ចការពារអ្នកប្រើប្រាស់នៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

ការធ្វើអាជីវកម្ម ឬ ពាណិជ្ជកម្ម កត្តាសុវត្ថិភាពក្នុងប្រតិបត្តិការនៅតាមវិស័យនីមួយៗគឺជារឿងសំខាន់បំផុតដើម្បីទទួលបានការទុកចិត្ត ទៅលើពាណិជ្ជកម្មនោះ ជាពិសេសពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលជាការប្រតិបត្តិការពាណិជ្ជកម្មដោយប្រើប្រាស់នូវបច្ចេកវិទ្យាជាចម្បងក្នុងការដំណើរការ។ ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ខុសពីការធ្វើពាណិជ្ជកម្មដោយផ្ទាល់ ត្រង់ប្រើប្រាស់នូវអេឡិចត្រូនិកជាជំនួយ។ ហេតុដូច្នេះវាលំបាកក្នុងការទទួលបាននូវការទុកចិត្តពីភាគីនៃដំណើរការពាណិជ្ជកម្មនេះ ជាពិសេស ទៅលើអ្នកប្រើប្រាស់ផ្ទាល់តែម្តង ដែលអាចមានបញ្ហាច្រើនទៅដល់ពួកគាត់។ ដូច្នេះហើយបានជារដ្ឋាភិបាលខិតខំបង្កើតឱ្យមាននូវច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ដែលនឹងដាក់អនុវត្តន៍ឆាប់ៗនេះ។ ការការពារចំពោះអ្នកប្រើប្រាស់នេះក៏មានចែងនៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែល។ ការការពារអ្នកប្រើប្រាស់នៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក បានផ្តោតសំខាន់ទៅលើការការពារទៅលើព័ត៌មាននៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក **(ចំណុច១)** ការការពារអ្នកប្រើប្រាស់នៅក្នុងទំនាក់ទំនងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលមិនបានស្នើសុំ **(ចំណុច២)** និង ការការពារទៅលើទិន្នន័យជាដើម **(ចំណុច៣)** ។ ការចែងពីការការពារអ្នកប្រើប្រាស់នៅក្នុងសេចក្តីព្រាងច្បាប់នេះមិនអាចគ្រប់គ្រាន់ នោះទេពោលគ្រប់ភាគីដែលបានប្រើប្រាស់នូវ ទំនាក់ទំនងអេឡិចត្រូនិកក្នុង

សកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក អាចយកច្បាប់នានាផ្សេងៗទៀតយកមកអនុវត្តបាន ដើម្បីឱ្យអ្នកប្រើប្រាស់ទទួលបាននូវការការពារ ទទួលបាននូវសុវត្ថភាព ទៅលើការប្រើប្រាស់របស់ខ្លួន តែរាល់បទប្បញ្ញត្តិទាំងអស់នោះត្រូវតែមានទំនាក់ទំនងទៅនឹងកិច្ចការពារអ្នកប្រើប្រាស់ជាដាច់ខាត[67]។

### ១. ការការពារព័ត៌មាននៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ការការពារព័ត៌មានរបស់ អ្នកដែលប្រើប្រាស់សេវា ឬ ទំនិញដែលកើតចេញពីទំនាក់ទំនងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានទទួលនូវការការពារដោយច្បាប់ នៅចំពោះមុខគ្រប់បុគ្គលដែលប្រើប្រាស់នូវទំនាក់អេឡិចត្រូនិកនោះដើម្បីធ្វើការលក់ទំនិញ ឬសេវា នោះទៅដល់អ្នកប្រើប្រាស់។ ហើយម្យ៉ាងទៀតនោះ បុគ្គលដែលប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកដើម្បីលក់ទំនិញ ឬ សេវាទៅឲ្យអ្នកប្រើប្រាស់ នោះត្រូវផ្តល់ព័ត៌មានត្រឹមត្រូវ រួមទាំងលក្ខខណ្ឌផ្សេងៗទៀតដូចជាភាពច្បាស់លាស់ និងងាយយល់បាន ហើយមានព័ត៌មានយ៉ាងតិចដូចមានចែងនៅផ្នែកខាងក្រោម[68]៖

ក-ឈ្មោះ ឬនាមករណ៍ ស្របច្បាប់របស់បុគ្គល អាសយដ្ឋានអាជីវកម្មដែលបានចុះបញ្ជី និងមធ្យោបាយអេឡិចត្រូនិកសម្រាប់ទំនាក់ទំនង ឬលេខទូរស័ព្ទ។

ខ-ទម្រង់ទំនាក់ទំនងដែលរហ័ស ងាយស្រួល និងមានប្រសិទ្ធភាពរវាងអ្នកប្រើប្រាស់ជាមួយអ្នកលក់។

គ-ខចែង លក្ខខណ្ឌ និងសោហ៊ុយរបស់ទំនិញ ឬសេវានានាដែលពាក់ព័ន្ធនឹងប្រតិបត្តិការពាណិជ្ជកម្ម ជាពិសេស ខចែង លក្ខខណ្ឌ និងមធ្យោបាយ ទូទាត់ប្រាក់ និងព័ត៌មានលម្អិតពាក់ព័ន្ធនឹងការដក ឬលុបចោលការបញ្ជាទិញ ការបញ្ឈប់ការ ការប្រគល់ និងការផ្លាស់ប្តូរទំនិញ និងការសងប្រាក់មកវិញ។

ឃ-ទំនិញ និងសេវាជាក់ស្តែងដែលដាក់លក់។

ព័ត៌មានដែលបានបង្ហាញខាងលើចាប់ទុកថាជា ព័ត៌មានគ្រប់គ្រាន់សម្រាប់ឲ្យអ្នកប្រើប្រាស់អាចមានសមត្ថភាពក្នុងការសម្រេចចិត្តលើប្រតិបត្តិការពាណិជ្ជកម្ម និងសម្រាប់រក្សាទុកដោយត្រឹមត្រូវជាព័ត៌មាន ប៉ុន្តែគេមិនអាចយកព័ត៌ទាំងអស់នោះមកអនុវត្តន៍ឡើយសម្រាប់វិស័យធានារ៉ាប់រង និងវិស័យមូលបត្រ[69]ឡើយ។

---

[67] សូមពិគ្រោះ៖ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ៣០

[68] សូមពិគ្រោះ៖ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ២៧ កថាខណ្ឌទី១

[69] សូមពិគ្រោះ៖ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ខែឧសភា ឆ្នាំ២០១៩,មាត្រា២៧ កថាខណ្ឌទី២

**២.ការការពារអ្នកប្រើប្រាស់នៅក្នុងទំនាក់ទំនងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលមិនបានស្នើសុំ**

នៅក្នុងចំណុចនេះយើងនឹងធ្វើការសិក្សាទៅលើចំណុចមួយថ្មី ដែលផ្តោតសំខាន់ទៅលើការការពារអ្នកប្រើប្រាស់គឺនៅក្នុងករណីដែលអ្នកប្រើប្រាស់នោះស្ថិតនៅក្នុងស្ថានភាពជាជនរងគ្រោះ ព្រោះបុគ្គលដែលបានធ្វើពាណិជ្ជកម្មជាមួយគាត់នោះមិនបានធ្វើទំនាក់ទំនងពាណិជ្ជកម្មមិនបានស្នើសុំ។ ដែលមានខ្លឹមសារថាបុគ្គលណាក៏ដោយ ទោះបីជាមានទីតាំងអាជីវកម្មក្នុង ឬក្រៅកម្ពុជា ហើយដែលផ្ញើទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំទៅកាន់អ្នកប្រើប្រាស់ដែលស្ថិតនៅក្នុង ឬក្រៅកម្ពុជា តាមរយៈប្រព័ន្ធផ្សព្វផ្សាយ ឬតាមរយៈអន្តរការី ឬអ្នកផ្តល់សេវាទូរគមនាគមន៍ ត្រូវផ្តល់ជម្រើសច្បាស់លាស់ និងងាយស្រួលសម្រាប់ អ្នកប្រើប្រាស់អាចធ្វើការបដិសេធមិនទទួលយកនូវទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំនោះ[70]។

**៣. ការការពារទៅលើទិន្នន័យ**

ការការពារទៅលើទិន្នន័យ គឺជារឿងសំខាន់នៅក្នុងប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះ ព្រោះគ្រប់បុគ្គលតែងប្រាថ្នាចង់បាននូវការការធ្វើពាណិជ្ជកម្ម ភាពជាឯកជនក្នុងការធ្វើពាណិជ្ជកម្ម ដូចជា បញ្ហា សំខាត់នៃឯកសារ ដែលភាគីបានធ្វើ ដូចជា កិច្ចសន្យាដែលភាគីបានធ្វើសម្រាប់ដំណើការពាណិជ្ជកម្ម ការផ្តល់នូវសុវត្ថិភាព មានសុវត្ថិភាពទៅលើ ធាតុផ្សំនានាដែលមាននៅក្នុងការធ្វើពាណិជ្ជកម្ម ជាពិសេសការការពារទៅលើទិន្នន័យ ដែលយើងនឹងលើកយកមកសិក្សានៅក្នុងផ្នែកនេះ ដើម្បីបន្ថែមទៅលើចំណុចខាងលើ។

ជារួមនោះបុគ្គលដែលរក្សាព័ត៌មានជាលក្ខណៈឯកជនក្រោមទម្រង់អេឡិចត្រូនិក ត្រូវធានាថាព័ត៌មាននោះទទួលបាននូវការការពារ ប្រកបដោយសុវត្ថិភាពគ្រប់កាលៈទេសៈសមហេតុសមផលក្នុងគោលបំណងដើម្បីចៀសវាង ការបាត់បង់ ការចូល ការប្រើប្រាស់ ការបែកធ្លាយ ឬការបង្ហាញព័ត៌មានទាំងនោះ តែវាទទួលបាននូវការលើកលែងក្នុងករណីដែលមានការអនុញ្ញាតពីម្ចាស់នៃព័ត៌មាននោះ ឬពីភាគីផ្សេងទៀតដែលមានការអនុញ្ញាតត្រឹមត្រូវតាមច្បាប់[71]។

ដូច្នេះដើម្បីឲ្យទទួលបាននូវសុវត្ថិភាពនោះបុគ្គលដែលរក្សាព័ត៌មាននោះ ត្រូវប្រើគ្រប់មធ្យោបាយក្នុងការការពារសុវត្ថិភាពព័ត៌មានដែលផ្តល់ឱ្យតតិយជន ដើម្បីចៀសវាងការប្រើប្រាស់ព័ត៌ មាន ដោយគ្មានការអនុញ្ញាត[72]។

[70] សូមពិគ្រោះ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា២៨

[71] សូមពិគ្រោះ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ២៩ កថាខណ្ឌទី១

[72] សូមពិគ្រោះ សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩, មាត្រា ២៩ កថាខណ្ឌទី២

បុគ្គលទាំងឡាយមិនត្រូវចូលប្រើប្រាស់ ទាញយក ថតចម្លង ស្រង់យក ឬធ្វើឲ្យបែកធ្លាយទិន្នន័យដែលស្ថិតនៅក្រោមការរក្សាទុករបស់បុគ្គលផ្សេងទៀតដោយទុច្ចរិតឬគ្មានការអនុញ្ញាតិនោះឡើយ។

# ជំពូកទី២

# ដំណើរការពាណិជ្ជកម្ម

# តាមប្រព័ន្ធអេឡិចត្រូនិក

## ជំពូកទី២ ដំណើរការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

យើងបានសិក្សារួចមកហើយអំពីជំពូកដំបូង អំពីការបង្កើតឱ្យមានឡើងនូវកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលបានកើតតាមរយៈប្រព័ន្ធអេឡិចត្រូនិក ពោលគឺការប្រើប្រាស់នូវបច្ចេកវិទ្យាក្នុងការបង្កើត ដែលជាដំណាក់ការមួយផ្ដើមដំបូងនាំឱ្យមានប្រតិបត្តិការពាណិជ្ជកម្មមួយកើតឡើង។ យើងក៏បានសិក្សាផងដែលអំពីសុវត្ថិភាពនៃការបង្កើតកិច្ចសន្យាអេឡិចត្រូនិក និងអំពីភស្តុតាងនៃទំនាក់ទំនងអេឡិចត្រូនិក។ បន្ទាប់ពីបានសិក្សាទៅលើការផ្ដើមឱ្យមាននូវកិច្ចសន្យានៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករួចមក នៅក្នុងជំពូកនេះយើងនឹងសិក្សាទៅលើ ដំណើរការនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ នៅជំពូកនេះផងដែរយើងនឹងសិក្សាទៅលើប្រាំមួយផ្នែកធំៗ **ផ្នែកទី១** អំពីទំនាក់ទំនងនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក **ផ្នែកទី២** សិទ្ធ និងករណីកិច្ចរបស់ភាគីក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដោយអន្តរការី និងអ្នកផ្ដល់សេវា **ផ្នែកទី៤** សកម្មភាព និងប្រតិបត្តិការរបស់រដ្ឋាភិបាលលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក **ផ្នែកទី៦** ដំណើការទូទាត់/ផ្ទេរប្រាក់ជាអេឡិចត្រូនិកនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក **ផ្នែកទី៣** ការបញ្ចប់នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក **ផ្នែកទី៥** ជាផ្នែកបញ្ចប់។

### ផ្នែកទី១ ទំនាក់ទំនងនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

នៅក្នុងផ្នែកនេះយើងនឹងសិក្សាទៅលើទំនាក់ទំនងដែលកើតមាន នៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែរជាលក្ខខណ្ឌដើម្បីឱ្យកើតមាននូវដំណើការរពាណិជ្ជកម្មមួយនេះឡើង។ យើងនឹងសិក្សាទៅលើ ទំនាក់ទំនងពេលវេលា និងទីកន្លែងបញ្ជូនចេញ នៃទំនាក់ទំនងអេឡិចត្រូនិក (**កថាខណ្ឌ១**) ការទទួលទំនាក់ទំនងអេឡិចត្រូនិក (**កថាខណ្ឌ២**) ទីតាំងអាជីវកម្ម (**កថាខណ្ឌ៣**)។

#### កថាខណ្ឌ១ ទំនាក់ទំនងពេលវេលា និងទីកន្លែងបញ្ជូនចេញ និងទទួល នៃទំនាក់ទំនងអេឡិចត្រូនិក

ការបញ្ជូនចេញនូវព័ត៌មានអេឡិចត្រូនិក និងការទទួលនូវព័ត៌មានអេឡិចត្រូនិក ជាចំណុចចាប់ផ្ដើមដែលនាំឱ្យកើតមានឡើងនូវដំណើរការអេឡិចត្រូនិក។

ព័ត៌មានអេឡិចត្រូនិកត្រូវបានបញ្ជូនចេញនូវពេល ព័ត៌មានអេឡិចត្រូនិកនោះបានចាកចេញពីប្រព័ន្ធព័ត៌មានដែលគ្រប់គ្រងដោយអ្នកផ្ញើ ឬ អ្នកផ្ញើជំនួសដែលធ្វើឡើងក្នុងនាមអ្នកផ្ញើ។ ការបញ្ជូនចេញនេះ ក៏ត្រូវបានចាប់ទុកថាបញ្ជូនចេញដូចគ្នានៅពេលដែលព័ត៌មានអេឡិចត្រូនិកនោះត្រូវបានទទួលដោយភាគីជាអ្នកទទួល។ ព័ត៌មានក្នុងអេឡិចត្រូនិកត្រូវបានកំណត់ពីទីកន្លែងនៃការបញ្ជូនចេញ គឺនៅទីតាំងអាជីវកម្មរបស់អ្នកផ្ញើនូវព័ត៌មានអេឡិចត្រូនិកនោះ ទោះបីជាព័ត៌មានអេឡិចត្រូនិកបានផ្ញើចេញពីទីតាំងណាក៏ដោយចុះ។

**កថាខណ្ឌ២ ទំនាក់ទំនងពេលវេលា និងទីកន្លែងទទួល**

ការទទួលនូវព័ត៌មានអេឡិចត្រូនិក គឺជាពេលដែល ព័ត៌មានអេឡិចត្រូនិកអាចទាញយកបានដោយអ្នកទទួល នៅក្នុងអាស័យដ្ឋានរបស់អ្នកទទួលដែលបានបញ្ជាក់ប្រាប់ជាមុនហើយ។ មួយវិញទៀតព័ត៌មានអេឡិចត្រូនិក ត្រូវបានទទួលនូវពេលដែលព័ត៌មានអេឡិចត្រូនិកនោះអាចទាញយកបានដោយអ្នកទទួល តាមរយៈអាស័យដ្ឋានមួយ ហើយអ្នកទទួលបានទទួលដឹងអំពីការផ្ញើចេញ នូវការទទួលនូវទំនាក់ទំនងអេឡិចត្រូនិកទៅកាន់អាស័យដ្ឋាននោះ។ ទំនាក់ទំនងក្នុងប្រព័ន្ធអេឡិចត្រូនិកត្រូវបានសន្មត់ថា បានទទួលនៅទីកន្លែងដែលជាទីតាំងអាជីវកម្មរបស់អ្នកទទួល។

ប្រសិនបើអាស័យដ្ឋានអេឡិចត្រូនិក មិនត្រូវបានផ្តល់ដោយអ្នកទទួល នោះពេលវេលាទទួលបានព័ត៌មាន គឺជាពេលដែលដែលទទួលបានព័ត៌មានអេឡិចត្រូនិកនោះ គឺជាពេលវេលាដែលអ្នកទទួលបានដឹងអំពីការផ្ញើចេញ និង អាចទាញយកព័ត៌មាននោះតាមរយៈអាស័យដ្ឋានអេឡិចត្រូនិកណាមួយ ហើយសន្មត់ថាបានទទួលនៅកន្លែងដែលជាទីតាំងអាជីវកម្មរបស់អ្នកទទួល។

ប្រសិនបើអាសយដ្ឋានអេឡិចត្រូនិកត្រូវបានផ្តល់ដោយអ្នកទទួល ព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិក ត្រូវបានសន្មត់ថាបានទទួលនៅពេលព័ត៌មាននោះបានទៅដល់អាស័យដ្ឋានអេឡិចត្រូនិករបស់អ្នកទទួល ហើយត្រូវបានចាត់ទុកថាបានទទួលនៅទីកន្លែងដែលជាទីតាំងអាជីវកម្មរបស់អ្នកទទួល។

**កថាខណ្ឌ៣ ទីតាំងអាជីវកម្ម**

ទីតាំងអាជីវកម្មសំដៅដល់ ទីតាំងទាំងឡាយណាដែលភាគីរក្សាទីស្នាក់ការអចិន្ត្រៃយ៍ដើម្បីប្រតិបត្តិការសកម្មភាពសេដ្ឋកិច្ច នឹងជាទីតាំងដែលសំដៅទៅលើៈ

ក-ទីតាំងដែលអ្នកផ្ញើ ឬអ្នកទទួលចង្អុលបង្ហាញ លើកលែងតែភាគីណាមួយបានបង្ហាញថាអ្នកអះអាងនោះ ពុំមានទីតាំងអាជីវកម្មនៅទីនោះឡើយ

ខ-ប្រសិនបើភាគីណាមួយមិនចង្អុលបង្ហាញទីកន្លែងអាជីវកម្មត្រូវកំណត់ណាមួយ ហើយភាគីនោះមានទីតាំងអាជីវកម្មច្រើនជាងមួយកន្លែងទីតាំងអាជីវកម្ម ត្រូវកំណត់ថាជាទីកន្លែងដែលមានទំនាក់ទំនងជិតស្និតជាងគេ ទៅនឹងកិច្ចសន្យាដែលពាក់ព័ន្ធដោយត្រូវពិចារណាផងដែរអំពីកាលៈទេសៈដែលបានដឹង ឬពិនិត្យដោយភាគីនៅពេលណាមួយមុន ឬក្នុងពេលចុះកិច្ចសន្យា។

គ-សម្រាប់រូបវន្តបុគ្គលដែលពុំមានទីតាំងអាជីវកម្មទេ នោះទីតាំងអាជីវកម្មសំដៅដល់ទីលំនៅអចិន្ត្រៃយ៍របស់បុគ្គលនោះ។

ហើយមិនត្រូវចាប់ទុកថាជាទីតាំងអាជីវកម្មរបស់ភាគីនោះតែដោយគ្រាន់តែជា

- ទីតាំងដែលសម្ភារៈ ឬឧបករណ៍បច្ចេកវិទ្យានៃប្រព័ន្ធព័ត៌មានត្រូវបានប្រើ
- អាស័យដ្ឋានអេឡិចត្រូនិក ឬ ឈ្មោះដែលកម្មសិទ្ធិដែលភ្ជាប់ជាមួយនឹងទីតាំងរបស់ភាគី។

## ផ្នែកទី២ សិទ្ធិ និងករណីកិច្ចរបស់ភាគីក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

បន្ទាប់ពីបុគ្គលដែលជាភាគីនៅក្នុងពាណិជ្ជកម្ម បានព្រមព្រៀងបង្កើតនូវពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមក ហើយមានកម្មវត្ថុច្បាស់លាស់នៅក្នុងពាណិជ្ជកម្មនោះ អាចជាការលក់ទំនិញ ឬសេវា ដោយប្រើប្រាស់នូវប្រព័ន្ធអេឡិចត្រូនិកជាគោល និងនូវពេលដែលកិច្ចសន្យាពាណិជ្ជកម្មនោះមានលក្ខខណ្ឌគ្រប់គ្រាន់បង្កើតឱ្យមានសុពលភាព អានុភាពហើយនោះ នោះសិទ្ធ និងករណីកិច្ចរបស់ភាគី ក៏កើតមានឡើងដែរ។ នៅក្នុងផ្នែកនេះយើងនឹងសិក្សាទៅលើសិទ្ធិ និងករណីកិច្ចរបស់អ្នកលក់ទំនិញ ឬសេវា ដោយប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិក **(កថាខណ្ឌ១)** និងសិទ្ធិ និងករណីកិច្ចរបស់អ្នកទិញទំនិញ ឬសេវា ដោយប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិក **(កថាខណ្ឌ២)** ។

### កថាខណ្ឌ១ សិទ្ធិ និងករណីកិច្ចរបស់អ្នកលក់ទំនិញ ឬសេវា ដោយប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិក

#### ១. ករណីកិច្ចរបស់អ្នកលក់ទំនិញ ឬសេវា ដោយប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិក

#### ១-១ ករណីកិច្ចផ្ទេរសិទ្ធិ

អ្នកដែលប្រើប្រាស់នូវទំនាក់ទំនងអេឡិចត្រូនិកធ្វើពាណិជ្ជកម្មដូចជាការលក់ទំនិញ ឬសេវាទៅឱ្យអតិថិជនរបស់ខ្លួន មានករណីកិច្ចផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិរបស់ខ្លួន (ទំនិញ ឬសេវា) របស់ខ្លួនដែលខ្លួនបានលក់ ទៅឱ្យភាគីម្ខាងទៀតដែលទិញនូវទំនិញ ឬសេវានោះ។

#### ១-២. ករណីកិច្ចរក្សាទុកដែលជាកម្មវត្ថុ

អ្នកលក់នូវ ទំនិញ ឬសេវាដែលធ្វើឡើងក្រោមទម្រង់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានករណីកិច្ចថែរក្សាវត្ថុ ឬសេវា ដែលជាកម្មវត្ថុនៃការធ្វើពាណិជ្ជកម្ម ដូចជាការលក់នូវទំនិញ ឬសេវាដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកប្រគល់ដ៏ល្អ រហូតដល់ពេលដែលបានផ្ទេរនូវកម្មវត្ថុនោះទៅឱ្យអ្នកទិញ។

#### ២. សិទ្ធិរបស់អ្នកលក់ទំនិញ ឬសេវា ដោយប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិក

#### ២-១. សិទ្ធិទាមទារឱ្យបង់ប្រាក់ថ្លៃទិញ

អ្នកលក់នូវ ទំនិញ ឬសេវាដែលប្រើប្រាស់នូវប្រព័ន្ធអេឡិចត្រូនិកដើម្បីធ្វើអាជីវកម្មរបស់ខ្លួនក្នុងការលក់ទំនិញ ឬសេវា ណាមួយមានសិទ្ធិទាមទាឱ្យអ្នកទិញដែលប្រើប្រាស់នូវប្រព័ន្ធអេឡិចត្រូនិកដូចគ្នា បង់នូវប្រាក់ថ្លៃទិញបាន បើសិនជាអ្នកទិញនោះមិនទាន់បានបង់ប្រាក់ទៅឱ្យអ្នកលក់នោះទេ។ ការបង់នូវថ្លៃទំនិញ ឬសេវា នោះអាចទូទាត់ ឬផ្ទេរប្រាក់ជាអេឡិចត្រូនិកបាន ដែលយើងនឹងលើកយកមកសិក្សាដូចគ្នា នៅក្នុង (ផ្នែកទី៣) ខាងក្រោម។

#### ២- ២. ការតវ៉ាឱ្យអនុវត្តព្រមគ្នា

អ្នកលក់ទំនិញ ឬសេវា អាចប្រកែកមិនព្រមផ្ទេរសិទ្ធិលើទំនិញ ឬផ្តល់នូវសេវា ដែលជាកម្មវត្ថុ និងមិនព្រមប្រគល់នូវវត្ថុ ឬសេវាដែលជាកម្មវត្ថុនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកទៅអ្នកទិញបានរហូតដល់អ្នកទិញបានផ្តល់ការសង ចំពោះកាតព្វកិច្ចបង់ថ្លៃលក់។ តែបើសិនជាកាតព្វកិច្ចរបស់អ្នកទិញ ពុំទាន់ដល់ពេលកំណត់ត្រូវសង ឬករណីដែលមានការព្រមព្រៀងគ្នាអំពីការអនុវត្តករណីកិច្ចផ្ទេរសិទ្ធិ ឬកាតព្វកិច្ចប្រគល់ជាមុននោះគេមិនយកអនុវត្តឡើយចំពោះការលើកឡើងខាងលើ។

## កថាខណ្ឌ២ សិទ្ធិ និងករណីកិច្ចរបស់អ្នកទិញទំនិញ ឬសេវា ដោយប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិក

### ១. ករណីកិច្ចរបស់អ្នកទិញទំនិញ ឬសេវា ដោយប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិក

ក្រោយពីបង្កើតឱ្យមានឡើងនូវកិច្ចសន្យាលក់ទិញទំនិញ ឬសេវា តាមទម្រង់អេឡិចត្រូនិកដែលជាការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងសម័យសេដ្ឋកិច្ចឌីជីថល នៅក្នុងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដូចជាការទិញនូវទំនិញ ឬសេវា អ្នកទិញមានករណីកិច្ចជាច្រើនជូនចំពោះអ្នកលក់ ដូចជាករណីកិច្ចបង់ថ្លៃជាប្រាក់ ដែលបានសន្យាក្នុងកិច្ចសន្យា និងមានករណីកិច្ចទទួលវត្ថុដែលអ្នកទិញបានទិញពីអ្នកលក់ជាដើម ការផ្តល់ឱ្យនូវកម្មវត្ថុនៃកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះ អាចផ្តល់ឱ្យដោយផ្ទាល់តាមមធ្យោបាយរបស់អ្នកលក់ និងអាចប្រើប្រាស់នូវអន្តរការីជាដើម។

### ១.១. ករណីកិច្ចបង់ថ្លៃទិញ ឬសេវា

អ្នកទិញទំនិញ ឬសេវា មានករណីកិច្ចបង់ថ្លៃទិញជាប្រាក់ តាមកាលបរិច្ឆេទ និងទីកន្លែងដែលបានកំណត់នៅក្នុងកិច្ចសន្យាពាណិជ្ជកម្មនោះ។ ការបង់នូវថ្លៃទំនិញ ឬសេវានោះអ្នកទិញអាចមានជម្រើសច្រើនក្នុងការបង់។ នៅក្នុងសម័យសេដ្ឋកិច្ចឌីជីថលនេះ ពោលគឺអ្នកទិញអាចជ្រើសរើសការទូទាត់ ឬផ្ទេរប្រាក់ជាអេឡិចត្រូនិកបាន (ផ្នែកទី៣)។ ហើយចំពោះកាលបរិច្ឆេទ និងទីកន្លែងដែលត្រូវបង់នេះត្រូវបានសម្រេចដោយផ្អែកលើការព្រមព្រាងរបស់គូភាគីក្នុងកិច្ចសន្យា។

### ១.២. ករណីកិច្ចទទួលវត្ថុ ឬសេវាដែលខ្លួនបានទិញ

អ្នកទិញទំនិញ ឬសេវាមានករណីកិច្ចទទួលកម្មវត្ថុដែលខ្លួនបានទិញ[73]។ ប្រសិនបើអ្នកលក់បានបានប្រគល់កម្មវត្ថុនៃកិច្ចសន្យាឱ្យអ្នកទិញ ប៉ុន្តែបើអ្នកទិញ បដិសេធក្នុងការទទួលកម្មវត្ថុដែលបានប្រគល់ នោះអ្នកទិញត្រូវទទួលខុសត្រូវចំពោះការយឺតយ៉ាវនៅក្នុងការទទួលនោះ ឧទាហរណ៍ អ្នកលក់បានខូចខាតទៅលើការប្រើប្រាស់សេវាដឹកជញ្ជូន សេវាថែទាំទំនិញឬសេវានោះជាដើម។

[73] សូមពិគ្រោះ *សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីកម្ពុជា ភាគ១-៣* រៀបរៀងដោយក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ,បោះពុម្ពលើកទី១ ឆ្នាំ២០១៣, ភាគ២ ទំព័រទី១៨-១៩

**២. សិទ្ធិរបស់អ្នកទិញទំនិញ ឬសេវា ដោយប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិក**

**២-១. សិទ្ធិទទួលទំនិញ**

អ្នកទិញទំនិញ ឬសេវាលើប្រព័ន្ធអេឡិចត្រូនិកមានសិទ្ធិទទួលទំនិញ ឬសេវានោះ ហើយម្យ៉ាងទៀតក្រោយពេលដែលអ្នកទិញ បានបង់ថ្លៃទិញហើយ នោះអ្នកទិញអាចទទួលផលបាន។

**២-២. សិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នា**

អ្នកទិញទំនិញ ឬសេវា អាចមិនព្រមបង់ថ្លៃទិញបាន រហូតដល់ពេលដែលអ្នកលក់ បានផ្តល់នូវការសងចំពោះកាតព្វកិច្ចរបស់ខ្លួន។ តែបើមិនទាន់ដល់ការកំណត់ប្រគល់នូវកាតព្វកិច្ចនោះការតវ៉ាឱ្យអនុវត្តព្រមគ្នាមិនយកមកអនុវត្តឡើយ។

**២-៣. ការតវ៉ាដោយមានការបារម្ភ**

ទោះបីជាអ្នកទិញនូវទំនិញ ឬសេវាបានអនុញ្ញាតឱ្យអ្នកលក់មានពេលកំណត់ដើម្បីអនុវត្តកាតព្វកិច្ចក៏ដោយ ប្រសិនបើមានការបារម្ភ យ៉ាងជាក់ស្តែងថា អ្នកលក់ទំនិញ ឬសេវា នឹងមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ក៏អ្នកទិញទំនិញ ឬសេវា អាចប្រកែកមិនបងថ្លៃទំនិញបានដែរ[74]។ តែបើមានការដាក់ប្រតិភោគ ឬចាត់ចែងវិធានការដើម្បីរំលត់ការបារម្ភនោះ ការដែលចែងអំពីការតវ៉ាដោយមានការបារម្ភខាងលើមិនត្រូវយកមកអនុវត្តឡើយ។

## ផ្នែកទី៣ ដំណើរការទូទាត់ ឬផ្ទេរប្រាក់ជាអេឡិចត្រូនិកនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

នូវពេលដែលបច្ចេកវិទ្យាកាន់តែរីកចម្រើន គឺកាន់តែមានភាពងាយស្រួលសម្រាប់មនុស្សក្នុងការប្រតិបត្តិការពាណិជ្ជកម្ម។ នៅក្នុងសម័យសេដ្ឋកិច្ចឌីជីថល ការប្រើប្រាស់នូវបច្ចេកវិទ្យាអេឡិចត្រូនិកបាននឹងកំពុងធ្វើឱ្យមាននូវកំណើនសេដ្ឋកិច្ចជាតិ និងពិភពលោក។ ការរីកចម្រើននូវបច្ចេកវិទ្យាអេឡិចត្រូនិក បានធ្វើឱ្យការធ្វើពាណិជ្ជកម្មកាន់តែមានភាពរីកចម្រើន រីកចម្រើនត្រង់ថា គេបានយកប្រព័ន្ធអេឡិចត្រូនិកមកធ្វើជាស្ពានក្នុងការធ្វើអាជីវកម្ម។ ហើយសូម្បីតែការទូទាត់ប្រាក់ ឬផ្ទេរប្រាក់ដែលកើតចេញពីប្រតិបត្តិការពាណិជ្ជកម្មនោះក៏ប្រើប្រាស់នូវបច្ចេកវិទ្យាអេឡិចត្រូនិកដើម្បីទូទាត់ ឬផ្ទេរដែរ។ នៅក្នុងផ្នែកនេះយើងនឹងធ្វើការសិក្សាទៅលើ ការទូទាត់ ឬផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក (**កថាខណ្ឌ១**) ការទទួលខុសត្រូវរបស់អ្នកផ្តល់សេវា(**កថាខណ្ឌ២**) ការទទួលខុសត្រូវរបស់អតិថិជន(**កថាខណ្ឌ៣**) ។

[74] សូមពិគ្រោះ *សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីកម្ពុជា ភាគ១-៣* រៀបរៀងដោយក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ,បោះពុម្ពលើកទី១ ឆ្នាំ២០១៣, ភាគ២ ទំព័រទី២០

## កថាខណ្ឌ១ ការទូទាត់ ឬផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក

ការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក សំដៅដល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ឬបុគ្គលទាំងឡាយណាដែលត្រូវបានអនុញ្ញាតដោយធនាគារជាតិនៃ កម្ពុជាឱ្យធ្វើប្រតិបត្តិការប្រព័ន្ធទូទាត់ប្រាក់ ឱ្យផ្តល់សេវាទូទាត់ ឱ្យចេញឧបករណ៍ទូទាត់អេឡិចត្រូនិក ឬមធ្យោបាយទូទាត់ ឬប្រតិបត្តិការផ្សេងទៀតដែលអាចចាត់ទុកថាជាក់ឱ្យដំណើរការការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក ដល់សាធារណ:ជន។

បុគ្គលអាចធ្វើការទូទាត់ ឬផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកបានដើម្បីងាយស្រួលក្នុងការធ្វើពាណិជ្ជកម្មរបស់ខ្លួន ជាពិសេសពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលពេលខ្លះអ្នកលក់ដែលជារូបវន្តបុគ្គល ឬនីតិបុគ្គល នៅឆ្ងាយពីអតិថិជនរបស់ខ្លួន ចឹងហើយជម្រើសនូវការទូទាត់ប្រាក់ ឬផ្ទេរប្រាក់ទៅលើទំនិញ ឬសេវា មិនអាចទៅផ្ទាល់បាននោះទេ ដូច្នេះជម្រើសទូទាត់ ឬផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ជម្រើសល្អ និងពន្លឿនរហ័សក្នុងការធ្វើពាណិជ្ជកម្ម ។

ហើយម្យ៉ាងទៀត បុគ្គលណាដែលធ្វើប្រតិបត្តិការប្រព័ន្ធទូទាត់ ផ្តល់សេវាទូទាត់ ចេញផ្សាយឧបករណ៍ទូទាត់ជាអេឡិចត្រូនិក ឬផ្តល់មធ្យបាយទូទាត់អេឡិចត្រូនិក ឬធ្វើប្រតិបត្តិការណាដែលត្រូវបានចាត់ទុកថា ជាការផ្តល់ការទូទាត់សងប្រាក់អេឡិចត្រូនិកដល់សាធារណជន ត្រូវស្នើសុំការអនុញ្ញាត ឬអាជ្ញាប័ណ្ណជាមុនពីធនាគរជាតិកម្ពុជា។ ហើយធនាគារជាតិនៃកម្ពុជាជាស្ថាប័នដែលមានសមត្ថកិច្ចក្នុងការរៀបចំ ច្បាប់ ក៏ដូចជាបទប្បញ្ញត្តិទាក់ទងនឹងការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកផងដែរ។

## កថាខណ្ឌ២ ការទទួលខុសត្រូវរបស់អ្នកផ្តល់សេវាទូទាត់

អ្នកផ្តល់នូវសេវាទូទាត់សំដៅ ដល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ឬបុគ្គលដទៃទៀតដែលត្រូវបានអនុញ្ញាតដោយធនាគារជាតិនៃ កម្ពុជាឱ្យធ្វើប្រតិបត្តិការប្រព័ន្ធទូទាត់ចេញផ្សាយ ឧបករណ៍ទូទាត់អេឡិចត្រូនិក ឬមធ្យោបាយទូទាត់អេឡិចត្រូនិក ឬប្រតិបត្តិការណាដែលត្រូវបាន ចាត់ទុកថាជាការផ្តល់ការទូទាត់សងប្រាក់ អេឡិចត្រូនិកដល់សាធារណ:ជន។

បុគ្គលផ្តល់សេវាទូទាត់ មិនត្រូវផ្តល់ជូនអតិថិជននូវឧបករណ៍ទូទាត់ដែលអតិថិជនមិនបានស្នើសុំនោះទេ លើកលែងតែករណីដែលប័ណ្ណ ទូទាត់នោះត្រូវបានហួសរយ:ពេលប្រើប្រាស់ ឬដល់ពេលដែលត្រូវផ្លាស់ប្តូរ។

### ១. ការត្រួតពិនិត្យអតិថិជនដោយអ្នកផ្តល់សេវាទូទាត់

នៅមុនពេលធ្វើប្រតិបត្តិការផ្ទេរប្រាក់អេឡិចត្រូនិក អ្នកផ្តល់សេវាត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ពីអត្តសញ្ញាណរបស់អតិថិជន និងផ្ទៀងផ្ទាត់ឡើងវិញនូវភាពត្រឹមត្រូវនៃការផ្ទេរប្រាក់អេឡិច

ត្រូនិកហើយអ្នកផ្តល់សេវាទូទាត់ត្រូវទទួលខុសត្រូវក្នុងករណីដែល៖

ក- ប្រតិបត្តិការកើតឡើងដោយគ្មានការអនុញ្ញាតពីអតិថិជន

ខ- ប្រតិបត្តិការកើតឡើងបន្ទាប់ពីដឹងថាមានការបន្លំបាត់បង់ ឬចោរកម្មឧបករណ៍ផ្ទេរប្រាក់អេឡិចត្រូនិក និង

គ-ប្រតិបត្តិការកើតឡើងបន្ទាប់ពីមានការជូនដំណឹងពី អតិថិជនដែលមានបកស្រាយក្នុងថាខណ្ឌទី៣ ខាងក្រោម។

ឃ- ការខកខានមិនបានប្រតិបត្តិតាមបញ្ជារបស់អតិថិជន ឬការប្រតិបត្តិខុសបញ្ជាអតិថិជន

ង- ភាពមិនប្រក្រតីនៃប្រព័ន្ធបច្ចេកវិទ្យា កំហុសក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកទេស ឬភាពខ្វះខាតនៃឧបករណ៍ផ្ទេរប្រាក់អេឡិចត្រូនិក។

**២. ឧបករណ៍ទូទាត់អេឡិចត្រូនិក**

ឧបករណ៍ទូទាត់អេឡិចត្រូនិក សំដៅដល់ឧបករណ៍ទាំងឡាយណាដែលបង្កើតឡើងដើម្បីគ្រប់គ្រង បញ្ជា និងប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិក។ វាអាចជាសកម្មភាព៖

ក- ការផ្ទេរប្រាក់

ខ- ការដក និងការដាក់ប្រាក់

គ- ការធ្វើប្រតិបត្តិការក្នុងករណី

ឃ- ការបញ្ចូលប្រាក់ ឬដកប្រាក់ពីឧបករណ៍ដែលអាចបញ្ចូលប្រាក់បាន។

**៣. ការរួចផុតពីការទទួលខុសត្រូវរបស់អ្នកផ្តល់សេវាទូទាត់**

បុគ្គលផ្តល់នូវសេវាទូទាត់អាចរួចផុតពីការទទួលខុសត្រូវបានក្នុងករណីប្រធានស័ក្តិ ឬជាកំហុសរបស់អតិថិជនផ្ទាល់តែប៉ុណ្ណោះ ដែលក្នុងករណីប្រធានស័ក្តិនេះវាហួសពីសមត្ថកិច្ចគ្រប់គ្រងរបស់បុគ្គលផ្តល់សេវាទូទាត់នោះ ។

ការទទួលខុសត្រូវនេះគឺបុគ្គលផ្តល់នូវសេវាទូទាត់ ត្រូវសងថ្លៃខូចខាតជូនអតិថិជន ក្នុងរយៈពេលមិនឱ្យលើសពី៣០ថ្ងៃគិតចាប់ពីថ្ងៃបានទទួលការជូនដំណឹងពីអតិថិជន នូវកម្រៃប្រតិបត្តិការដែលបានខាតបង់សោហ៊ុយ និងការពិន័យក្នុងការបង់ប្រាក់យឺតយ៉ាវដែលកើតចេញពីប្រតិបត្តិការនោះ ដោយមិនទាន់គិតពីការបញ្ចូលការសងថ្លៃខូចខាតដទៃទៀតដែលអាចកើតមានឡើងទៅលើអតិថិជនឡើយ។

**កថាខណ្ឌ៣ ការទទួលខុសត្រូវរបស់អតិថិជន**

មិនខុសអីពីអ្នកផ្តល់សេវាទូទាត់នោះទេ នៅក្នុងប្រតិបត្តិការទូទាត់ ឬផ្ទេរប្រាក់អេឡិចត្រូនិក អតិថិជនផ្ទាល់ក៏ចូលរួមចំណែកទទួលខុសត្រូវនោះដែល។

**១. ការជូនដំណឹងរបស់អតិថិជនចំពោះការដែលខូចខាត**

ក្នុងករណីដែលអតិថិជនបានបាត់បង់ ឬចោរកម្ម ឬប្រតិបត្តិការដែលកើតឡើងដោយគ្មានការអនុញ្ញាត ឬកំហុសឆ្គង និងភាពមិនត្រឹមត្រូវផ្សេងទៀតនៅក្នុងគណនីរបស់ខ្លួន អតិថិជនត្រូវជូនដំណឹងដល់ បុគ្គលផ្តល់សេវាទូទាត់។ អតិថិជនត្រូវជូនដំណឹងដល់បុគ្គលផ្តល់សេវាទូទាត់ ឬគ្រឹះស្ថានដែលទទួលបានការអនុញ្ញាតពីបុគ្គលផ្តល់សេវាទូទាត់ អំពីករណីបាត់បង់ ឬអំពើចោរកម្មលើឧបករណ៍ ឬមធ្យោបាយផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ឬការលួចយកទិន្នន័យសម្រាប់ប្រើប្រាស់ជាមួយឧបករណ៍ទូទាត់។ ការជូនដំណឹងអាចធ្វើឡើងតាមរយៈជាលាយលក្ខណ៍អក្សរ ឬ តាមមធ្យោបាយអេឡិចត្រូនិកណាមួយដែលទទួលយកដោយបុគ្គលផ្តល់សេវាទូទាត់នោះ ហើយត្រូវជូនដំណឹងជាបន្ទាន់តាមលទ្ធភាពដែលអាចធ្វើទៅបាន ឬមិនឲ្យលើសរយៈពេល ២ថ្ងៃ បន្ទាប់ពីបានដឹងថាមានករណីចោរកម្ម ឬបាត់បងឧបករណ៍ទូទាត់កើតឡើង

**២. ក្នុងករណីមានបន្ទុកគ្រប់គ្រាន់បង្ហាញពីកំហុសអតិថិជន**

ម្យ៉ាងទៀតក្នុងករណីដែលបុគ្គលផ្តល់សេវាទូទាត់មានភស្តុតាងគ្រប់គ្រានបញ្ជាក់ថា ការបាត់បង់ ឬការខូចខាតជាកំហុសអតិថិជន នោះបុគ្គលដែលផ្តល់សេវាទូទាត់មានសិទ្ធិទាមទារឱ្យអតិថិជនទទួលខុសត្រូវទាំងស្រុងចំពោះការខាតបង់ ឬខូចខាតអស់ទាំងនោះ។

**៣. ក្នុងករណីមិនមានបន្ទុកគ្រប់គ្រាន់បង្ហាញពីកំហុសអតិថិជន**

ប៉ុន្តែបើរកមិនឃើញពីភស្តុតាងដែលបញ្ជាក់ពីកំហុសរបស់អតិថិជន ពោលគឺរកភស្តុតាងពុំបានពីភាពមានកំហុសរបស់អតិថិជន នោះបុគ្គលផ្តល់សេវាទូទាត់ត្រូវទទួលខុសត្រូវទាំងស្រុងលើចំនួនទឹកប្រាក់ដែលបានបាត់បង់នោះ។

## ផ្នែកទី៤ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដោយអន្តរការី និងអ្នកផ្តល់សេវា

នៅក្នុងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក គឺមិនបានសំដៅទៅលើតែទីតាំងអាជីវកម្មដែលមានតែទីតាំងអាជីវកម្មជិតៗនោះទេ ក៏មិនមែនមានតែនៅក្នុងប្រទេសតែប៉ុណ្ណោះដែរ ព្រោះការធ្វើអាជីវកម្មប្រភេទនេះ អាចឱ្យបុគ្គលធ្វើអាជីវកម្មបានគ្រប់ទីកន្លែងដោយប្រើប្រាស់តាមមធ្យោបាយអេឡិចត្រូនិកនេះឯង ដូចជាការធ្វើពាណិជ្ជកម្មពីប្រទេសមួយទៅប្រទេសមួយ ដូចជាការលក់ទំនិញ ឬសេវា។

ហេតុដូច្នេះហើយបានជាការធ្វើពាណិជ្ជកម្មប្រភេទនេះចាំបាច់ត្រូវមានអន្តរការី និងអ្នកផ្តល់សេវាជូនបុគ្គលដែលមានទំនាក់ទំនងពាណិជ្ជកម្មនេះ។

អន្តរការី អាចហៅបានថាជាភ្នាក់ងារ ជាភ្នាក់ងារកណ្តាល ឬអ្នកដែលភ្ជាប់ទំនាក់ទំនងរវាងភាគី[75]។ អន្តរការីនៅក្នុងនៃដែលពាក់ព័ន្ធនឹងទំនាក់ទំនងអេឡិចត្រូនិក សំដៅដល់បុគ្គលដែល៖

- បុគ្គលដែលតំណាងឱ្យអ្នកផ្ញើ អ្នកទទួល អ្នកបញ្ជូន ឬអ្នករក្សាទុក
- បុគ្គលផ្តល់សេវាទូរគមនាគមន៍
- បុគ្គលផ្តល់សេវាអ៊ិនធើណែត
- បុគ្គលផ្តល់មធ្យោបាយស្វែងរកទិន្នន័យណាមួយតាមប្រព័ន្ធអេឡិចត្រូនិក
- បុគ្គលផ្តល់សេវាទូទាត់តាមអនឡាញ
- បុគ្គលផ្តល់សេវាដេញថ្លៃតាមអនឡាញ
- បុគ្គលផ្តល់សេវាទីផ្សារអនឡាញ និងសេវាពាណិជ្ជកម្មតាមបណ្តាញអ៊ិនធើណែត។

នៅក្នុងផ្នែកនេះយើងនឹងសិក្សាទៅលើ តួនាទីរបស់អន្តរការី និងអ្នកផ្តល់សេវា **(កថាខណ្ឌ១)** រួមទាំង កាតព្វកិច្ចរបស់អន្តរការី និងអ្នកផ្តល់សេវា **(កថាខណ្ឌ២)** និងការមិនទទួលខុសត្រូវរបស់អន្តរការី និងអ្នកផ្តល់សេវា ដែលជាចំនុចបញ្ចប់ **(កថាខណ្ឌ៣)**។

## កថាខណ្ឌ១ តួនាទីរបស់អន្តរការី និងអ្នកផ្តល់សេវា

### ១. តួនាទីរបស់អន្តរការី

អន្តរការី មានតួនាទីផ្ញើ ទទួល បញ្ជូន ឬរក្សាទុកដោយបណ្តោះអាសន្ន ឬដោយអចិន្ត្រៃយ៍នូវទំនាក់ទំនងអេឡិចត្រូនិកនោះ ឬ ផ្តល់សេវានានាដែលពាក់ព័ន្ធនឹងទំនាក់ទំនាក់ទំនងអេឡិចត្រូនិក នឹងរួមបញ្ចូលផងដែរនូវបុគ្គលដែលតំណាងអោយអ្នកផ្ញើ ទទួល បញ្ជូន ឬរក្សាទុកខាងលើ អ្នកផ្តល់សេវាទូរគមនាគមន៍ អ្នកផ្តល់សេវាបណ្តាញនានា អ្នកផ្តល់សេវាអ៊ីនធើណែត អ្នកផ្តល់មធ្យោបាយស្វែងរកទិន្នន័យណាមួយតាមប្រព័ន្ធអេឡិចត្រូនិក គេហទំព័រសម្រាប់ទូទាត់ប្រាក់ ដេញថ្លៃ ទីផ្សារតាមអ៊ីនធើណែត និងហាងផ្តល់សេវាអ៊ីនធើណែត។

### ២. តួនាទីរបស់អ្នកផ្តល់សេវា

អ្នកផ្តល់សេវា ជាបុគ្គលដែលមានតួនាទីជាអ្នកផ្តល់សេវាព័ត៌មាន និងសេវាទំនាក់ទំនង រួមមានការផ្ញើ ការទទួល ការរក្សាទុក ឬដំណើរការទំនាក់ទំនងអេឡិចត្រូនិក ឬការផ្តល់សេវាផ្សេងៗទៀតដែលពាក់ព័ន្ធតាមរយៈប្រព័ន្ធអេឡិចត្រូនិក។ ហើយជាបុគ្គលដែលមានតួនាទី ជាម្ចាស់កាន់កាប់ ដំណើរការ គ្រប់គ្រង ឬត្រួតពិនិត្យប្រព័ន្ធស្វិចសាធារណៈ ឬអាចជាអ្នកផ្តល់សេវាទូរគមនាគមន៍ផងដែល។ រួមបញ្ចូលនូវបុគ្គលដែល៖

- បុគ្គលតំណាងឱ្យអ្នកផ្ញើ អ្នកទទួល អ្នកបញ្ជូន ឬអ្នករក្សាទុក
- បុគ្គលដែលផ្តល់សេវាទូរគមនាគមន៍

[75] សូមពិគ្រោះ៖ www.*Salatraju.com*, រួចចុចលើពាក្យវាក្យស័ព្ទច្បាប់, រួចស្វែងរកពាក្យ អន្តរការី

- បុគ្គលដែលសេវាបណ្តាញនានា
- បុគ្គលដែលផ្តល់សេវាអ៊ិនធើណែត
- បុគ្គលដែលផ្តល់មធ្យោបាយស្វែងរកទិន្នន័យណាមួយតាមប្រព័ន្ធអេឡិចត្រូនិក
- បុគ្គលដែលផ្តល់សេវាទូទាត់តាមអនឡាញ
- បុគ្គលដែលផ្តល់សេវាដេញថ្លៃតាមអនឡាញ
- បុគ្គលដែលផ្តល់សេវាទីផ្សារអនឡាញ និងសេវាពាណិជ្ជកម្មតាមបណ្តាញអ៊ិនធើណែត។

**កថាខណ្ឌ២ ភាតព្វកិច្ចរបស់អន្តរការី និងអ្នកផ្តល់សេវា**

បើអន្តរការី ឬបុគ្គលដែលផ្តល់សេវាដឹងថាព័ត៌មាននៅក្នុងកំណត់ត្រាអេឡិចត្រូនិកអាចបង្កឱ្យមានការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ឬព្រហ្មទណ្ឌ នោះអន្តរការី ឬបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវចាត់វិធានការជាបន្ទាន់ដូចខាងក្រោម៖

ក-ដកព័ត៌មានចេញពីប្រព័ន្ធព័ត៌មានដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងឈប់ផ្តល់សេវាពាក់ព័ន្ធនឹងព័ត៌មាននោះ។

ខ-រក្សាទុកព័ត៌មានជាភស្តុតាង និងជូនដំណឹងដល់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ឬក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនានាអំពីអង្គហេតុ និងអត្តសញ្ញាណនៃជនសង្ស័យ។

បើសិនអន្តរការី ឬបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រពន្ធអេឡិចត្រូនិកដឹងអំពីអង្គហេតុណាមួយ ឬស្ថានភាពណាមួយដែលអាចបណ្តាលអោយមានការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ឬព្រហ្មទណ្ឌ អន្តរការី ឬបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវចាត់វិធានការជាបន្ទាន់ដូចខាងក្រោម៖

ក-អនុវត្តតាមនីតិវិធីដូចមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមនីតិវិធីព្រហ្មទណ្ឌដែលមានជាធរមាន ឬក្រមសីលធម៌ពាក់ព័ន្ធនានា ឬ

ខ-រក្សាទុកព័ត៌មានជាភស្តុតាង និងជូនដំណឹងដល់ក្រសួងប្រៃសណីយ៍ និងទៅទូរគមនាគមន៍ ឬក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនានា។

ក៏ប៉ុន្តែបើបុគ្គលណាជូនដំណឹងអំពីសកម្មភាពខុសច្បាប់ទៅដល់អន្តរការី ឬ អ្នកផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយដឹងថាការជូនដំណឹងនោះខុសពីការពិត ឬមានលក្ខណៈបោកបញ្ឆោត ត្រូវទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ឬព្រហ្មទណ្ឌពីបទល្មើសទាំងនោះ។

បន្ទាប់ពីទទួលបានព័ត៌មាន ឬទទួលដំណឹងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ឬក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ អាចបញ្ជាឱ្យអន្តរការី និងអ្នកផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ៖

ក-ដកព័ត៌មានចេញពីប្រព័ន្ធព័ត៌មានដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន ឬ

ខ-ផ្អាក ឬឈប់ផ្តល់សេវាដល់បុគ្គលនោះ ឬ

គ-ផ្អាក ឬឈប់ផ្តល់សេវាពាក់ព័ន្ធនឹងកំណត់ត្រាអេឡិចត្រូនិក

**កថាខណ្ឌ៣ ការមិនទទួលខុសត្រូវរបស់អន្តរការី និងអ្នកផ្តល់សេវា**

**១. ការមិនទទួលខុសត្រូវរបស់អន្តរការី និងអ្នកផ្តល់សេវា**

អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនត្រូវទទួលខុសត្រូវតាមរយៈកិច្ចសន្យា ឬក្រៅកិច្ចសន្យា ឬកំណត់ដោយច្បាប់ ចំពោះការអនុវត្តដោយសុទ្ធចិត្តទៅតាមបទបញ្ជារបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ឬក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមិនត្រូវទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ឬព្រហ្មទណ្ឌបើសិនជាពាក់ព័ន្ធនឹងព័ត៌មានដែលមានកំណត់ត្រាអេឡិចត្រូនិកដែលវាបានពាក់ព័ន្ធនឹងការផ្តល់នូវសេវារបស់អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនោះឡើយក្នុងករណីដែលខ្លួនមិនមែនជាអ្នកផ្ញើកំណត់ត្រានោះ និងក្នុងករណីដែល៖

ក-អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនោះពុំបានដឹងថាព័ត៌មានដែលបានផ្ញើនោះបង្កឱ្យមានការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ឬព្រហ្មទណ្ឌ ឬ

ខ-អន្តរការី និង បុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រពន្ធអេឡិចត្រូនិកនោះពុំបានដឹងអំពីអង្គហេតុ ឬកាលៈទេសៈដែលអាចឱ្យស្មានទុកថាព័ត៌មាននោះអាចបង្កឱ្យមានការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ឬព្រហ្មទណ្ឌ

គ-អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មនៅតាមប្រព័ន្ធអេឡិចត្រូនិកនោះបានដឹងនាពេលក្រោយថា ព័ត៌មាន ឬអង្គហេតុ ឬកាលៈទេសៈដែលអាចឲ្យស្មានទុកថា ព័ត៌មាននោះអាចបង្កឱ្យមានការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ឬព្រហ្មទណ្ឌ ហើយបានអនុវត្តតាមនីតិវិធីចំពោះព័ត៌មានខុសច្បាប់ និងការបរិហាកេរ្តិ៍។

ម្យ៉ាងទៀតអន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមិនតម្រូវឱ្យតាមដានត្រួតពិនិត្យកំណត់ត្រាអេឡិចត្រូនិកណាមួយដែលដំណើរការ ដោយប្រព័ន្ធអេឡិចត្រូនិកដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួនទេ ទោះបីជាដំណើរការនៃកំណត់ត្រាអេឡិចត្រូនិកនោះ អាចបង្កើតជាបទល្មើស ឬនាំឱ្យមានការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី នោះឡើយលើកលែងតែមានកំណត់ផ្សេងដោយក្រសួងមានសមត្ថកិច្ច។

**២. ការមិនអាចរួចផុតពីការទទួលខុសត្រូវរបស់អន្តរការី និងអ្នកផ្តល់សេវា**

បើទោះបីដូចបានយកមកបង្ហាញនៅចំណុចទី១ខាងលើរួចមកហើយក្តី ក៏អន្តរការី និងអ្នកផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនអាចរួចផុតពីការទទួលខុសត្រូវនោះឡើយនូវ៖

ក-កាតព្វកិច្ចដែលបង្កើតឡើងដោយច្បាប់ ឬបទដ្ឋានគតិយុត្តនានា ឬ

ខ-កាតព្វកិច្ចអនុលោមតាមបទបញ្ជា ឬសេចក្តីបង្គាប់របស់តុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត ឬ

គ-កាតព្វកិច្ចតាមកិច្ចសន្យា។

**៣. ក្រមសីលធម៌សម្រាប់អន្តរការី និងអ្នកផ្តល់សេវា**

អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈ និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលកំណត់ដោយប្រកាសក្រសួង រវាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងពាណិជ្ជកម្ម។

ហើយក្រមសីលធម៌វិជ្ជាជីវៈ ឬក្រមសីលធម៌ត្រូវកំណត់ និងរៀបចំឡើងដោយមានការចូលរួមសហការគ្នារវាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងពាណិជ្ជកម្ម ដោយសហការជាមួយក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ។

## ផ្នែកទី៥ ការបញ្ចប់នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ការលក់ទំនិញ ឬសេវា តាមរយៈការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលបង្កើតបានជាកិច្ចសន្យាពាណិជ្ជកម្មដើម្បីធ្វើការលក់នូវទំនិញ ឬសេវា ឬកម្មវត្ថុផ្សេងៗទៀត ទៅឱ្យបុគ្គលទាំងឡាយដែលបានទិញនូវទំនិញ ឬសេវានោះ ក៏មានលក្ខខណ្ឌដែលនាំឱ្យប្រតិបត្តិការពាណិជ្ជកម្មនេះបញ្ចប់ដែរគឺនូវពេលដែលកម្មវត្ថុ គោលបំណង របស់បុគ្គលទាំងនោះបានសម្រេចស្របទៅតាមឆន្ទៈដែលមាននៅក្នុងកិច្ចសន្យារបស់បុគ្គលម្នាក់ៗ។ ការបញ្ចប់នូវការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានប្រភេទៗផ្សេងៗពីគ្នា ពោលនូវពេលដែលកិច្ចសន្យាពាណិជ្ជកម្មអនុវត្តទៅនាំឱ្យមានបញ្ហាដល់ការធ្វើប្រតិបត្តិការ ដូចជាមានមូលហេតុដែលនាំឱ្យមាន មោឃភាព ដូចមានចែងនៅក្នុងក្រមរដ្ឋប្បវេណី មូលហេតុនាំឱ្យមានការលុបចោលនៃកិច្ចសន្យាពាណិជ្ជកម្ម មូលហេតុនាំឱ្យមានការលាយកិច្ចសន្យា មូលហេតុនាំមានការក្ស័យធន ឬបិទក្រុមហ៊ុនអាជីវកម្ម ។ល។ តែយ៉ាងណាមិញនៅក្នុងផ្នែកនេះ យើងនឹងសិក្សាទៅលើតែការបញ្ចប់នៃការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបញ្ចប់ដោយមូលហេតុ ការសម្រេចបានទៅតាមឆន្ទៈរបស់បុគ្គលអំពីគោលបំណង និងកម្មវត្ថុដែលមាននៅក្នុងខ្លឹមសារនៃកិច្ចសន្យាតែប៉ុណ្ណោះ។ នៅក្នុងផ្នែកនេះយើងនឹងសិក្សាទៅលើការទូទាត់ប្រាក់ទៅលើទំនិញ ឬសេវា (**កថាខណ្ឌទី១**) ការបញ្ជូនទំនិញ ឬសេវា របស់បុគ្គលដែលជាអ្នកលក់បានដោយជោគជ័យ (**កថាខណ្ឌទី២**) ការបានទទួលដោយជោគជ័យនូវទំនិញ ឬសេវា (**កថាខណ្ឌទី៣**) និងការមកដល់នៃសេវា ឬទំនិញនោះ (**កថាខណ្ឌទី៤**)។

**កថាខណ្ឌ១ ការទូទាត់ប្រាក់នៅលើទំនិញ ឬសេវា**

នៅពេលដែលទំនាក់ទំនងកិច្ចសន្យាស្តីពី ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានកើតឡើង ហើយ ហើយវាមានសុពលភាព អានុភាព ដែលអាចអនុវត្តបន្តបានហើយនោះបុគ្គលដែលជាបុគ្គលដែលមាននូវទំនាក់ទំនងនៅកិច្ចសន្យានេះ មានកាតព្វកិច្ចអនុវត្តនូវកិច្ចសន្យានេះ។ បុគ្គលដែលជាអ្នកទិញមានកាតព្វកិច្ចធ្វើការប្រគល់ប្រាក់ ឬទូទាត់ប្រាក់ទៅឱ្យបុគ្គលដែលជាអ្នកលក់នូវទំនិញ ឬសេវានោះ ដើម្បីសម្រេចនូវកម្មវត្ថុនៅក្នុងកិច្ចសន្យា មុនបុគ្គលដែលជាអ្នកលក់ប្រគល់កម្មវត្ថុនៃការលក់មកឱ្យ។ ការទូទាត់ប្រាក់នូវក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានវិធីសាស្ត្រខុសគ្នាក្នុងការទូទាត់ប្រាក់ទៅឱ្យបុគ្គលដែលជាអ្នកលក់ទំនិញ ឬសេវា បើទោះបីជាបុគ្គលនោះស្ថិតនៅទីណាក៏ដោយ។ ការទូទាត់ប្រាក់អាចធ្វើឡើងបានតាមរយៈ ឧបករណ៍ទូទាត់តាមប្រព័ន្ធអេឡិចត្រូនិកដែលជាប័ណ្ណ ឬកាតទូទាត់ ឬ ឧបករណ៍ទូទាត់ទាំងឡាយដែលមានទម្រង់ជា អេឡិចត្រូនិក ហើយមានមុខងារសម្រាប់ទូទាត់ប្រាក់។ ឬតាមរយៈ ឧបករណ៍ទូទាត់អេឡិចត្រូនិកចល័ត ឬតាមរយៈឧបករណ៍ទូទាត់ដែលមានមុខងារស្រដៀងគ្នា ដើម្បីបញ្ជាឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុធ្វើការចុះឥណពន្ធ ឬឥណទានក្នុងគណនី។ ការទូទាត់តាមវិធីអស់ខាងលើសុទ្ធតែអាចឱ្យភាគីធ្វើការទូទាត់ទៅកាន់បុគ្គលជាអ្នកលក់បានគ្រប់ទីកន្លែងនៃទីតាំងអាជីវកម្មរបស់ខ្លួន។ ឧទាហរណ៍ កាត ATM ជាដើម ដែលអនុញ្ញាតឱ្យបុគ្គលទូទាត់ទៅបានគ្រប់ទីកន្លែងនៃទីតាំងអាជីវកម្មនោះ ដូចជាទៅ Amazon.com ដែលមានទីតាំងអាជីវកម្មនៅអាមេរិច និង Alilybab.com ដែលមានទីតាំងអាជីវកម្មនៅចិន ។ បន្ទាប់ពីមានការទូទាត់ ឬការប្រគល់ប្រាក់ជូនទៅដល់បុគ្គលដែលជាពាណិជ្ជករ ដែលបានធ្វើពាណិជ្ជកិច្ចតាមប្រពន្ធអេឡិចត្រូនិក ដូចជាការលក់ទំនិញ ឬសេវា របស់ខ្លួន នោះបុគ្គលដែលជាអ្នកដែលមានករណីកិច្ចទទួលនូវទំនិញ ឬសេវា មានករណីកិច្ចរង់ចាំទទួលនូវទំនិញ ឬសេវានោះ បន្ទាប់ពីបុគ្គលដែលជាអ្នកលក់បានបញ្ជូនចេញទៅឱ្យ។

**កថាខណ្ឌ២ ការបញ្ជូនចេញដោយជោគជ័យ**

បើមានការទូទាត់ ឬប្រគល់ប្រាក់ ឬផ្ទេរទៅឱ្យបុគ្គលជាអ្នកលក់នូវទំនិញ ឬសេវារួចហើយ អ្នកលក់មានកាតព្វកិច្ចធ្វើការបញ្ជូននូវទំនិញរបស់ខ្លួនទៅឱ្យបុគ្គល ឬផ្តល់សេវាទៅឱ្យបុគ្គលដែលជាអ្នកទិញនោះ។ កិច្ចសន្យាពាណិជ្ជកម្មដែលភាគីបានព្រមព្រៀងគ្នាបង្កើតដើម្បីធ្វើពាណិជ្ជកម្មជាមួយគ្នានោះ នឹងបញ្ចប់នូវពេលដែលពាណិជ្ជករដែលជាអ្នកលក់នូវទំនិញ ឬសេវាបានបញ្ជូនទៅឱ្យភាគីបានសម្រេចទៅតាមឆន្ទៈរបស់ភាគីដែលព្រមព្រៀងគ្នាតាមកិច្ចសន្យានោះ។ អាចរាប់ថាបានបញ្ជូនចេញដោយជោគជ័យ គឺនូវពេលដែលភាគីទំនិញនោះបានទទួលដោយបុគ្គលជាអ្នកទិញនោះ។

**កថាខណ្ឌ៣ ការបានទទួលដោយជោគជ័យ**

ការមកដល់នូវទំនិញ ឬសេវា មិនថាតាមមធ្យោបាយណាមួយ ឬតាមរយៈអន្តរការី ហើយបាន

ទៅដល់បុគ្គលដែលជាអ្នកទិញ ហើយបុគ្គលទាំងនោះបានទូទាត់ប្រាក់ ឬ ប្រគល់ប្រាក់បានជោគជ័យហើយ នោះទំនាក់ទំនងនៃកិច្ចសន្យាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក៏បានបញ្ចប់ដែល ព្រោះភាគីបានបំពេញនូវកាតព្វកិច្ចឱ្យគ្នាទៅវិញទៅមក រហូតទៅដល់ដំណាក់ការចុងក្រោយហើយនោះ។ ប៉ុន្តែបើមានការចែងផ្សេងពីនេះដែលកើតឡើងទៅតាមឆន្ទះរបស់ភាគីដែលនៅតែចង់បន្តទិញនោះ ទំនាក់ទំនងនៃការធ្វើពាណិជ្ជតាមប្រព័ន្ធអេឡិចត្រូនិកនឹងនៅតែបន្តកើតមានជាហូរហែរ លុះត្រាណារហូតដល់ភាគីព្រមព្រៀងគ្នាបញ្ចប់ ជាឧទាហរណ៍ដូចជាការ ផ្តល់សេវាតភ្ជាប់ការប្រើប្រាស់សេវាអ៊ីនធើណែត ជាដើម និងទំនាក់ទំនងទិញអ៊ីវ៉ាន់ជាដើម។

## ផ្នែកទី៦ សកម្មភាព និងប្រតិបត្តិការរបស់រដ្ឋាភិបាលលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ពិតណាស់ការធ្វើនូវប្រតិបត្តិការអ្វីមួយត្រូវការចាំបាច់បំផុតពីការចូលរួមរបស់រដ្ឋាភិបាល ជាពិសេសវិស័យពាណិជ្ជកម្មដែលជាសរសគ្រឹះដ៏រឹងមាំក្នុងការកសាងសេដ្ឋកិច្ចជាតិ។ គេឃើញជាក់ស្តែងក្នុងរយៈពេលថ្មីៗនេះ (២០១៩) រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាអនុវត្តន៍ឱ្យបានពេញលេញនូវការកសាង ការពង្រីកនូវប្រព័ន្ធសេដ្ឋកិច្ចឌីជីថល ស្របទៅតាមបដិវត្តឧស្សាហកម្មដំណាក់កាលទី៤ ដោយផ្តោតទៅលើប្រព័ន្ធបច្ចេកវិទ្យានេះ។ នៅក្នុងវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក៏ដូច្នេះដែល មានការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់រាជរដ្ឋាបាលកម្ពុជា រហូតទៅដល់ឈានទៅការបង្កើតច្បាប់ដើម្បីប្រតិបត្តិការទៀតផង។ នៅក្នុងផ្នែកនេះយើងនឹងសិក្សាទៅលើ ការប្រើប្រាស់ទម្រង់អេឡិចត្រូនិកដោយរដ្ឋាភិបាល (**កថាខណ្ឌ១**) ដែលបញ្ជាក់ពីការចូលរួមពីរាជរដ្ឋាភិបាលកម្ពុជា និងតួនាទីរបស់ក្រសួង ឬ ស្ថាប័នក្នុងវិស័យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (**កថាខណ្ឌ២**)។

### កថាខណ្ឌ១ ការប្រើប្រាស់ទម្រង់អេឡិចត្រូនិកដោយរដ្ឋាភិបាល

ក្រសួង ឬស្ថាប័នរដ្ឋនានាអាចប្រើប្រាស់ទម្រង់អេឡិចត្រូនិកសម្រាប់សកម្មភាពដូចនៅខាងក្រោម៖

ក-ការទទួលចុះបញ្ជីឯកសារ ឬការបំពេញលក្ខខណ្ឌតម្រូវ សម្រាប់បង្កើត ឬរក្សាទុកឯកសារ

ខ-ការចេញអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាត ឬ

គ-បញ្ញត្តិសម្រាប់មធ្យោបាយ និងរបៀបក្នុងការទូទាត់ប្រាក់

ឃ-សកម្មភាពផ្សេងទៀតដែលកំណត់ដោយក្រសួង ស្ថាប័នរដ្ឋដែលមានសមត្ថកិច្ចពាក់ព័ន្ធ។

### កថាខណ្ឌ២ តួនាទីរបស់ក្រសួង ឬស្ថាប័ន

នៅពេលដែលក្រសួង ស្ថាប័នរដ្ឋសម្រេចអនុវត្តកិច្ចការណាមួយ ដូចមានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះហើយ ក្រសួង ស្ថាប័ននោះមានតួនាទីជាអ្នកបញ្ជាក់៖

ក-របៀប និងទម្រង់ ដែលព័ត៌មានទំនាក់ទំនងអេឡិចត្រូនិក ត្រូវទទួលចុះបញ្ជី បង្កើត រក្សាទុក

ឬបោះផ្សាយ និង

ខ-ប្រភេទនៃហត្ថលេខាដែលតម្រូវឱ្យធ្វើនៅពេលដែលមានការតម្រូវឱ្យចុះហត្ថលេខាលទំនាក់ទំនងអេឡិចត្រូនិកនោះ និង

គ-របៀប និងទម្រង់ដែលហត្ថលេខានោះត្រូវភ្ជាប់ទៅលើទំនាក់ទំនងអេឡិចត្រូនិក និង

ឃ-ដំណើការគ្រប់គ្រង និងនីតិវិធីដែលសមស្របដើម្បីធានាសុក្រិតភាព សុវត្ថិភាព និងរក្សាការសម្ងាត់នៃទំនាក់ទំនងអេឡិចត្រូនិក ឬការទូទាត់ប្រាក់ និង

ង-លក្ខខណ្ឌកំណត់ដទៃផ្សេងទៀតដែលផ្តល់តម្លៃសមមូលរវាងឯកសារ ឬការទូទាត់ក្នុងទម្រង់អេឡិចត្រូនិក ជាមួយឯកសារ ឬការទូទាត់ក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ។

# ជំពូកទី៣

# ឧក្រិដ្ឋកម្មបច្ចេកវិទ្យាក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងការទប់ស្កាត់តាមបទពិសោធន៍របស់កម្ពុជា

## ជំពូកទី៣ ឧក្រិដ្ឋកម្មបច្ចេកវិទ្យាក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងការទប់ស្កាត់តាមបទពិសោធន៍កម្ពុជា

ស្របពេលដែលវិស័យបច្ចេកវិទ្យា ជាពិសេសប្រព័ន្ធអេឡិចត្រូនិក កាន់តែរីកចម្រើនទៅមុខ ការរីកចម្រើនទាំងនោះ បាននាំមកនូវប្រយោជន៍ជាច្រើនដល់មនុស្សនៅលើពិភពលោក។ ការរីកចម្រើននូវវិស័យបច្ចេកវិទ្យានេះបានផ្តល់ទាំងផលវិជ្ជមាន និងអវិជ្ជមាន។ វិជ្ជមាន ក៏ព្រោះថា ការរីកចម្រើននូវបច្ចេកវិទ្យាវាបាននាំពិភពលោកទៅរកការរីចម្រើនមួយថ្មីដែលស្របទៅតាមបដិវត្តន៍ឧស្សាហកម្មជំនាន់៤ ដែលផ្តោតសំខាន់ទៅលើបច្ចេកវិទ្យាជាពិសេសពិភពឌីជីថល ដូចជានាំឱ្យមានសេដ្ឋកិច្ចឌីជីថលដែលរាជរដ្ឋាភិបាលកម្ពុជាកំពុងខ្នះខ្នែង ដើម្បីសម្រេចឱ្យបាននូវ ពិភពឌីជីថលនៃសេដ្ឋកិច្ចឱ្យស្របទៅតាមពិភពលោក និយាយឱ្យត្រង់ដើម្បីដើរឱ្យទាន់ពិភពលោក។ តែចំពោះលទ្ធផលអវិជ្ជមាន មានជាអាទិ៍ដូចជាការ ការនាំឱ្យកើតមានឡើងនូវឧក្រិដ្ឋកម្មបច្ចេកវិទ្យា និងលំបាកក្នុងការគ្រប់គ្រង ជាពិសេសចំពោះកម្ពុជាផ្ទាល់តែម្តង នូវពេលដែលខ្លួនមិនទាន់បានសម្របខ្លួនទាន់ពេលវេលា តែក៏មិនមែនមានន័យថាកម្ពុជាពុំមានសមត្ថភាពក្នុងការគ្រប់គ្រងនោះទេ។ នៅក្នុងជំពូកនេះយើងនឹងសិក្សាទៅលើ បទល្មើសដែលកើតចេញពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (**ផ្នែកទី១**) និង ការទប់ស្កាត់រយៈពេលកន្លងមកតាមបទពិសោធន៍កម្ពុជា (**ផ្នែកទី២**)។

### ផ្នែកទី១ បទល្មើសដែលកើតចេញពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

នៅក្នុងផ្នែកនេះយើងនឹងបន្តរសិក្សាទៅលើ បទល្មើសដែលអាចនឹងកើតមានឡើងនៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលជាប្រភេទម្យ៉ាងដែលនៃបទឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ិនធើណែត។ ដោយយើងនឹងសិក្សាទៅលើ ប្រភេទបទល្មើសដែលកើតមានលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (**កថាខណ្ឌ១**) និង លក្ខណៈសម្គាល់ប្រភេទបទល្មើសឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យាក្នុងរឿងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (**កថាខណ្ឌ២**)។

#### កថាខណ្ឌ១ ប្រភេទបទល្មើសដែលកើតមានលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

នៅក្នុងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក គឺជៀសមិនផុតឡើយអំពីអំពើល្មើសមួយដែលនឹងកើតមាន ហើយបង្កើតបានទៅជាបទល្មើសដែលផ្ទុយទៅនឹងច្បាប់នាំឱ្យកើតមានចលាចលលើប្រព័ន្ធបច្ចេកវិទ្យា ដែលអាចនាំឱ្យការធ្វើប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកប្រព្រឹត្តទៅមានភាពរអ:រអួល។ ចំពោះបទល្មើសទាំងនោះអាចមានច្រើនដែលវាកើតមានឡើងអាស្រ័យទៅលើប្រព័ន្ធបច្ចេកវិទ្យាថ្មីដែលមានន័យថាវាបានដើរទន្ទឹមគ្នា នឹងមានការវិវត្តរបស់ប្រព័ន្ធបច្ចេកវិទ្យាជាពិសេសប្រព័ន្ធអេឡិចត្រូនិកដោយផ្ទាល់តែម្តង។

ប្រភេទបទល្មើសដែលកើតមានលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានជាអាទិ៍ដូចជា៖

- ការលួចអត្តសញ្ញាណ

- ការចូលប្រើប្រាស់ ទាញយក ថតចម្លង ស្រង់យក ឬធ្វើឲ្យបែកធ្លាយទិន្នន័យ ដែលស្ថិតនៅក្រោមការរក្សាទុករបស់បុគ្គលផ្សេងទៀត
- ការលួចអត្តសញ្ញាណ
- ការក្លែងប្រព័ន្ធអេឡិចត្រូនិក
- ការបង្កើតកូដព្យាបាល
- ការបំពានលើកូដនីយកម្ម
- ការផ្ញើទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំ
- ការមិនអនុវត្តកាតព្វកិច្ចការពារទិន្នន័យ
- បទមិនរាយការណ៍អំពីព័ត៌មានខុសច្បាប់
- ការមិនអនុវត្តតាមក្រមសិលធម៌វិជ្ជាជីវៈ និងបទប្បញ្ញត្តិពាក់ព័ន្ធ
- ការបំពានលើការចេញសេចក្តីបញ្ជាក់យថាភូតភាព
- ការទូទាត់សងប្រាក់ជាអេឡិចត្រូនិកដោយគ្មានការអនុញ្ញាត
- បទក្លែងបន្លំឧបករណ៍ទូទាត់សងប្រាក់ជាអេឡិចត្រូនិក

**កថាខណ្ឌ២ លក្ខណៈសម្គាល់ប្រភេទបទល្មើសឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យាក្នុងរឿងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

នៅក្នុងកថាខណ្ឌនេះយើងនឹងសិក្សាទៅលើបទល្មើសនីមួយៗ ដោយលម្អិតទៅលើប្រភេទបទល្មើសនីមួយៗដូចខាងក្រោមៈ

**១. ការចូលប្រើប្រាស់ ទាញយក ថតចម្លង ស្រង់យក ឬធ្វើឲ្យបែកធ្លាយទិន្នន័យ ដែលស្ថិតនៅក្រោមការរក្សាទុករបស់បុគ្គលផ្សេងទៀត**

ការចូលប្រើប្រាស់ ទាញយក ថតចម្លង ស្រង់យក ឬធ្វើឲ្យបែកធ្លាយទិន្នន័យ ដែលស្ថិតនៅក្រោមការរក្សាទុករបស់បុគ្គលផ្សេងទៀត ជាអំពើទាំងឡាយណាដែលធ្វើការចូលប្រើប្រាស់ ទាញយកថតចម្លង ស្រង់យក ឬធ្វើឲ្យបែកធ្លាយទិន្នន័យ ដែលស្ថិតនៅក្រោមការគ្រប់របស់បុគ្គលផ្សេងដោយ ទុច្ចរិត ឬដោយគ្មានការអនុញ្ញាតនោះ ត្រូវចាប់ទុកថាជាអំពើល្មើស។

**២. ការលួចអត្តសញ្ញាណ**

ជាអំពើដែលប្រើប្រាស់អត្តសញ្ញាណ កំណត់ត្រា ហត្ថលេខាអេឡិចត្រូនិក អាស័យដ្ឋានអេឡិចត្រូនិក លេខសម្ងាត់ ឬភិនភាគសម្គាល់របស់បុគ្គលផ្សេងទៀតដោយទុច្ចរិត ឬដោយគ្មានការអនុញ្ញាត ត្រូវចាប់ទុកថាជាអំពើល្មើស ក្នុងការលួចអត្តសញ្ញាណ។

**៣. ការក្លែងប្រព័ន្ធអេឡិចត្រូនិក**

ជាការជ្រៀតជ្រែកទិន្នន័យ ឬការបង្កើតប្រព័ន្ធអេឡិចត្រូនិក ក្នុងគោលបំណងក្លែងបន្លំ ឬបង្កការ

ភាន់ច្រលំ ដើម្បីទាញយកផលប្រយោជន៍ ឬក្នុងគោលបំណងទាក់ទាញឲ្យមានការប្រើប្រាស់ហើយ នាំឲ្យមានព្យសនកម្មដល់បុគ្គលដែលប្រើប្រាស់នោះ ឬតតិយជន ។

**៤. ការបង្កើតកូដព្យាបាល**

ជាអំពើទាំងឡាយណាដែលជា ការបង្កើត ការផ្តល់ ការបង្កលទ្ធភាព ការចែកចាយ ឬការបញ្ជូននូវលេខកូដចម្លងមេរោគ តាមមធ្យោបាយអេឡិចត្រូនិក ទៅឧបករណ៍ ឬប្រព័ន្ធអេឡិចត្រូនិក គឺជាអំពើបង្កើតកូដព្យាបាល។

**៥. ការបំពានលើកូដនីយកម្ម**

ការបំពានលើកូដនីយកម្ម ជាការដាក់កូដក្នុងទំនាក់ទំនងអេឡិចត្រូនិក ដែលជាភស្តុតាងអាចនាំទៅដល់ការចោទប្រកាន់ ឬដាក់កូដលើទិន្នន័យ ឬភស្តុតាងក្នុងប្រព័ន្ធអេឡិចត្រូនិក ដែលទាក់ទងនឹងបទល្មើស។

**៦. ការផ្ញើទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំ**

ជាការផ្ញើទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំ ទៅកាន់អ្នកប្រើប្រាស់ដែលមិនអនុលោមតាមបទប្បញ្ញត្តិស្តីពីទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំ។

**៧. ការមិនអនុវត្តកាតព្វកិច្ចការពារទិន្នន័យ**

ជាអំពើដែលបុគ្គលមិនបាន អនុវត្តនូវកាតព្វកិច្ចការពារទិន្នន័យដោយបុគ្គលដែលរក្សាព័ត៌មានជាលក្ខណៈឯកជនក្រោមទម្រង់អេឡិចត្រូនិក ត្រូវចាប់ទុកថាជាបទល្មើស។

**៨. បទមិនរាយការណ៍អំពីព័ត៌មានខុសច្បាប់**

ជាអំពើសំដៅទៅលើ អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលមិនបានអនុវត្តតាមនីតិវិធីចំពោះព័ត៌មានខុសច្បាប់ដូចមានបង្ហាញខាងលើ ដែលត្រូវចាត់ទុកថាជាប្រភេទបទល្មើសផងដែរ។

**៩. ការមិនអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈ និងបទប្បញ្ញត្តិពាក់ព័ន្ធ**

ជាអំពើមិនអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈ និងបទប្បញ្ញត្តិពាក់ព័ន្ធដោយអន្តរការី និងបុគ្គលផ្តល់ សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលត្រូវចាត់ទុកថាជាបទល្មើសដែរ។

**១០. ការបំពានលើការចេញសេចក្តីបញ្ជាក់យថាភូតភាព**

ជាការធ្វើប្រតិបត្តិការប្រព័ន្ធទូទាត់ ការផ្តល់សេវាទូទាត់ ការចេញផ្សាយឧបករណ៍ទូទាត់ជាអេឡិចត្រូនិក ឬការផ្តល់មធ្យោបាយទូទាត់ជាអេឡិចត្រូនិក ឬការធ្វើប្រតិបត្តិការណាមួយដែលត្រូវបានចាត់ទុកថាជាការទូទាត់សងប្រាក់ជាអេឡិចត្រូនិកដល់សាធារណៈជន ដោយមិនមានការអនុញ្ញាត ឬអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ត្រូវចាត់ទុកថាជាអំពើល្មើសផងដែល។

**១១. ការទូទាត់សងប្រាក់ជាអេឡិចត្រូនិកដោយគ្មានការអនុញ្ញាត**

ជាការធ្វើប្រតិបត្តិការប្រព័ន្ធទូទាត់ ការផ្តល់សេវាទូទាត់ ការចេញផ្សាយឧបករណ៍ទូទាត់ជា

អេឡិចត្រូនិក ឬការផ្តល់មធ្យោបាយទូទាត់អេឡិចត្រូនិក ឬ ការធ្វើប្រតិបត្តិការណាមួយដែលត្រូវបានចាត់ទុកថាជាការទូទាត់សងប្រាក់ជាអេឡិចត្រូនិកដល់សាធារណៈជន ដោយមិនមានការអនុញ្ញាត ឬអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ត្រូវចាត់ទុកថាជាបទល្មើសដែរ។

**១២. បទក្លែងបន្លំឧបករណ៍ទូទាត់សងប្រាក់ជាអេឡិចត្រូនិក**

ជាការចេញផ្សាយប័ណ្ណទូទាត់ ឬការកែប្រែប័ណ្ណទូទាត់ទៅជាទម្រង់ណាមួយដែលខុសពីទម្រង់ដើម ដោយគ្មានការអនុញ្ញាតក្នុងគោលបំណងទុច្ចរិត ឆបោក ឬក្លែងបន្លំដែលនាំឲ្យមានព្យសនកម្មដល់បុគ្គលមួយផ្សេងទៀត។

## ផ្នែកទី២ ការទប់ស្កាត់រយៈពេលកន្លងមកតាមបទពិសោធន៍កម្ពុជា

ដូចបានបង្ហាញខាងលើរួចមកហើយ បទល្មើសដែលកើតមាននៅលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ភាគច្រើនជាបទល្មើសដែលជាប់ទាក់ទិនទៅនឹងបច្ចេកវិទ្យាអេឡិចត្រូនិក ឬឧក្រិដ្ឋកម្មបច្ចេកវិទ្យា Cybercrime ។ ច្បាប់ស្តីពី ឧក្រិដ្ឋកម្មបច្ចេកវិទ្យា នៅកម្ពុជាមិនទាប់មាននៅឡើយទេ ដែលជាហេតុធ្វើឱ្យមានការលំបាកក្នុងការទប់ស្កាត់នូវឧក្រិដ្ឋកម្មប្រភេទនេះ។ តែចំពោះបទល្មើសបច្ចេកវិទ្យាមួយចំនួនដែលមានចែងនៅក្នុងសេចក្តីព្រាងច្បាប់ស្តីពី ពាណិជ្ជកម្មតាមប្រពន្ធអេឡិចត្រូនិកវិញ ក៏ជាបទល្មើសដែលចូលទៅក្នុងបទល្មើសបច្ចេកវិទ្យាផងដែល។

តាមបទពិសោតន៍រយៈពេលកន្លងមកចំពោះ បទល្មើសបច្ចេកវិទ្យានេះ ក៏ពុំមែនមានន័យថាកម្ពុជាពុំបានទប់ស្កាត់នោះដែល ត្បិតកម្ពុជាមិនទាន់មានច្បាប់គ្រប់គ្រាន់គ្រប់គ្រងទៅលើបទល្មើសបច្ចេកវិទ្យានេះ តែកម្ពុជាក៏មានវាធានដើម្បីដោះស្រាយនូវបញ្ហាទាំងនេះដែល។

ការដោះស្រាយនូវបទល្មើសបច្ចេកវិទ្យាគឺបាន ស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃដែលមានសមត្ថកិច្ចក្នុងការដោះស្រាយ និង ដើម្បីថែរក្សានូវសណ្តាប់ធ្នាប់សង្គម។ ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ដែលស្ថិតនៅក្រោមរចនាសម្ព័ន្ធរបស់ក្រសួងមហាផ្ទៃជាអ្នកមានតួនាទីក្នុងការដោះស្រាយ និងទប់ស្កាត់នូវបញ្ហាដែលកើតមាន ដោយមានការសហការណ៍ពីស្ថាប័នជំនាញផ្សេងៗ។ ដែលនៅក្នុងកថាខណ្ឌនេះយើងនឹងសិក្សាទៅលើ ភារកិច្ចរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត (**កថាខណ្ឌ១**) រចនាសម្ព័ន្ធរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត (**កថាខណ្ឌ២**) និង តួនាទីរបស់ការិយាល័យប្រឆាំងបទល្មើសបច្ចេកវិទ្យា (**កថាខណ្ឌ៣**)។

### កថាខណ្ឌ១ ភារកិច្ចរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត

ក-អនុវត្តការងាររក្សាសន្តិសុខ សុវត្ថិភាពក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

ខ-ការពារអាយុជីវិត សិទ្ធិ សេរីភាព កិត្តិយស សេចក្តីថ្លៃថ្នូរ ទ្រព្យសម្បត្តិ និងផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន

គ-ការពារសុវត្ថិភាពថ្នាក់ដឹកនាំជាតិ អន្តរជាតិ និងភ្ញៀវបរទេស

ឃ-ការពារការសម្ងាត់ជាតិ ការពារស្ថាប័ន សម្បត្តិវប្បធម៌ បេតិកភណ្ឌជាតិ ទ្រព្យសម្បត្តិសាធារណៈ និងគោលដៅសំខាន់ៗ

ង-រៀបចំសណ្តាប់ធ្នាប់សាធារណៈ សណ្តាប់ធ្នាប់ចរាចរណ៍ផ្លូវគោក ផ្លូវទឹក ផ្លូវដែក និងការងារបង្ការ ពន្លត់អគ្គីភ័យ និងសង្គ្រោះ

ច-ចាត់វិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបរាល់សកម្មភាពជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ លើនីតិជន អនីតិជន និងអំពើហឹង្សាក្នុងគ្រួសារតាមនីតិវិធី

ឆ- ចាត់វិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រឿងញៀនក្នុងដែនសមត្ថកិច្ចទទួលខុសត្រូវ

ជ-ចាត់វិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបឧក្រិដ្ឋកម្មឆ្លងដែន ឧក្រិដ្ឋកម្មមានអង្គការចាត់តាំង និងបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ បទល្មើសបច្ចេកវិទ្យា និងល្បែងស៊ីសងខុសច្បាប់ ព្រមទាំងបទល្មើសផ្សេងៗទៀតដែលដែលប្រឆាំង នឹងសន្តិសុខជាតិ សណ្តាប់ធ្នាប់សង្គមនិងប្រភេទភារកិច្ចជាច្រើនផ្សេងៗទៀត[76]។

**កថាខណ្ឌ២ រចនាសម្ព័ន្ធរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត**

រចនាសម្ព័ន្ធរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត មានរចនាសម្ព័ន្ធដូចតទៅ[77]៖

**ក-ផែនគ្រប់គ្រងធនធានមនុស្ស**

-ការិយាល័យបុគ្គលិក

-ការិយាល័យបណ្តុះបណ្តាល

**ខ-ផែនសេនាធិការ**

-ការិយាល័យរដ្ឋបាល

-ការិយាល័យសរុប និងផែនការ

[76] សូមពិគ្រោះ ប្រកាសស្តីពី ការកែសម្រួលការរៀបចំ និងការប្រព្រឹត្តិទៅរបស់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ-ខេត្ត, ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៨, ប្រការ១

[77] សូមពិគ្រោះ ប្រកាសស្តីពី ការកែសម្រួលការរៀបចំ និងការប្រព្រឹត្តិទៅរបស់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ-ខេត្ត, ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៨, ប្រការ៣

-ការិយាល័យវិទ្យុទាក់ទង

-ការិយាល័យអក្សរសម្ងាត់

-ការិយាល័យកិច្ចការបុគ្គលិកនគរបាលរដ្ឋបាល

-ការិយាល័យអន្តរាគមន៍ និងតម្រួតបទបញ្ជា

**គ-ផែននគរបាលព្រហ្មទណ្ឌ**

-ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់

-ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល

-ការិយាល័យនគរបាលបច្ចេកទេស និងវិទ្យាសាស្ត្រ

**ឃ-ផែនប្រឆាំងបទល្មើស**

-ការិយាល័យនគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច

-ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន

-ការិយាល័យប្រឆាំងគ្រឿងញៀន

**ង-ផែនសន្តិសុខ**

-ការិយាល័យសន្តិសុខផ្ទៃក្នុង

-ការិយាល័យគ្រប់គ្រងសន្តិសុខឯកជន (មាននៅស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ ព្រះសីហនុ និងស្នងការដ្ឋាននគរបាលខេត្តសៀមរាប)

-ការិយាល័យប្រឆាំងបទល្មើសបច្ចេកវិទ្យា (មាននៅស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ) ជាចំណុចសំខាន់ដែលយើងនឹងធ្វើការសិក្សា។

-ការិយាល័យអង្គរក្ស (មាននៅស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ)

**ច-ផ្នែកសណ្តាប់ធ្នាប់**

-ការិយាល័យនគរបាលផ្លូវគោក

-ការិយាល័យនគរបាលផ្លូវទឹក (មាននៅស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ និងខេត្តដែលមានផ្លូវទឹក)

-ការិយាល័យនគរបាលសណ្តាប់ធ្នាប់

-ការិយាល័យនគរបាលទេសចរណ៍ (មាននៅស្នងការដ្ឋាននគរបាលខេត្តមួយចំនួន)

-ការិយាល័យនគរបាលការពារបេតិកភណ្ឌ (មាននៅស្នងការដ្ឋាននគរបាលខេត្តមួយចំនួន)

**ឆ-ផែនគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងអគ្គីភ័យ**

-ការិយាល័យនគរបាលបង្ការពន្លត់អគ្គីភ័យ និងសង្គ្រោះ

-ការិយាល័យនគរបាលគ្រប់គ្រងអាវុធជាតិផ្ទុះ និងជាតិពុល

**ជ-ផែនអន្តោប្រវេសន៍**

-ការិយាល័យគ្រប់គ្រងជនបរទេស

-ការិយាល័យស៊ើបអង្កេត និងអនុវត្តនីតិវិធី ( មាននៅស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ កណ្តាល កំពង់ស្ពឺ ព្រះសីហនុ និងស្នងការដ្ឋាននគរបាលខេត្តសៀមរាប)

**ឈ-ផែនអត្តសញ្ញាណកម្ម**

-ការិយាល័យគ្រប់គ្រងការស្នាក់នៅ

-ការិយាល័យអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

**ញ-ផែនភស្តុភារ និងហិរញ្ញវត្ថុ**

-ការិយាល័យផ្សព្វផ្សាយអប់រំ

-ការិយាល័យភស្តុភារ

-ការិយាល័យគណនេយ្យ

-ការិយាល័យសុខាភិបាល

ដ-វរសេនាតូចនគរបាលការពារព្រំដែនគោក (មាននៅស្នងការដ្ឋាននគរបាលខេត្តជាប់ព្រំដែន លើកលែងតែស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ)

**ប-អធិការដ្ឋាននគបាលក្រុង ស្រុក ខណ្ឌ**

**ឧ-ប៉ុស្តិ៍នគរបាលឃុំ សង្កាត់**

**កថាខណ្ឌ៣ តួនាទីរបស់ការិយាល័យប្រឆាំងបទល្មើសបច្ចេកវិទ្យា**

ការិយាល័យប្រឆាំងបទល្មើសបច្ចេកវិទ្យាមានតួនាទីដូចតទៅ[78]៖

-ផ្តើមយោបល់លើកគោលការណ៍ ផែនការ វិធានការលើការងារប្រឆាំងបទល្មើសបច្ចេកវិទ្យា

-សហការជាមួយសាខាចែកចាយសេវាទូរគមនាគម៍គ្រប់ប្រភេទ ដើម្បីត្រួតពិនិត្យការចុះបញ្ជីភ្ជាប់ប្រើប្រាស់សេវាទូរគមនាគម៍ និងបច្ចេកវិទ្យាតាមការកំណត់

-សហការជាមួយស្ថាប័នរដ្ឋ និងឯកជន ដែលធ្វើអាជីវកម្មសេវាហិរញ្ញវត្ថុ ដើម្បីស្រាវជ្រាវស៊ើបអង្កេត ប្រមូលភស្តុតាង និងបង្ក្រាបបទល្មើសហិរញ្ញវត្ថុតាមប្រព័ន្ធបច្ចេកវិទ្យា

-តាមដានប្រមូលព័ត៌មានលើបណ្តាញសង្គម និងអ៊ីនធើណែត វិភាគវាយតម្លៃសភាពការណ៍បង្កអសន្តិសុខ និងអស្ថិរភាព

-ស្រាវជ្រាវស៊ើបបញ្ជាក់ ប្រមូលភស្តុតាង និងសាវតារបស់គណនីមុខសញ្ញាប្រព្រឹត្តបទល្មើសតាមបណ្តាញសង្គមបច្ចេកវិទ្យា ដើម្បីកសាងសំណុំរឿងតាមនីតិវិធី

-ធ្វើរបាយការណ៍ស្រាវជ្រាវករណី និងការប្រមូលគ្រប់គ្រងវត្ថុតាងជូននាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា ដើម្បីផ្តល់ការណែនាំជំនាញផ្នែកបច្ចេកទេស និងការធ្វើកោសល្យវិច័យបច្ចេកវិទ្យាតាមនីតិវិធី។

-ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ

-ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់

-បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឱ្យ។

[78] សូមពិគ្រោះ ប្រកាសស្តីពី ការកែសម្រួលការរៀបចំ និងការប្រព្រឹត្តិទៅរបស់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ-ខេត្ត, ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨, ប្រការ៤ ចំណុច ឆ លេខរៀងទី៤ ស្តីពីតួនាទីការិយាល័យប្រឆាំងបទល្មើសបច្ចេកវិទ្យា

# សេចក្ដីសន្និដ្ឋាន

មកដល់ពេលបច្ចុប្បន្ននេះ ការរីកចម្រើននៃបច្ចេកវិទ្យា ការវិវត្តខ្លួននៃបដិវត្តឧស្សាហកម្មដំណាក់កាល៤ ការរីកចម្រើននូវប្រព័ន្ធអ៊ិនធើណេត ឬសាយប៊ើស្បេស (Cyberspace) ជាពិសេសការរីកចម្រើននៃបច្ចេកវិទ្យាបាននឹងរុញច្រើនឲ្យកម្ពុជាកាន់តែរីកចម្រើនស្ទើគ្រប់វិស័យ ជាពិសេសការរីកចម្រើននៃវិស័យពាណិជ្ជកម្មដែលកាន់តែបង្កើតភាពងាយស្រួលជូន ប្រជាពលរដ្ឋកាន់ទទួលបាននូវភាពងាយស្រួលចំពោះការរស់នៅរបស់ខ្លួនតាមរយៈការីចចម្រើននៃវិស័យពាណិជ្ជកម្មដែលភ្ជាប់ទៅនឹងបដិវត្តឧស្សាហកម្មទាំងនេះ។ ជាឧទាហរណ៍ស្រាប់នៅក្នុងពេលបច្ចុប្បន្ននេះ កម្ពុជាបានក្លាចខ្លួនជាប្រទេសដែលទទួលយកនូវការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះ គឺទាំងស្ថាប័នរដ្ឋ និងស្ថាប័នឯកជន។

បច្ចុប្បន្នស្ថាប័នរដ្ឋ និងឯកជនបានប្រើប្រាស់បច្ចេកវិទ្យា ក្នុងការទូទាត់ប្រាក់ ផ្ទេរប្រាក់ រក្សាទុកប្រាក់ និងធ្វើការបញ្ជាទិញទំនិញតាមអ៊ិនធើណែត ឬអនឡាញ ការកក់នូវ សេវាផ្គត់ផ្គង់នានា ដូចជាការកក់សណ្ឋាគារ ការកក់នូវសេវាផ្គត់ផ្គង់អ៊ិនធើណែត ។ ការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកនេះដោយមានស្ថាប័នរដ្ឋបានកំពុងអនុវត្ត ហើយដើម្បីបង្កើតភាពងាយស្រួលជូនប្រជាពលរដ្ឋឲ្យកាន់តែមានភាពរហ័ស លឿនមិនខាតពេលវេលា មិនចំណាយលុយច្រើន ឬតម្លៃផ្សេងៗទៀតនោះមាន ដូចជា ការទូទាត់ថ្លៃភ្លើងដោយអគ្គីសនីកម្ពុជា ការទូទាត់ថ្លៃទឹក និងសេវាកម្មផ្សេងទៀតដែលប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យាដូចគ្នា មានដូចជា ការចុះបញ្ជីយានយន្ត ការទិញស្លាកលេខយានយន្តដោយប្រព័ន្ធអេឡិចត្រូនិក ការបង្កើតឲ្យមានលើសេវាទាំងនោះ ដែលទាំងអស់នេះជាការរៀបចំមួយថ្មីឡើងសម្រាប់ប្រជាពលរដ្ឋឲ្យកាន់តែងាយស្រួលបន្ថែមទៀត។ ចំណែកឯស្ថាប័នឯកជនឯនោះវិញកាន់តែអាចរកប្រាក់ចំណេញបានកាន់តែច្រើនតាមរយៈការធ្វើពាណិជ្ជកម្មរបស់ខ្លួន ដូចជាការដាក់លក់ទំនិញ ឬសេវា ជារបស់ក្រុមហ៊ុនខ្លួន និងអាចបញ្ជាឲ្យអតិថិជនអាចកម្ម៉ង់ទិញនូវទំនិញ ឬសេវាពីក្រុមហ៊ុនខ្លួនបាន ដោយមានការដឹកជញ្ជូនបានលឿនរហ័ស ទាន់ចិត្តនូវពេលដែលអ្នកប្រើប្រាស់ពុំមានពេលគ្រប់គ្រាន់ក្នុងការដើរទិញដោយខ្លួនឯង ដូចជាការទិញម្ហូបជាដើម។ នៅកម្ពុជាបច្ចុប្បន្នមានក្រុមហ៊ុនច្រើន ដែលគេស្គាល់ និងកំពុងឈរឈ្មោះរបស់សំឡេងក្នុងពេលបច្ចុប្បន្នដែលធ្វើការការទៅតាមការរៀបខាងលើនោះ តែយើងអាចលើកយក ពីរទៅបីក្រុមហ៊ុនមកធ្វើការបង្ហាញ ក្នុងនោះមានដូចជាចំពោះក្រុមហ៊ុនអ៊ីនធើណែតមានដូចជាក្រុមហ៊ុន អ៊ីហ្សីខម ដែលជាក្រុមហ៊ុនឈានមុខគេផ្គត់ផ្គង់នូវសេវាអ៊ីធើណេត ក្រុមហ៊ុន PASS APP និង GRAB ដែលជាក្រុមហ៊ុនផ្គត់ផ្គង់ទៅលើសេវាដឹកជញ្ជូនអតិថិជនពីកន្លែងមួយទៅកន្លែងមួយដោយមាន APP ផ្ទាល់ខ្លួនក្នុងការធ្វើអាជីវកម្មពាណិជ្ជកម្មរបស់ខ្លួនដែលយកប្រព័ន្ធបច្ចេកវិទ្យាជាស្នូលក្នុងការផ្គត់ផ្គង់ សេវាឲ្យក្រុមហ៊ុនរបស់ខ្លួនដូចជា App របស់ក្រុមហ៊ុន PASS APP និងរបស់ GRAB ។ ចំណែកឯក្រុមហ៊ុនដែលផ្គត់ផ្គង់ទៅលើសេវាបញ្ជាទិញ ឬកម្មង់ម្ហូបអាហារក៏មានច្រើនគួរសមដែល តែសូមលើកយកក្រុមហ៊ុន E-GETS

មួយយកបង្ហាញ។ ក្រុមហ៊ុននេះបានធ្វើការវិវត្តខ្លួនទោះមិនទាន់ខ្លាំងតែក៏សន្ទុះនៃការអភិវឌ្ឍន៍ក៏មានច្រើនគួរសមដែរ។ បច្ចុប្បន្ននេះក្រុមហ៊ុនមានសាខាចំនួន៣នៅកម្ពុជា ក្នុងនោះមាននៅខេត្តព្រះសីហនុ នៅក្រុងបាវិត ខេត្តស្វាយរៀង និងទី៣ នៅរាជធានីភ្នំពេញ។ ក្រុមហ៊ុន E-GETS នៅភ្នំពេញបច្ចុប្បន្នមានអ្នកដឹកជញ្ជូន ឬអន្តរការីចំនួន ៥០០ នាក់សម្រាប់ដឹកជញ្ជូននៅពេលដែលមានការបញ្ជាទិញ ក៏ដូចជាការកម្ម៉ង់ពីអតិថិជនរបស់ខ្លួនដោយប្រើប្រាស់ App ផ្ទាល់ ។

នៅក្នុងពេលបច្ចុប្បន្ន បើទោះបីជាយើងមិនទាន់ដើរទាន់នូវបច្ចេកវិទ្យានៅក្នុងយុគសម័យបដិវត្តឧស្សាហកម្មដំណាក់កាលទី៤ក៏ដោយ ក៏គេឃើញថារដ្ឋាភិបាលមាននូវការយកចិត្តទុកដាក់ក្នុងការគ្រប់គ្រង និងចុះប្រើប្រាស់សម្រាប់មធ្យោបាយអភិវឌ្ឍន៍ខ្លួនបើទោះបីជាមិនទាន់ច្បាប់ពេញលេញក្នុងការគ្រប់គ្រងក៏ដោយ តែមធ្យោបាយផ្សេងៗបាននឹងដាក់ឲ្យប្រើប្រាស់ដើម្បីបង្កើតភាពងាយស្រួលជូនប្រជាពលរដ្ឋរបស់ខ្លួន។ បច្ចុប្បន្នរដ្ឋាភិបាលបានកំពុងបង្កើតនូវសេចក្តីព្រាងច្បាប់ជាច្រើនដើម្បីដើរឲ្យទាន់នូវការវិវត្តទាំងនោះមានដូចជា ការបង្កើតឲ្យមាននូវសេចក្តីព្រាងច្បាប់ស្តីពីការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ការបង្កើតសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ និងកំពុងសិក្សាដើម្បីបង្កើតឲ្យមាននៅសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យា និងព័ត៌មានវិទ្យាជាដើម។

ការរីកចម្រើននៃបច្ចេកវិទ្យាជាមួយនឹង ការធ្វើពាណិជ្ជកម្ម ពោលគឺការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ជាប្រតិបត្តិការមួយមិនងាយស្រួលក្នុងការប្រតិបត្តិនោះឡើយ។ ជាសញ្ញាណមុននឹងនាំឲ្យមាននូវការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះទំនាក់ទំនងទៅលើការបង្កើតកិច្ចសន្យាគឺជារឿងចាំបាច់បំផុតសម្រាប់ការបំពេញទៅតាមកម្មវត្ថុដូចជាទំនិញ ឬសេវា ដែលខ្លួនបានដាក់លក់ ឬបម្រើនូវសេវា ដែលរកចាំពីបុគ្គលម្ខាងទៀតដើម្បីបង្កើតអានុភាពនៃកិច្ចសន្យា។ ការធ្វើនូវពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានគិតគូគ្រប់ជ្រុងជ្រោយដើម្បីឲ្យដំណើរការរលូនទៅដូចជាការគិតពីសុវត្ថិភាពនៃកំណត់ត្រាអេឡិចត្រូនិក ការគិតពីសុវត្ថិភាពនៃភស្តុតាង និងសុវត្ថិភាពហត្ថលេខាអេឡិចត្រូនិក។ ការធ្វើនូវពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នូវពេលដែលភាគីបានសម្តែងនូវឆន្ទះចប់សព្វគ្រប់ហើយ ពោលកិច្ចសន្យាមួយមានអានុភាពហើយនោះ សិទ្ធិនឹងកាតព្វកិច្ចករណីកិច្ច ក៏ផ្តល់ឲ្យភាគីសម្រាប់អនុវត្តន៍តាមដែល ដូចជាករណីកិច្ចបង់ប្រាក់ ទូទាត់ប្រាក់ ទៅលើទំនិញ ឬសេវា ករណីកិច្ចប្រគល់ទំនិញ ឬផ្តល់នូវសេវាជាអាទ៍។ នៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ការប្រគល់ទំនិញ ឬផ្តល់សេវាអ្វីអាចមានអន្តរការីសម្រាប់ធ្វើការដឹកជញ្ជូន ទៅគ្រប់ទីកន្លែង។ ខាងលើជាការផ្តល់នូវផលវិជ្ជមានចំពោះ បដិវត្តឧស្សាហកម្មដំណាក់កាលតី៤ សាយប៊ើស្ប៉េស (Cyberspace) ឬអ៊ិនធើណែត ជាគឺការធ្វើនូវពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកតែម្តង ប៉ុន្តែការរីកចម្រើននៃបច្ចេកវិទ្យាខាងលើ ជាពិសេសការធ្វើនូវពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកវាមិនមែនជះតែលើលទ្ធផលវិជ្ជមាននោះទេ ក៏មានដែលលទ្ធផលអវិជ្ជមានដែលអាចអនុវត្តន៍ទៅធ្វើឲ្យមាន

បញ្ហា បញ្ហាទាំងនេះដោយសារយើងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ធ្វើពាណិជ្ជកម្ម ដែលនឹងអាចនាំឲ្យកើតមាននូវឧក្រិដ្ឋកម្មបច្ចេកវិទ្យា ឧក្រិដ្ឋកម្មព័ត៌មានវិទ្យា ធ្វើឲ្យប៉ះពាល់ដល់សុវត្ថិភាព ទំនុកចិត្ត ការធ្វើពាណិជ្ជកម្មតាមរយៈប្រព័ន្ធអេឡិចត្រូនិកនេះ។

## អានុសាសន៍

ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ផ្តល់នូវផលប្រយោជន៍ជាច្រើនជូនកម្ពុជាក្នុងសម័យសេដ្ឋកិច្ចឌីជីថលនេះហើយការជះឥទ្ធិពលវិជ្ជមានទាំងអស់នោះជាខឿនក្នុងការកសាងសេដ្ឋកិច្ច ឲ្យកាន់តែរីកចម្រើនជាងពេលបច្ចុប្បន្ន ដោយការប្រើប្រាស់នូវបច្ចេកវិទ្យាអេឡិចត្រូនិក។

ពិតណាស់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក សម្រាប់បរិបទកម្ពុជា មិនទាន់មានទទួលបាននូវលទ្ធផលវិជ្ជមានទាំងស្រុងនោះទេ ទាំងអស់នេះក៏ព្រោះថាការធ្វើពាណិជ្ជកម្មប្រភេទនេះវាជាសញ្ញាណថ្មីសម្រាប់កម្ពុជា ក្នុងការពង្រឹងពង្រីកខ្លួនឲ្យស្រប់ទៅតាមពិភពសេដ្ឋកិច្ចឌីជីថល ដែលកម្ពុជាពុំទាន់មាន សមត្ថភាពគ្រប់គ្រាន់ទទួលយកនូវការផ្លាស់ប្តូរបរិបទពិភពលោកទាំងស្រុងនៅឡើយ។ ខាងក្រោមនេះគឺជា អានុសាសន៍ខ្លះៗដែលកើតចេញពីការរកឃើញពីការសិក្សា ស្រាវជ្រាវទៅលើប្រធានបទស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលអនុសាសន៍ទាំងនោះរួមមាន៖

❖ ពាក់ព័ន្ធនឹងវិស័យច្បាប់ ៖ រាជរដ្ឋាភិបាលកម្ពុជាត្រូវតែពន្លឿននូវការតាក់តែងច្បាប់ដែលពាក់ព័ន្ធនានា ដែលទាក់ទងទៅនឹងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដូចជាច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ក្រមសិលធម៌ទាក់ទងនឹងអន្តរការីច្បាប់ស្តីពីការបង្រ្កាប់បទល្មើសបច្ចេកវិទ្យា ព័ត៌មានវិទ្យា ដើម្បីធ្វើការគ្រប់គ្រងនឹងធានាសុវត្ថិភាពជូនបុគ្គលទាំងឡាយជាពិសេស អ្នកវិនិយោគ ក្រុមហ៊ុនធំ ទាំងជាតិ អន្តរជាតិ ក្នុងការប្រតិបត្តិនូវការធ្វើពាណិជ្ជកម្មប្រភេទនេះឲ្យកាន់តែមានភាពរលូន ងាយស្រួលក្នុងការ ធ្វើពាណិជ្ជកម្មនានា ដោយប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកនេះ។ ជាពិសេសរាជរដ្ឋាភិបាលកម្ពុជាត្រូវមានគោលនយោបាយមួយច្បាស់លាស់ ដើម្បីទាក់ទាញអ្នកវិនិយោគបន្ថែមទៀតមិនថាក្នុងក្របខណ្ឌតំបន់ និងក្រៅតំបន់ឲ្យមកវិនិយោគលើផ្នែកបច្ចេកវិទ្យាព័ត៌មាន ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីទទួលបាននូវការកាត់បន្ថយនូវថ្លៃសេវានៅក្នុងប្រតិបត្តិការ តាមប្រព័ន្ធអេឡិចត្រូនិក រួមទាំងពង្រីកបាននូវការកាត់បន្ថយនៅក្នុងការនាំចេញនូវទំនេញឬ សេវាទៅកាន់ទីផ្សារខាងក្រៅ។

❖ ការអប់រំ៖ បដិវត្តឧស្សាហកម្មជំណាក់កាល៤ បានរីកសាយភាយហើយនៅលើសកលលោកទោះទៅដល់ទីណា កន្លែងណា ក៏ដោយប្រជាជននៅលើពិភពលោកជាពិសេសនៅប្រទេសអភិវឌ្ឍន៍នានាបានដឹង បានស្គាល់ នូវការរីកចម្រើនទាំងនោះ ចេះប្រើ ចេះទាញយកប្រយោជន៍ពី ការរីកចម្រើនអស់ទាំងនោះតាមរយៈបដិវត្តឧស្សាហកម្មនោះឯក ការរីកចម្រើនទាំងនោះមានដូចជា ការរីកចម្រើននៃពិភពឌីជីថល សាយបើស្បេស (Cyberspace) និងប្រព័ន្ធបច្ចេកវិទ្យានានា។ តាមរយៈការរីកចម្រើនទាំងអស់នេះ តួនាទីរបស់រាជរដ្ឋាភិបាលត្រូវបង្រៀន ផ្សព្វផ្សាយ នូវការរីកចម្រើនទាំងអស់នោះជូនប្រជាពលរដ្ឋកម្ពុជា នូវការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា ដូចជាអ៊ីនធើណែត និងប្រព័ន្ធបច្ចេកវិទ្យានានាផ្សេងទៀតដើម្បីជាប្រយោជន៍សម្រាប់ពួកគាត់រៀងខ្លួន ដូចជាការប្រើប្រាស់ដើម្បីធ្វើអាជីវ

កម្ម ពាណិជ្ជកម្មតាមអនឡាយ ឬពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ការទទួលព័ត៌មានជាតិ អន្តរជាតិ ការប្រើប្រាស់ប្រាស់ដើម្បីកែរលំអ្ន រិៈគន់ក្នុងន័យស្ថាបនា និងការឈោងទៅចាប់ឪកាសនានាដែលមាននៅបរិបទពិភពលោក ដូចជាការទទួលបាននូវការងារក្នុងក្រុមហ៊ុនធំៗ និងការទទួលបាននូវអាហារូបករណ៍ដែលមានផ្សព្វផ្សាយលើសាយប៊ើស្ប៉េស (Cyberspace) ឬអ៊ីនធើណេត។

❖ ចូលរួមជម្រុញ និងលើកទឹកចិត្តដល់វិស័យឯកជននៅក្នុងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

❖ រាជរដ្ឋាភិបាលក៏ត្រូវមានតួនាទីក្នុងការពង្រីក និងពង្រឹងបន្ថែមទៀតនូវបណ្តាញពាណិជ្ជកម្មដែលកំពុងតែកើតមាន និងព្យាយាមរកអ្នកវិនិយោគនានា មកបង្កើតថ្មី ដើម្បីកំណើនសេដ្ឋកិច្ចជាតិតាមរយៈការយកនូវគោលនយោបាយសេដ្ឋកិច្ចឌីជីថលក្នុងបដិវត្តន៍ឧស្សាហកម្មជំណាក់កាលទី៤ មកជាប្រយោជន៍។

❖ រាជរដ្ឋាភិបាលកម្ពុជាមានតួនាទីត្រួតពិនិត្យ ថែរក្សាសុវត្ថិភាព ធានាភាពលឿនរហ័សជូនបុគ្គលដែលបានធ្វើការវិនិយោគលើការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងវាយតម្លៃឲ្យបានច្បាស់លាស់ពីផលប៉ះពាល់ផ្សេងៗដែលអាចកើតមាន ព្រមទាំងរកវិធីដោះស្រាយចំពោះផលប៉ះពាល់ដែលកើតមានទាំងនោះដើម្បីធានាបាននូវការអភិវឌ្ឍមួយ ប្រកបដោយចីរភាពក្នុងក្របខណ្ឌពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

❖ រាជរដ្ឋាភិបាលកម្ពុជាត្រូវតាមដាន និងត្រួតពិនិត្យដោយស្ថាប័នពាក់ព័ន្ធ ឲ្យបានច្បាស់ លាស់មុននឹងចេញផ្តល់ឲ្យ នូវវិញ្ញាបនកម្មជូនបុគ្គលដែលបានធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

❖ រាជរដ្ឋាភិបាលកម្ពុជាត្រូវបង្ការ ទប់ស្កាត់ និងប្រឆាំងនូវរាល់បទល្មើសទាំងឡាយដែលពាក់ព័ន្ធនឹងវិស័យព័ត៌មានវិទ្យា បទល្មើសបច្ចេកវិទ្យា ហើយដែលធ្វើឲ្យប៉ះពាល់ខ្លាំង ជះឥទ្ធិពលខ្លាំងដល់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

## បញ្ជីឯកសារយោង

- ❖ វចនានុក្រមខ្មែរ ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនាបណ្ឌិត្យ ព.ស ២៥១១ គ.ស ១៩៦៧
- ❖ សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី ដែលត្រូវបានរៀបចំដោយគណ:កម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបោះផ្សាយដោយទីស្តីការគណ:រដ្ឋមន្ត្រី នៅឆ្នាំ២០០៧។
- ❖ ច្បាប់ទូទៅ
  - ច្បាប់ស្តីក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ ២០០៧
  - សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី រៀបចំដោយគណ:កម្មាការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី ដោយក្រសួងយុត្តិធម៌ ភ្នំពេញ២០១០
  - សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីកម្ពុជា បោះពុម្ពនៅក្នុងខែ មិនា ឆ្នាំ ២០១២
- ❖ ច្បាប់ដោយឡែក
  - ➢ ច្បាប់
    - សេចក្តីព្រាងច្បាប់ស្តីពី ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ ២០១៩
    - ច្បាប់ស្តីពីសហគ្រាសសាធារណ: ឆ្នាំ ២០០៥
  - ➢ អនុក្រឹត្យ
    - អនុក្រឹត្យស្តីពីហត្ថលេខាឌីជីថល ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ២០១៧
  - ➢ ប្រកាស
    - ការកែសម្រួលការរៀបចំ និងកការប្រព្រឹត្តិទៅរបស់ស្នងការដ្ឋាននគរបាលរាជធានីខេត្ត ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨
- ❖ សៀវភៅពាក់ព័ន្ធ
  - សារណាបញ្ចប់ការសិក្សា ស្តីពីការរៀបចំច្បាប់ពាណិជ្ជកម្មអេឡិចត្រូនិកនៅកម្ពុជា សរសេដោយនិស្សិតឈ្មោះ ក. ញ៉ឹក ពេជ្រម៉ូលីកា និង ឡឹក សីហា ដែលដឹកនាំដោយសាស្ត្រាចារ្យ សន សោភ័ណ ឆ្នាំសរសេសារណា ២០១៤
  - សារណាបញ្ចប់ការសិក្សា ស្តីពី ពាណិជ្ជកម្មអេឡិចត្រូនិក សរសេដោយនិស្សិតឈ្មោះ អុន រតនា និង អ៊ុត ចាន់លីនណា ដែលដឹកនាំដោយសាស្ត្រាចារ្យ ជិន វណ្ណារ៉ា ឆ្នាំសរសេសារណា ២០១២
  - អត្ថបទជំនួយស្មារតីស្តីពី *បដិវត្តន៍ឧស្សាហកម្មទី៤(ឧស្សាហកម្ម៤.0)* , វ៉ុល១ លេខទី៣, ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៩, ដោយមជ្ឈមណ្ឌលអភិវឌ្ឍកម្ពុជា

- អត្ថបទជំនួយស្មារតីស្តីពី *សារប្រយោជន៍នៃសាយប៊ើស្បេសក្នុងដំណើការអភិវឌ្ឍនៅកម្ពុជា* , ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧, ដោយមជ្ឈមណ្ឌលអភិវឌ្ឍកម្ពុជា
- បដិវត្តន៍ឧស្សាហកម្មលើកទី៤ ដោយ KLAUS SCHWAB
- INDRODUCTION E-COMMERCE by Jenifer Mitra (April-14-2010) (ឧបសម្ព័ន្ធ)

# ឧបសម្ព័ន្ធ

# សេចក្តីព្រាងច្បាប់ស្តីពីការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចុះថ្ងៃទី៣០ ខែ ឧសភា ឆ្នាំ ២០១៩

ឯកសារសម្រាប់ប្រជុំអន្តរក្រសួងបន្ទៀត
ថ្ងៃទី 05 ខែ 6 ឆ្នាំ 2019

សេចក្ដីព្រាង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ច្បាប់

## ស្ដីពី

# ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ក្រសួងពាណិជ្ជកម្ម

ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .- គោលបំណង**

ច្បាប់នេះមានគោលបំណង៖

១. គ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងព្រះរាជាណាចក្រកម្ពុជានិងជាមួយអន្តរជាតិ។

២. បង្កើតភាពប្រាកដប្រជាផ្នែកគតិយុត្តក្នុងប្រតិបត្តិការផ្នែករដ្ឋប្បវេណីនិងផ្នែកពាណិជ្ជកម្មដែលទាក់ទងទៅនឹងទំនាក់ទំនងអេឡិចត្រូនិក។

៣. ផ្តល់ទំនុកចិត្តដល់សាធារណជនក្នុងការប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

**មាត្រា២ .- គោលដៅ**

ច្បាប់នេះមានគោលដៅដូចខាងក្រោម៖

១. កំណត់អំពីយថាភូតភាព សុក្រឹតភាព និងភាពអាចជឿទុកចិត្តបាននៃទម្រង់អេឡិចត្រូនិក។

២. ជំរុញការអភិវឌ្ឍក្របខណ្ឌគតិយុត្ត និងធុរកិច្ច ដើម្បីអនុវត្តពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកប្រកបដោយសុវត្ថិភាព។

៣. បង្ការនិងបង្ក្រាបអំពើដែលបង្កការខូចខាតដល់ទិន្នន័យនិងប្រព័ន្ធព័ត៌មាន។

៤. លុបបំបាត់ឧបសគ្គទាំងឡាយដែលរាំងស្ទះដល់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកហើយដែលកើតចេញពីភាពមិនប្រាកដប្រជានៃលក្ខខណ្ឌតម្រូវចំពោះលិខិតជាលាយលក្ខណ៍អក្សរនិងហត្ថលេខា។

៥. សម្រួលដល់ការតម្កល់ឯកសារតាមប្រព័ន្ធអេឡិចត្រូនិកជាមួយស្ថាប័នសាធារណៈ និងលើកកម្ពស់ការផ្តល់សេវាកម្មប្រកបដោយប្រសិទ្ធភាពរបស់ស្ថាប័នសាធារណៈ តាមរយៈការប្រើប្រាស់កំណត់ត្រាតាមប្រព័ន្ធអេឡិចត្រូនិកដែលអាចជឿទុកចិត្តបាន។

៦. បង្កើតវិធាន បទប្បញ្ញត្តិ និងស្តង់ដា ដែលទាក់ទងនឹងយថាភូតភាពនិងសុក្រឹតភាពរបស់កំណត់ត្រាតាមប្រព័ន្ធអេឡិចត្រូនិក។

**មាត្រា៣ .- វិសាលភាព**

ច្បាប់នេះត្រូវអនុវត្តលើសកម្មភាព ឯកសារ និងប្រតិបត្តិការផ្នែករដ្ឋប្បវេណីនិងពាណិជ្ជកម្មទាំងអស់ដែលធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិក លើកលែងតែសកម្មភាព ឯកសារ និងប្រតិបត្តិការទាក់ទងនឹង៖

- ការបង្កើតឬការអនុវត្តលិខិតប្រគល់សិទ្ធិ
- ការបង្កើតឬការចុះហត្ថលេខាលើមតកសាសន៍ លិខិតកែមតកសាសន៍ ឬបញ្ហាផ្សេងៗទៀតទាក់ទិននឹងសន្តតិកម្ម។
- រាល់កិច្ចសន្យាសម្រាប់ការលក់ ការផ្ទេរ ឬការបោះបង់សិទ្ធិលើអចលនទ្រព្យឬផលប្រយោជន៍ផ្សេងៗទៀតក្នុងទ្រព្យនោះ

- ការផ្ទេរអចលនវត្ថុឬផលប្រយោជន៍ណាមួយដែលពាក់ព័ន្ធនឹងអចលនវត្ថុនោះ
- ករណីលើកលែងផ្សេងទៀតដែលត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៤ .- និយមន័យ**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះត្រូវបានកំណត់និយមន័យដូចមានក្នុងសទ្ទានុក្រម ដែលមានចែងក្នុងឧបសម្ព័ន្ធនៃច្បាប់នេះ។

## ជំពូកទី២
## សុពលភាពនៃទំនាក់ទំនងអេឡិចត្រូនិក

**មាត្រា៥ .- ការទទួលស្គាល់លក្ខណៈគតិយុត្តនៃទំនាក់ទំនងអេឡិចត្រូនិក**

គ្មានបុគ្គលណាម្នាក់អាចបដិសេធមិនទទួលស្គាល់សុពលភាព អានុភាពគតិយុត្ត ភាពអាចទទួលយកបានឬភាពដែលអាចយកទៅអនុវត្តបាននៃទំនាក់ទំនងអេឡិចត្រូនិក ដោយគ្រាន់តែសម្អាងលើមូលហេតុដែលថាវាធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិកឬស្ថិតនៅក្នុងទំនាក់ទំនងអេឡិចត្រូនិកឡើយ។

**មាត្រា៦ .- លក្ខខណ្ឌតម្រូវជាលាយលក្ខណ៍អក្សរ**

១. នៅពេលដែលបទប្បញ្ញត្តិណាមួយ តម្រូវឲ្យផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរ ឬធ្វើកំណត់ត្រាជាលាយលក្ខណ៍អក្សរ ត្រូវចាត់ទុកថា លក្ខខណ្ឌតម្រូវនេះត្រូវបានបំពេញប្រសិនបើព័ត៌មាននេះធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិក ហើយអាចចូលប្រើប្រាស់បាន និងអាចទាញយកទៅប្រើប្រាស់នៅពេលក្រោយបាន។

២. នៅពេលដែលលក្ខខណ្ឌក្នុងកថាខណ្ឌ១ ត្រូវយកមកអនុវត្ត លក្ខខណ្ឌតម្រូវតាមច្បាប់ដែលទាមទារឲ្យបុគ្គលណាមួយផ្តល់សំណៅចម្លងច្រើនច្បាប់ក្នុងពេលតែមួយស្តីអំពីព័ត៌មានណាមួយ ឬកិច្ចការណាមួយទៅឲ្យបុគ្គលមួយផ្សេងទៀត បុគ្គលដែលផ្តល់អាចបំពេញលក្ខខណ្ឌនេះដោយគ្រាន់តែផ្តល់ក្រោមទម្រង់អេឡិចត្រូនិកតែមួយច្បាប់បាន។

**មាត្រា៧ .- លក្ខខណ្ឌតម្រូវចំពោះហត្ថលេខា**

១. នៅពេលដែលមានបទប្បញ្ញត្តិណាមួយតម្រូវឲ្យមានហត្ថលេខារបស់បុគ្គលណាមួយ លក្ខខណ្ឌតម្រូវនេះត្រូវចាត់ទុកថាបានបំពេញតាមរយៈការចុះហត្ថលេខាអេឡិចត្រូនិក ប្រសិនបើហត្ថលេខាអេឡិចត្រូនិកដែលបានប្រើនោះ ត្រូវបានបង្កើតឡើងតាមរយៈមធ្យោបាយដែលៈ

ក. អាចកំណត់អត្តសញ្ញាណបុគ្គល និងបង្ហាញការឯកភាពរបស់បុគ្គលនោះលើព័ត៌មាន ឬកំណត់ត្រាដែលមាននៅក្នុងទំនាក់ទំនងអេឡិចត្រូនិកនោះ។

ខ. អាចជឿជាក់បាន ស្របតាមចរិតលក្ខណៈ គោលបំណង និងកាលៈទេសៈ ដែលទំនាក់ទំនងអេឡិចត្រូនិកនោះត្រូវបានបង្កើតឡើង ឬត្រូវបានប្រាស្រ័យទាក់ទង។

២. ទោះបីជាបទប្បញ្ញត្តិណាមួយកំណត់អំពីលក្ខខណ្ឌតម្រូវឲ្យមានចុះហត្ថលេខា ឬគ្រាន់តែកំណត់អំពីផលវិបាកនៃការមិនចុះហត្ថលេខាក៏ដោយ ក៏កថាខណ្ឌ១ខាងលើត្រូវយកមកអនុវត្តផងដែរ។

**មាត្រា៨ .- លក្ខខណ្ឌតម្រូវសម្រាប់រក្សាព័ត៌មានតាមទម្រង់ដើម**

លក្ខខណ្ឌគតិយុត្តក្នុងការរក្សាព័ត៌មានដែលមិនត្រូវបានធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិក អាចត្រូវបានបំពេញដោយការរក្សាព័ត៌មាននោះក្រោមទម្រង់អេឡិចត្រូនិក ប្រសិនបើ៖

១. ទម្រង់អេឡិចត្រូនិកនោះជាមធ្យោបាយដែលអាចជឿទុកចិត្តបានដើម្បីកំណត់ភាពពេញលេញរបស់ព័ត៌មាននោះ។ និង

២. ព័ត៌មាននោះអាចចូលយកបានដោយងាយស្រួល សម្រាប់យកទៅប្រើប្រាស់បានពេលក្រោយ។

**មាត្រា៩ .- ទម្រង់បែបបទដែលកំណត់**

នៅពេលដែលបទប្បញ្ញត្តិណាមួយតម្រូវឲ្យព័ត៌មានធ្វើឡើងក្នុងទម្រង់បែបបទណាមួយ លក្ខខណ្ឌតម្រូវនោះត្រូវជំនួសដោយការផ្តល់ព័ត៌មានតាមទម្រង់អេឡិចត្រូនិកបាន ប្រសិនបើទម្រង់អេឡិចត្រូនិកនោះត្រូវបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

ក. មានផ្ទុកព័ត៌មានដូចគ្នា ឬដូចគ្នាភាគច្រើនទៅនឹងទម្រង់បែបបទដែលបានកំណត់។

ខ. អាចចូលទៅមើលបាន អាចយល់បាន និងអាចទាញយកមកប្រើប្រាស់បាននៅពេលក្រោយ។

គ. អាចឲ្យបុគ្គលដែលទទួលបានព័ត៌មាននោះរក្សាទុកបាន។

**មាត្រា១០ .- លក្ខខណ្ឌតម្រូវលើការរក្សាទុកកំណត់ត្រា**

១. នៅពេលដែលបទប្បញ្ញត្តិណាមួយតម្រូវឲ្យរក្សាទុកនូវឯកសារ កំណត់ត្រា ឬព័ត៌មានជាក់លាក់ណាមួយ លក្ខខណ្ឌតម្រូវនោះត្រូវចាត់ទុកថាបានបំពេញ ប្រសិនបើ ការរក្សាទុកនោះបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

ក. ព័ត៌មានដែលមាននៅក្នុងទំនាក់ទំនងអេឡិចត្រូនិកនោះអាចចូលប្រើប្រាស់បាន និងសម្រាប់យកទៅប្រើប្រាស់នាពេលអនាគត។

ខ. ទំនាក់ទំនងអេឡិចត្រូនិកត្រូវបានរក្សាទុកក្នុងទម្រង់ដើមដែលត្រូវបានបង្កើតឡើង ផ្ញើ ឬទទួលបាន ឬក្នុងទម្រង់ដែលអាចត្រូវបានបង្ហាញពីសុក្រិតភាពនៃព័ត៌មាននោះ។

គ. ព័ត៌មានទាំងនោះ ត្រូវរក្សាទុកដើម្បីឲ្យបុគ្គលណាម្នាក់អាចកំណត់បាននូវប្រភពដើម និងគោលដៅនៃទំនាក់ទំនងអេឡិចត្រូនិកនោះ កាលបរិច្ឆេទ និងពេលវេលាដែលទំនាក់ទំនងអេឡិចត្រូនិកនោះត្រូវបានផ្ញើឬទទួល។

២. កាតព្វកិច្ចក្នុងការរក្សាឯកសារ កំណត់ត្រា ឬព័ត៌មានស្របតាមកថាខណ្ឌ១ មិនរាប់បញ្ចូលព័ត៌មានណាមួយ សម្រាប់តែធ្វើការបញ្ជូនឬទទួលសារនោះឡើយ។

**មាត្រា១១ .- លក្ខខណ្ឌតម្រូវស្តីពីភស្តុតាង**

គ្មានបទប្បញ្ញត្តិណាមួយក្នុងការអនុវត្តវិធានស្តីពីភស្តុតាង អាចជំទាស់ការទទួលយកទំនាក់ទំនងអេឡិចត្រូនិកជាភស្តុតាង ដោយគ្រាន់តែឈរលើមូលដ្ឋានដែលថា៖

ក. ភស្តុតាងនោះជាទំនាក់ទំនងអេឡិចត្រូនិក ឬ

ខ. ភស្តុតាងនោះមិនស្ថិតក្នុងទម្រង់ដើម។

**មាត្រា១២ .- ការបង្កើតកិច្ចសន្យានិងសុពលភាពកិច្ចសន្យា**

១. សំណើ ស្នើការ និងកិច្ចសន្យា អាចធ្វើឡើងតាមមធ្យោបាយអេឡិចត្រូនិកបាន។

២. កិច្ចសន្យាក្នុងទម្រង់អេឡិចត្រូនិកដូចមានចែងក្នុងកថាខណ្ឌ(១) មានសុពលភាព អានុភាពគតិយុត្ត និងភាពអាចអនុវត្តបាន នៅពេលដែលសំណើនិងស្នើការត្រូវគ្នា។

**មាត្រា១៣ .- អានុភាពរវាងគូភាគី**

អ្នកផ្ញើនិងអ្នកទទួលនៃទំនាក់ទំនងអេឡិចត្រូនិក មិនត្រូវបដិសេធអានុភាពគតិយុត្ត សុពលភាព និងភាពអាចអនុវត្តបាននៃការបង្ហាញឆន្ទៈ ឬសេចក្តីថ្លែងផ្សេងៗរបស់ខ្លួនឡើយ។

**មាត្រា១៤ .- ការអនុវត្តដោយឡែកតាមការព្រមព្រៀងរបស់គូភាគី**

១. តាមការព្រមព្រៀង គូភាគីដែលចូលរួមក្នុងការបង្កើត ការផ្ញើ ការទទួល ការរក្សាទុក ឬ ដំណើរការទំនាក់ទំនងអេឡិចត្រូនិក អាចអនុវត្តផ្សេងពីបទប្បញ្ញត្តិដូចមានចែងនៅក្នុងជំពូកទី២ នៃច្បាប់នេះ លើកលែងតែមានការកំណត់ផ្សេងពីនេះ។

២. ទោះជាមានបញ្ញត្តិដូចមានចែងក្នុងជំពូក២ គូភាគីនៃកិច្ចសន្យា ឬប្រតិបត្តិការណាមួយ អាច៖

ក. មិនប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិក ទំនាក់ទំនងអេឡិចត្រូនិក ឬហត្ថលេខា អេឡិចត្រូនិកក្នុងកិច្ចសន្យា ឬ ប្រតិបត្តិការណាមួយតាមការព្រមព្រៀងគ្នា។ ឬ

ខ. ដាក់លក្ខខណ្ឌតម្រូវបន្ថែមផ្សេងៗដែលពាក់ព័ន្ធនឹងទម្រង់ ឬយថាភូតភាពនៃកិច្ចសន្យា ឬប្រតិបត្តិការតាមការព្រមព្រៀងគ្នា។

## ជំពូកទី៣
## ដំណើរការនៃទំនាក់ទំនងអេឡិចត្រូនិក

**មាត្រា១៥ .- ពេលវេលានិងទីកន្លែងនៃការបញ្ជូនចេញនិងការទទួលព័ត៌មានក្នុងទំនាក់ទំនង អេឡិចត្រូនិក**

១. ព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិកមួយត្រូវចាត់ទុកថា បានបញ្ជូនចេញនៅពេលដែល៖

ក.ព័ត៌មាននោះ បានចាកចេញពីប្រព័ន្ធព័ត៌មានដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ អ្នកផ្ញើឬរបស់ភាគីដែលផ្ញើជំនួសក្នុងនាមអ្នកផ្ញើ។ ឬ

ខ.ក្នុងករណីដែលព័ត៌មាននោះ ត្រូវបានបញ្ជូនតែមិនទាន់បានចាកចេញពីប្រព័ន្ធ ព័ត៌មានដែលស្ថិតក្រោមការគ្រប់គ្រងរបស់អ្នកផ្ញើឬរបស់ភាគីដែលផ្ញើជំនួសព័ត៌មាន ត្រូវចាត់ទុកថា បានបញ្ជូនចេញនៅពេលដែលព័ត៌មាននោះត្រូវបានទទួលក្នុងពេល ណាមួយ។

២. ព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិកមួយត្រូវបានសន្មតថាបានបញ្ជូនចេញពីទីតាំងអាជីវកម្មរបស់អ្នកផ្ញើ ទោះបីព័ត៌មាននោះត្រូវបានផ្ញើចេញពីទីតាំងណាក៏ដោយ។

៣. ពេលវេលានៃការទទួលព័ត៌មានគឺពេលដែលព័ត៌មាននោះ អាចទាញយកបានដោយអ្នកទទួលនៅក្នុងអាសយដ្ឋានអេឡិចត្រូនិកដែលអ្នកទទួលបានបញ្ជាក់ជាមុន។ ព័ត៌មានត្រូវបានសន្មតថាបានទទួលនៅទីកន្លែងដែលជាទីតាំងអាជីវកម្មរបស់អ្នកទទួល។

៤. ប្រសិនបើអាសយដ្ឋានអេឡិចត្រូនិកមិនត្រូវបានផ្តល់ដោយអ្នកទទួល នោះពេលវេលាទទួលបានព័ត៌មាន គឺជាពេលវេលាដែលអ្នកទទួលបានដឹងអំពីការផ្ញើចេញនិងអាចទាញយកព័ត៌មាននោះ តាមរយៈអាសយដ្ឋានអេឡិចត្រូនិកណាមួយ ហើយសន្មតថាបានទទួលនៅទីកន្លែងដែលជាទីតាំងអាជីវកម្មរបស់អ្នកទទួល។

៥. ប្រសិនបើអាសយដ្ឋានអេឡិចត្រូនិកត្រូវបានផ្តល់ដោយអ្នកទទួល ព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិកត្រូវបានសន្មតថាបានទទួលនៅពេលព័ត៌មាននោះបានទៅដល់អាសយដ្ឋានអេឡិចត្រូនិករបស់អ្នកទទួល ហើយត្រូវបានចាត់ទុកថាបានទទួលនៅទីកន្លែងដែលជាទីតាំងអាជីវកម្មរបស់អ្នកទទួល។

## មាត្រា១៦ .- សំណើបង្កើតកិច្ចសន្យា

រាល់ការស្នើសុំចុះកិច្ចសន្យា តាមរយៈទំនាក់ទំនងអេឡិចត្រូនិកដែលមិនសំដៅតែដល់បុគ្គលណាមួយជាក់លាក់ផ្សេងទៀត ត្រូវបានចាត់ទុកថាជាការអញ្ជើញឲ្យធ្វើសំណើបង្កើតកិច្ចសន្យាតែប៉ុណ្ណោះ។ ការស្នើសុំចុះកិច្ចសន្យានោះ នឹងត្រូវចាត់ទុកថាជាសំណើបង្កើតកិច្ចសន្យា ប្រសិនបើការស្នើសុំនោះបានបង្ហាញឲ្យឃើញច្បាស់អំពីឆន្ទៈរបស់ខ្លួនថានឹងត្រូវជាប់កាតព្វកិច្ចនៅពេលមានស្វីការពីភាគីម្ខាងទៀត។

## មាត្រា១៧ .- ការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តសម្រាប់បង្កើតកិច្ចសន្យា

កិច្ចសន្យាដែលបង្កើតឡើងដោយអន្តរកម្មរវាងប្រព័ន្ធស្វ័យប្រវត្តនៃបុគ្គលមួយ ជាមួយរូបវន្តបុគ្គលណាមួយឬជាមួយប្រព័ន្ធស្វ័យប្រវត្តនៃបុគ្គលផ្សេងទៀត មិនអាចត្រូវបាន បដិសេធអំពីសុពលភាព អានុភាពគតិយុត្ត ឬភាពអាចអនុវត្តបាននៃកិច្ចសន្យានោះឡើយ ដោយសម្អាងលើហេតុផលអវត្តមាននៃរូបវន្តបុគ្គលក្នុងការពិនិត្យឬក្នុងការចូលធ្វើសកម្មភាពដោយផ្ទាល់ ក្នុងប្រព័ន្ធស្វ័យប្រវត្តឬក្នុងការបង្កើតកិច្ចសន្យា។

## មាត្រា១៨ .- កំហុសឆ្គងនៃការបញ្ចូលព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិក

នៅពេលដែលបុគ្គលបញ្ចូលព័ត៌មានខុសនៅក្នុងទំនាក់ទំនងអេឡិចត្រូនិកជាមួយប្រព័ន្ធស្វ័យប្រវត្តរបស់ភាគីម្ខាងទៀត ហើយប្រព័ន្ធស្វ័យប្រវត្តនេះមិនផ្តល់ឱកាសឲ្យបុគ្គលនោះធ្វើការកែប្រែនូវព័ត៌មានដែលខុស បុគ្គលឬភាគីដែលជំនួសមុខឲ្យបុគ្គលដែលបញ្ចូលព័ត៌មាននោះ

មានសិទ្ធិកែតម្រូវ ឬដកចេញនូវព័ត៌មានដែលខុសនោះបាន ក្នុងករណី៖

១. បុគ្គលនោះបានជូនដំណឹងទៅភាគីម្ខាងទៀតអំពីកំហុសដែលបានកើតឡើងឲ្យបានឆាប់បំផុត ហើយត្រូវបង្ហាញថាខ្លួនបានបញ្ចូលព័ត៌មានខុសនៅក្នុងទំនាក់ទំនងអេឡិចត្រូនិក។

២. បុគ្គលនោះមិនទទួលបានផលប្រយោជន៍ណាមួយ ដោយសារការបញ្ចូលព័ត៌មានខុសនេះ មុនពេលដែលខ្លួនធ្វើការជូនដំណឹងទៅឲ្យភាគីម្ខាងទៀត ហើយមិនបង្កការខូចខាតដល់ផលប្រយោជន៍របស់ភាគីម្ខាងទៀតឬតតិយជនណាមួយ។

បទប្បញ្ញត្តិដែលមានចែងក្នុងមាត្រានេះ មិនអនុវត្តចំពោះវិស័យមូលបត្រឡើយ។

## ជំពូកទី៤
## កំណត់ត្រាអេឡិចត្រូនិកនិងហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព

### មាត្រា១៩ .- កំណត់ត្រាអេឡិចត្រូនិកដែលមានសុវត្ថិភាព

កំណត់ត្រាអេឡិចត្រូនិកមួយត្រូវបានចាត់ទុកថាជាកំណត់ត្រាអេឡិចត្រូនិកដែលមានសុវត្ថិភាព លុះត្រាតែបានអនុវត្តស្របតាមនីតិវិធីសុវត្ថិភាពត្រឹមត្រូវ ដែលធានាបានថាកំណត់ត្រាអេឡិចត្រូនិកនោះ មិនត្រូវបានកែប្រែ គិតចាប់ពីពេលវេលាកំណត់ជាក់លាក់ណាមួយរហូតដល់ពេលធ្វើការពិនិត្យផ្ទៀងផ្ទាត់។

### មាត្រា២០ .- ហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព

១. ហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព~~និងអាចជឿជាក់បាន~~ លុះត្រាតែគោរពទៅតាមលក្ខខណ្ឌខាងក្រោម៖

ក. ផ្សារភ្ជាប់ទៅកាន់ហត្ថលេខីតែម្នាក់គត់។

ខ. កំណត់បានអត្តសញ្ញាណរបស់ហត្ថលេខី។

គ. ត្រូវបានបង្កើតឡើងដោយប្រើប្រាស់មធ្យោបាយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ហត្ថលេខី។

ឃ. បញ្ជាក់អំពីពេលវេលានិងកាលបរិច្ឆេទនៃការចុះហត្ថលេខា។

ង. បញ្ជាក់អំពីស្ថានភាពដើមនៃសារ ឬកំណត់ត្រាអេឡិចត្រូនិកដែលត្រូវបានផ្សារភ្ជាប់ដោយហត្ថលេខានោះ។

២. កថាខណ្ឌ១ខាងលើ មិនកម្រិតលទ្ធភាពរបស់បុគ្គលណាមួយក្នុងទំនាក់ទំនងអេឡិចត្រូនិកឡើយ ក្នុងការ៖

ក. កំណត់លក្ខខណ្ឌបន្ថែមផ្សេងទៀតពាក់ព័ន្ធនឹងភាពអាចជឿជាក់បានរបស់ហត្ថលេខាអេឡិចត្រូនិក ឬ

ខ. លើកភស្តុតាងអំពីភាពមិនអាចជឿជាក់បាននៃហត្ថលេខាអេឡិចត្រូនិក។

**មាត្រា២១ .- ការសន្មតទាក់ទងនឹងកំណត់ត្រានិងហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព**

១. លើកលែងតែមានភស្តុតាងផ្ទុយ ក្នុងដំណើរការដែលពាក់ព័ន្ធនឹងកំណត់ត្រាអេឡិចត្រូនិកដែលមានសុវត្ថិភាព កំណត់ត្រាអេឡិចត្រូនិកដែលមានសុវត្ថិភាពត្រូវបានសន្មតថាជាកំណត់ត្រាអេឡិចត្រូនិកដែលមិនត្រូវបានកែប្រែចាប់តាំងពីពេលជាក់លាក់ណាមួយ។

២. លើកលែងតែមានភស្តុតាងផ្ទុយ ក្នុងដំណើរការពាក់ព័ន្ធនឹងហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព ហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាពត្រូវបានសន្មតដូចខាងក្រោម៖

- ក. ហត្ថលេខាអេឡិចត្រូនិកនោះ គឺជាហត្ថលេខារបស់ បុគ្គលពាក់ព័ន្ធ និង
- ខ. ហត្ថលេខាអេឡិចត្រូនិកនោះ ត្រូវបានចុះហត្ថលេខាដោយបុគ្គលមានឆន្ទៈក្នុងការចុះហត្ថលេខា ឬបានឯកភាពលើកំណត់ត្រាអេឡិចត្រូនិកនោះ។

៣. ក្នុងករណីដែលគ្មានកំណត់ត្រាអេឡិចត្រូនិកសុវត្ថិភាព ឬហត្ថលេខាអេឡិចត្រូនិកសុវត្ថិភាព គ្មានបទប្បញ្ញត្តិណាមួយនៅក្នុងជំពូកទី៤ អាចសន្មតបានជាមុនអំពីយថាភូតភាព ឬសុក្រិតភាពនៃកំណត់ត្រាអេឡិចត្រូនិក ឬហត្ថលេខាអេឡិចត្រូនិកនោះឡើយ។

**មាត្រា២២ .- ស្ថាប័នមានសមត្ថកិច្ចគ្រប់គ្រងនីតិវិធីសុវត្ថិភាព**

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រងនីតិវិធីសុវត្ថិភាព សម្រាប់កំណត់ត្រាអេឡិចត្រូនិកនិងហត្ថលេខាអេឡិចត្រូនិក។

ការគ្រប់គ្រងនីតិវិធីសុវត្ថិភាពសម្រាប់កំណត់ត្រាអេឡិចត្រូនិកនិងហត្ថលេខាអេឡិចត្រូនិកត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត។

## ជំពូកទី៥
## អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

**មាត្រា២៣ .- ការទទួលខុសត្រូវរបស់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

១. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនទទួលខុសត្រូវផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌពាក់ព័ន្ធនឹងព័ត៌មានដែលមានក្នុងកំណត់ត្រាអេឡិចត្រូនិកដែលពាក់ព័ន្ធនឹងការផ្តល់សេវារបស់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនោះឡើយ ក្នុងករណីដែលខ្លួនមិនមែនជាអ្នកផ្ញើកំណត់ត្រានោះនិងក្នុងករណីដែល៖

- ក. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនោះមិនបានដឹងថាព័ត៌មានដែលបានផ្ញើនោះបង្កឲ្យមានការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌឬ
- ខ. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនោះមិនបានដឹងអំពីអង្គហេតុឬកាលៈទេសៈដែលអាចឲ្យស្មានទុកថាព័ត៌មាននោះអាចបង្កឲ្យមានការទទួល ខុសត្រូវផ្នែក រដ្ឋប្បវេណី ឬព្រហ្មទណ្ឌ ឬ

គ. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានដឹងនាពេលក្រោយថាព័ត៌មាន ឬអង្គហេតុ ឬកាលៈទេសៈដែលអាចឲ្យស្មានទុកថា ព័ត៌មាននោះអាចបង្កឲ្យមានការទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណី ឬព្រហ្មទណ្ឌ ហើយបានអនុវត្តតាមនីតិវិធីចំពោះព័ត៌មានខុសច្បាប់ និងការបរិហាកេរ្តិ៍ដូចមានចែងក្នុងមាត្រា២៤ ខាងក្រោម។

២. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនតម្រូវឲ្យតាមដានត្រួតពិនិត្យកំណត់ត្រាអេឡិចត្រូនិកណាមួយដែលដំណើរការដោយប្រព័ន្ធអេឡិចត្រូនិកដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន ទោះបីជាដំណើរការនៃកំណត់ត្រាអេឡិចត្រូនិកនោះ អាចបង្កើតជាបទល្មើស ឬនាំឲ្យមានការទទួលខុសត្រូវរដ្ឋប្បវេណីនោះឡើយ លើកលែងតែមានការកំណត់ផ្សេងពីនេះ។

៣. បញ្ញត្តិនៃមាត្រានេះមិនត្រូវយកមកអនុវត្តដើម្បីឲ្យអន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករួចផុតពី៖

ក. កាតព្វកិច្ចដែលបង្កើតឡើងដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តនានា ឬ

ខ. កាតព្វកិច្ចអនុលោមតាមបទបញ្ជា ឬសេចក្តីបង្គាប់របស់តុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត ឬ

គ. កាតព្វកិច្ចតាមកិច្ចសន្យា។

**មាត្រា២៤.- នីតិវិធីចំពោះព័ត៌មានខុសច្បាប់និងការបរិហាកេរ្តិ៍**

១. ក្នុងករណីដែលអន្តរការី ឬបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានដឹងថាព័ត៌មានក្នុងកំណត់ត្រាអាចបង្កឲ្យមានការទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌ អន្តរការី ឬបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវចាត់វិធានការជាបន្ទាន់ ដូចខាងក្រោម៖

ក. ដកព័ត៌មានចេញពីប្រព័ន្ធព័ត៌មានដែលស្ថិតក្រោមការគ្រប់គ្រងរបស់អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ហើយឈប់ផ្តល់សេវាពាក់ព័ន្ធនឹងព័ត៌មាននោះ។

ខ. រក្សាទុកព័ត៌មានជាភស្តុតាងនិងជូនដំណឹងដល់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនានាអំពីអង្គហេតុនិងអត្តសញ្ញាណនៃជនសង្ស័យ។

២. ក្នុងករណីដែលអន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដឹងអំពីហេតុការណ៍ណាមួយ ឬស្ថានភាពណាមួយដែលអាចបណ្តាលឲ្យមានការទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌ អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវ៖

ក. អនុវត្តតាមនីតិវិធីដូចមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ឬក្រមនីតិវិធីព្រហ្មទណ្ឌដែលមានជាធរមាន ឬក្រមសីលធម៌ពាក់ព័ន្ធនានា ឬ

ខ. រក្សាទុកព័ត៌មានជាភស្តុតាងនិងជូនដំណឹងដល់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនានា។

៣. នៅពេលបានដឹងឬទទួលដំណឹងពាក់ព័ន្ធនឹងព័ត៌មានក្នុងកំណត់ត្រាអេឡិចត្រូនិក ដែលអាចបង្កឲ្យមានការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ឬក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ អាចបញ្ជាឲ្យអន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក៖

ក. ដកព័ត៌មានចេញពីប្រព័ន្ធព័ត៌មានដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន ឬ

ខ. ផ្អាកឬឈប់ផ្តល់សេវាដល់បុគ្គលនោះ ឬ

គ. ផ្អាកឬឈប់ផ្តល់សេវាពាក់ព័ន្ធនឹងកំណត់ត្រាអេឡិចត្រូនិក។

៤. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មអេឡិចត្រូនិកមិនត្រូវទទួលខុសត្រូវផ្នែករដ្ឋប្បវេណី តាមកិច្ចសន្យាឬក្រៅកិច្ចសន្យា ឬកំណត់ដោយច្បាប់ ចំពោះការអនុវត្តដោយសុទ្ធចិត្តតាមបញ្ជារបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ឬក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

៥. បុគ្គលដែលជូនដំណឹងអំពីសកម្មភាពខុសច្បាប់ទៅដល់អន្តរការីឬបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយដឹងថាការជូនដំណឹងនោះខុសពីការពិតឬមានលក្ខណៈបោកបញ្ឆោត ត្រូវទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌពីអំពើនោះ។

**មាត្រា២៥ .- ក្រមសីលធម៌វិជ្ជាជីវៈនិងបទប្បញ្ញត្តិសម្រាប់ អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាម ប្រព័ន្ធអេឡិចត្រូនិក**

១. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈ និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍និងក្រសួងពាណិជ្ជកម្ម។

២. ក្រមសីលធម៌វិជ្ជាជីវៈ ដែលបានលើកឡើងក្នុងកថាខណ្ឌ១ ត្រូវកំណត់និងរៀបរៀងឡើងដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍និងក្រសួងពាណិជ្ជកម្ម ដោយសហការជាមួយក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ។

**មាត្រា២៦ (ថ្មី).- កាតព្វកិច្ចពន្ធ ការលើកទឹកចិត្ត និងការអនុគ្រោះ**

បុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវស្ថិតនៅក្រោមនីតិរូបនៃរបបសារពើពន្ធជាធរមាន និងទទួលបានការលើកទឹកចិត្តនិងការអនុគ្រោះនានា ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៦
## កិច្ចការពារអ្នកប្រើប្រាស់

### មាត្រា២៧ .- ព័ត៌មានអប្បបរមាក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

១. បុគ្គលដែលប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកដើម្បីលក់ទំនិញឬសេវាទៅឲ្យអ្នកប្រើប្រាស់ត្រូវផ្តល់ព័ត៌មានត្រឹមត្រូវ ច្បាស់លាស់ និងងាយយល់បាន ហើយត្រូវមានព័ត៌មានយ៉ាងតិចដូចខាងក្រោម ៖

ក. ឈ្មោះឬនាមករណ៍ស្របច្បាប់របស់បុគ្គល អាសយដ្ឋានអាជីវកម្មដែលបានចុះបញ្ជី និងមធ្យោបាយអេឡិចត្រូនិកសម្រាប់ទំនាក់ទំនងឬលេខទូរសព្ទ។

ខ. ទម្រង់ទំនាក់ទំនងដែលរហ័ស ងាយស្រួល និងមានប្រសិទ្ធភាពរវាងអ្នកប្រើប្រាស់ជាមួយអ្នកលក់។

គ. ខចែង លក្ខខណ្ឌ និងសោហ៊ុយរបស់ទំនិញឬសេវានានាដែលពាក់ព័ន្ធនឹងប្រតិបត្តិការពាណិជ្ជកម្ម ជាពិសេស ខចែង លក្ខខណ្ឌ និងមធ្យោបាយទូទាត់ប្រាក់ និងព័ត៌មានលម្អិតពាក់ព័ន្ធនឹងការដក ឬលុបចោលការបញ្ជាទិញ ការបញ្ឈប់ ការប្រគល់ និងការប្តូរទំនិញ និងការសងប្រាក់មកវិញ។ និង

ឃ. ទំនិញនិងសេវាជាក់ស្តែងដែលដាក់លក់។

២. ព័ត៌មានដែលមានចែងក្នុងកថាខណ្ឌ១ខាងលើ ចាំបាច់ត្រូវមានលក្ខណៈគ្រប់គ្រាន់ដើម្បីឲ្យអ្នកប្រើប្រាស់អាចធ្វើការសម្រេចចិត្តលើប្រតិបត្តិការពាណិជ្ជកម្មនិងរក្សាទុកជាព័ត៌មាន។

បទប្បញ្ញត្តិនៃមាត្រានេះមិនយកមកអនុវត្តចំពោះវិស័យមូលបត្រ និងធានារ៉ាប់រងឡើយ។

### មាត្រា២៨ .- ទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំ

បុគ្គលណាក៏ដោយ ទោះបីជាមានទីតាំងអាជីវកម្មក្នុងឬក្រៅព្រះរាជាណាចក្រកម្ពុជាដែលផ្ញើទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំទៅកាន់អ្នកប្រើប្រាស់ដែលស្ថិតនៅក្នុងឬក្រៅព្រះរាជាណាចក្រកម្ពុជា តាមរយៈប្រព័ន្ធផ្សព្វផ្សាយ ឬតាមរយៈអន្តរការី ឬអ្នកផ្តល់សេវាទូរគមនាគមន៍ ត្រូវផ្តល់ជម្រើសច្បាស់លាស់និងងាយស្រួលសម្រាប់ឲ្យអ្នកប្រើប្រាស់អាចធ្វើការបដិសេធមិនទទួលយកទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំនោះ។

### មាត្រា២៩ .- ការការពារទិន្នន័យ

បុគ្គលណាដែលរក្សាព័ត៌មានជាលក្ខណៈឯកជនក្រោមទម្រង់អេឡិចត្រូនិក ត្រូវធានាថា៖

១- ព័ត៌មាននោះត្រូវបានការពារប្រកបដោយសុវត្ថិភាពគ្រប់កាលៈទេសៈសមហេតុផលដើម្បីជៀសវាង៖

ក- ការបាត់បង់ និង

ខ- ការចូល ការប្រើប្រាស់ ការកែប្រែ ការបែកធ្លាយ ឬការលាតត្រដាងព័ត៌មានទាំង

នោះ លើកលែងតែមានការអនុញ្ញាតពីម្ចាស់នៃព័ត៌មាននោះឬពីភាគីផ្សេងទៀតដែលអនុញ្ញាតដោយច្បាប់។

២- បុគ្គលដែលរក្សាព័ត៌មាននោះត្រូវប្រើគ្រប់មធ្យោបាយក្នុងការការពារសុវត្ថិភាពព័ត៌មានដែលផ្តល់ឲ្យតតីយជនស្របតាមចំណុចខ នៃកថាខណ្ឌទី១ខាងលើ ដើម្បីជៀសវាងការប្រើប្រាស់ ឬការលាតត្រដាងព័ត៌មានដោយគ្មានការអនុញ្ញាត ឬលើសពីការអនុញ្ញាត។

៣. បុគ្គលទាំងឡាយមិនត្រូវចូលប្រើប្រាស់ ទាញយក ថតចម្លង ស្រង់យក ឬធ្វើឲ្យបែកធ្លាយទិន្នន័យ ដែលស្ថិតក្រោមការរក្សាទុករបស់បុគ្គលផ្សេងទៀត ដោយទុច្ចរិត ឬគ្មានការអនុញ្ញាតិឡើយ។

**មាត្រា៣០ .- ការអនុវត្តបទប្បញ្ញត្តិទាក់ទងនឹងកិច្ចការពារអ្នកប្រើប្រាស់**

បុគ្គលដែលប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកក្នុងសកម្មភាពពាណិជ្ជកម្មជាមួយអ្នកប្រើប្រាស់ ក៏ត្រូវអនុវត្តតាមបទប្បញ្ញត្តិនានាទាក់ទងនឹងកិច្ចការពារអ្នកប្រើប្រាស់ផងដែរ។

## ជំពូកទី៧
## សកម្មភាពនិងប្រតិបត្តិការរបស់រដ្ឋតាមប្រព័ន្ធអេឡិចត្រូនិក

**មាត្រា៣១ .- ការទទួលស្គាល់ទំនាក់ទំនងអេឡិចត្រូនិកដោយស្ថាប័នរដ្ឋ**

១- ក្រសួងឬស្ថាប័នរដ្ឋនានាអាចប្រើប្រាស់ទម្រង់អេឡិចត្រូនិកសម្រាប់សកម្មភាពដូចខាងក្រោម៖

ក- ការទទួលចុះបញ្ជីឯកសារ ឬការបំពេញលក្ខខណ្ឌតម្រូវ សម្រាប់បង្កើតឬរក្សាទុកឯកសារ។

ខ- ការចេញអាជ្ញាបណ្ណឬលិខិតអនុញ្ញាត។

គ- ការកំណត់មធ្យោបាយនិងរបៀបក្នុងការទូទាត់ប្រាក់ ឬ

ឃ- សកម្មភាពផ្សេងទៀតដែលកំណត់ដោយក្រសួង ឬស្ថាប័នរដ្ឋ។

២- នៅពេលដែល ក្រសួង ឬស្ថាប័នរដ្ឋសម្រេចប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកសម្រាប់សកម្មភាព ឬប្រតិបត្តិការណាមួយ ដូចមានចែងក្នុងកថាខណ្ឌ១ខាងលើ ក្រសួងឬស្ថាប័ននោះអាចបញ្ជាក់៖

ក- របៀបនិងទម្រង់ដែលព័ត៌មានក្នុងទំនាក់ទំនងអេឡិចត្រូនិក ត្រូវទទួលចុះបញ្ជី បង្កើត រក្សាទុក ឬបោះផ្សាយ។

ខ- ប្រភេទនៃហត្ថលេខាដែលតម្រូវឲ្យធ្វើនៅពេលដែលមានការតម្រូវឲ្យចុះហត្ថលេខាក្នុងទំនាក់ទំនងអេឡិចត្រូនិកនោះ។

គ- របៀបនិងទម្រង់ដែលហត្ថលេខានោះត្រូវភ្ជាប់ក្នុងទំនាក់ទំនងអេឡិចត្រូនិក។

ឃ- ដំណើការគ្រប់គ្រងនិងនីតិវិធីដែលសមស្របដើម្បីធានាសុក្រឹតភាព សុវត្ថិភាព និងការរក្សាការសម្ងាត់នៃទំនាក់ទំនងអេឡិចត្រូនិក ឬការទូទាត់ប្រាក់ និង

ង- លក្ខខណ្ឌកំណត់ផ្សេងទៀតដែលផ្តល់តម្លៃសមមូលរវាងឯកសារ ឬការទូទាត់ក្នុងទម្រង់អេឡិចត្រូនិក ជាមួយនឹងឯកសារ ឬការទូទាត់ក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ។

## ជំពូកទី៨
## ភស្តុតាងអេឡិចត្រូនិក

### មាត្រា៣២ .- ការទទួលយកជាទូទៅនូវភស្តុតាងអេឡិចត្រូនិក

គ្មានបទប្បញ្ញត្តិនៃវិធានស្តីពីភស្តុតាងណាមួយដែលយកមកអនុវត្ត ដើម្បីបដិសេធក្នុងការទទួលយកជាទូទៅនូវកំណត់ត្រាអេឡិចត្រូនិកធ្វើជាភស្តុតាង ដោយហេតុផលគ្រាន់តែសម្អាងលើមូលដ្ឋានថា វាជាកំណត់ត្រាអេឡិចត្រូនិកនោះឡើយ ទោះបីជាភស្តុតាងនោះមិនស្ថិតក្នុងទម្រង់ដើមក៏ដោយ។

### មាត្រា៣៣ .- សុក្រឹតភាពនៃប្រព័ន្ធអេឡិចត្រូនិក

១- នៅក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ សុពលភាពនៃភស្តុតាងអេឡិចត្រូនិកអាចត្រូវបានបញ្ជាក់តាមរយៈសុក្រឹតភាពនៃប្រព័ន្ធអេឡិចត្រូនិក ដែលបានកត់ត្រាឬរក្សាទុកនូវទិន្នន័យណាមួយ។

២- លើកលែងតែមានភស្តុតាងផ្ទុយ ប្រព័ន្ធអេឡិចត្រូនិកដែលបានប្រើប្រាស់សម្រាប់កត់ត្រាឬរក្សាទុកកំណត់ត្រាអេឡិចត្រូនិក ត្រូវបានសន្មតថាមានសុក្រឹតភាព ក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ តាមលក្ខខណ្ឌណាមួយដូចខាងក្រោម៖

ក- ក្នុងករណីមានភស្តុតាងគាំទ្រដល់អង្គហេតុណាមួយដែលបញ្ជាក់ថាប្រព័ន្ធអេឡិចត្រូនិក ឬឧបករណ៍ស្រដៀងគ្នាផ្សេងទៀត បានដំណើរការជាប្រក្រតីនៅពេលដែលកំណត់ត្រាអេឡិចត្រូនិកនោះត្រូវបានកត់ត្រាឬរក្សាទុកឬនៅពេលដែលយកទៅធ្វើជាភស្តុតាង ឬក្នុងករណីដែលប្រព័ន្ធអេឡិចត្រូនិក ឬឧបករណ៍ស្រដៀងគ្នាផ្សេងទៀតនោះមិនបានដំណើរការជាប្រក្រតី ឬឈប់ដំណើរការទាំងស្រុង ប៉ុន្តែមិនធ្វើឲ្យប៉ះពាល់ដល់សុក្រឹតភាពនៃកំណត់ត្រាអេឡិចត្រូនិក ហើយគ្មានមូលហេតុសមស្របណាផ្សេងយកមកជំទាស់សុក្រឹតភាពនៃកំណត់ត្រានោះ ឬ

ខ- ក្នុងករណីមានភស្តុតាងអាចបង្ហាញបានថា កំណត់ត្រាអេឡិចត្រូនិកត្រូវបានកត់ត្រាឬរក្សាទុក ដោយភាគីដែលមានផលប្រយោជន៍ផ្ទុយគ្នាទៅនឹងភាគីម្ខាងទៀតដែលប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិកនោះជាភស្តុតាងក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ ឬ

គ- នៅពេលដែលមានភស្តុតាងអាចបង្ហាញបានថា កំណត់ត្រាអេឡិចត្រូនិកត្រូវបានកត់ត្រាឬរក្សាទុកជាប្រក្រតីក្នុងគោលបំណងអាជីវកម្មធម្មតាដោយបុគ្គលដែលមិនមែនជាភាគីក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ ហើយបុគ្គលនោះមិនបាន

កត់ត្រាឬរក្សាទុកនូវកំណត់ត្រាអេឡិចត្រូនិកក្រោមការគ្រប់គ្រងរបស់ភាគីដែលប្រើប្រាស់ កំណត់ត្រាអេឡិចត្រូនិកនោះជាភស្តុតាងក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់។

**មាត្រា៣៤ .. សុក្រឹតភាពនៃព័ត៌មាន**

១- លើកលែងតែមានភស្តុតាងផ្ទុយពីនេះ កំណត់ត្រាអេឡិចត្រូនិកដែលបានកត់ត្រាឬរក្សាទុកនៅក្នុងប្រព័ន្ធអេឡិចត្រូនិក ត្រូវបានសន្មតថាមានសុក្រឹតភាពនៅក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ ប្រសិនបើកំណត់ត្រាអេឡិចត្រូនិកនោះ៖

ក- នៅពេញលេញនិងគ្មានការកែប្រែក្រៅពីការធ្វើបដិលេខបន្ថែមណាមួយ ឬការផ្លាស់ប្តូរដែលមិនសំខាន់ណាមួយដែលកើតឡើងនៅក្នុងដំណើរការជាប្រក្រតីនៃទំនាក់ទំនង ការរក្សាទុក ឬការបង្ហាញ។

ខ- ត្រូវបានបញ្ជាក់ ឬចុះហត្ថលេខានៅក្នុងទម្រង់អេឡិចត្រូនិក តាមរយៈមធ្យោបាយដែលផ្តល់ឲ្យដោយអ្នកផ្តល់នីតិវិធីសុវត្ថិភាពដែលមានអាជ្ញាបណ្ណត្រឹមត្រូវ។

គ- មានសុក្រឹតភាពនិងមានខ្លឹមសារដែលត្រូវបានបញ្ជាក់ដោយក្រសួងឬស្ថាប័នមានសមត្ថកិច្ច។

ឃ- ត្រូវបានកត់ត្រាទុកនៅក្នុងឧបករណ៍រក្សាទុក ឬតាមមធ្យោបាយអេឡិចត្រូនិកផ្សេងទៀតដែលមិនអនុញ្ញាតឲ្យមានការកែប្រែទៅលើកំណត់ត្រាអេឡិចត្រូនិក។

ង- ត្រូវបានត្រួតពិនិត្យនិងបញ្ជាក់ពីសុក្រឹតភាព ដោយអ្នកជំនាញដែលត្រូវបានតែងតាំងដោយតុលាការ។

ច- នៅពេលដែលមានភស្តុតាងគាំទ្រដល់អង្គហេតុណាមួយ ដែលបញ្ជាក់ថាប្រព័ន្ធអេឡិចត្រូនិក ឬឧបករណ៍ស្រដៀងគ្នាផ្សេងទៀត បានដំណើរការជាប្រក្រតីនៅគ្រប់រយៈពេលសំខាន់ៗ ឬក្នុងករណីដែលប្រព័ន្ធអេឡិចត្រូនិក ឬឧបករណ៍ស្រដៀងគ្នាផ្សេងទៀតនោះមិនបានដំណើរការជាប្រក្រតី ឬឈប់ដំណើរការទាំងស្រុង តែសុក្រឹតភាពនៃកំណត់ត្រា មិនរងការប៉ះពាល់ដោយសារស្ថានភាពទាំងនោះទេ ហើយគ្មានមូលហេតុសមស្របណាផ្សេងទៀតដែលចោទជាមន្ទិលសង្ស័យលើសុក្រឹតភាពនៃកំណត់ត្រានោះឡើយ ឬ

ឆ- នៅពេលដែលមានភស្តុតាងអាចបង្ហាញបានថា កំណត់ត្រាអេឡិចត្រូនិកត្រូវបានកត់ត្រាឬរក្សាទុក ដោយភាគីដែលចូលរួមនៅក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់នោះ ហើយដែលភាគីមានទំនាស់ផលប្រយោជន៍ផ្ទុយគ្នា ទៅនឹងភាគីម្ខាងទៀត ដែលមានបំណងប្រើប្រាស់កំណត់ត្រាអេឡិចត្រូនិកនោះឬ

២- នៅពេលដែលមានភស្តុតាងអាចបង្ហាញបានថា កំណត់ត្រាអេឡិចត្រូនិកត្រូវបានកត់ត្រាឬរក្សាទុកតាមធម្មតា និងក្នុងគោលបំណងអាជីវកម្មធម្មតា ដោយបុគ្គលដែលមិនមែនជា ភាគី

នៅក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ ហើយបុគ្គលនោះមិនបានកត់ត្រាឬរក្សាទុកនូវកំណត់ត្រាអេឡិចត្រូនិក ក្រោមការគ្រប់គ្រងរបស់ភាគីដែលមានបំណងប្រើប្រាស់កំណត់ត្រា អេឡិចត្រូនិកនោះ។

៣- នៅពេលដែលរបាយការណ៍ ត្រូវបានកត់ត្រាទុកនៅក្នុងកំណត់ត្រាអេឡិចត្រូនិក ដែលត្រូវបានបង្កើតឡើងដោយប្រព័ន្ធអេឡិចត្រូនិក មិនត្រូវបានចាត់ទុកថាជាពាក្យចចាមអារ៉ាមទេនោះ របាយការណ៍ទាំងនោះអាចទទួលយកបាន ប្រសិនបើលក្ខខណ្ឌ ដូចដែលមានចែងនៅក្នុងកថាខណ្ឌ២ ទាក់ទងនឹងកំណត់ត្រាអេឡិចត្រូនិកនោះត្រូវបានបំពេញ។

**មាត្រា៣៥ .- ឯកសារដែលបានបោះពុម្ពចេញ**

ឯកសារដែលបានបោះពុម្ពត្រឹមត្រូវស្របនឹងខ្លឹមសារដើមចេញពីកំណត់ត្រាអេឡិចត្រូនិក អាចយកមកប្រើប្រាស់ជាភស្តុតាងបានក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់។

**មាត្រា៣៦ .- បន្ទុកក្នុងការបង្ហាញអំពីយថាភូតភាពនៃភស្តុតាងអេឡិចត្រូនិក**

១- បុគ្គលដែលស្នើសុំបង្ហាញកំណត់ត្រាអេឡិចត្រូនិកក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ណាមួយ បុគ្គលនោះត្រូវទទួលបន្ទុកបង្ហាញពីយថាភូតភាពនៃកំណត់ត្រាអេឡិចត្រូនិកដោយមានភស្តុតាងគាំទ្រដល់កំណត់ត្រាដែលបានបង្ហាញ។

២- ក្នុងករណីមានបទប្បញ្ញត្តិណាមួយការពារបុគ្គលងាយរងគ្រោះដែលរាប់បញ្ចូលទាំងអ្នកប្រើប្រាស់និងកុមារ ហើយដែលមានកំណត់អំពីបន្ទុកនៃការបង្ហាញភស្តុតាងដែលផ្តល់ប្រយោជន៍ដល់បុគ្គលទាំងនោះច្រើនជាងច្បាប់នេះ បទប្បញ្ញត្តិនោះត្រូវមានអាទិភាពជាងមាត្រានេះ។

**មាត្រា៣៧ .- បទដ្ឋាននៃការកត់ត្រាឬការរក្សាទុកកំណត់ត្រាអេឡិចត្រូនិក**

ដើម្បីកំណត់បានថា កំណត់ត្រាអេឡិចត្រូនិកត្រូវទទួលយក ឬមិនទទួលយកក្នុងបទប្បញ្ញត្តិផ្សេងទៀត ការបង្ហាញភស្តុតាងអាចត្រូវធ្វើឡើងដោយផ្អែកលើបទដ្ឋាន នីតិវិធី ការប្រើ ឬការអនុវត្តនៃការកត់ត្រា ឬរក្សាទុកកំណត់ត្រាអេឡិចត្រូនិក ដោយត្រូវពិនិត្យពិចារណាអំពីប្រភេទអាជីវកម្ម ចរិតលក្ខណៈ និងគោលបំណងនៃកំណត់ត្រាអេឡិចត្រូនិកនោះ។

**មាត្រា៣៨ .- ការចេញលិខិតបញ្ជាក់យថាភូតភាព**

១. ក្នុងករណីដែលបុគ្គលណាមួយមានបំណងចង់បង្ហាញយថាភូតភាពនៃកំណត់ត្រាអេឡិចត្រូនិកមួយដើម្បីធ្វើជាភស្តុតាង បុគ្គលនោះអាចស្នើសុំភស្តុតាងនោះពីអ្នកជំនាញពាក់ព័ន្ធនឹងយថាភូតភាពនៃកំណត់ត្រាអេឡិចត្រូនិកនោះក្រោមទម្រង់ជាលិខិតបញ្ជាក់។

២. លិខិតបញ្ជាក់យថាភូតភាពដូចមានចែងក្នុងកថាខណ្ឌ១ ត្រូវចេញដោយ៖

ក. ក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬបុគ្គលដែលទទួលខុសត្រូវពាក់ព័ន្ធនឹងប្រតិបត្តិការឬការគ្រប់គ្រងអ្នកបង្កើតនីតិវិធីសុវត្ថិភាពជាក់លាក់ណាមួយ ឬអ្នកបង្កើតនីតិវិធីសុវត្ថិភាពដែលទទួលស្គាល់ដោយតុលាការ ឬ

ខ- អ្នកជំនាញដែលតែងតាំងឬដែលទទួលស្គាល់ដោយតុលាការ។

**មាត្រា៣៩ .- នីតិវិធីផ្សេងទៀតក្នុងការបង្កើតភស្តុតាងអេឡិចត្រូនិក**

បន្ថែមលើមធ្យោបាយបង្ហាញភស្តុតាងដូចមានចែងក្នុងច្បាប់នេះ ភស្តុតាងអេឡិចត្រូនិក អាចត្រូវបានបង្កើតឡើង តាមបច្ចេកទេសនិងនីតិវិធីផ្សេងទៀតដូចជា ការបញ្ជាក់ដោយសារការី ឬស្ថាប័នមានសមត្ថកិច្ច កំណត់ត្រាក្នុងមធ្យោបាយអេឡិចត្រូនិកដែលមិនអនុញ្ញាតឲ្យមានការកែប្រែបាន និងលទ្ធផលកោសល្យវិច្ច័យលើប្រព័ន្ធអេឡិចត្រូនិកតាមការរកឃើញរបស់យុត្តាធិការតុលាការ។

**មាត្រា៤០ .- ការទទួលយកកំណត់ត្រាអេឡិចត្រូនិកពីបរទេស**

ភស្តុតាងអេឡិចត្រូនិកដែលបញ្ជាក់ដោយក្រសួងឬស្ថាប័នមានសមត្ថកិច្ចនៃបណ្តារដ្ឋបរទេស ត្រូវបានទទួលយកជាភស្តុតាង ប្រសិនបើប្រព័ន្ធអេឡិចត្រូនិកដែលកត់ត្រាឬរក្សាទុកកំណត់ត្រាអេឡិចត្រូនិកនោះមានសុក្រឹតភាពស្របតាមបទដ្ឋាន ដូចមានចែងក្នុងជំពូកទី៨នៃច្បាប់នេះ។

**មាត្រា៤១ .- ការទទួលយកព័ត៌មានអេឡិចត្រូនិកមកពីបរទេស**

ដើម្បីកំណត់ថាព័ត៌មានក្នុងទម្រង់អេឡិចត្រូនិកមួយអាចទទួលយកឬមិនអាចទទួលយកបាន ឬអាចទទួលយកបានត្រឹមកម្រិតណាមួយនោះ មិនត្រូវគិតពីទីតាំងដែលព័ត៌មាននោះត្រូវបានបង្កើតឡើងឬត្រូវបានប្រើប្រាស់ ឬទីតាំងអាជីវកម្មដែលបានបង្កើតឡើងនៅបរទេសនោះឡើយ ឲ្យតែកំណត់ត្រាអេឡិចត្រូនិកនោះអាចចូលនិងទាញយកមកប្រើបាននៅក្នុងដែនសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៩
## ការទូទាត់និង/ឬការផ្ទេរប្រាក់តាមអេឡិចត្រូនិក

**មាត្រា៤២ .- ប្រតិបត្តិការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក**

បុគ្គលណាដែលធ្វើប្រតិបត្តិការប្រព័ន្ធទូទាត់ ផ្តល់សេវាទូទាត់ ចេញផ្សាយឧបករណ៍ទូទាត់ជាអេឡិចត្រូនិក ឬផ្តល់មធ្យោបាយទូទាត់ជាអេឡិចត្រូនិក ឬធ្វើប្រតិបត្តិការណាដែលត្រូវបានចាត់ទុកថាជាការផ្តល់ការទូទាត់សងប្រាក់អេឡិចត្រូនិកដល់សាធារណជនត្រូវស្នើសុំការអនុញ្ញាត ឬអាជ្ញាបណ្ណជាមុនពីធនាគារជាតិនៃកម្ពុជា។

ធនាគារជាតិនៃកម្ពុជាជាស្ថាប័នមានសមត្ថកិច្ចក្នុងការរៀបចំបទប្បញ្ញត្តិទាក់ទងនឹងការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក។

**មាត្រា៤៣ ៈ ការទទួលខុសត្រូវរបស់បុគ្គលផ្តល់សេវាទូទាត់**

១- បុគ្គលផ្តល់សេវាទូទាត់មិនត្រូវផ្តល់ជូនអតិថិជននូវឧបករណ៍ទូទាត់ ដែលអតិថិជនមិនបានស្នើសុំនោះទេ លើកលែងតែករណីដែលបណ្ណទូទាត់នោះជាបណ្ណទូទាត់ហួសរយៈពេលប្រើប្រាស់ ឬដល់ពេលត្រូវផ្លាស់ប្តូរ។

២- មុនពេលធ្វើប្រតិបត្តិការផ្ទេរប្រាក់តាមអេឡិចត្រូនិក បុគ្គលផ្តល់សេវាត្រូវបញ្ជាក់ឲ្យបានច្បាស់ពីអត្តសញ្ញាណរបស់អតិថិជននិងផ្ទៀងផ្ទាត់ឡើងវិញនូវភាពត្រឹមត្រូវនៃការផ្ទេរប្រាក់អេឡិចត្រូនិក។ បុគ្គលផ្តល់សេវាទូទាត់ត្រូវទទួលខុសត្រូវលើករណីដូចខាងក្រោមៈ

- ប្រតិបត្តិការកើតឡើងដោយគ្មានការអនុញ្ញាតពីអតិថិជន
- ប្រតិបត្តិការកើតឡើងបន្ទាប់ពីដឹងថាមានការបន្លំ បាត់បង់ ឬចោរកម្មនៃឧបករណ៍ផ្ទេរប្រាក់អេឡិចត្រូនិក
- ប្រតិបត្តិការកើតឡើងបន្ទាប់ពីមានការជូនដំណឹងពីអតិថិជនដូចមានចែងក្នុងមាត្រា៩៣ខាងក្រោម
- ការខកខានមិនបានប្រតិបត្តិតាមបញ្ជារបស់អតិថិជនឬការប្រតិបត្តិខុសពីបញ្ជារបស់អតិថិជន
- ភាពមិនប្រក្រតីនៃប្រព័ន្ធបច្ចេកទេស កំហុសក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកទេស ឬភាពខ្វះខាតនៃឧបករណ៍ផ្ទេរប្រាក់អេឡិចត្រូនិក។

៣- បុគ្គលផ្តល់សេវាទូទាត់អាចរួចផុតពីការទទួលខុសត្រូវបានតែក្នុងករណីប្រធានស័ក្តិ ឬជាកំហុសរបស់អតិថិជនផ្ទាល់ប៉ុណ្ណោះ។

៤- ក្នុងករណីដែលបុគ្គលផ្តល់សេវាទូទាត់ត្រូវទទួលខុសត្រូវ បុគ្គលផ្តល់សេវាទូទាត់ត្រូវសងថ្លៃខូចខាតជូនអតិថិជនក្នុងរយៈពេលមិនឲ្យលើសពី៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលការជូនដំណឹងពីអតិថិជនដូចមានចែងក្នុងមាត្រា៤៣នៃច្បាប់នេះ នូវកម្រៃប្រតិបត្តិការដែលបានខាតបង់សោហ៊ុយ និងការពិន័យក្នុងការបង់ការប្រាក់យឺតយ៉ាវដែលកើតចេញពីប្រតិបត្តិការនេះដោយ មិនទាន់គិតបញ្ចូលការសងថ្លៃខូចខាតដទៃទៀតដែលអាចកើតឡើងចំពោះអតិថិជន។

**មាត្រា៤៤ ៈ ការទទួលខុសត្រូវរបស់អតិថិជន**

១- អតិថិជនត្រូវជូនដំណឹងដល់បុគ្គលផ្តល់សេវាទូទាត់ អំពីប្រតិបត្តិការដែលកើតឡើងដោយគ្មានការអនុញ្ញាត កំហុសឆ្គង ឬភាពមិនត្រឹមត្រូវផ្សេងទៀតនៅក្នុងគណនីរបស់ខ្លួន។

២- អតិថិជនត្រូវជូនដំណឹងដល់បុគ្គលផ្តល់សេវាទូទាត់ ឬគ្រឹះស្ថានដែលទទួលបានការអនុញ្ញាតពីបុគ្គលផ្តល់សេវាទូទាត់ អំពីករណីបាត់បង់ ឬអំពើរចោរកម្មលើឧបករណ៍/ មធ្យោបាយផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ឬការលួចយកទិន្នន័យសម្រាប់ប្រើប្រាស់ជាមួយឧបករណ៍ទូទាត់។ ការជូនដំណឹងនេះអាចធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬតាមមធ្យោបាយអេឡិចត្រូនិកណា

មួយដែលទទួលយកដោយបុគ្គលផ្តល់សេវាទូទាត់ ហើយត្រូវជូនដំណឹងជាបន្ទាន់តាមលទ្ធភាពដែលអាចធ្វើទៅបាន ឬមិនឲ្យលើសរយៈពេល២(ពីរ)ថ្ងៃ បន្ទាប់ពីបានដឹងថាមានករណីចោរកម្ម ឬបាត់បង់ឧបករណ៍ទូទាត់កើតឡើង។

៣- ក្នុងករណីមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ការបាត់បង់ ឬការខូចខាតក្នុងករណីខាងលើជាកំហុសរបស់អតិថិជន បុគ្គលផ្តល់សេវាទូទាត់មានសិទ្ធិទាមទារឲ្យអតិថិជនទទួលខុសត្រូវទាំងស្រុងចំពោះការបាត់បង់ឬការខូចខាតនោះ។

៤- ក្នុងករណីមិនមានភស្តុតាងបញ្ជាក់អំពីកំហុសរបស់អតិថិជនទេ បុគ្គលផ្តល់សេវាទូទាត់ត្រូវទទួលខុសត្រូវទាំងស្រុង ចំពោះការបាត់បង់ ឬការខូចខាតនោះ ដោយឥតលក្ខខណ្ឌ។

## ជំពូកទី១០ (ថ្មី)
## បទល្មើស

### មាត្រា៤៥ ថ្មី .- ការចូលប្រើប្រាស់ ទាញយក ថតចម្លង ស្រង់យក ឬធ្វើឲ្យបែកធ្លាយទិន្នន័យ ដែលស្ថិតក្រោមការរក្សាទុករបស់បុគ្គលផ្សេងទៀត

ការចូលប្រើប្រាស់ ការទាញយក ការថតចម្លង ការស្រង់យក ឬការធ្វើឲ្យបែកធ្លាយទិន្នន័យ ដែលស្ថិតក្រោមគ្រប់គ្រងឬរក្សាទុកដោយបុគ្គលផ្សេងទៀត ដោយទុច្ចរិត ឬដោយគ្មានការអនុញ្ញាត ត្រូវចាត់ទុកជាអំពើល្មើស។

### មាត្រា៤៦ ថ្មី.- ការលួចអត្តសញ្ញាណ

ការប្រើប្រាស់អត្តសញ្ញាណ កំណាត់ត្រា ហត្ថលេខាអេឡិចត្រូនិក អាសយដ្ឋានអេឡិចត្រូនិក លេខសម្ងាត់ ឬភិនភាគសម្គាល់របស់បុគ្គលផ្សេងទៀតដោយទុច្ចរិត ឬដោយគ្មានការអនុញ្ញាត ត្រូវចាត់ទុកជាអំពើល្មើស។

### មាត្រា៤៧ ថ្មី .- ការក្លែងប្រព័ន្ធអេឡិចត្រូនិក

ការជ្រៀតជ្រែកទិន្នន័យ ឬការបង្កើតប្រព័ន្ធអេឡិចត្រូនិក ក្នុងគោលបំណងក្លែងបន្លំ ឬបង្កការភាន់ច្រឡំ ដើម្បីទាញយកផលប្រយោជន៍ ឬក្នុងគោលបំណងទាក់ទាញឲ្យមានការប្រើប្រាស់ ហើយនាំឲ្យមានព្យសនកម្មដល់បុគ្គលដែលប្រើប្រាស់នោះឬតតីយជន ត្រូវចាត់ទុកជាអំពើល្មើស។

### មាត្រា៤៨ ថ្មី .- ការបង្កើតកូដព្យាបាទ

ការបង្កើត ការផ្តល់ ការបង្កលទ្ធភាព ការចែកចាយ ឬការបញ្ជូននូវលេខកូដចម្លងមេរោគតាមមធ្យោបាយអេឡិចត្រូនិក ទៅឧបករណ៍ ឬប្រព័ន្ធអេឡិចត្រូនិក ត្រូវចាត់ទុកជាអំពើល្មើស។

**មាត្រា៤៩ ថ្មី .. ការបំពានលើកូដនីយកម្ម**

ការដាក់កូដក្នុងទំនាក់ទំនងអេឡិចត្រូនិក ដែលជាភស្តុតាងអាចនាំទៅដល់ការចោទប្រកាន់ ឬដាក់កូដលើទិន្នន័យ ឬភស្តុតាងក្នុងប្រព័ន្ធអេឡិចត្រូនិក ដែលទាក់ទិននឹងបទល្មើស ត្រូវចាត់ទុកជាអំពើល្មើស។

**មាត្រា៥០ ថ្មី .. ការមិនអនុវត្តតាមបទប្បញ្ញត្តិស្តីពីព័ត៌មានអប្បបរមាក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

ការប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកដើម្បីលក់ទំនិញ ឬសេវា ទៅឲ្យអ្នកប្រើប្រាស់ ដោយមិនអនុលោមតាមបទប្បញ្ញត្តិស្តីពីព័ត៌មានអប្បបរមាក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដូចមានចែងក្នុងមាត្រា២៧ ត្រូវចាត់ទុកជាអំពើល្មើស។

**មាត្រា៥១ ថ្មី .. ការផ្ញើទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំ**

ការផ្ញើទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំទៅកាន់អ្នកប្រើប្រាស់ដែលមិនអនុលោមតាមបទប្បញ្ញត្តិស្តីពីទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំដូចមានចែងក្នុងមាត្រា២៨ ត្រូវចាត់ទុកជាអំពើល្មើស។

**មាត្រា៥២ ថ្មី .. ការមិនអនុវត្តកាតព្វកិច្ចការពារទិន្នន័យ**

ការមិនអនុវត្តតាមកាតព្វកិច្ចការពារទិន្នន័យដោយបុគ្គលដែលរក្សាព័ត៌មានជាលក្ខណៈឯកជនក្រោមទម្រង់អេឡិចត្រូនិក ដូចមានចែងក្នុងកថាខណ្ឌ១ និងកថាខណ្ឌ២ នៃមាត្រា២៩ ត្រូវចាត់ទុកជាអំពើល្មើស។

**មាត្រា៥៣ ថ្មី .. បទមិនរាយការណ៍អំពីព័ត៌មានខុសច្បាប់**

អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលមិនអនុវត្តតាមនីតិវិធីចំពោះព័ត៌មានខុសច្បាប់ និងការបរិហាកេរ្តិ៍ ដូចមានចែងក្នុងមាត្រា២៤ ត្រូវចាត់ទុកជាអំពើល្មើស។

**មាត្រា៥៤ ថ្មី .. ការមិនអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈនិងបទប្បញ្ញត្តិពាក់ព័ន្ធ**

ការមិនអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈនិងបទប្បញ្ញត្តិពាក់ព័ន្ធ ដោយអន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រា២៤ ត្រូវចាត់ទុកជាអំពើល្មើស។

**មាត្រា៥៥ ថ្មី.. ការបំពានលើការចេញសេចក្តីបញ្ជាក់យថាភូតភាព**

ការបំពាននឹងសច្ចសីលភាព នៃសេចក្តីបញ្ជាក់យថាភូតភាពនៃកំណត់ត្រាឬភស្តុតាងអេឡិចត្រូនិក ដូចមានចែងក្នុងមាត្រា៣៨ ត្រូវចាត់ទុកជាអំពើល្មើស។

**មាត្រា៥៦ ថ្មី .. ការទូទាត់សងប្រាក់ជាអេឡិចត្រូនិកដោយគ្មានការអនុញ្ញាត**

ការធ្វើប្រតិបត្តិការប្រព័ន្ធទូទាត់ ការផ្តល់សេវាទូទាត់ ការចេញផ្សាយឧបករណ៍ទូទាត់ជាអេឡិចត្រូនិក ឬការផ្តល់មធ្យោបាយទូទាត់ជាអេឡិចត្រូនិក ឬការធ្វើប្រតិបត្តិការណាមួយដែលត្រូវបានចាត់ទុកថាជាការទូទាត់សងប្រាក់ជាអេឡិចត្រូនិកដល់សាធារណជនដោយមិនមានការអនុញ្ញាត ឬអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ត្រូវចាត់ទុកជាអំពើល្មើស។

**មាត្រា៥៧ ថ្មី .. បទក្លែងបន្លំឧបករណ៍ទូទាត់សងប្រាក់ជាអេឡិចត្រូនិក**

ការចេញផ្សាយបណ្ណទូទាត់ ឬការកែប្រែបណ្ណទូទាត់ទៅជាទម្រង់ណាមួយដែលខុសពីទម្រង់ដើម ដោយគ្មានការអនុញ្ញាតក្នុងគោលបំណងទុច្ចរិត ឆបោក ឬក្លែងបន្លំដែលនាំឲ្យមានព្យសនកម្មដល់បុគ្គលមួយផ្សេងទៀត ត្រូវចាត់ទុកជាអំពើល្មើស។

## ជំពូកទី១១ (ថ្មី)
## ទោសប្បញ្ញត្តិ

**មាត្រា៥៨ ថ្មី .. អំពើល្មើសលើការចូលប្រើប្រាស់ ទាញយក ថតចម្លង ស្រង់យក ឬធ្វើឲ្យបែកធ្លាយទិន្នន័យដែលស្ថិតក្រោមការរក្សាទុករបស់បុគ្គលផ្សេងទៀត**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ...... ឆ្នាំ ទៅ ........ ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី ............... រៀល ទៅ .................. រៀល ចំពោះអំពើចូលប្រើប្រាស់ ទាញយក ថតចម្លង ស្រង់យក ឬធ្វើឲ្យបែកធ្លាយទិន្នន័យដែលស្ថិតក្រោមការរក្សាទុករបស់បុគ្គលផ្សេងទៀត ។

**មាត្រា៥៩ ថ្មី.. អំពើល្មើសលើការលួចអត្តសញ្ញាណ**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ...... ឆ្នាំ ទៅ ........ ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី ............... រៀល ទៅ .................. រៀល ចំពោះអំពើប្រើប្រាស់អត្តសញ្ញាណ កំណត់ត្រា ហត្ថលេខាអេឡិចត្រូនិក អាសយដ្ឋានអេឡិចត្រូនិក លេខសម្ងាត់ ឬភិនភាគពិសេសរបស់បុគ្គលផ្សេងទៀតដោយទុច្ចរិត ឬដោយគ្មានការអនុញ្ញាត។

**មាត្រា៦០ ថ្មី .. អំពើល្មើសលើការក្លែងប្រព័ន្ធអេឡិចត្រូនិក**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ...... ឆ្នាំ ទៅ ........ ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី ............... រៀល ទៅ .................. រៀល ចំពោះអំពើជ្រៀតជ្រែកទិន្នន័យ ឬប្រព័ន្ធអេឡិចត្រូនិក ក្នុងគោលបំណងឲ្យបុគ្គលមួយផ្សេងទៀតយល់ថាជាទិន្នន័យ ឬប្រព័ន្ធអេឡិចត្រូនិកនោះពិតប្រាកដ ដើម្បីប្រើប្រាស់ផ្ទាល់ខ្លួន ឬឲ្យតតិយជនប្រើប្រាស់ ដែលនាំឲ្យមានព្យសនកម្មដល់បុគ្គលដែលប្រើប្រាស់នោះ ឬតតិយជន។

**មាត្រា៦១ ថ្មី .. អំពើល្មើសលើការបង្កើតកូដព្យាបាទ**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ...... ឆ្នាំ ទៅ ........ ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី ............... រៀល ទៅ ................. រៀល ចំពោះអំពើបង្កើត ផ្តល់ បង្កលទ្ធភាព ចែកចាយ ឬបញ្ជូននូវលេខកូដចម្លងមេរោគ តាមមធ្យោបាយអេឡិចត្រូនិក ទៅឧបករណ៍ ឬប្រព័ន្ធអេឡិចត្រូនិក។

**មាត្រា៦២ ថ្មី .. អំពើល្មើសលើការបំពានលើកូដនីយកម្ម**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ...... ឆ្នាំ ទៅ ........ ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី ............... រៀល ទៅ ................. រៀល ចំពោះអំពើដាក់កូដក្នុងទំនាក់ទំនងអេឡិចត្រូនិកដែលជាភស្តុតាងអាចនាំទៅដល់ការចោទប្រកាន់ ឬដាក់កូដលើទិន្នន័យក្នុងប្រព័ន្ធអេឡិចត្រូនិក ទាក់ទិននឹងបទល្មើស ឬភស្តុតាងដែលអាចនាំទៅដល់ការចោទប្រកាន់ ក្នុងគោលបំណងប្រព្រឹត្តបទល្មើស ឬលាក់បាំងភស្តុតាង។

**មាត្រា៦៣ ថ្មី .. អំពើល្មើសលើការមិនអនុវត្តតាមបទប្បញ្ញត្តិស្តីពីព័ត៌មានអប្បបរមាក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ...... ឆ្នាំ ទៅ ........ ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី ............... រៀល ទៅ ................. រៀល ចំពោះអំពើប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកដើម្បីលក់ទំនិញ ឬសេវាទៅឲ្យអ្នកប្រើប្រាស់ ដោយមិនអនុលោមតាមបទប្បញ្ញត្តិស្តីពីព័ត៌មានអប្បបរមាក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

**មាត្រា៦៤ ថ្មី .. អំពើល្មើសលើការផ្ញើទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំ**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ...... ឆ្នាំ ទៅ ........ ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី ............... រៀល ទៅ ................. រៀល ចំពោះអំពើផ្ញើទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំ ទៅកាន់អ្នកប្រើប្រាស់។

**មាត្រា៦៥ ថ្មី .. អំពើល្មើសលើការមិនអនុវត្តកាតព្វកិច្ចការពារទិន្នន័យ**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ...... ឆ្នាំ ទៅ ........ ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី ............... រៀល ទៅ ................. រៀល ចំពោះអំពើមិនអនុវត្តតាមកាតព្វកិច្ចការពារទិន្នន័យរបស់បុគ្គលដែលរក្សាព័ត៌មានជាលក្ខណៈឯកជនក្រោមទម្រង់អេឡិចត្រូនិក។

**មាត្រា៦៦ ថ្មី .. អំពើល្មើសលើការមិនរាយការណ៍អំពីព័ត៌មានខុសច្បាប់**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ...... ឆ្នាំ ទៅ ........ ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី ............... រៀល ទៅ ................. រៀល ចំពោះអំពើរបស់អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលមិនអនុវត្តតាមនីតិវិធីចំពោះព័ត៌មានខុសច្បាប់ និងការបរិហាកេរ្តិ៍។

**មាត្រា៦៧ ថ្មី .. អំពើល្មើសលើការមិនអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈនិងបទប្បញ្ញត្តិពាក់ព័ន្ធ**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ...... ឆ្នាំ ទៅ ........ ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី ............... រៀល ទៅ .................. រៀល ចំពោះអំពើមិនអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈនិងបទប្បញ្ញត្តិពាក់ព័ន្ធ របស់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ។

**មាត្រា៦៨ ថ្មី.. អំពើល្មើសលើការបំពានលើការចេញសេចក្តីបញ្ជាក់យថាភូតភាព**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ...... ឆ្នាំ ទៅ ........ ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី ............... រៀល ទៅ .................. រៀល ចំពោះអំពើបំពាននឹងសច្ចសីលភាព នៃសេចក្តីបញ្ជាក់យថាភូតភាព។

**មាត្រា៦៩ ថ្មី .. អំពើល្មើសលើការទូទាត់សងប្រាក់ជាអេឡិចត្រូនិកដោយគ្មានការអនុញ្ញាត**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ...... ឆ្នាំ ទៅ ........ ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី ............... រៀល ទៅ .................. រៀល ចំពោះអំពើធ្វើប្រតិបត្តិការប្រព័ន្ធទូទាត់ ផ្តល់សេវាទូទាត់ ចេញផ្សាយឧបករណ៍ទូទាត់ជាអេឡិចត្រូនិក ឬផ្តល់មធ្យោបាយទូទាត់ជាអេឡិចត្រូនិក ឬធ្វើប្រតិបត្តិការណាដែលត្រូវបានចាត់ទុកថាជាការផ្តល់ការទូទាត់សងប្រាក់អេឡិចត្រូនិកដល់សាធារណជន ដោយមិនមានការអនុញ្ញាត ឬអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ។

**មាត្រា៧០ ថ្មី .. អំពើល្មើសលើការក្លែងបន្លំឧបករណ៍ទូទាត់សងប្រាក់ជាអេឡិចត្រូនិក**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ...... ឆ្នាំ ទៅ ........ ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី ............... រៀល ទៅ .................. រៀល ចំពោះអំពើចេញផ្សាយបណ្ណទូទាត់ ឬកែប្រែបណ្ណទូទាត់ ទៅជាទម្រង់ណាមួយដែលខុសពីទម្រង់ដើម ដោយគ្មានការអនុញ្ញាតក្នុងគោលបំណងឆបោក ឬក្លែងបន្លំដែលនាំឲ្យមានព្យសនកម្មដល់បុគ្គលមួយផ្សេងទៀត។

# ជំពូកទី១២
# អវសានប្បញ្ញត្តិ

**មាត្រា៧១ .- បទប្បញ្ញត្តិ**

រាជរដ្ឋាភិបាល ក្រសួងស្ថាប័នពាក់ព័ន្ធ អាចចេញ អនុក្រឹត្យ ប្រកាស ឬបទដ្ឋានគតិយុត្ត នានាដែលចាំបាច់។

**មាត្រា៧២ .- បទប្បញ្ញត្តិផ្ទុយ**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ខែ ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភា
លើកទី នីតិកាលទី៦។
ថ្ងៃ ខែ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៩

**ប្រធានរដ្ឋសភា**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**

## ឧបសម្ព័ន្ធ
## និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើនៅក្នុងច្បាប់នេះត្រូវបានកំណត់និយមន័យដូចតទៅ៖

**១- ការចូលប្រើប្រាស់/អាក់សេស(Access)** ៖ សំដៅដល់ការចូលទៅប្រើកម្មវិធីកុំព្យូទ័រ ប្រព័ន្ធកុំព្យូទ័រ ប្រព័ន្ធឬបណ្តាញអេឡិចត្រូនិក ដើម្បីទាក់ទង បញ្ជូន រក្សាទុក ឬទាញយកនូវទិន្នន័យ ព័ត៌មាន ឬឯកសារផ្សេងៗទៀតក្នុងប្រព័ន្ធអេឡិចត្រូនិកតាមគ្រប់មធ្យោបាយ។

**២- អ្នកទទួល(Addressee)** ៖ សំដៅដល់បុគ្គលដែលទទួលទំនាក់ទំនងអេឡិចត្រូនិក ស្របតាមឆន្ទៈរបស់អ្នកផ្ញើ លើកលែងតែអន្តរការីក្នុងការប្រាស្រ័យទាក់ទងតាមប្រព័ន្ធអេឡិចត្រូនិក។

**៣- ប្រព័ន្ធស្វ័យប្រវត្ត(Automated System)** ៖ សំដៅដល់កម្មវិធីកុំព្យូទ័រ ប្រព័ន្ធកុំព្យូទ័រ ប្រព័ន្ធឬបណ្តាញអេឡិចត្រូនិក ឬមធ្យោបាយអេឡិចត្រូនិកផ្សេងទៀតដែលត្រូវបានប្រើប្រាស់សម្រាប់ជូនដំណឹង ឬឆ្លើយតបដោយស្វ័យប្រវត្តដោយគ្មានអន្តរាគមន៍ពីរូបវន្តបុគ្គលណាមួយ។

**៤- បណ្ណ/កាតទូទាត់(Card)** ៖ សំដៅដល់បណ្ណ/កាតធនាគារ បណ្ណឥណទាន/ឥណពន្ធ ស្មាតកាត (Smart Card) ឬបណ្ណ/កាតទូទាត់ ទោះបីក្នុងទម្រង់អេឡិចត្រូនិកដែលផ្ទុកតម្លៃ ហើយមានមុខងារសម្រាប់ទូទាត់។

**៥- កម្មវិធីចម្លងមេរោគ(Contaminant)** ៖ សំដៅដល់កម្មវិធីអេឡិចត្រូនិកដែលត្រូវបានបង្កើតឡើងដើម្បី៖

(ក) កែប្រែ បំផ្លាញ កត់ត្រា បញ្ជូនទិន្នន័យឬកម្មវិធីនៅក្នុងប្រព័ន្ធអេឡិចត្រូនិក ឬ

(ខ) ជ្រៀតជ្រែកតាមគ្រប់មធ្យោបាយនូវដំណើរការប្រក្រតីរបស់ប្រព័ន្ធឬបណ្តាញអេឡិចត្រូនិក។

**៦- ម្ចាស់បណ្ណ/កាតទូទាត់(Cardholder)** ៖ សំដៅដល់បុគ្គលដែលមានឈ្មោះចារិកនៅលើបណ្ណ/កាត និងជាបុគ្គលដែលទទួលប្រយោជន៍ពីបណ្ណ/កាតទូទាត់នោះ។

**៧- ទំនាក់ទំនង(Communication)** ៖ សំដៅដល់អំណះអំណាង សេចក្តីថ្លែងការណ៍ ការទាមទារ សេចក្តីជូនដំណឹង សំណូមពរ សំណើ ឬស្នើការ ដែលគូភាគីត្រូវធ្វើ ឬសម្រេចចិត្តធ្វើពាក់ព័ន្ធនឹងការបង្កើត ឬការអនុវត្តកិច្ចសន្យា។

**៨- បណ្ណ/កាតទូទាត់ក្លែងក្លាយ(Counterfeit card)** ៖ សំដៅដល់បណ្ណ/កាតទូទាត់ទាំងឡាយណាដែលត្រូវបានបង្កើតឡើងដោយការបង្ហាញឬការពិពណ៌នាដែលត្រូវបានប្រឌិតឡើង កែប្រែក្លែងបន្លំ ឬបណ្ណ/កាតទូទាត់ដែលមានសមាសធាតុណាមួយនៃបណ្ណ/កាតទូទាត់នោះមានលក្ខណៈខុសច្បាប់។

**៩- ទិន្នន័យ(Data)** ៖ សំដៅដល់បណ្តុំលេខ អក្សរ និមិត្តសញ្ញា សារ រូបភាព សំឡេង វីដេអូ ព័ត៌មាន ឬកម្មវិធីអេឡិចត្រូនិក ដែលត្រូវបានរៀបចំក្នុងទម្រង់សមស្របសម្រាប់ប្រើប្រាស់ក្នុងមូលដ្ឋានទិន្នន័យ ឬប្រព័ន្ធអេឡិចត្រូនិក។

**១០- អេឡិចត្រូនិក(Electronic)** ៖ សំដៅដល់អ្វីដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យាដែលមានចរន្តអគ្គីសនី ឌីជីថល ម៉ាញេទិច អុបទិក ជីវមាត្រ អេឡិចត្រូគីមី វ៉ាយអឺឡេស (wireless) អេឡិចត្រូម៉ាញេទិក ឬបច្ចេកវិទ្យាដែលមានមុខងារប្រហាក់ប្រហែលផ្សេងទៀត។

**១១- អាសយដ្ឋានអេឡិចត្រូនិក(Electronic Address)** សំដៅដល់លេខ ឬអាសយដ្ឋានប្រើប្រាស់សម្រាប់ផ្ញើ ឬទទួលការជូនដំណឹង ឯកសារ ព័ត៌មាន ឬទំនាក់ទំនងតាមមធ្យោបាយអេឡិចត្រូនិក។

**១២- ឧករណ៍ទូទាត់អេឡិចត្រូនិក(Electronic Payment Instrument)**៖ សំដៅដល់បណ្ណ/កាតទូទាត់ ឬឧបករណ៍ទូទាត់ទាំងឡាយណាដែលមានទម្រង់ជាអេឡិចត្រូនិក ហើយមានមុខងារសម្រាប់ទូទាត់សងប្រាក់។

**១៣- ទំនាក់ទំនងអេឡិចត្រូនិក(Electronic Communication)** ៖ សំដៅដល់ព័ត៌មានដែលត្រូវបានទាក់ទង ដំណើរការ កត់ត្រាទុក បង្ហាញឡើង បង្កើតឡើង រក្សាទុក ទទួលបាន ឬបញ្ជូនតាមមធ្យោបាយអេឡិចត្រូនិក។

**១៤- ឧបករណ៍អេឡិចត្រូនិក(Electronic device)**៖ សំដៅដល់ឧបករណ៍ទាំងឡាយណាដែលបង្កើតឡើងដើម្បីគ្រប់គ្រង បញ្ជា និងប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិក។

**១៥- ភស្តុតាងអេឡិចត្រូនិក(Electronic evidence)** សំដៅដល់ព័ត៌មាន ទិន្នន័យ ឬឯកសារនានា ដែលបានបង្កើតឡើង រក្សាទុក ផ្ញើចេញឬទទួលក្នុងទម្រង់ឬទំនាក់ទំនងអេឡិចត្រូនិកសម្រាប់ជាសម្អាងទាក់ទងនឹងអង្គហេតុណាមួយក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់ ហើយព័ត៌មាន ទិន្នន័យ ឬឯកសារនោះមានយថាភូតភាពស្របតាមច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

**១៦- ទម្រង់អេឡិចត្រូនិក(Electronic form)** ៖ សំដៅដល់ទម្រង់នៃព័ត៌មាន ទិន្នន័យ ឬឯកសារដែលបង្កើត បញ្ជូន ទទួលបាន ឬរក្សាទុកក្នុងប្រព័ន្ធអេឡិចត្រូនិក។

**១៧- ការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក(Electronic fund transfer)** ៖ សំដៅដល់ប្រតិបត្តិការទាំងឡាយណាដែលធ្វើឡើងតាមរយៈបញ្ជារផ្ទេរប្រាក់អេឡិចត្រូនិក ឬតាមឧបករណ៍អេឡិចត្រូនិកចល័ត ឬតាមឧបករណ៍អេឡិចត្រូនិកដែលមានមុខងារស្រដៀងគ្នា ដើម្បីបញ្ជាឲ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុធ្វើការចុះឥណពន្ធ ឬឥណទានក្នុងគណនី។

**១៨- កំណត់ត្រាអេឡិចត្រូនិក(Electronic record)៖** សំដៅដល់កំណត់ត្រាដែលត្រូវបានបង្កើតឡើង ទាក់ទង ទទួល រក្សាទុក ឬដំណើរការក្នុងប្រព័ន្ធអេឡិចត្រូនិក ឬសម្រាប់បញ្ជូនពីប្រព័ន្ធអេឡិចត្រូនិកមួយទៅប្រព័ន្ធអេឡិចត្រូនិកមួយទៀត។

**១៩- បុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក(Electronic-Commerce service provider)** ៖ សំដៅដល់បុគ្គលដែលប្រើប្រាស់មធ្យោបាយអេឡិចត្រូនិកដើម្បីផ្គត់ផ្គង់ទំនិញ និង/ឬសេវា លើកលែងគ្រឹះស្ថានធានារ៉ាប់រង។

**២០-** ហត្ថលេខាអេឡិចត្រូនិក**(Electronic Signature)** ៖ សំដៅដល់រាល់ហត្ថលេខាដែលត្រូវបានបង្កើតឡើងតាមមធ្យោបាយអេឡិចត្រូនិកសម្រាប់ប្រើប្រាស់កំណត់អត្តសញ្ញាណរបស់ហត្ថលេខី ដែលរួមមាន ហត្ថលេខាឌីជីថល ហត្ថលេខាជីវមាត្រ និងហត្ថលេខាដទៃទៀត។

**២១- ប្រព័ន្ធអេឡិចត្រូនិក(Electronic system)** ៖ សំដៅដល់ឧបករណ៍អេឡិចត្រូនិក ឬបណ្តុំឧបករណ៍តភ្ជាប់គ្នា ឬទាក់ទងគ្នា តាមរយៈកម្មវិធីអេឡិចត្រូនិក ដែលអាចធ្វើឲ្យដំណើរការជាស្វ័យប្រវត្តនៃទិន្នន័យ ព័ត៌មាន ឬឯកសារ រួមបញ្ចូលទាំងឧបករណ៍អេឡិចត្រូនិកសម្រាប់រក្សាទុកទិន្នន័យ ព័ត៌មាន ឬឯកសារនោះ។

**២២- ប្រព័ន្ធព័ត៌មាន**(Information system) ៖ សំដៅដល់ប្រព័ន្ធសម្រាប់បង្កើត ផ្ញើ ទទួល រក្សាទុក ឬដំណើរការកំណត់ត្រាអេឡិចត្រូនិក។

**២៣- អន្តរការី**(Intermediary)៖ សំដៅដល់បុគ្គលដែលផ្តល់សេវា ផ្ញើ ទទួល បញ្ជូន ឬរក្សាទុកជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍នូវទំនាក់ទំនងអេឡិចត្រូនិកនោះ ឬផ្តល់សេវាផ្សេងទៀតដែលពាក់ព័ន្ធនឹងទំនាក់ទំនងអេឡិចត្រូនិក រួមបញ្ចូលនូវបុគ្គលដូចខាងក្រោម៖

១- បុគ្គលដែលតំណាងឲ្យអ្នកផ្ញើ អ្នកទទួល អ្នកបញ្ជូន ឬអ្នករក្សាទុក

២- បុគ្គលផ្តល់សេវាទូរគមនាគមន៍

៣- បុគ្គលផ្តល់សេវាបណ្តាញនានា

៤- បុគ្គលផ្តល់សេវាអ៊ិនធឺណែត

៥- បុគ្គលផ្តល់មធ្យោបាយស្វែងរកទិន្នន័យណាមួយតាមប្រព័ន្ធអេឡិចត្រូនិក

៦- បុគ្គលផ្តល់សេវាទូទាត់តាមអនឡាញ

៧- បុគ្គលផ្តល់សេវាដេញថ្លៃតាមអនឡាញ

៨- បុគ្គលផ្តល់សេវាទីផ្សារអនឡាញនិងសេវាពាណិជ្ជកម្មតាមបណ្តាញអ៊ិនធឺណែត។

**២៤- បុគ្គលចេញបណ្ណ/កាតទូទាត់**(Issuer) ៖ សំដៅដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬបុគ្គលណាមួយដែលបានចេញបណ្ណ/កាតទូទាត់ ដែលបានទទួលការអនុញ្ញាត។

**២៥- កូដព្យាបាទ**(Malicious code)៖ សំដៅដល់កម្មវិធី ឬតួនាទីលាក់មុខនៃកម្មវិធីដែលចម្លងមេរោគដល់ទិន្នន័យ ព័ត៌មាន ឬឯកសារ ដោយមានឬគ្មានបន្សល់ទុកស្លាកស្នាមសម្គាល់នៃមេរោគនោះក្នុងឯកសារអេឡិចត្រូនិកដែលបានឆ្លងមេរោគ ហើយមេរោគនោះអាចចម្លងបន្តក្នុងប្រព័ន្ធដោយឯកឯង ឬដោយមានអន្តរាគមន៍ពីមនុស្ស។

**២៦- អ្នកផ្ញើ**(Originator) ៖ សំដៅដល់ភាគីឬអ្នកតំណាងដែលបានផ្តើមប្រតិបត្តិការបង្កើត រក្សាទុក ឬបញ្ជូនទិន្នន័យតាមមធ្យោបាយអេឡិចត្រូនិក ដោយមិនរាប់បញ្ចូលអន្តរការី។

**២៧- បុគ្គលផ្តល់សេវាទូទាត់**(Payment Service Provider) ៖ សំដៅដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬបុគ្គលដទៃទៀតដែលបានទទួលការអនុញ្ញាត ឬអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជាឲ្យធ្វើប្រតិបត្តិការប្រព័ន្ធទូទាត់ ចេញផ្សាយឧបករណ៍ទូទាត់អេឡិចត្រូនិក ឬមធ្យោបាយទូទាត់ជាអេឡិចត្រូនិក ឬធ្វើប្រតិបត្តិការណាដែលត្រូវបានចាត់ទុកថាជាការផ្តល់ការទូទាត់សងប្រាក់ជាអេឡិចត្រូនិកដល់សាធារណជន។

**២៨- ទីតាំងអាជីវកម្ម**(Place of business) ៖ សំដៅដល់

ក- ទីតាំងដែលអ្នកផ្ញើ ឬអ្នកទទួលបានចង្អុលបង្ហាញ លើកលែងតែភាគីណាមួយបានបង្ហាញថាអ្នកអះអាងនោះ ពុំមានទីតាំងអាជីវកម្មនៅទីនោះឡើយ។

ខ- ប្រសិនបើភាគីណាមួយមិនបានចង្អុលបង្ហាញទីកន្លែងអាជីវកម្មជាក់លាក់ណាមួយ ហើយភាគីនោះមានទីតាំងអាជីវកម្មច្រើនជាងមួយកន្លែង ទីតាំងអាជីវកម្មត្រូវកំណត់ថាជាទីកន្លែងដែលមានទំនាក់ទំនងជិតស្និទ្ធជាងគេទៅនឹងកិច្ចសន្យាដែលពាក់ព័ន្ធ ដោយត្រូវពិចារណាផងដែរអំពីកាលៈទេសៈដែលបានដឹងឬពិនិត្យដោយភាគីនៅពេលណាមួយមុនឬក្នុងពេលចុះកិច្ចសន្យា។

គ- សម្រាប់រូបវន្តបុគ្គលដែលពុំមានទីតាំងអាជីវកម្មទេនោះ ទីតាំងអាជីវកម្មសំដៅដល់ទីលំនៅអចិន្ត្រៃយ៍របស់បុគ្គលនោះ។

មិនត្រូវចាត់ទុកថាជាទីតាំងអាជីវកម្មរបស់ភាគីដោយគ្រាន់តែជា៖

- ទីតាំងដែលសម្ភារៈឬឧបករណ៍បច្ចេកវិទ្យានៃប្រព័ន្ធព័ត៌មានត្រូវបានប្រើ
- អាសយដ្ឋានអេឡិចត្រូនិកឬឈ្មោះដែនកម្មសិទ្ធិ(Domain Name) ដែលភ្ជាប់ជាមួយនឹងទីតាំងរបស់ភាគី។

**២៩- កំណត់ត្រា**(Record) សំដៅដល់ព័ត៌មាន ទិន្នន័យ ឬឯកសារដែលត្រូវបានកត់ត្រាចូល រក្សាទុក ឬបញ្ចូលទៅក្នុងទម្រង់រូបីយ ឬដែលត្រូវបានរក្សាទុកក្នុងទម្រង់អេឡិចត្រូនិក ជា

ក្រដាសស្នាម ឬទម្រង់ប្រភេទផ្សេងទៀត ហើយដែលអាចទាញយកកំណត់ត្រានោះវិញបានក្នុងទម្រង់ជាក់លាក់ដែលអាចមើលបាន។

**៣០- បុគ្គលផ្តល់សេវា**(Service provider )៖ សំដៅដល់

(ក) បុគ្គលដែលផ្តល់សេវាព័ត៌មាន និងសេវាទំនាក់ទំនង រួមមាន ការផ្ញើ ការទទួល ការរក្សាទុក ឬដំណើរការទំនាក់ទំនងអេឡិចត្រូនិក ឬការផ្តល់សេវាតាមប្រព័ន្ធអេឡិចត្រូនិកផ្សេងទៀត។

(ខ) បុគ្គលដែលជាម្ចាស់ បុគ្គលកាន់កាប់ បុគ្គលដំណើរការ បុគ្គលគ្រប់គ្រង ឬបុគ្គលត្រួតពិនិត្យបណ្តាញស្វិចសាធារណៈ (Public Switched Network) ឬបុគ្គលដែលផ្តល់សេវាទូរគមនាគមន៍។ ឬ

(គ) បុគ្គលផ្សេងទៀតដែលប្រតិបត្តិ ឬរក្សាទុកទិន្នន័យបម្រើឲ្យសេវាទំនាក់ទំនងអេឡិចត្រូនិកនោះ ឬអ្នកប្រើប្រាស់សេវា។

**៣១- បុគ្គលផ្តល់នីតិវិធីសុវត្ថិភាព**( Security procedure provider)៖ សំដៅដល់បុគ្គលបង្កើត ឬផ្តល់នីតិវិធីសុវត្ថិភាព។

**៣២- នីតិវិធីសុវត្ថិភាព**(Security Procedure) ៖ សំដៅដល់នីតិវិធីដែលកំណត់ដោយច្បាប់ ឬកិច្ចសន្យា ឬការសម្រេចដោយភាគីណាមួយ ហើយដែលត្រូវបានប្រើក្នុងគោលបំណង៖

(ក) ផ្ទៀងផ្ទាត់ថាហត្ថលេខា ទំនាក់ទំនង ឬប្រតិបត្តិការក្នុងប្រព័ន្ធអេឡិចត្រូនិក ពិតជារបស់បុគ្គលនោះ។

(ខ) រកឲ្យឃើញកំហុសឆ្គង ឬការកែប្រែនៅក្នុងទំនាក់ទំនង ឬក្នុងកន្លែងរក្សាទុកកំណត់ត្រាអេឡិចត្រូនិក ចាប់តាំងពីពេលជាក់ណាមួយ។

នីតិវិធីសុវត្ថិភាពខាងលើអាចតម្រូវឲ្យប្រើរូបមន្តអាល់ហ្គោរីត(algorithms)ឬកូដ ពាក្យឬលេខសម្រាប់ សម្គាល់អត្តសញ្ញាណ កូដនីយកម្ម សំនួរសម្ងាត់ ឬការទទួលស្គាល់នីតិវិធីណាមួយ ឬក៏ឧបករណ៍សុវត្ថិភាពស្រដៀងគ្នាផ្សេងទៀត។

**៣៣- ព័ត៌មាន ឬកំណត់ត្រាជាលាយលក្ខណ៍អក្សរ**(writing/written) សំដៅដល់ព័ត៌មាន ឬកំណត់ត្រាផ្សេងៗទៀត ដែលត្រូវបានសរសេរ ចារឹក ឬបោះពុម្ពនៅលើក្រដាស ឬសម្ភារៈផ្សេងៗទៀត។

**៣៤- អ៊ីមែល ឬសារអេឡិចត្រូនិក** សំដៅដល់ សារឬព័ត៌មានដែលត្រូវបានបង្កើតឡើងឬបញ្ជូន ឬទទួលបានពីប្រព័ន្ធអេឡិចត្រូនិក រួមទាំងឯកសារភ្ជាប់ក្នុងអត្ថបទ រូបភាព សំឡេង វីដេអូ និងកំណត់ត្រាអេឡិចត្រូនិកណាមួយផ្សេងទៀតដែលអាចបញ្ជូនជាមួយសារបាន។

៣៥- **សន្តតិកម្ម** សំដៅដល់ការផ្ទេរនូវសិទ្ធិនិងករណីកិច្ចរបស់មតកជនទៅឲ្យសន្តតិជនម្នាក់ ឬច្រើននាក់តាមឆន្ទៈឬតាមច្បាប់។

៣៦- **ស្វីការ** សំដៅដល់ការសំដែងឆន្ទៈ ដែលបុគ្គលម្នាក់បានបញ្ចេញការយល់ព្រមរបស់ខ្លួន ចំពោះសំណើដែលបុគ្គលដ៏ទៃបានស្នើមកខ្លួនដើម្បីបង្កើតកិច្ចសន្យា។

# ដ្យាក្រាមសង្ខេបស្តីពី ការ
# បង្កើត និង សុពលភាពនៃ
# កិច្ចសន្យា

## 【ឧបសម្ព័ន្ធ ៣】 ការបង្កើត និង សុពលភាពនៃកិច្ចសន្យា



# ប្រកាសស្តីពីការកែសម្រួល
# ការរៀបចំ និងការប្រព្រឹត្ត
# ទៅរបស់ ស្នងការដ្ឋាន
# នគរបាលរាជធានី ខេត្ត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ: ៦២៤៤ ប្រក

# ប្រកាស
## ស្តីពី
## ការកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅ របស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃព្រហស្បតិ៍ ១រោច ខែបឋមាសាឍ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងប្រកាសលេខ ១៩១២ ប្រ.ក ចុះថ្ងៃពុធ ១១កើត ខែពិសាខ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត
- យោងតាមសំណើរបស់អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ

## សម្រេច

**ប្រការ១.-**

ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ស្ថិតនៅក្រោមឱវាទអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត និងស្ថិតនៅក្រោមការបញ្ជាដឹកនាំជំនាញរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ មានសមត្ថកិច្ចគាំពារ និងថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពជូនប្រជាពលរដ្ឋនៅក្នុងរាជធានី ខេត្ត ។

**ប្រការ២.-**

ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត មានភារកិច្ច ដូចខាងក្រោម ៖

-អនុវត្តការងាររក្សាសន្តិសុខ សុវត្ថិភាពក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

-ការពារអាយុជីវិត សិទ្ធិ សេរីភាព កិត្តិយស សេចក្តីថ្លៃថ្នូរ ទ្រព្យសម្បត្តិ និងផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន

-ការពារសុវត្ថិភាពថ្នាក់ដឹកនាំជាតិ-អន្តរជាតិ និងភ្ញៀវបរទេស

-ការពារការសម្ងាត់ជាតិ ការពារស្ថាប័ន សម្បត្តិវប្បធម៌ បេតិកភណ្ឌជាតិ ទ្រព្យសម្បត្តិសាធារណៈ និងគោលដៅសំខាន់ៗ

-រៀបចំសណ្តាប់ធ្នាប់សាធារណៈ សណ្តាប់ធ្នាប់ចរាចរផ្លូវគោក ផ្លូវទឹក ផ្លូវដែក និងការងារបង្ការ ពន្លត់អគ្គិភ័យ និងសង្គ្រោះ

-ចាត់វិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបរាល់សកម្មភាពជួញដូរមនុស្ស អាជីវកម្មផ្លូវភេទលើនីតិជន អនីតិជន និងអំពើហិង្សាក្នុងគ្រួសារតាមនីតិវិធី

-ចាត់វិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រឿងញៀនក្នុងដែនសមត្ថកិច្ចទទួលខុសត្រូវ

-ចាត់វិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបឧក្រិដ្ឋកម្មឆ្លងដែន ឧក្រិដ្ឋកម្មមានអង្គការចាត់តាំង និងបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ បទល្មើសបច្ចេកវិទ្យា និងល្បែងស៊ីសងខុសច្បាប់ ព្រមទាំងបទល្មើសផ្សេងៗទៀតដែលប្រឆាំងនឹងសន្តិសុខជាតិ សណ្តាប់ធ្នាប់សង្គម

-ចាត់វិធានការគ្រប់គ្រងសកម្មភាពក្រុមហ៊ុនផ្តល់សេវាសន្តិសុខ

-ចាត់វិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបអំពើវិច្ឆេទកម្មសេដ្ឋកិច្ច និងបង្ក្រាបបទល្មើសសេដ្ឋកិច្ចគ្រប់ប្រភេទ

-ធ្វើការងារបច្ចេកទេសវិទ្យាសាស្ត្រព្រហ្មទណ្ឌ

-ចាត់វិធានការគ្រប់គ្រងមុខសញ្ញាល្មើសច្បាប់នានាក្នុងដែនសមត្ថកិច្ចទទួលខុសត្រូវ

-ចុះបញ្ជី និងគ្រប់គ្រងស្ថិតិ អាវុធ គ្រឿងផ្ទុះ ជាតិងាយឆេះ ជាតិពុល អាស៊ីដខ្លាំង និងមុខរបរដែលងាយប៉ះពាល់ដល់សន្តិសុខសង្គម

-ធ្វើការងារស្រាវជ្រាវប្រមូលព័ត៌មាន បង្ការ ទប់ស្កាត់ និងបង្ក្រាបសកម្មភាពបង្កចលាចលសង្គម និងសកម្មភាពភេរវកម្ម

-ចាប់ខ្លួន ឃាត់ខ្លួនបណ្តោះអាសន្ន រៀបចំ និងបញ្ជូនសំណុំរឿង ជនល្មើស ព្រមទាំងវត្ថុតាងទៅអយ្យការតាមច្បាប់

-អនុវត្ត និងសហការអនុវត្តសាលក្រម សាលដីកា និងដីកានានារបស់ស្ថាប័នអយ្យការ និងតុលាការ

-សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ អនុវត្តវិធានការបង្ការ ទប់ស្កាត់គ្រោះមហន្តរាយផ្សេងៗ

-តាមដានការចុះបញ្ជីការស្នាក់នៅរបស់ប្រជាជន និងការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន

-ធ្វើការងារគ្រប់គ្រងជនបរទេសមិនមែនអន្តោប្រវេសន្ត ជនបរទេសអន្តោប្រវេសន្ត និងជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគឯកជនក្នុងភូមិសាស្ត្រទទួលខុសត្រូវ

-ស្រាវជ្រាវរកមនុស្សបាត់ខ្លួន

-គ្រប់គ្រង បញ្ជា ដឹកនាំមន្ត្រីការិយាល័យជំនាញ អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ វរសេនាតូចនគរបាលការពារព្រំដែនគោក ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ និងប៉ុស្តិ៍នគរបាលការពារព្រំដែនគោក

-គ្រប់គ្រងចលនទ្រព្យ និងអចលនទ្រព្យរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត

-ធ្វើការងាររដ្ឋបាល បុគ្គលិក បណ្តុះបណ្តាល និងការងារកស្តុភារ គណនេយ្យរបស់ស្នងការដ្ឋាននគរ-បាលរាជធានី ខេត្តតាមការកំណត់

-ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងទិសដៅបន្តរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត តាមការកំណត់

-បំពេញភារកិច្ចផ្សេងៗទៀត ដែលអគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិប្រគល់ឲ្យ ។

**ប្រការ៣..**

ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត មានរចនាសម្ព័ន្ធដូចខាងក្រោម ៖

**ក- ផែនការងារធនធានមនុស្ស**

១- ការិយាល័យបុគ្គលិក

២- ការិយាល័យបណ្តុះបណ្តាល

៣- ការិយាល័យផ្សព្វផ្សាយអប់រំ

**ខ- ផែនការងារសេនាធិការ**

១- ការិយាល័យរដ្ឋបាល

២- ការិយាល័យសរុប ផែនការ

៣- ការិយាល័យវិទ្យុទាក់ទង

៤- ការិយាល័យអក្សរសម្ងាត់

៥- ការិយាល័យកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាល

៦- ការិយាល័យអន្តរាគមន៍ និងតម្រួតបទបញ្ជា

**គ- ផែនការងារនគរបាលព្រហ្មទណ្ឌ**

១- ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់

២- ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល

៣- ការិយាល័យនគរបាលបច្ចេកទេស និងវិទ្យាសាស្ត្រ

**ឃ- ផែនការងារនគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច**

- ការិយាល័យនគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច

**ង- ផែនការងារប្រឆាំងគ្រឿងញៀន**

- ការិយាល័យប្រឆាំងគ្រឿងញៀន

**ច- ផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងការងារយេនឌ័រ**

- ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន

**ឆ- ផែនការងារសន្តិសុខ**

១- ការិយាល័យសន្តិសុខផ្ទៃក្នុង

២- ការិយាល័យប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន

៣- ការិយាល័យគ្រប់គ្រងសន្តិសុខឯកជន (លើកលែងខេត្តរតនគិរី និងខេត្តឧត្តរមានជ័យ)

៤- ការិយាល័យប្រឆាំងបទល្មើសបច្ចេកវិទ្យា (មាននៅរាជធានីភ្នំពេញ ខេត្តសៀមរាប ស្វាយរៀង និង ខេត្តព្រះសីហនុ)

៥- ការិយាល័យអង្គរក្ស (មាននៅស្នងការដ្ឋាននគរបាលខេត្តសៀមរាប)

ជ- ផែនការងារនគរបាលសណ្តាប់ធ្នាប់

១- ការិយាល័យនគរបាលសណ្តាប់ធ្នាប់

២-ការិយាល័យនគរបាលទេសចរណ៍ ( លើកលែងខេត្តកំពង់ឆ្នាំង ព្រៃវែង ស្វាយរៀង ប៉ៃលិន សៀមរាប និងខេត្តត្បូងឃ្មុំ)

៣-ការិយាល័យនគរបាលការពារបេតិកភណ្ឌ (មាននៅរាជធានីភ្នំពេញ ខេត្តតាកែវ កំពង់ធំ បាត់ដំបង សៀមរាប ឧត្តរមានជ័យ និងខេត្តព្រះវិហារ)

៤-ការិយាល័យនគរបាលចរាចរណ៍ផ្លូវគោក

៥-ការិយាល័យនគរបាលចរាចរណ៍ផ្លូវទឹក (លើកលែងខេត្តកំពង់ស្ពឺ ស្វាយរៀង ប៉ៃលិន បន្ទាយមានជ័យ ឧត្តរមានជ័យ ព្រះវិហារ មណ្ឌលគិរី និងខេត្តរតនគិរី )

*+ ដោយឡែក នៅស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ផែនការងារនគរបាលសណ្តាប់ធ្នាប់ បំបែកជា០២ផែនគឺ ៖*

១- ផែនការងារនគរបាលសណ្តាប់ធ្នាប់ ដែលមានការិយាល័យចំណុះចំនួន០៣ គឺ ៖

- ការិយាល័យនគរបាលសណ្តាប់ធ្នាប់
- ការិយាល័យនគរបាលទេសចរណ៍
- ការិយាល័យនគរបាលការពារបេតិកភណ្ឌ

២- ផែនការងារនគរបាលចរាចរណ៍ ដែលមានការិយាល័យចំណុះចំនួន០២ គឺ ៖

- ការិយាល័យនគរបាលចរាចរណ៍ផ្លូវគោក
- ការិយាល័យនគរបាលចរាចរណ៍ផ្លូវទឹក

ឈ- ផែនការងារគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងអគ្គិភ័យ

១- ការិយាល័យនគរបាលបង្ការ ពន្លត់អគ្គិភ័យ និងសង្គ្រោះ

២-ការិយាល័យគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងជាតិពុល

ញ- ផែនការងារអន្តោប្រវេសន៍

១- ការិយាល័យគ្រប់គ្រងជនបរទេស

២- ការិយាល័យស៊ើបអង្កេត និងអនុវត្តនីតិវិធី

ដ- ផែនការងារអត្តសញ្ញាណកម្ម

១- ការិយាល័យគ្រប់គ្រងការស្នាក់នៅ

២-ការិយាល័យអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

ឋ- ផែនការងារភស្តុភារ និងហិរញ្ញវត្ថុ

១- ការិយាល័យភស្តុភារ

២-ការិយាល័យគណនេយ្យ

៣-ការិយាល័យសុខាភិបាល

ឱ- ផែននគរបាលការពារព្រំដែនគោក ( មាននៅស្នងការដ្ឋាននគរបាលខេត្តជាប់ព្រំដែន និងលើកលែងស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ និងវរសេនាតូចនគរបាលអន្តរាគមន៍ ដែលចំណុះនាយកដ្ឋាននគរបាលការពារព្រំដែនគោក ) ។

ឍ- អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ ។

ណ- ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ។

**ប្រការ៤.**

តួនាទី និងភារកិច្ចរបស់ការិយាល័យ ចំណុះផែនការងារនីមួយៗមានដូចខាងក្រោម ៖

**ក- ផែនការងារធនធានមនុស្ស**

**១- ការិយាល័យបុគ្គលិក** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារបុគ្គលិក ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ វិធានការលើការងារធនធានមនុស្ស និងរចនាសម្ព័ន្ធរបស់ស្នងការដ្ឋាន
- អនុវត្តវិធានការជំនាញគ្រប់គ្រងមន្ត្រីនគរបាលជាតិរបស់ស្នងការដ្ឋាន
- កសាងផែនការក្របខ័ណ្ឌមន្ត្រីនគរបាលជាតិស្របតាមការប្រែប្រួលអំពីភារកិច្ច និងរចនាសម្ព័ន្ធ
- លើកសំណើសុំគោលការណ៍តែងតាំងមុខតំណែង ឋានន្តរសក្តិ ដំឡើងឋានៈ ឋានន្តរសក្តិ ការផ្ទេរផ្លាស់ប្តូរភារកិច្ច ការលើកសរសើរជូនរង្វាន់ ការដាក់វិន័យ ការដាក់ឲ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើម ការដាក់ឲ្យនៅក្នុងភាពទំនេរគ្មានបៀវត្ស ការអនុញ្ញាតច្បាប់ឈប់សម្រាក ការលុបឈ្មោះចេញពីក្របខ័ណ្ឌ ការដាក់ឲ្យចូលនិវត្តន៍ ចូលបាត់បង់សមត្ថភាពការងារ និងគោលនយោបាយធានារ៉ាប់រងសង្គមតាមបែបបទ និងនីតិវិធី
- ពិនិត្យផ្ទៀងផ្ទាត់បញ្ជីឈ្មោះក្នុងតារាងទូទាត់ប្រាក់បៀវត្សប្រចាំខែរបស់មន្ត្រីនគរបាលជាតិ
- សិក្សាអំពីបុគ្គលិកលក្ខណៈ ឧបនិស្ស័យ សមត្ថភាព មុខជំនាញឯកទេសដែលបានបណ្តុះបណ្តាល បទពិសោធន៍ គំនិតផ្តួចផ្តើមរបស់មន្ត្រីនគរបាលជាតិបម្រើគោលដៅបន្តវេន
- រៀបចំការងារគ្រប់គ្រងស្ថិតិទិន្នន័យបុគ្គលិក តារាងព្រឹត្តបត្រពិន្ទុ និងទុកដាក់ថែរក្សាសំណុំលិខិតឯកត្តជនមន្ត្រីនគរបាលជាតិតាមប្រព័ន្ធព័ត៌មានវិទ្យា
- រៀបចំក្រុមប្រឹក្សាវិន័យ និងក្រុមប្រឹក្សាប្រឡងប្រណាំងរបស់នគរបាលជាតិតាមការកំណត់
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នង-ការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**២- ការិយាល័យបណ្តុះបណ្តាល** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារបណ្តុះបណ្តាល ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារបណ្តុះបណ្តាល
- កសាងផែនការបណ្តុះបណ្តាលមន្ត្រីនគរបាលជាតិតាមការកំណត់
- ស្រាវជ្រាវធ្វើទំនើបកម្មខ្លឹមសារឯកសារបង្ហាត់បង្រៀន និងកម្មវិធីបណ្តុះបណ្តាល
- លើកសំណើចាត់បញ្ជូនមន្ត្រីនគរបាលជាតិសិក្សាវគ្គបណ្តុះបណ្តាល វគ្គបំប៉ន និងសិក្ខាសាលាក្នុង និងក្រៅប្រទេសតាមការកំណត់
- រៀបចំបើកវគ្គបណ្តុះបណ្តាលបំប៉នរយៈពេលខ្លីនៅនឹងកន្លែង
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នង-ការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

៣- **ការិយាល័យផ្សព្វផ្សាយអប់រំ** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារផ្សព្វផ្សាយអប់រំ ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារផ្សព្វផ្សាយអប់រំ
- ធ្វើការងារផ្សព្វផ្សាយអប់រំដល់មន្ត្រីក្រោមឱវាទស្នងការដ្ឋាន ដើម្បីជានាការអនុវត្តមុខវិជ្ជាជីវៈសារព័ត៌មាន
- ចាត់វិធានការជំនាញអប់រំសតិអារម្មណ៍ប្រជាពលរដ្ឋ ដើម្បីចូលរួមគាំទ្រកិច្ចប្រតិបត្តិការគ្រប់មុខជំនាញរបស់នគរបាលជាតិ
- ផ្សព្វផ្សាយព័ត៌មានតាមរយៈទស្សនាវដ្តី នាទីសន្តិសុខមាតុភូមិ គេហទំព័រ បណ្តាញសង្គម អំពីសមិទ្ធផលនានា និងការរីកចម្រើនរបស់សង្គមជាតិ ដែលឆ្លុះបញ្ចាំងពីសកម្មភាព និងស្នាដៃរបស់រាជរដ្ឋាភិបាល ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ មន្ត្រីនគរបាលជាតិ ស្របតាមវិជ្ជាជីវៈសារព័ត៌មាន
- ប្រមូល ចងក្រងនូវឯកសារ លិខិតបទដ្ឋានគតិយុត្ត សមិទ្ធផល ស្នាដៃជាប្រវត្តិសាស្ត្រនានារបស់នគរបាលជាតិកម្ពុជាគ្រប់ជំនាន់ ដើម្បីរៀបចំទុកដាក់ ថែរក្សាក្នុងបណ្ណាល័យ
- ពង្រឹងសមត្ថភាពមន្ត្រីជំនាញផ្សព្វផ្សាយអប់រំ អំពីជំនាញវិជ្ជាជីវៈសារព័ត៌មាន
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**ខ- ផែនការងារសេនាធិការ**

១- **ការិយាល័យរដ្ឋបាល** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងាររដ្ឋបាល និងបញ្ជូនបញ្ហារបស់ស្នងការទៅអង្គភាពក្រោមឱវាទ ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងាររបៀប និងទំនាក់ទំនងសាធារណៈ
- ធ្វើការងាររបៀប ទទួល និងបញ្ជូនលិខិតចេញ ចូលទៅតាមជំនាញតាមការកំណត់
- រៀបចំការប្រជុំ កន្លែងធ្វើការ ពិធីការ និងការងារអនាម័យរបស់ស្នងការដ្ឋាន
- តាមដានត្រួតពិនិត្យការអនុវត្តបទបញ្ជា សារាចរ សេចក្តីណែនាំផ្សេងៗ
- ស្រាវជ្រាវរៀបចំកសាងលិខិតបទដ្ឋាន បទបញ្ជាផ្ទៃក្នុង និងរបៀបរបបការងារជូនស្នងការពិនិត្យសម្រេច
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

២- **ការិយាល័យសរុប ផែនការ** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារសរុប ផែនការ ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់កសាងផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងទិសដៅការងាររបស់ស្នងការដ្ឋាន
- ប្រមូលរបាយការណ៍ បូកសរុប វិភាគព័ត៌មានសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពសង្គម និងលទ្ធផលកិច្ចប្រតិបត្តិការរបស់នគរបាលជាតិដើម្បីមានវិធានការ
- ផ្សព្វផ្សាយ និងតាមដានការអនុវត្តផែនការសកម្មភាពរបស់ស្នងការដ្ឋាន ព្រមទាំងបូកសរុបដកពិសោធន៍កិច្ចប្រតិបត្តិការ
- ណែនាំតាមដានត្រួតពិនិត្យ និងបូកសរុបការអនុវត្តគោលនយោបាយ (ភូមិ ឃុំមានសុវត្ថិភាព)

- គ្រប់គ្រង និងដំណើរការប្រព័ន្ធកត់ត្រាទិន្នន័យរបស់ស្នងការដ្ឋាន
- រៀបចំចងក្រងទុកដាក់តំកល់ និងថែរក្សាឯកសារតាមគោលការណ៍បច្ចេកទេស
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**៣- ការិយាល័យវិទ្យុទាក់ទង** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារវិទ្យុទាក់ទង ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្ដើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារវិទ្យុទាក់ទង
- គ្រប់គ្រង និងប្រើប្រាស់វិទ្យុទាក់ទងដើម្បីកិច្ចប្រតិបត្តិការ
- អនុវត្តការងារបញ្ជូនទទួលព័ត៌មានតាមគ្រប់មធ្យោបាយរវាងស្នងការដ្ឋានជាមួយអង្គភាពក្រោមឱវាទ
- តាមដានការបម្រែបម្រួលនៃទំនាក់ទំនង និងមានវិធានការ ដើម្បីធានាប្រសិទ្ធភាព សុវត្ថិភាព និងនិរន្តរភាពនៃដំណើរការបញ្ជូនទទួលព័ត៌មាន
- ចុះបញ្ជីគ្រប់គ្រង និងបែងចែកព័ត៌មានទៅតាមអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ និងវរសេនាតូចនគរបាលការពារព្រំដែនគោក
- លើកគម្រោងប្រើប្រាស់ និងថែទាំជួសជុលវិទ្យុគមនាគមន៍គ្រប់ប្រភេទរបស់ស្នងការដ្ឋាន
- ប្រចាំការ២៤ម៉ោង ដើម្បីទទួលព័ត៌មានទាន់ហេតុការណ៍ពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធដល់សន្តិសុខសណ្ដាប់ធ្នាប់សង្គម
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**៤- ការិយាល័យអក្សរសម្ងាត់** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារអក្សរសម្ងាត់ ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្ដើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារអក្សរសម្ងាត់
- ទទួល និងបញ្ជូនសារទូរលេខសម្ងាត់ទៅស្ថាប័ន អង្គភាពពាក់ព័ន្ធ
- បាំងសារទូរលេខសម្ងាត់ ប្រែសារទូរលេខសម្ងាត់ប្រព័ន្ធទាក់ទងអក្សរសម្ងាត់របស់ស្នងការដ្ឋាន
- លើកគម្រោងប្រើប្រាស់ និងថែទាំជួសជុលសម្ភារបរិក្ខារ និងម៉ាស៊ីនសារទូរលេខសម្ងាត់
- ចុះបញ្ជី និងរក្សាទុកសារទូរលេខសម្ងាត់
- បញ្ជូនសារទូរលេខសម្ងាត់តាមប្រព័ន្ធអ៊ីនធឺណែត អ៊ីម៉ែល ទូរសារ និងប្រៃសណីយ៍ទូរគមនាគមន៍
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**៥- ការិយាល័យកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាល** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាល ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាល
- គ្រប់គ្រង ដឹកនាំ ណែនាំមន្ត្រីប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ អំពីកិច្ចការនគរបាល និងសហគមន៍
- កសាងផែនការ និងរបៀបរបបធ្វើការងាររបស់នគរបាល និងសហគមន៍ស្របតាមតួនាទី ភារកិច្ចតាមការកំណត់
- ទំនាក់ទំនង និងសហការជាមួយរដ្ឋបាលដែនដី សមត្ថកិច្ចពាក់ព័ន្ធ និងសហគមន៍ ក្នុងការក្តាប់សភាពការណ៍ក្នុងមូលដ្ឋាន ដើម្បីបម្រើការងារជំនាញ
- កត់ត្រាទិន្នន័យព័ត៌មានមន្ត្រីប៉ុស្តិ៍នគរបាលរដ្ឋបាលដើម្បីបម្រើផែនការបណ្តុះបណ្តាល បំប៉នជំនាញ
- ណែនាំតាមដានត្រួតពិនិត្យការងារគ្រប់គ្រង និងថែរក្សាអគារទីស្នាក់ការរបស់ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់
- ក្តាប់សំណូមពរពីប្រជាពលរដ្ឋ សហគមន៍ សហគ្រាស គ្រឹះស្ថានសិក្សា វត្តអារ៉ាម ដើម្បីមានវិធានការដោះស្រាយ
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នង-ការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**៦- ការិយាល័យអន្តរាគមន៍ និងតម្រួតបទបញ្ជា** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារអន្តរាគមន៍ និងតម្រួតបទបញ្ជា ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារអន្តរាគមន៍ និងតម្រួតបទបញ្ជា
- ចាត់វិធានការអន្តរាគមន៍បង្ការ និងបង្ក្រាបសកម្មភាពភេរវកម្ម ការធ្វើបាតុកម្ម កុប្បកម្មខុសច្បាប់ ដែលបង្កមហន្តរាយដល់សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម
- សហការជាមួយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធអនុវត្តវិធានការបង្ការទប់ស្កាត់គ្រោះមហន្តរាយ ដើម្បីការពារទ្រព្យសម្បត្តិសាធារណៈ អាយុជីវិត និងទ្រព្យសម្បត្តិប្រជាពលរដ្ឋ
- ត្រៀមមធ្យោបាយសម្ភារ ឧបករណ៍បច្ចេកទេស អាវុធយុទ្ធភ័ណ្ឌ និងចល័តកម្លាំងប្រចាំការការពារសន្តិសុខ សុវត្ថិភាពគណៈប្រតិភូតាមគោលដៅ
- លើកគម្រោងផែនការ និងចាត់វិធានការជំនាញការពារបណ្តាគោលដៅសំខាន់ៗតាមការកំណត់
- អនុវត្តវិធានការជំនាញយាមប្រចាំការ ត្រួតពិនិត្យឆែកឆេរ និងរៀបចំសណ្តាប់ធ្នាប់លើមធ្យោបាយ និងមនុស្សចេញចូលគោលដៅក្នុងសមត្ថកិច្ចទទួលខុសត្រូវ
- ល្បាតចល័តការពារនៅតាមគោលដៅសំខាន់ៗ និងធ្វើអន្តរាគមន៍នៅទីកន្លែងដែលមានមនុស្សតវ៉ា ការធ្វើបាតុកម្ម និងការសម្តែងមតិនៅទីសាធារណៈ ដើម្បីធានាសន្តិសុខសណ្តាប់ធ្នាប់
- សហការជាមួយអង្គភាពពាក់ព័ន្ធត្រៀមកម្លាំងចាត់វិធានការចាំបាច់ដើម្បីសង្គ្រោះប្រជាពលរដ្ឋដែលជួបគ្រោះមហន្តរាយផ្សេងៗ
- ផ្សព្វផ្សាយ និងតាមដានត្រួតពិនិត្យការអនុវត្តក្រមសីលធម៌ បទកំណត់ បទបញ្ជា លិខិតបទដ្ឋានគតិយុត្តនានា ដើម្បីលើកកម្ពស់សីលធម៌ គុណធម៌ កិត្តិយស សេចក្តីថ្លៃថ្នូររបស់នគរបាលជាតិ

- ហ្វឹកហ្វឺនមុខជំនាញរបៀប សណ្ដាប់ធ្នាប់កងជួរ និងយុទ្ធសាស្ត្របុគ្គលដល់មន្ត្រីនគរបាលជាតិ
- រៀបចំទទួលបដិសណ្ឋារកិច្ចថ្នាក់ដឹកនាំជាតិ និងអន្តរជាតិ
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**គ- ផែនការងារនគរបាលព្រហ្មទណ្ឌ**

**១- ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារព្រហ្មទណ្ឌកម្រិតធ្ងន់ ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្ដើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារព្រហ្មទណ្ឌកម្រិតធ្ងន់
- ចាត់វិធានការជំនាញបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសឧក្រិដ្ឋ ស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ
- ស៊ើបអង្កេតស្រាវជ្រាវបទល្មើស ចាប់ខ្លួន ឃាត់ខ្លួន ឃុំខ្លួនបណ្ដោះអាសន្ន រៀបចំ និងបញ្ជូនសំណុំរឿង ជនសង្ស័យ ព្រមទាំងវត្ថុតាងទៅអយ្យការតាមច្បាប់
- អនុវត្ត និងសហការអនុវត្តសាលក្រម សាលដីកា និងដីកានានារបស់ស្ថាប័នអយ្យការ និងតុលាការ
- ប្រើប្រាស់វិធីសាស្ត្រជំនាញតាមដានស្រាវជ្រាវស៊ើបបញ្ជាក់កំណត់អត្តសញ្ញាណ ប្រវត្តិសកម្មភាពរបស់ជនសង្ស័យល្មើសច្បាប់
- រៀបចំវិធីសាស្ត្របង្ការទប់ស្កាត់ និងបង្ក្រាបបទឧក្រិដ្ឋតាមក្រមនីតិវិធីព្រហ្មទណ្ឌ
- ស៊ើបអង្កេតបឋម និងអនុវត្តដីកាចាត់ឲ្យសាកសួរជំនួស ក្នុងករណីបទល្មើសជាក់ស្ដែងតាមនីតិវិធីព្រហ្មទណ្ឌ
- រៀបចំការងារទទួលពាក្យបណ្ដឹង ធ្វើកំណត់ហេតុ និងសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធចុះពិនិត្យកន្លែងកើតហេតុប្រមូលព័ត៌មាន សម្ភារ វត្ថុតាង និងកំណត់អត្តសញ្ញាណជនសង្ស័យ
- កសាង និងប្រើប្រាស់ភ្នាក់ងារសម្ងាត់ ដើម្បីបម្រើការងារជំនាញតាមការកំណត់
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**២- ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារព្រហ្មទណ្ឌកម្រិតស្រាល ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្ដើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារព្រហ្មទណ្ឌកម្រិតស្រាល
- ចាត់វិធានការជំនាញបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសមជ្ឈិមស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ
- ស៊ើបអង្កេតស្រាវជ្រាវបទល្មើស ចាប់ខ្លួន ឃាត់ខ្លួន ឃុំខ្លួនបណ្ដោះអាសន្ន រៀបចំ និងបញ្ជូនសំណុំរឿង ជនសង្ស័យ ព្រមទាំងវត្ថុតាងទៅអយ្យការតាមច្បាប់
- អនុវត្ត និងសហការអនុវត្តសាលក្រម សាលដីកា និងដីកានានារបស់ស្ថាប័នអយ្យការ និងតុលាការ
- ប្រើប្រាស់វិធីសាស្ត្រជំនាញតាមដានស្រាវជ្រាវស៊ើបបញ្ជាក់កំណត់អត្តសញ្ញាណ ប្រវត្តិសកម្មភាពរបស់ជនសង្ស័យល្មើសច្បាប់

- រៀបចំវិធីសាស្ត្របង្ការទប់ស្កាត់ និងបង្ក្រាបបទមជ្ឈឹមតាមក្រមនីតិវិធីព្រហ្មទណ្ឌ
- ស៊ើបអង្កេតបឋម និងអនុវត្តដីកាចាត់ឲ្យសាកសួរជំនួស ក្នុងករណីបទល្មើសជាក់ស្តែងតាមនីតិវិធីព្រហ្មទណ្ឌ
- រៀបចំការងារទទួលពាក្យបណ្តឹង ធ្វើកំណត់ហេតុ និងសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធចុះពិនិត្យកន្លែងកើតហេតុប្រមូលព័ត៌មាន សម្ភារ វត្ថុតាង និងកំណត់អត្តសញ្ញាណជនសង្ស័យ
- កសាង និងប្រើប្រាស់ភ្នាក់ងារសម្ងាត់ ដើម្បីបម្រើការងារជំនាញតាមការកំណត់
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នង-ការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**៣- ការិយាល័យនគរបាលបច្ចេកទេស និងវិទ្យាសាស្ត្រ** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារបច្ចេកទេស និងវិទ្យាសាស្ត្រ ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារបច្ចេកទេស និងវិទ្យាសាស្ត្រ
- សហការធ្វើកោសល្យវិច័យសាមញ្ញ កោសល្យវិច័យគីមីសាស្ត្រ និងជីវសាស្ត្រ
- ចាត់តាំងណែនាំអនុវត្តវិធានការជំនាញក្នុងការចុះទៅកន្លែងកើតហេតុ ដើម្បីធ្វើការវាយតម្លៃអំពីអត្ថិភាពនៃបទល្មើស ឬឧបទ្ទវហេតុផ្សេងៗ និងកត់ត្រាហេតុការណ៍ដែលកើតឡើង
- អនុវត្តវិធានការជំនាញក្នុងការរៀបចំ កសាង គ្រប់គ្រងសលាកប័ត្រជនសង្ស័យដែលបានឃាត់ខ្លួន បញ្ចូលទិន្នន័យក្នុងប្រព័ន្ធព័ត៌មានវិទ្យា
- សហការប្រើប្រាស់វិធីសាស្ត្រជំនាញធ្វើកោសល្យវិច័យដើម្បីកំណត់អត្តសញ្ញាណ ប្រភពនៃបទ-ល្មើសនានា
- កសាង គ្រប់គ្រងបណ្ណសារ និងរក្សាទុកទិន្នន័យគំរូប្រៀបធៀប ដើម្បីបម្រើការងារជំនាញស្រាវជ្រាវស៊ើបអង្កេត
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នង-ការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**ឃ- ផែនការងារនគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច**

**ការិយាល័យនគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារប្រឆាំងបទល្មើសសេដ្ឋកិច្ច ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារប្រឆាំងបទល្មើសសេដ្ឋកិច្ច
- សហការជាមួយសមត្ថកិច្ចជំនាញពាក់ព័ន្ធលើការងារមានជាអាទិ៍ ៖
  + ចាត់វិធានការជំនាញបង្ការ និងបង្ក្រាបវិច្ឆេទកម្មសេដ្ឋកិច្ច ការស្តុកទំនិញខុសច្បាប់ ការផលិត ការធ្វើចរាចរទំនិញក្លែងក្លាយ និងទំនិញហួសរយៈពេលប្រើ
  + ចាត់វិធានការបង្ការ និងបង្ក្រាបបទល្មើសសារពើពន្ធគ្រប់ប្រភេទ និងបទល្មើសក្នុងការលក់ ការផ្សាយថ្លៃទំនិញ ការផ្សាយបញ្ឆោតបន្លំ

+ ស្វែងរកមុខសញ្ញាល្មើសសារពើពន្ធ ដែលរូបវន្តបុគ្គល នីតិបុគ្គលនានាកំពុងធ្វើ ពាណិជ្ជកម្ម អាជីវកម្ម និងផលិតកម្ម ដើម្បីមានវិធានការ

+ តាមដានស្រាវជ្រាវស៊ើបអង្កេតលើរូបវន្តបុគ្គល នីតិបុគ្គលដែលនាំចូល ផលិត ធ្វើចរាចរនៅលើទីផ្សារនូវផលិតផលក្លែងបន្លំម៉ាក សម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកពាណិជ្ជនាម និងការប្រកួតប្រជែងមិនស្មោះត្រង់ ដើម្បីមានវិធានការ

+ អនុវត្តវិធានការស្រាវជ្រាវស៊ើបអង្កេតលើទីតាំងផលិតកម្មគ្មានច្បាប់អនុញ្ញាត ឬកំពុងរំលោភច្បាប់ ដើម្បីកសាងសំណុំរឿងបញ្ជូនទៅតុលាការតាមនីតិវិធី

+ តាមដានស៊ើបអង្កេតទីតាំងអាជីវកម្ម ផលិតកម្ម និងចុះត្រួតពិនិត្យការបំពុលបរិស្ថាន

- អនុវត្តវិធានការជំនាញក្នុងការងារប្រយុទ្ធប្រឆាំងបទល្មើសអាជីវកម្ម សេវាកម្ម ផលិតកម្ម
- ធ្វើបច្ចុប្បន្នភាពទិន្នន័យព័ត៌មានរបស់អាជីវកម្ម សេវាកម្ម និងផលិតកម្មស្របច្បាប់ និងមិនស្របច្បាប់ ដើម្បីបម្រើការងារជំនាញស្រាវជ្រាវស៊ើបអង្កេត និងគ្រប់គ្រង
- អនុវត្តវិធានការជំនាញស្រាវជ្រាវប្រមូលព័ត៌មាន និងត្រួតពិនិត្យតម្លៃទំនិញនៅលើទីផ្សារ វិភាគវាយតម្លៃរកមូលហេតុបាតុភាពអវិជ្ជមានដែលប៉ះពាល់ដល់ស្ថិរភាពតម្លៃទំនិញលើទីផ្សារ
- ស្រាវជ្រាវ បង្ការទប់ស្កាត់ និងបង្ក្រាបសកម្មភាពធ្វើសន្និធិទំនិញខុសច្បាប់ ការផលិត ការធ្វើចរាចរទំនិញលើទីផ្សារមានបរិមាណមិនត្រឹមត្រូវតាមស្តង់ដារ និងមាត្រសាស្ត្រ ទំនិញខូចគុណភាព ឬទំនិញហាមឃាត់ និងការក្លែងបន្លំគុណភាព
- កសាង និងប្រើប្រាស់ភ្នាក់ងារសម្ងាត់ ដើម្បីបម្រើការងារជំនាញតាមការកំណត់
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**ង- ផែនការងារប្រឆាំងគ្រឿងញៀន**

**ការិយាល័យប្រឆាំងគ្រឿងញៀន** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារប្រឆាំងគ្រឿងញៀន ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារប្រឆាំងគ្រឿងញៀន
- ចាត់វិធានការជំនាញបង្ការ និងបង្ក្រាបការប្រើប្រាស់ ការដឹកជញ្ជូន ការធ្វើជំនួញគ្រឿងញៀនគ្រប់ប្រភេទ
- ស្រាវជ្រាវតាមដានបុគ្គល យានជំនិះ ទីកន្លែងគោលដៅ និងប្រមូលព័ត៌មានពាក់ព័ន្ធសកម្មភាពអត្តសញ្ញាណជនសង្ស័យ ដើម្បីបម្រើការងារជំនាញ
- ស្រាវជ្រាវស្វែងរកច្រកផ្លូវធ្វើសកម្មភាព និងសមាសភាពក្រុមឧក្រិដ្ឋជនគ្រឿងញៀនមានការចាត់តាំងជាប្រព័ន្ធជួញដូរដឹកជញ្ជូន និងផលិតគ្រឿងញៀន
- សហការជាមួយអង្គភាពពាក់ព័ន្ធប្រមូលព័ត៌មានអំពីសកម្មភាពជំនួញសារធាតុញៀន សារធាតុគីមីផ្សំហាមឃាត់ និងការផលិតកែច្នៃគ្រឿងញៀនខុសច្បាប់ ការដាំដុះរុក្ខជាតិញៀន ការជួញដូរ ការចរាចរ ការដឹកជញ្ជូន ការរក្សាទុក ការស្តុកទុកគ្រឿងញៀនខុសច្បាប់

- ធ្វើបញ្ជីកំណត់មុខសញ្ញាប្រព្រឹត្តបទល្មើសគ្រឿងញៀនគ្រប់ប្រភេទ គោលដៅប្រឈមខ្ពស់ និងបណ្តាច្រកព្រំដែនដឹកជញ្ជូនឆ្លងកាត់
- សិក្សាល្បិចកលការលាក់បំពួន ការដឹកជញ្ជូន និងសហការត្រួតពិនិត្យស្វែងរកការនាំចេញ នាំចូល ដឹកជញ្ជូន ការផលិតស្តុកទុកសារធាតុញៀន សារធាតុគីមីផ្សំហាមឃាត់ ឱសថមានផ្ទុកសារធាតុញៀនដែលច្បាប់កំណត់ និងការបង្វែរសារធាតុគីមីផ្សំពីជំនួញស្របច្បាប់ទៅជាការផលិតគ្រឿងញៀនខុសច្បាប់
- ធ្វើជំរឿន និងគ្រប់គ្រងជនរងគ្រោះដោយគ្រឿងញៀន ស្រាវជ្រាវស្វែងរកអ្នកញៀនគ្រឿងញៀននៅតាមលំនៅដ្ឋាន អង្គភាពប្រមូលផ្តុំ មណ្ឌលស្តារនីតិសម្បទា និងចូលរួមជាមួយអាណាព្យាបាលធ្វើការអប់រំឲ្យទៅមណ្ឌលសុខភាពឬមណ្ឌលអប់រំព្យាបាលតាមច្បាប់
- បែងចែកប្រភេទអ្នករងគ្រោះដោយការប្រើប្រាស់គ្រឿងញៀនតាមប្រភេទគ្រឿងញៀន ប្រភេទអាយុ មុខរបរ និងរូបភាពការប្រើប្រាស់ ដើម្បីលើកសំណើគោលការណ៍បន្សាប និងព្យាបាល
- ចងក្រងបញ្ជី និងគ្រប់គ្រងគោលដៅប្រឈមងាយរងគ្រោះមានជាអាទិ៍ ៖ គ្រឹះស្ថានសិក្សា ក្លឹបរាត្រី ទីតាំងប្រកបអាជីវកម្ម ខារ៉ាអូខេ រង្គសាល បើកល្បែង ផ្ទះជួល ផ្ទះសំណាក់ សណ្ឋាគារ ខុនដូ តំបន់មិនរៀបរយដែលងាយកើតបទល្មើស
- ស្រាវជ្រាវ និងគ្រប់គ្រងគោលដៅអាជីវកម្មរូបិយប័ណ្ណ រូបិយវត្ថុ គ្រឹះស្ថានឥណទាន ស្ថាប័នហិរញ្ញវត្ថុ បនល្បែង ក្រុមហ៊ុនរដ្ឋ ឯកជនដែលមាន ឬគ្មានច្បាប់អនុញ្ញាតដើម្បីស្វែងរកអត្តសញ្ញាណម្ចាស់សាច់ប្រាក់ ប្រភពរូបិយប័ណ្ណ រូបិយវត្ថុ និងការចោចសោច់ប្រាក់ ការផ្ទេរ ការជួញដូរចលន អចលនទ្រព្យដែលជាការលាងលុយយកខ្នក់មកជាលុយស្របច្បាប់
- ដំណើរការស្រាវជ្រាវល្បិចកល សកម្មភាពរបស់ឧក្រិដ្ឋជនគ្រឿងញៀនក្នុងការសម្អាតប្រាក់ដែលបានមកពីផលជំនួញគ្រឿងញៀនខុសច្បាប់
- កសាង និងប្រើប្រាស់ភ្នាក់ងារសម្ងាត់ ដើម្បីបម្រើការងារជំនាញតាមការកំណត់
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នង-ការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**ច- ផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងការងារយេនឌ័រ**

**ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន
- ចាត់វិធានការជំនាញបង្ការ និងបង្ក្រាបសកម្មភាពរំលោភលើរូបរាងកាយបុគ្គល និងសេចក្តីថ្លៃថ្នូរ
- អនុវត្តគោលការណ៍ វិធីសាស្ត្របង្ការទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរ ការរត់ពន្ធមនុស្ស អំពើហិង្សាក្នុងគ្រួសារ ការប្រទូស្តកេរខ្មាស់ និងរំលោភសេពសន្ថវៈលើនីតិជន អនីតិជន និងកាមសាស្ត្រលើកុមារ
- ចាប់ខ្លួនចារី សហចារី ដកហូតសម្ភារ វត្ថុតាងពាក់ព័ន្ធ និងកសាងសំណុំរឿងបញ្ជូនទៅតុលាការតាមនីតិវិធី

- ស៊ើបអង្កេតរាល់ករណី និងពាក្យបណ្តឹងដែលពាក់ព័ន្ធអំពើជួញដូរ អាជីវកម្មផ្លូវភេទ អំពើកាមសាស្ត្រ និងអំពើកេងប្រវ័ញ្ចគ្រប់រូបភាពលើកុមារ
- អនុវត្តវិធានការជំនាញស្រាវជ្រាវស៊ើបអង្កេតបណ្តាគោលដៅបញ្ចាំងវីដេអូអាសអាភាស និងទីតាំងផលិតចែកចាយរូបភាពអាសអាភាស
- ស៊ើបអង្កេតរាល់ករណី និងពាក្យបណ្តឹងពាក់ព័ន្ធអំពើហិង្សាក្នុងគ្រួសារដែលប៉ះពាល់ដល់រូបរាងកាយ ការធ្វើទារុណកម្ម និងអំពើប្រទូស្តកេរខ្មាស់ រំលោភសេពសន្ថវៈលើនីតិជន និងអនីតិជន
- សហការជាមួយស្ថាប័នពាក់ព័ន្ធដើម្បីធ្វើកោសល្យវិច័យស្លាកស្នាម របួសដោយអំពើរំលោភសេពសន្ថវៈលើនីតិជន និងអនីតិជន
- រៀបចំបណ្តាញទូរស័ព្ទពិសេស វិទ្យុទាក់ទង ចាត់កម្លាំងប្រចាំការ ២៤ម៉ោង សម្រាប់ទទួលព័ត៌មានអំពីហេតុការណ៍ដែលកើតឡើង
- កសាង និងប្រើប្រាស់ភ្នាក់ងារសម្ងាត់ ដើម្បីបម្រើការងារជំនាញតាមការកំណត់
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**ធ- ផែនការងារសន្តិសុខ**

**១- ការិយាល័យសន្តិសុខផ្ទៃក្នុង** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារសន្តិសុខផ្ទៃក្នុង ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារសន្តិសុខផ្ទៃក្នុង
- ប្រមូល និងវិភាគព័ត៌មានគ្រប់ប្រភេទដែលពាក់ព័ន្ធដល់សន្តិសុខជាតិ
- ស៊ើបបញ្ជាក់ព័ត៌មាន ចងក្រងទុកជាឯកសារជាតិ និងឯកសារជំនាញ
- ប្រមូលព័ត៌មានសន្តិសុខផ្ទៃក្នុង ដើម្បីស៊ើបបញ្ជាក់ប្រមូលភស្តុតាង បម្រើកិច្ចប្រតិបត្តិការជំនាញតាមច្បាប់កំណត់
- សហការជាមួយអង្គភាពពាក់ព័ន្ធស៊ើបបញ្ជាក់ព័ត៌មាន ដើម្បីបង្ការ និងទប់ស្កាត់សកម្មភាពធ្វើឲ្យបែកការសម្ងាត់រដ្ឋ
- សហការជាមួយស្ថាប័នពាក់ព័ន្ធលើវិធានការការពារសន្តិសុខ សុវត្ថិភាពជូនឥស្សរជន និងគោលដៅសំខាន់ៗ
- សហការជាមួយអង្គភាពពាក់ព័ន្ធដែលមានសមត្ថកិច្ចគ្រប់គ្រងការងារសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ដើម្បីបង្ការទប់ស្កាត់រាល់សកម្មភាពបង្កអស្ថិរភាពនយោបាយ ចលាចលសង្គម
- សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធស្រាវជ្រាវបង្ការ ទប់ស្កាត់ការសម្អាតប្រាក់ហិរញ្ញប្បទានភេរវកម្ម ការបង្កើតតំបន់អប្បគមន៍ កសាងកម្លាំងប្រដាប់អាវុធខុសច្បាប់ កុប្បកម្ម និងអំពើទុច្ចរិតនានា
- ចាត់វិធានការស្រាវជ្រាវ និងតាមដានសកម្មភាពការលួចជ្រៀតចូលដោយប្រើឈ្មោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលនានា ធ្វើសកម្មភាពខុសច្បាប់ និងការនាំពលករខ្មែរចេញធ្វើការក្រៅប្រទេស
- សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធស្រាវជ្រាវប្រមូលព័ត៌មានពាក់ព័ន្ធសកម្មភាពខុសច្បាប់ក្នុងវិស័យអប់រំ វប្បធម៌ សិល្បៈ ប្រព័ន្ធឃោសនា ភេរវកម្ម ផលិតកម្ម ផ្សព្វផ្សាយ និងការចែកចាយព័ត៌មានតាមគ្រប់មធ្យោបាយ

- កសាង និងប្រើប្រាស់ភ្នាក់ងារសម្ងាត់ដើម្បីបម្រើការងារជំនាញតាមការកំណត់
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នង-ការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**២- ការិយាល័យប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្ដើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន
- ប្រមូលព័ត៌មាន និងស៊ើបបញ្ជាក់រាល់ព័ត៌មានពាក់ព័ន្ធអំពើភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន បទល្មើសប្រឆាំងនឹងសន្តិសុខជាតិ
- ស្វែងរកចាប់ខ្លួនមុខសញ្ញាភេរវជន និងកសាងសំណុំរឿងបញ្ជូនទៅតុលាការតាមនីតិវិធី
- ប្រមូលព័ត៌មានពីគ្រប់មជ្ឈដ្ឋាន ដើម្បីពិនិត្យវិភាគវាយតម្លៃអំពីឧបាយកល និងសកម្មភាពភេរវកម្ម
- ស្រាវជ្រាវបង្ការទប់ស្កាត់បាតុភាពទំនាស់ក្នុងសហគមន៍ជាតិសាសន៍ សាសនា ការបង្កើតតំបន់ អបយ្ប-គមន៍ កសាងកម្លាំងប្រដាប់អាវុធខុសច្បាប់
- ចាត់វិធានការស្រាវជ្រាវក្រុមភេរវករ និងបណ្ដាញអង្គការភេរវកម្មដែលមានការចាត់តាំង
- ចងក្រង គ្រប់គ្រងបញ្ជីខ្មៅមុខសញ្ញាភេរវករ និងអង្គការភេរវកម្ម
- ស្រាវជ្រាវ បង្ការទប់ស្កាត់សកម្មភាពប្រមូលផ្ដុំមនុស្សខុសច្បាប់មានជាអាទិ៍ ៖ បាតុកម្ម កូដកម្ម កុប្បកម្ម វិទ្ធង្សនា និងការបង្កចលាចលផ្សេងៗ
- ចាត់វិធានការស្រាវជ្រាវចងក្រងបញ្ជីអង្គការ ក្រុមហ៊ុន និងមុខសញ្ញាពាក់ព័ន្ធការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- ស្រាវជ្រាវរចនាសម្ព័ន្ធ និងដំឡើងបញ្ជីអង្គការមុខសញ្ញាសង្ស័យឧក្រិដ្ឋកម្មឆ្លងដែន
- ចងក្រងដំឡើងបញ្ជីសហគមន៍ទៅតាមប្រភេទ និងនិកាយសាសនានីមួយៗ
- ស្រាវជ្រាវមុខសញ្ញា និងសមាសភាពដែលយកសហគមន៍ និងសាសនាធ្វើសកម្មភាពក្រោមរូបភាពផ្សេងៗ ដើម្បីញុះញង់បង្កចលាចលអស្ថិរភាពសង្គម
- ស្រាវជ្រាវអនុវត្តដីកា និងការពារជនសង្ស័យដែលត្រូវឃុំខ្លួនបណ្ដោះអាសន្នតាមនីតិវិធី
- កសាង និងប្រើប្រាស់ភ្នាក់ងារសម្ងាត់ដើម្បីបម្រើការងារជំនាញតាមការកំណត់
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នង-ការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**៣- ការិយាល័យគ្រប់គ្រងសន្តិសុខឯកជន** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារគ្រប់គ្រងសន្តិសុខឯកជន ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្ដើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារគ្រប់គ្រងសន្តិសុខឯកជន
- ត្រួតពិនិត្យសំណុំបែបបទការស្នើសុំច្បាប់អនុញ្ញាតជ្រើសរើសភ្នាក់ងារសន្តិសុខឯកជនរបស់សហគ្រាស គ្រឹះស្ថាននានា

- គ្រប់គ្រងទិន្នន័យ សំណុំបែបបទ និងបញ្ជីឈ្មោះភ្នាក់ងារសន្តិសុខឯកជនតាមប្រព័ន្ធព័ត៌មានវិទ្យា
- លើកផែនការបណ្តុះបណ្តាលជំនាញឯកទេស ដល់ភ្នាក់ងារសន្តិសុខឯកជន
- ប្រមូលព័ត៌មានតាមបណ្តាសហគ្រាស គ្រឹះស្ថាននានាដែលប្រើសេវាសន្តិសុខឯកជន
- ត្រួតពិនិត្យណែនាំសហគ្រាស គ្រឹះស្ថាននានា ដែលប្រើសេវាសន្តិសុខឯកជនផ្ទាល់ខ្លួនអនុវត្តតាមកិច្ចសន្យាជាមួយស្នងការដ្ឋាននគរបាលរាជធានី ខេត្ត
- ត្រួតពិនិត្យឧបករណ៍ សម្ភារបច្ចេកទេស មធ្យោបាយ សត្វសម្រាប់បម្រើសកម្មភាពការពារសន្តិសុខ
- សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធអន្តរាគមន៍ និងស៊ើបអង្កេតរាល់បាតុភាព ឬឧបទ្ទវហេតុដែលកើតឡើងនៅតាមគោលដៅសហគ្រាស គ្រឹះស្ថាននានាដែលប្រើសេវាសន្តិសុខផ្ទាល់ខ្លួន
- សហការជាមួយសហគ្រាស គ្រឹះស្ថាននានាដែលប្រើសេវាសន្តិសុខឯកជនផ្ទាល់ខ្លួន ការពារទីតាំង និងការពារការដឹកជញ្ជូនរូបិយប័ណ្ណ ទ្រព្យសម្បត្តិ និងវត្ថុមានតម្លៃស្របច្បាប់
- លើកយោបល់សុំគោលការណ៍លុបចោល ឬផ្អាកសកម្មភាពជាបណ្តោះអាសន្ន ឬដកហូតលិខិតអនុញ្ញាត ឬផ្តល់ឡើងវិញចំពោះសហគ្រាស គ្រឹះស្ថាន ប្រើសេវាសន្តិសុខផ្ទាល់ខ្លួនដែលធ្វើសកម្មភាពផ្ទុយពីលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នង-ការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

៤- **ការិយាល័យប្រឆាំងបទល្មើសបច្ចេកវិទ្យា** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារប្រឆាំងបទល្មើសបច្ចេកវិទ្យា ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារប្រឆាំងបទល្មើសបច្ចេកវិទ្យា
- សហការជាមួយសាខាចែកចាយសេវាទូរគមនាគមន៍គ្រប់ប្រភេទ ដើម្បីត្រួតពិនិត្យការចុះបញ្ជី ភ្ជាប់ប្រើប្រាស់សេវាទូរគមនាគមន៍ និងបច្ចេកវិទ្យាតាមការកំណត់
- សហការជាមួយស្ថាប័នរដ្ឋ និងឯកជន ដែលធ្វើអាជីវកម្មសេវាហិរញ្ញវត្ថុ ដើម្បីស្រាវជ្រាវស៊ើបអង្កេតប្រមូលភស្តុតាង និងបង្ក្រាបបទល្មើសហិរញ្ញវត្ថុតាមប្រព័ន្ធបច្ចេកវិទ្យា
- តាមដានប្រមូលព័ត៌មានលើបណ្តាញសង្គម និងអ៊ីនធឺណែត វិភាគវាយតម្លៃសភាពការណ៍បង្កអសន្តិសុខ និងអស្ថិរភាពសង្គម
- ស្រាវជ្រាវស៊ើបបញ្ជាក់ ប្រមូលភស្តុតាង និងសាវតារបស់គណនីមុខសញ្ញាប្រព្រឹត្តបទល្មើសតាមបណ្តាញសង្គមបច្ចេកវិទ្យា ដើម្បីកសាងសំណុំរឿងតាមនីតិវិធី
- ធ្វើរបាយការណ៍ស្រាវជ្រាវករណី និងប្រមូល គ្រប់គ្រងវត្ថុតាងជូននាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា ដើម្បីផ្តល់ការណែនាំជំនាញបច្ចេកទេស និងការធ្វើកោសល្យវិច័យបច្ចេកវិទ្យាតាមនីតិវិធី
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នង-ការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

៥- **ការិយាល័យអង្គរក្ស** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារអង្គរក្ស ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្ដើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារអង្គរក្ស
- ការពារសុវត្ថិភាពថ្វាយព្រះមហាក្សត្រ ជូនថ្នាក់ដឹកនាំជាតិ និងអន្តរជាតិក្នុងរង្វង់សមត្ថកិច្ចទទួលខុសត្រូវ
- សហការជាមួយកម្លាំងសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីធានាការពារសន្តិសុខសុវត្ថិភាពជូនថ្នាក់ដឹកនាំជាន់ខ្ពស់ជាតិ ក្នុងពេលបំពេញបេសកកម្ម
- ស្រាវជ្រាវ ក្ដាប់សភាពការណ៍ដើម្បីកសាងផែនការការពារ និងបង្ការទប់ស្កាត់
- ប្រចាំការ២៤ម៉ោង ត្រៀមអន្តរាគមន៍ទប់ស្កាត់រាល់ឧបទ្ទវហេតុដែលកើតឡើងនៅតាមគោលដៅដែលទទួលខុសត្រូវ
- រក្សារបៀបរៀបរយ សណ្ដាប់ធ្នាប់សាធារណៈនៅជុំវិញបរិវេណគោលដៅប្រារព្ធពិធីផ្សេងៗ
- សហការជាមួយស្ថាប័នពាក់ព័ន្ធចាប់ខ្លួន ឃាត់ខ្លួនជនល្មើស រឺជនសង្ស័យដែលមានបំណងធ្វើសកម្មភាពជាក់ស្ដែង
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**ជ- ផែនការងារនគរបាលសណ្ដាប់ធ្នាប់**

១- **ការិយាល័យនគរបាលសណ្ដាប់ធ្នាប់** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារសណ្ដាប់ធ្នាប់ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្ដើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារសណ្ដាប់ធ្នាប់
- ចាត់វិធានការជំនាញក្នុងការរៀបចំសណ្ដាប់ធ្នាប់នៅតាមទីកន្លែងសាធារណៈ
- ល្បាត និងត្រួតពិនិត្យអំពើល្មើសនឹងបទប្បញ្ញត្តិសណ្ដាប់ធ្នាប់សាធារណៈ
- ណែនាំ និងពិន័យចំពោះជនដែលប្រព្រឹត្តល្មើសបទប្បញ្ញត្តិសណ្ដាប់ធ្នាប់សាធារណៈ
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

២- **ការិយាល័យនគរបាលទេសចរណ៍** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារទេសចរណ៍ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្ដើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារទេសចរណ៍
- ចាត់វិធានការជំនាញបង្ការទប់ស្កាត់ និងបង្ក្រាបសកម្មភាពប៉ះពាល់ដល់សុវត្ថិភាពរបស់ទេសចរ
- ស្រាវជ្រាវ ស៊ើបអង្កេត និងដោះស្រាយរាល់បទល្មើសច្បាប់ផ្សេងៗ ដែលប៉ះពាល់ដល់រូបរាងកាយអាយុជីវិត ទ្រព្យសម្បត្តិ និងកិត្តិយសរបស់ទេសចរ
- ពិនិត្យ និងដោះស្រាយពាក្យបណ្ដឹងដែលពាក់ព័ន្ធដល់ទេសចរជាតិ និងអន្តរជាតិ

- ធ្វើកំណត់ហេតុពាក្យបណ្តឹងអំពីការបាត់ខ្លួន ការប៉ះពាល់រូបរាងកាយ ទ្រព្យសម្បត្តិ ផលប្រយោជន៍ និងកិត្តិយសរបស់ទេសចរ
- សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ អនុវត្តការចាប់ខ្លួន ឃាត់ខ្លួនជនល្មើស ក្នុងករណីបទល្មើសជាក់ស្តែងតាមនីតិវិធី
- ចាត់វិធានការជំនាញថែរក្សាការពារសន្តិសុខ សុវត្ថិភាពដល់ទេសចរជាតិ និងអន្តរជាតិដែលមកកម្សាន្ត ឬទស្សនកិច្ច
- រក្សារបៀបរៀបរយសណ្តាប់ធ្នាប់សាធារណៈនៅបរិវេណរមណីយដ្ឋានវប្បធម៌ធម្មជាតិ និងរមណីយដ្ឋានផ្សេងៗទៀត
- បោះទីតាំងប្រចាំការការពារ និងល្បាតចល័តតាមគោលដៅដែលមានការប្រមូលផ្តុំទេសចរ ដើម្បីផ្តល់ ទទួលព័ត៌មាន និងអន្តរាគមន៍ទាន់ពេលវេលា
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

៣- **ការិយាល័យនគរបាលការពារបេតិកភណ្ឌ** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារការពារបេតិកភណ្ឌ ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារការពារបេតិកភណ្ឌ
- ចាត់វិធានការជំនាញការពារទ្រព្យសម្បត្តិវប្បធម៌បេតិកភណ្ឌប្រវត្តិសាស្ត្រជាតិ ក្នុងដែនសមត្ថកិច្ចទទួលខុសត្រូវ
- ឃោសនាផ្សព្វផ្សាយណែនាំអប់រំសង្គមដើម្បីចូលរួមថែរក្សាការពារបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រជាតិ
- ចុះបញ្ជីប័ណ្ណសារបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រជាតិក្នុងប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីបម្រើការងារគ្រប់គ្រងទុកដាក់ និងថែរក្សាការពារ
- សហការជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ សមត្ថកិច្ចពាក់ព័ន្ធ និងប្រជាពលរដ្ឋ ដើម្បីរួមចំណែកការពារបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រជាតិ
- ចាត់វិធានការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសបំផ្លិចបំផ្លាញ លួចលាក់ ប្លន់ ទិញ លក់ ជីករុករកជីកជញ្ជូនបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រជាតិ
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**ឈ- ផែនការងារនគរបាលចរាចរណ៍**

១- **ការិយាល័យនគរបាលចរាចរណ៍ផ្លូវគោក** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារចរាចរណ៍ផ្លូវគោក ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារចរាចរណ៍ផ្លូវគោក ផ្លូវដែក
- ត្រួតពិនិត្យ ណែនាំ និងពិន័យម្ចាស់យានយន្ត អ្នកបើកបរដែលល្មើសច្បាប់ចរាចរណ៍ផ្លូវគោក ផ្លូវដែក

- ចុះអង្កេត ស្រាវជ្រាវប្រមូលភស្តុតាងករណីរំលោភច្បាប់ចរាចរណ៍ និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងកសាងសំណុំរឿងបញ្ជូនទៅតុលាការតាមនីតិវិធី
- សហការត្រួតពិនិត្យបច្ចេកទេសនៅតាមយានដ្ឋានជួសជុល កែច្នៃ ដំឡើងយានយន្តគ្រប់ប្រភេទតាមការកំណត់
- សហការឃោសនាផ្សព្វផ្សាយអប់រំណែនាំប្រជាពលរដ្ឋឲ្យយល់ដឹង និងគោរពអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក ផ្លូវដែក
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

២- **ការិយាល័យនគរបាលចរាចរណ៍ផ្លូវទឹក** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារចរាចរណ៍ផ្លូវទឹក ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារចរាចរណ៍ផ្លូវទឹក
- ត្រួតពិនិត្យ ណែនាំ និងពិន័យម្ចាស់ជលយាន បរិបាលដែលល្មើសច្បាប់ចរាចរណ៍ផ្លូវទឹក
- ចុះអង្កេតស្រាវជ្រាវប្រមូលភស្តុតាងករណីរំលោភបទដ្ឋានសុវត្ថិភាពចរាចរណ៍ផ្លូវទឹក ព្រមទាំងកសាងសំណុំរឿងបញ្ជូនទៅតុលាការតាមនីតិវិធី
- សហការត្រួតពិនិត្យបច្ចេកទេសនៅតាមយានដ្ឋានជួសជុល កែច្នៃ ដំឡើងជលយានគ្រប់ប្រភេទតាមការកំណត់
- សហការឃោសនាផ្សព្វផ្សាយអប់រំណែនាំប្រជាពលរដ្ឋឲ្យយល់ដឹង និងគោរពអនុវត្តបទដ្ឋានសុវត្ថិភាពចរាចរណ៍ផ្លូវទឹក
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**៣- ផែនការងារគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងអគ្គិភ័យ**

១- **ការិយាល័យនគរបាលបង្ការ ពន្លត់អគ្គិភ័យ និងសង្គ្រោះ** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារបង្ការពន្លត់អគ្គិភ័យ និងសង្គ្រោះ ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្តើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារបង្ការពន្លត់អគ្គិភ័យ និងសង្គ្រោះ
- ចាត់វិធានការជំនាញបង្ការ ពន្លត់អគ្គិភ័យ និងសង្គ្រោះ
- ផ្សព្វផ្សាយអំពីវិធានការបង្ការ ទប់ស្កាត់គ្រោះមហន្តរាយដែលកើតឡើងដោយអគ្គិភ័យ ដោយធម្មជាតិ និងមនុស្ស
- ផ្សព្វផ្សាយណែនាំអប់រំដល់ប្រជាពលរដ្ឋ សហគមន៍អំពីការងារបង្ការ និងការពន្លត់អគ្គិភ័យ
- គ្រប់គ្រងការនាំចូល ស្តុក ចែកចាយ ដឹកជញ្ជូន និងការប្រើប្រាស់ឧបករណ៍ សម្ភារបរិក្ខារបម្រើការងារបង្ការអគ្គិភ័យតាមច្បាប់
- ប្រមូល កត់ត្រា គ្រប់គ្រងទិន្នន័យ និងដំឡើងផែនទីភូមិសាស្ត្រ វិភាគអំពីផលប៉ះពាល់ ដើម្បីមានវិធានការបង្ការ និងពន្លត់អគ្គិភ័យ

- គ្រប់គ្រងថែរក្សារថយន្ត ឧបករណ៍សម្ភារបរិក្ខារ ប្លង់ប្រភពទឹក ប្លង់យុទ្ធសាស្ត្រ និងប្រព័ន្ធបង្ការពន្លត់អគ្គិភ័យ
- លើកគម្រោងជួសជុលថែទាំ កែច្នៃមធ្យោបាយសម្ភារបច្ចេកទេសពន្លត់អគ្គិភ័យ និងសង្គ្រោះ
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចនៅនឹងកន្លែង ចាត់វិធានការបន្ទាន់ជួយសង្គ្រោះជីវិតមនុស្ស ទ្រព្យសម្បត្តិ និងពន្លត់អគ្គិភ័យ
- អនុវត្តវិធានការជំនាញសង្គ្រោះបន្ទាន់ក្នុងការដឹកជញ្ជូន ជម្លៀសជនរងគ្រោះដោយអគ្គិភ័យ និងឧបទ្ទវហេតុផ្សេងៗ ទៅរកទីកន្លែងសុវត្ថិភាព ឬបញ្ជូនទៅមន្ទីរពេទ្យ
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**២- ការិយាល័យគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងជាតិពុល** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងជាតិពុល ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្ដើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារគ្រប់គ្រងអាវុធគ្រឿងផ្ទុះ ជាតិពុល
- ចុះបញ្ជីគ្រប់គ្រងស្ថិតិអាវុធ គ្រឿងផ្ទុះ និងជាតិពុលតាមច្បាប់
- ត្រួតពិនិត្យ និងណែនាំបច្ចេកទេសដល់បណ្ដាក្រុមហ៊ុនអាជីវកម្ម ផលិតកម្មអង្គភាពនានាដែលប្រើប្រាស់សារធាតុងាយឆេះ
- គ្រប់គ្រងការនាំចូល ស្តុកទុក បែងចែក ដឹកជញ្ជូន និងការប្រើប្រាស់សារធាតុងាយឆេះ ងាយផ្ទុះឆេះតាមច្បាប់
- តាមដានការប្រើប្រាស់គ្រឿងផ្ទុះនៅតាមទីតាំងការដ្ឋាននានាក្នុងវង្វង់សមត្ថកិច្ចទទួលខុសត្រូវ
- ចាត់វិធានការជំនាញស្រាវជ្រាវ និងដកហូតអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវគ្រប់ប្រភេទដែលខុសច្បាប់
- សហការជាមួយសមត្ថកិច្ចជំនាញពាក់ព័ន្ធស្រាវជ្រាវបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសច្បាប់គ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ
- អនុវត្តវិធានការជំនាញស្រាវជ្រាវស៊ើបអង្កេតប្រមូលភស្តុតាង ឃាត់ខ្លួនជនសង្ស័យ និងកសាងសំណុំរឿងបញ្ជូនទៅតុលាការតាមនីតិវិធី
- គ្រប់គ្រងការប្រកបមុខរបរងាយប៉ះពាល់ដល់សង្គម សន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ ការទិញលក់ ដឹកជញ្ជូន នាំចូល ចែកចាយ និងការប្រើប្រាស់អាស៊ីដខ្លាំងតាមច្បាប់កំណត់
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**ជ- ផែនការងារអន្តោប្រវេសន៍**

**១- ការិយាល័យគ្រប់គ្រងជនបរទេស** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារគ្រប់គ្រងជនបរទេស ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្ដើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារគ្រប់គ្រងជនបរទេស
- គ្រប់គ្រងស្ថិតិ ការស្នាក់នៅ ការប្រកបមុខរបរជនបរទេសមិនមែនអន្តោប្រវេសន្ត ជនបរទេសអន្តោ-ប្រវេសន្ត ជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគឯកជន ជនបរទេសសុំសិទ្ធិជ្រកកោន ជនភៀសខ្លួន និងជនជាតិខ្មែរធ្វើមាតុភូមិនិវត្តន៍តាមច្បាប់ជាតិ និងអន្តរជាតិ
- សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធក្នុងការគ្រប់គ្រងការស្នាក់នៅ និងការប្រកបមុខរបររបស់ជនបរទេស
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នង-ការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**២- ការិយាល័យស៊ើបអង្កេត និងអនុវត្តនីតិវិធី** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារស៊ើប-អង្កេត និងអនុវត្តនីតិវិធីចំពោះបទល្មើសបង្កឡើងដោយជនបរទេស និងជនពាក់ព័ន្ធ ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្ដើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការបង្ការទប់ស្កាត់ស្រាវជ្រាវ និងបង្ក្រាបបទល្មើសប៉ះពាល់ដល់សន្តិសុខជាតិ និងសុវត្ថិភាពសង្គម ដែលប្រព្រឹត្តដោយជនបរទេស និងជនពាក់ព័ន្ធ
- ប្រមូលព័ត៌មានដែលពាក់ព័ន្ធសន្តិសុខជាតិ និងសុវត្ថិភាពសង្គម ដែលបង្កឡើងដោយជនបរទេស និងជនពាក់ព័ន្ធ
- សហការជាមួយស្ថាប័នតុលាការដើម្បីបើកការស៊ើបអង្កេត និងអនុវត្តនីតិវិធីច្បាប់រាល់បទល្មើសប៉ះពាល់ដល់សន្តិសុខជាតិ និងសុវត្ថិភាពសង្គម ដែលប្រព្រឹត្តដោយជនបរទេស និងជនពាក់ព័ន្ធ
- ប្រមូល និងគ្រប់គ្រងទិន្នន័យជនបរទេសដែលជាប់ពន្ធនាគារ និងជនបរទេសដែលជួបគ្រោះថ្នាក់ផ្សេងៗ ក្នុងដែនសមត្ថកិច្ចទទួលខុសត្រូវ
- ពិនិត្យ ស៊ើបបញ្ជាក់អំពីអត្តសញ្ញាណ និងសាវតារជនបរទេសដែលស្នើសុំរៀបអាពាហ៍អាពិពាហ៍ជាមួយពលរដ្ឋខ្មែរ
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នង-ការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**ឋ- ផែនការងារអត្តសញ្ញាណកម្ម**

**១- ការិយាល័យគ្រប់គ្រងការស្នាក់នៅ** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើគ្រប់គ្រងការស្នាក់នៅរបស់ប្រជាពលរដ្ឋ ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្ដើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារគ្រប់គ្រងការស្នាក់នៅរបស់ប្រជា-ពលរដ្ឋ
- គ្រប់គ្រងការប្រែប្រួល និងធ្វើបច្ចុប្បន្នភាពបញ្ជីស្នាក់នៅរបស់ប្រជាពលរដ្ឋ
- ទទួល និងបែងចែកឯកសារសម្គាល់ការស្នាក់នៅ ឯកសារសម្គាល់គ្រួសារ និងឯកសារផ្លាស់ប្ដូរទីលំនៅដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ប្រមូលគ្រប់គ្រង និងវិភាគទិន្នន័យស្ដីពីការស្នាក់នៅរបស់ប្រជាពលរដ្ឋ ពីអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ

- ចាត់វិធានការ បង្ការ ទប់ស្កាត់ និងស្រាវជ្រាវភាពមិនប្រក្រតីក្នុងការចុះបញ្ជីស្នាក់នៅរបស់ប្រជាពលរដ្ឋ
- ផ្សព្វផ្សាយអប់រំ ប្រជាពលរដ្ឋអំពីបែបបទនីតិវិធី និងសារៈសំខាន់នៃការចុះបញ្ជីស្នាក់នៅរបស់ប្រជាពលរដ្ឋ
- ស្រាវជ្រាវស្វែងរកមនុស្សបាត់ខ្លួន
- សហការជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការស្រង់ស្ថិតិផ្សេងទៀត
- គ្រប់គ្រង ថែរក្សាទិន្នន័យចុះបញ្ជីការស្នាក់នៅរបស់ប្រជាពលរដ្ឋតាមប្រព័ន្ធព័ត៌មានវិទ្យា
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

២- **ការិយាល័យអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្ដើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- ចាត់វិធានការស្រង់ និងធ្វើបច្ចុប្បន្នភាពទិន្នន័យប្រជាពលរដ្ឋដែលត្រូវផ្ដល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- តាមដានជំរុញ និងអនុវត្តការងារផ្ដល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ផ្សព្វផ្សាយអប់រំជូនប្រជាពលរដ្ឋអំពីបែបបទនីតិវិធី និងសារៈសំខាន់នៃអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- គ្រប់គ្រងថែរក្សាទិន្នន័យអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរតាមប្រព័ន្ធព័ត៌មានវិទ្យា
- គ្រប់គ្រងថែរក្សា ឧបករណ៍សម្ភារបច្ចេកទេសបម្រើឲ្យការងារអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- ចាត់វិធានការ បង្ការទប់ស្កាត់ស្រាវជ្រាវភាពមិនប្រក្រតី ទាក់ទងការផ្ដល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**ឌ- ផែនការងារភស្តុភារ និងហិរញ្ញវត្ថុ**

១- **ការិយាល័យភស្តុភារ** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារភស្តុភារ ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្ដើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារភស្តុភារ
- លើកគម្រោងផែនការ និងបើកផ្ដល់សម្ភារ សំលៀកបំពាក់ ឯកសណ្ឋាន ស្បៀងអាហារ ប្រេងឥន្ធនៈ និងការផ្គត់ផ្គង់ទព្វសម្ភារផ្សេងៗទៀត តាមការកំណត់របស់ក្រសួង
- លើកគម្រោង និងបើកផ្ដល់សម្ភារបច្ចេកទេស បរិក្ខារសឹក គ្រឿងបន្លាស់មធ្យោបាយនានារបស់នគរបាលជាតិ
- គ្រប់គ្រង និងធ្វើសន្និធិត្រីមាស ឆមាស ឆ្នាំ នូវទ្រព្យសម្បត្តិរដ្ឋ សម្ភារប្រើប្រាស់ផ្សេងៗ របស់ស្នងការដ្ឋាន តាមការកំណត់របស់ក្រសួង
- គ្រប់គ្រងចលនទ្រព្យ និងអចលនទ្រព្យរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត

- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នង-ការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**២- ការិយាល័យគណនេយ្យ** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារគណនេយ្យ ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្ដើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារគណនេយ្យ
- កសាងផែនការថវិកា និងផែនការយុទ្ធសាស្ត្រថវិការបស់ស្នងការដ្ឋាន
- លើកគម្រោង និងបើកផ្ដល់បៀវត្ស របបឧបត្ថម្ភផ្សេងៗតាមការកំណត់របស់រដ្ឋ និងការចំណាយប្រតិបត្តិការរបស់ស្នងការដ្ឋាន
- លើកគម្រោងសាងសង់ ជួសជុល ថែទាំអគារធ្វើការ ទីបញ្ជាការ ជម្រកស្នាក់នៅ លេណដ្ឋាន ដើម្បីបម្រើកិច្ចប្រតិបត្តិការ
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នង-ការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**៣- ការិយាល័យសុខាភិបាល** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារសុខាភិបាល ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្ដើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារសុខាភិបាល
- ពិនិត្យសុខភាព និងបើកផ្ដល់ឱសថសម្រាប់ថែទាំព្យាបាលជម្ងឺដល់មន្ត្រីនគរបាលជាតិនៅក្រោមឱវាទស្នងការដ្ឋាន
- កសាងផែនការ វិធានការ វិធីសាស្ត្រក្នុងការងារសុខាភិបាល បម្រើដល់មន្ត្រីនគរបាលជាតិក្រោមឱវាទស្នងការដ្ឋាន
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នង-ការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**៧- ផែននគរបាលការពារព្រំដែនគោក** មានតួនាទីធ្វើជាសេនាធិការជូនស្នងការលើការងារការពារព្រំដែនគោក ដែលមានភារកិច្ចដូចខាងក្រោម ៖

- ផ្ដើមយោបល់លើកគោលការណ៍ ផែនការ និងវិធានការលើការងារការពារព្រំដែនគោក
- អនុវត្តវិធានការជំនាញក្ដាប់សភាពការណ៍ ប្រមូលព័ត៌មាន ល្បាតថែរក្សាការពារបង្គោលសីមាវត្ថុ ធាតុគោល សញ្ញាសម្គាល់ផ្សេងៗក្នុងរង្វង់សមត្ថកិច្ចទទួលខុសត្រូវ
- ប្រើប្រាស់វិធានការជំនាញ បង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសឆ្លងដែន និងបទល្មើសនៅតាមខ្សែបន្ទាត់ព្រំដែនគោក

- កសាងផែនការយាមល្បាតការពារព្រំដែន ផែនការការពារទីបញ្ជាការវរសេនាតូច ប៉ុស្តិ៍នគរបាលការពារព្រំដែនគោក និងកសាងប្រព័ន្ធការពារតាមយុទ្ធសាស្ត្រ
- សហការជាមួយរដ្ឋបាលដែនដី និងសមត្ថកិច្ចពាក់ព័ន្ធ ក្តាប់ស្ថានភាពប្រជាពលរដ្ឋ ការពារសន្តិសុខសណ្តាប់ធ្នាប់ និងសង្គ្រោះអាយុជីវិត ការពារទ្រព្យសម្បត្តិប្រជាពលរដ្ឋក្នុងគ្រោះមហន្តរាយផ្សេងៗ
- ទំនាក់ទំនងសហការជាមួយរដ្ឋបាលដែនដី និងសមត្ថកិច្ចនៃប្រទេសជិតខាង ក្នុងការដោះស្រាយបាតុភាពដែលកើតឡើងដោយថាហេតុនៅតាមតំបន់ព្រំដែនគោកតាមការកំណត់
- សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធអនុវត្តការចាប់ខ្លួន ឃាត់ខ្លួនពាក់ព័ន្ធបទល្មើសឆ្លងដែន និងបទល្មើសនៅតាមខ្សែបន្ទាត់ព្រំដែនគោកតាមនីតិវិធី
- សហការជាមួយរដ្ឋបាលដែនដី និងសមត្ថកិច្ចពាក់ព័ន្ធឃោសនាអប់រំប្រជាពលរដ្ឋចូលរួមអនុវត្តគោលនយោបាយការពារជាតិ ច្បាប់ បទប្បញ្ញត្តិផ្សេងៗ អំពីព្រំដែន សំដៅកសាងព្រំដែនសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ
- គ្រប់គ្រង និងប្រើប្រាស់បណ្តាញវិទ្យុទាក់ទង ទូរសារ ទូរស័ព្ទសម្រាប់បម្រើកិច្ចប្រតិបត្តិការ
- លើកគម្រោងសាងសង់ ជួសជុលទីបញ្ជាការ ជម្រកស្នាក់នៅ ហេណដ្ឋាន និងការងារបង្កបង្កើនផល ចិញ្ចឹមសត្វ ដើម្បីរួមចំណែកលើកកម្ពស់ជីវភាពរបស់មន្ត្រីនគរបាលជាតិ
- ធ្វើការងាររដ្ឋបាល បុគ្គលិក ភស្តុភារ និងគណនេយ្យរបស់វរសេនាតូចនគរបាលការពារព្រំដែនគោកតាមការកំណត់
- ណែនាំតាមដានត្រួតពិនិត្យការអនុវត្តមុខជំនាញដល់ប៉ុស្តិ៍នគរបាលការពារព្រំដែនគោក
- ធ្វើរបាយការណ៍បូកសរុបសន្និដ្ឋាន វាយតម្លៃអំពីលទ្ធផលការងារ និងលើកទិសដៅការងារជូនស្នងការដ្ឋានតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលស្នងការប្រគល់ឲ្យ ។

**ប្រការ៥.**

រចនាសម្ព័ន្ធរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ៦.**

- ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ដឹកនាំដោយស្នងការចំនួន០១រូប និងមានស្នងការរងមួយចំនួនជាជំនួយការសម្រាប់ដឹកនាំផែនការងារនីមួយៗ ។ ដោយឡែក ផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងការងារយេនឌ័រ ដឹកនាំដោយស្នងការរងជានារី
- ការិយាល័យចំណុះផែនការងារនីមួយៗដឹកនាំដោយនាយការិយាល័យចំនួន០១រូប និងមាននាយរងចំនួន០២រូប ជាជំនួយការ ។ ដោយឡែកការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន មាននាយរងការិយាល័យចំនួន០១រូប ជានារី
- វរសេនាតូចនគរបាលការពារព្រំដែនគោកនីមួយៗ ដឹកនាំដោយមេបញ្ជាការចំនួន០១រូប និងមានមេបញ្ជាការរងចំនួន០៤រូប ជាជំនួយការ ។

**ប្រការ៧.**

រចនាសម្ព័ន្ធរបស់ការិយាល័យ និងតួនាទី ភារកិច្ចរបស់ផ្នែកចំណុះការិយាល័យនីមួយៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ ។

**ប្រការ៨.-**

ទំនាក់ទំនងការងារ ៖

- រវាងស្នងការនគរបាលរាជធានី ខេត្ត និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ជាទំនាក់ទំនងណែនាំអនុវត្តគោលការណ៍ ផែនការរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ពាក់ព័ន្ធការងារសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ
- រវាងស្នងការដ្ឋាននគរបាលរាជធានី ខេត្ត និងនាយកដ្ឋាន អង្គភាពក្រោមឱវាទក្រសួង ជាទំនាក់ទំនងបញ្ជាដឹកនាំការងារជំនាញ
- រវាងអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ វរសេនាតូចនគរបាលការពារព្រំដែនគោក និងស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ជាទំនាក់ទំនងគ្រប់គ្រងបញ្ជាដឹកនាំការងារជំនាញ ។

**ប្រការ៩.-**

ប្រកាសលេខ ១៩១២ ប្រ.ក ចុះថ្ងៃពុធ ១១កើត ខែពិសាខ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី ២៥ ខែ មេសា ឆ្នាំ២០១៨ ស្ដីពីការកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ត្រូវទុកជានិរាករណ៍ និងជំនួសដោយប្រកាសនេះ ។

**ប្រការ១០.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានកសុការ និងហិរញ្ញវត្ថុ ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធានក្រុមប្រឹក្សានីតិកម្ម អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និងស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃអង្គារ ១២កើត ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែ៧ ឆ្នាំ២០១៨

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្ដេចក្រឡាហោម ស ខេង**

<u>កន្លែងទទួល៖</u>

*-ទីស្ដីការគណៈរដ្ឋមន្ត្រី*
*-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យសម្ដេចឧបនាយករដ្ឋមន្ត្រី*
*-ដូចប្រការ១០*
*-ឯកសារ-កាលប្បវត្តិ*

ឧបសម្ព័ន្ធនៃប្រកាសលេខ ៦៤៥ ប្រ.ក
ចុះថ្ងៃ ១៤កើត ខែ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៨
ស្តីពីការកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ។

# ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ

- I-ផែនការងារធនធានមនុស្ស
  - ១-ការិ.បុគ្គលិក
  - ២-ការិ.បណ្តុះបណ្តាល
  - ៣-ការិ.ផ្សព្វផ្សាយអប់រំ
- II- ផែនការងារសេនាធិការ
  - ១-ការិ.រដ្ឋបាល
  - ២-ការិ.សរុប ផែនការ
  - ៣-ការិ.វិទ្យុទាក់ទង
  - ៤-ការិ.អក្សរសម្ងាត់
  - ៥-ការិ.កិច្ចការប៉ុ.ន.បរដ្ឋបាល
  - ៦-ការិ.អន្តរាគមន៍ និងតម្រូតបទបញ្ជា
- III- ផែនការងារន.បព្រហ្មទណ្ឌ
  - ១-ការិ.នប.ព្រហ្មទណ្ឌកម្រិតធ្ងន់
  - ២-ការិ.នប.ព្រហ្មទណ្ឌកម្រិតស្រាល
  - ៣-ការិ.នប.បច្ចេកទេស និងវិទ្យាសាស្ត្រ
- IV-ផែនការងារន.បប្រឆាំងបទល្មើសសេដ្ឋកិច្ច
  - ការិ.ន.បប្រឆាំងបទល្មើសសេដ្ឋកិច្ច
- V-ផែនការងារប្រឆាំងគ្រឿងញៀន
  - ការិ.ប្រឆាំងគ្រឿងញៀន
- VI-ផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងការងារយេនឌ័រ
  - ការិ.ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន
- VII-ផែនការងារសន្តិសុខ
  - ១-ការិ.សន្តិសុខផ្ទៃក្នុង
  - ២-ការិ.ប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន
  - ៣-ការិ.គ្រប់គ្រងសន្តិសុខឯកជន
  - ៤-ការិ.ប្រឆាំងបទល្មើសបច្ចេកវិទ្យា
- VIII-ផែនការងារន.បសណ្តាប់ធ្នាប់
  - ១-ការិ.ន.បសណ្តាប់ធ្នាប់
  - ២-ការិ.ន.បទេសចរណ៍
  - ៣-ការិ.ន.បការពារបេតិកភណ្ឌ
- IX-ផែនការងារន.បចរាចរណ៍
  - ១-ការិ.ន.បចរាចរណ៍ផ្លូវគោក
  - ២-ការិ.ន.បចរាចរណ៍ផ្លូវទឹក
- X-ផែនការងារគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងអគ្គិភ័យ
  - ១-ការិ.ន.បបង្ការ ពន្លត់អគ្គិភ័យ និងសង្គ្រោះ
  - ២-ការិ.គ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងជាតិពុល
- XI-ផែនការងារអន្តោប្រវេសន៍
  - ១-ការិ.គ្រប់គ្រងជនបរទេស
  - ២-ការិ.ស៊ើបអង្កេតនិងអនុវត្តនីតិវិធី
- XII-ផែនការងារអត្តសញ្ញាណកម្ម
  - ១-ការិ.គ្រប់គ្រងការស្នាក់នៅ
  - ២-ការិ.អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- XIII-ផែនការងារភស្តុភារ និងហិរញ្ញវត្ថុ
  - ១-ការិ.ភស្តុភារ
  - ២-ការិ.គណនេយ្យ
  - ៣-ការិ.សុខាភិបាល
- អធិការដ្ឋានន.បខណ្ឌ
  - ប៉ុស្តិ៍ន.បរដ្ឋបាលសង្កាត់

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្តេចក្រឡាហោម ស ខេង

ឧបសម្ព័ន្ធនៃប្រកាសលេខ [illegible] ប្រ.ក
ចុះថ្ងៃ [illegible] ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៨
ស្តីពីការកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅរបស់ស្នងការដ្ឋាន
នគរបាលរាជធានី ខេត្ត

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

# ស្នងការដ្ឋាននគរបាលខេត្ត

- I-ផែនការងារធនធានមនុស្ស
  - ១-ការិ.បុគ្គលិក
  - ២-ការិ.បណ្តុះបណ្តាល
  - ៣-ការិ.ផ្សព្វផ្សាយអប់រំ
- II- ផែនការងារសេនាធិការ
  - ១-ការិ.រដ្ឋបាល
  - ២-ការិ.សរុប ផែនការ
  - ៣-ការិ.វិទ្យុទាក់ទង
  - ៤-ការិ.អក្សរសម្ងាត់
  - ៥-ការិ.កិច្ចការប៉ុ.ន.បរដ្ឋបាល
  - ៦-ការិ.អន្តរាគមន៍និងតម្រួតបទបញ្ជា
- III- ផែនការងារន.បព្រហ្មទណ្ឌ
  - ១-ការិ.នប.ព្រហ្មទណ្ឌកម្រិតធ្ងន់
  - ២-ការិ.នប.ព្រហ្មទណ្ឌកម្រិតស្រាល
  - ៣-ការិ.នប.បច្ចេកទេស និងវិទ្យាសាស្ត្រ
- IV-ផែនការងារន.បប្រឆាំងបទល្មើសសេដ្ឋកិច្ច
  - ការិ.ន.បប្រឆាំងបទល្មើសសេដ្ឋកិច្ច
- V-ផែនការងារប្រឆាំងគ្រឿងញៀន
  - ការិ.ប្រឆាំងគ្រឿងញៀន
- VI-ផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងការងារយេនឌ័រ
  - ការិ.ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន
- VII-ផែនការងារសន្តិសុខ
  - ១-ការិ.សន្តិសុខផ្ទៃក្នុង
  - ២-ការិ.ប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន
  - ៣-ការិ.គ្រប់គ្រងសន្តិសុខឯកជន
  - ៤-ការិ.ប្រឆាំងបទល្មើសបច្ចេកវិទ្យា
  - ៥-ការិ.អង្គរក្ស
- VIII-ផែនការងារន.បសណ្តាប់ធ្នាប់
  - ១-ការិ.ន.បសណ្តាប់ធ្នាប់
  - ២-ការិ.ន.បទេសចរណ៍
  - ៣-ការិ.ន.បការពារបេតិកភណ្ឌ
  - ៤-ការិ.ន.បចរាចរណ៍ផ្លូវគោក
  - ៥-ការិ.ន.បចរាចរណ៍ផ្លូវទឹក
- IX-ផែនការងារគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងអគ្គិភ័យ
  - ១-ការិ.ន.បបង្ការ ពន្លត់អគ្គិភ័យ និងសង្គ្រោះ
  - ២-ការិ.គ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងជាតិពុល
- X-ផែនការងារអន្តោប្រវេសន៍
  - ១-ការិ.គ្រប់គ្រងជនបរទេស
  - ២-ការិ.ស៊ើបអង្កេតនិងអនុវត្តនីតិវិធី
- XI-ផែនការងារអត្តសញ្ញាណកម្ម
  - ១-ការិ.គ្រប់គ្រងការស្នាក់នៅ
  - ២-ការិ.អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- XII-ផែនការងារភស្តុភារ និងហិរញ្ញវត្ថុ
  - ១-ការិ.ភស្តុភារ
  - ២-ការិ.គណនេយ្យ
  - ៣-ការិ.សុខាភិបាល
- XIII-ផែនន.បការពារព្រំដែនគោក
- **អធិការដ្ឋានន.បក្រុង ស្រុក**
  - **ប៉ុស្តិ៍ន.បរដ្ឋបាលឃុំ សង្កាត់**

# ឯកសារជំនួយស្មារតីៈ
# បដិវត្តន៍ឧស្សាហកម្មទី៤
# ( ឧស្សាហកម្ម៤.0 )

វ៉ុល១ លេខទី៣ ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៩

# បដិវត្តន៍ឧស្សាហកម្មទី៤ (ឧស្សាហកម្ម ៤.០)

តាន់ មុន្នីវិសាល*

បដិវត្តន៍ឧស្សាហកម្មទី៤ បាន និងកំពុងក្លាយជាប្រធានបទដ៏មានសារៈសំខាន់ ដែលទទួលបានការចាប់អារម្មណ៍ពីសំណាក់មេដឹកនាំពិភពលោក អ្នកសិក្សាស្រាវជ្រាវ អ្នកអនុវត្ត អ្នកជំនាញ និងអ្នកបង្កើតគោលនយោបាយ ហើយប្រទេសជាច្រើនបានកំណត់យកបដិវត្តន៍ឧស្សាហកម្មទី៤ ជាអាទិភាពចម្បងក្នុងចំណោមអាទិភាពដទៃទៀត សម្រាប់កំណើន និងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួន។ ជាមួយនឹងបច្ចេកវិទ្យា និងនវានុវត្តន៍ថ្មីៗ ដូចជាបញ្ញាសប្បនិម្មិត និងបច្ចេកវិទ្យារ៉ូបូត (Robotics) បដិវត្តន៍ឧស្សាហកម្មទី៤ ត្រូវបានគេរំពឹងថា នឹងជះឥទ្ធិពលយ៉ាងខ្លាំងលើគ្រប់ទិដ្ឋភាពនៃជីវិតរបស់មនុស្ស រួមទាំងអភិបាលកិច្ច សង្គម និងរចនាសម្ព័ន្ធសេដ្ឋកិច្ច។ ទោះបីជាមានកាលានុវត្តភាព និងភាពរំជើបរំជួលជាច្រើនពីបច្ចេកវិទ្យាថ្មីៗ និងទំនើបៗក្នុងបដិវត្តន៍ឧស្សាហកម្មនេះក៏ដោយ អនាគតនៃបដិវត្តន៍ឧស្សាហកម្មទី៤ នៅតែមានភាពស្រពេចស្រពិលនៅឡើយ។ មែនទែនទៅ បដិវត្តន៍ឧស្សាហកម្ម មិនមែនជាអ្វីដែលថ្មីទាំងស្រុងទេ ប៉ុន្តែមនុស្សភាគច្រើននៅតែមិនស្គាល់ច្បាស់ថា តើជំនាន់ទី៤នៃបដិវត្តន៍ឧស្សាហកម្ម គឺជាអ្វីឲ្យប្រាកដ។ ដូច្នេះជំនួយស្មារតីនេះ នឹងពន្យល់ពីទិដ្ឋភាពទូទៅអំពីបដិវត្តន៍ឧស្សាហកម្មទី៤ ព្រមទាំងបង្ហាញដោយសង្ខេបពីឥទ្ធិពលរបស់បដិវត្តន៍ឧស្សាហកម្មទី៤ លើសង្គម ធុរកិច្ច និងសេដ្ឋកិច្ចសកល។

## ❖ តើអ្វីទៅជាបដិវត្តន៍ឧស្សាហកម្ម?

បដិវត្តន៍ឧស្សាហកម្ម ដែលកកើតឡើងដំបូងនៅចក្រភពអង់គ្លេស ត្រូវបានគេពិពណ៌នាថា ជាសម័យកាលនៃឧស្សាហូបនីយកម្ម និងនវានុវត្តន៍នៃការបង្កើតថ្មី ដែលត្រូវគេអះអាងថាបាននាំឲ្យសេដ្ឋកិច្ចមូលធននិយមកើតមានឡើង និងបានប្រែក្លាយវិធីសាស្ត្រនៃការផលិតបែបបុរាណឲ្យទៅជាផលិតកម្មឧស្សាហកម្ម (Chen, 2019)។ បដិវត្តន៍ឧស្សាហកម្មបានធ្វើឲ្យមានការផ្លាស់ប្តូរយ៉ាងខ្លាំងក្លា ឬទាំងស្រុងនៅតាមជនបទ និងទីក្រុងក្នុងតំបន់ជាច្រើននៃទ្វីបអឺរ៉ុប និងអាមេរិក ឲ្យក្លាយជាទីក្រុងឧស្សាហកម្ម ដែលបង្កើតប្រាក់ចំណូល និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចយ៉ាងឆាប់រហ័សតាមរយៈផលិតកម្មផ្អែកលើឧស្សាហកម្ម (History, 2019)។ កម្រិតជីវភាពរបស់ប្រជាជនបានកើនឡើង ដោយសារមនុស្សកាន់តែច្រើនអាចរកប្រាក់ចំណូលបានខ្ពស់ នៅពេលធ្វើការក្នុងរោងចក្រដែលខុសពីការធ្វើស្រែចម្ការ។ ម្យ៉ាងវិញទៀត ការប្រស្រ័យទាក់ទង និងការដឹកជញ្ជូនមានភាពរហ័ស និងទំនើបជាងមុនដោយសារនវានុវត្តន៍នៃបច្ចេកវិទ្យាថ្មីៗ ដែលត្រូវបានបង្កើតឡើងក្នុងសម័យកាលបដិវត្តន៍ឧស្សាហកម្ម។

លោក Klaus Schwab ស្ថាបនិក និងជានាយកប្រតិបត្តិនៃវេទិកាសេដ្ឋកិច្ចពិភពលោកបានគូសបញ្ជាក់ថា បដិវត្តន៍ឧស្សាហកម្ម បានឆ្លងកាត់ដំណាក់កាលមួយចំនួន មុននឹងឈានមកដល់ចំណុចបច្ចុប្បន្ននេះ (Schwab, 2016a)។ បដិវត្តន៍ឧស្សាហកម្មទី១ បានកើតឡើងរវាងឆ្នាំ១៧៦០ និងឆ្នាំ១៨៤០ ហើយផលិតកម្មមេកានិចក៏បានបង្ហាញខ្លួនជាលើកដំបូង តាមរយៈការបង្កើតម៉ាស៊ីនដើរដោយចំហាយទឹក គួបផ្សំជាមួយនឹងការប្រើប្រាស់ផ្លូវរថភ្លើង។ ការច្នៃប្រឌិតថ្មីនេះ បានត្រួសត្រាយផ្លូវផលិតកម្មឧស្សាហកម្មដំបូងគេ

*តាន់ មុន្នីវិសាល ជាអ្នកសម្របសម្រួលកម្មវិធីបណ្តុះបណ្តាលនិងផ្សព្វផ្សាយ នៅមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

© រក្សាសិទ្ធដោយ មអក | ខ្លឹមសារនៃអត្ថបទនេះគឺជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

ដូចជាឧស្សាហកម្មដែក និងដែកថែប ដែលបានលេចឡើងយ៉ាងឆាប់រហ័សនៅក្នុងដំណើរការនៃការផលិត។ បដិវត្តន៍ឧស្សាហកម្មទី២ បានបង្ហាញខ្លួននៅចុងសតវត្សរ៍ទី១៩ និងដើមសតវត្សរ៍ទី២០ តាមរយៈរបកគំហើញថាមពលអគ្គីសនី និងការបង្កើតខ្សែសង្វាក់ផលិតកម្មនៅក្នុងរោងចក្រ។ ម្យ៉ាងទៀត ផលិតកម្មទ្រង់ទ្រាយធំក៏ត្រូវបានចាត់ទុកជាលក្ខណៈកំណត់មួយនៃបដិវត្តន៍ឧស្សាហកម្មទី២ ផងដែរ។ ជាមួយនឹងការចាប់ផ្ដើមនៃយុគសម័យឌីជីថលនៅទសវត្សរ៍ឆ្នាំ៦០ បដិវត្តន៍ឧស្សាហកម្មទី៣ បានកើតឡើងដោយផ្អែកលើការអភិវឌ្ឍផ្នែកបច្ចេកវិទ្យា ប្រព័ន្ធអ៊ីនធឺណិត ព័ត៌មានវិទ្យា (IT) ស៊ីមីកុងឌុចទ័រ (Semiconductor) និងកុំព្យូទ័រភាវូបនីយកម្ម។ ទោះជាយ៉ាងណា គេជឿថា ការមកដល់នៃបដិវត្តន៍ឧស្សាហកម្មទី៤ គឺកាន់តែជិតបង្កើយ ហើយវានឹងមានឥទ្ធិពលយ៉ាងធំធេង លើជីវិតមនុស្ស ជាងបដិវត្តន៍ឧស្សាហកម្មនានាកន្លងមក។

## ❖ បដិវត្តន៍ឧស្សាហកម្មទី៤ ឬ ឧស្សាហកម្ម៤.0

លោក Schwab ជឿថា បដិវត្តន៍ឧស្សាហកម្មទី៤ បាន និងកំពុងអភិវឌ្ឍខ្លួនឡើងតាំងពីដើមសតវត្សរ៍ទី២១មកម្ល៉េះ ហើយដំណើរវិវត្តន៍នេះ គឺពឹងផ្អែកលើមូលដ្ឋានគ្រឹះរបស់បច្ចេកវិទ្យាឌីជីថលក្នុងបដិវត្តន៍ឧស្សាហកម្មទី៣។ ភាពជឿនលឿន និងទំនើបផ្ដាច់គេនៃនវានុវត្តន៍របស់បច្ចេកវិទ្យាថ្មីៗដូចជា ប្រព័ន្ធវិភាគទិន្នន័យធំ (Big Data Analytics), បច្ចេកវិទ្យាណាណូ (Nanotechnology), បច្ចេកវិទ្យា Gene Sequencing និង Quantum Computing ជាដើម ធ្វើឲ្យបដិវត្តន៍ឧស្សាហកម្មទី៤ ដែលកំពុងអភិវឌ្ឍខ្លួនកាន់ច្បាស់ឡើងមកនេះ មានវិសាលភាពធំធេងជាងបដិវត្តន៍ឧស្សាហកម្មជំនាន់មុនៗវាទាំងអស់។ ដូច្នេះហើយ បដិវត្តន៍ឧស្សាហកម្មទី៤ ត្រូវបានគេជឿថា នឹងប្របាច់បញ្ចូលគ្នាបច្ចេកវិទ្យារវាងពិភពរូបសាស្ត្រ ពិភពឌីជីថល និងពិភពជីវសាស្ត្រ។ ភាពរីកចម្រើននៃបច្ចេកវិទ្យាទៀតសោត មានការសាយភាយយ៉ាងឆាប់រហ័ស និងទូលំទូលាយជាងពេលណាៗទាំងអស់។ ឧទាហរណ៍៖ ប្រព័ន្ធអ៊ីនធឺណិត ចំណាយពេលតិចជាងមួយទសវត្សរ៍ប៉ុណ្ណោះ ក្នុងការរីកសុសសាយនៅទូទាំងពិភពលោក។ លោក Schwab បានគូសបញ្ជាក់របកគំហើញវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាថ្មីៗមួយចំនួន ដែលបានរួមចំណែកដល់ការកកើតឡើងនៃការបដិវត្តន៍ឧស្សាហកម្មទី៤ ដោយបានរាប់បញ្ចូលជាក្រុមទៅតាមប្រភេទរូបសាស្ត្រ (ការបោះពុម្ព3D, បច្ចេកវិទ្យារ៉ូបូតទំនើប-Advanced Robotics, និងរថយន្តដំណើរការស្វ័យប្រវត្តិ), ប្រភេទឌីជីថល (ឧបករណ៍តភ្ជាប់ទៅប្រព័ន្ធអ៊ីនធឺណិត-Internet of Things ឬ IoT និងឧបករណ៍កំណត់សញ្ញា-Sensor) និងប្រភេទជីវសាស្ត្រ (បច្ចេកវិទ្យា Gene Sequencing និង Gene Editing)។ ប្រភេទទាំងបីនេះ មានទំនាក់ទំនង និងពឹងផ្អែកលើដំណើរអភិវឌ្ឍន៍រវាងគ្នាទៅវិញទៅមក។ គួរកត់សម្គាល់ផងដែរថា ការអភិវឌ្ឍ និងការអនុវត្តប្រព័ន្ធអ៊ីនធឺណិតរូបសាស្ត្រ (Cyber-Physical System) គឺជាអ្វីដែលធ្វើឲ្យបដិវត្តន៍ឧស្សាហកម្មទី៤ ខុសប្លែកពីបដិវត្តន៍ឧស្សាហកម្មទី៣។ ម៉ាស៊ីន និងឧបករណ៍វៃឆ្លាតរបស់បច្ចេកវិទ្យាថ្មីនេះ នឹងត្រូវការអន្តរាគមន៍ពីមនុស្សតិចជាងមុនក្នុងការត្រួតពិនិត្យ និងប្រតិបត្តិការ ព្រោះវាត្រូវបានកំណត់ដើម្បីឲ្យធ្វើការទាក់ទងគ្នា និងដើរដោយស្វ័យប្រវត្តិ និងដោយឯករាជ្យនៅក្នុងប្រព័ន្ធ។

បដិវត្តន៍ឧស្សាហកម្មទី៤ ត្រូវបានហៅជាញឹកញាប់ក្នុងពាក្យម៉្យាងទៀតថា "ឧស្សាហកម្ម ៤.0"។ ខណៈដែលបដិវត្តន៍ឧស្សាហកម្មទី៤ មានភាពទាក់ទងជាមួយនឹងការផ្លាស់ប្តូរបច្ចេកវិទ្យាជារួមក្នុងទិដ្ឋភាពផ្សេងៗនៃជីវិតមនុស្ស ពាក្យថា "ឧស្សាហកម្ម៤.0" នេះ គឺពាក់ព័ន្ធនឹងការផ្លាស់ប្តូរបច្ចេកវិទ្យានៃប្រព័ន្ធផលិតកម្ម ក្នុងវិស័យឧស្សាហកម្ម។ ពាក្យ "ឧស្សាហកម្ម ៤.0" ដែលបង្កើតឡើងនៅពិព័រណ៍ Hannover ក្នុងឆ្នាំ២០១១ នៅអាល្លឺម៉ង់ ត្រូវបានគេប្រើរួមជាមួយនឹងបដិវត្តន៍ឧស្សាហកម្មទី៤ ដើម្បីសំដៅលើការផ្លាស់ប្តូរក្នុងខ្សែសង្វាក់តម្លៃសកលដែលកើតឡើងដោយកិច្ចសហប្រតិបត្តិការរវាងប្រព័ន្ធនិម្មិត និងប្រព័ន្ធរូបសាស្ត្រនៃផលិតកម្មក្នុង "រោងចក្រវៃឆ្លាត" (Schwab, 2016a)។

**ដំណាក់កាលនីមួយៗនៃបដិវត្តន៍ឧស្សាហកម្ម**




*ប្រភព: The Guardian*[1]

## ❖ ឥទ្ធិពលនៃឧស្សាហកម្ម ៤.0

បដិវត្តន៍ឧស្សាហកម្មទី៤ ត្រូវបានគេព្យាករថា នឹងមានឥទ្ធិពលលាតសន្ធឹងយ៉ាងខ្លាំងក្លាលើគ្រប់ទិដ្ឋភាពនៃជីវិតរបស់មនុស្ស បូករួមទាំងផលវិជ្ជមាន និងអវិជ្ជមាន ដោយអាស្រ័យលើការប្រើប្រាស់បច្ចេកវិទ្យារបស់វា និងកម្រិតនៃការត្រៀមខ្លួនរបស់សង្គមមនុស្សក្នុងតំបន់ និងពិភពលោក ដើម្បីសម្របខ្លួនទៅនឹងការផ្លាស់ប្តូរដ៏ធំធេងដែលឧស្សាហកម្ម ៤.0 បាន និងកំពុងនាំយកមក។ ចំពោះផលវិជ្ជមាននៃបច្ចេកវិទ្យា និងនវានុវត្តន៍របស់បដិវត្តន៍ឧស្សាហកម្មទី៤ ត្រូវបានរំពឹងទុកថា នឹងលើកកម្ពស់គុណភាពជីវិតរបស់មនុស្ស ក៏ដូចជាធ្វើឲ្យរបៀបរស់នៅ និងប្រព័ន្ធគមនាគមន៍កាន់តែប្រសើរឡើង។ ឧទាហរណ៍៖ បច្ចេកវិទ្យារបស់ឧបករណ៍តភ្ជាប់ទៅប្រព័ន្ធអ៊ីនធឺណិត (IoT) អាចផ្តល់ប្រសិទ្ធភាពកាន់តែខ្ពស់បន្ថែមទៀតដល់ប្រព័ន្ធទីក្រុងវៃឆ្លាត ដែលនឹងនាំការផ្លាស់ប្តូរលំនាំជីវិតនៅទីក្រុងទៅជាបទពិសោធន៍ថ្មីស្រឡាងមួយ ដែលកាន់តែមានសុវត្ថិភាព និងឧត្តមភាព។ ក្នុងផ្នែកសន្តិសុខ ទីក្រុងវៃឆ្លាត ត្រូវបានបំពាក់ដោយប្រព័ន្ធកាមេរ៉ាសុវត្ថិភាព (CCTV) ដែលមានលក្ខណៈពិសេស និងវៃឆ្លាតក្នុងការសម្គាល់ផ្ទៃមុខដើម្បីកំណត់អត្តសញ្ញាណរបស់ជនសង្ស័យ ទាំងមុន និងក្រោយពេលពួកគេប្រព្រឹត្តបទឧក្រិដ្ឋនានា (Low, 2018)។ ដូចគ្នានេះ ដើម្បីឲ្យការដឹកជញ្ជូនកាន់តែមានប្រសិទ្ធភាព កម្មវិធីទូរស័ព្ទវៃឆ្លាតត្រូវបានប្រើដើម្បីជួយប៉ាន់ស្មានពេលវេលាក្នុងការជ្រើសរើសមធ្យោបាយធ្វើដំណើរផ្សេងៗ ដោយផ្អែកលើស្ថានភាពចរាចរណ៍ជាក់ស្តែងនៅក្នុងទីក្រុង (Low, 2018)។ លើសពីនេះទៀត ការអភិវឌ្ឍបណ្តាញ 5G ក៏ជួយសម្របសម្រួលប្រព័ន្ធ និងបច្ចេកវិទ្យាដែលប្រើសម្រាប់ទីក្រុងវៃឆ្លាត។ ជាឧទាហរណ៍៖ បច្ចេកវិទ្យា 5G អាចធ្វើឲ្យយានយន្តទាំងឡាយដែលតភ្ជាប់គ្នាជាបណ្តាញ ដើម្បីផ្ទេរ និងចែករំលែកទិន្នន័យចរាចរណ៍ឲ្យគ្នាទៅវិញទៅមក ដើម្បីកាត់បន្ថយការកកស្ទះ(Castro, 2019)។ រថយន្តបើកដោយខ្លួនឯង ឬយានយន្តដំណើរការដោយស្វ័យប្រវត្តិ

[1] See more at Adepetun, A. (2018, October 03). Fourth industrial revolution Nigeria’s next phase of growth? *The Guardian*. Retrieved from https://guardian.ng/technology/fourth-industrial-revolution-nigerias-next-phase-of-growth/

ដែលបានអភិវឌ្ឍ និងធ្វើប្រតិបត្តិការក្នុងទីក្រុងវៃឆ្លាត ត្រូវការជំនួយបច្ចេកវិទ្យា 5G នេះ ព្រោះប្រតិបត្តិការនៃយានយន្តទាំងនោះទាមទារឲ្យមានអ៊ីនធឺណិតល្បឿនលឿនបំផុត និងការពន្យារពេលដំណើរការទាបដែលប្រព័ន្ធ 5G អាចផ្តល់ឲ្យបាន។

បច្ចេកវិទ្យារបស់បដិវត្តន៍ឧស្សាហកម្មទី៤ ក៏អាចបង្កើនកម្រិតនៃភាពងាយស្រួលដល់មនុស្សផ្ទាល់ ចំពោះអ្នកមានលទ្ធភាពប្រើប្រាស់សេវាកម្មក្នុងពិភពឌីជីថល ព្រោះសេវាកម្មជាច្រើន ដូចជាការទិញទំនិញតាមអនឡាញ និងការកក់សំបុត្រយន្តហោះជាដើម អាចធ្វើពីចម្ងាយបានដោយងាយ (Schwab, 2016b)។ លើសពីនេះដោយសារតែទិន្នន័យអនឡាញជាច្រើនបញ្ជូនពីឧបករណ៍ផ្សេងៗដែលត្រូវបានតភ្ជាប់ទៅប្រព័ន្ធពពក (the Cloud) បញ្ញាសប្បនិម្មិត នឹងអាចធ្វើការវិភាគ និងព្យាករ ដើម្បីបង្កើតសេវាកម្មវៃឆ្លាតយ៉ាងឆាប់រហ័សសម្រាប់អតិថិជន ក្នុងវិស័យផ្សេងៗជាច្រើនដូចជាវិស័យសុខាភិបាល ដឹកជញ្ជូន ហិរញ្ញវត្ថុ និងសេវាសាធារណៈទូទាំងប្រទេស។

ឧស្សាហកម្ម ៤.0 ក៏នាំមកនូវកាលានុវត្តភាពសេដ្ឋកិច្ចបន្ថែមទៀតដល់វិស័យឧស្សាហកម្មរបស់ប្រទេសណា ដែលអាចធ្វើការផ្លាស់ប្តូរផ្នែកបច្ចេកវិទ្យា និងប្រព័ន្ធឌីជីថលរបស់ខ្លួន។ គេបានរកឃើញថា បណ្តាប្រទេសទាំងឡាយដែលបានវិនិយោគលើបច្ចេកវិទ្យារបស់ឧបករណ៍តភ្ជាប់ និងគ្រប់គ្រងដោយប្រព័ន្ធអ៊ីនធឺណិតក្នុងឧស្សាហកម្ម ត្រូវបានព្យាករថានឹងទទួលបានផលចំណេញកាន់តែខ្ពស់លើកំណើននៃតម្លៃសេដ្ឋកិច្ចរបស់ខ្លួន។ របាយការណ៍របស់ Accenture and General Electric ក្នុងឆ្នាំ២០១៥ បានបង្ហាញថាការអភិវឌ្ឍបច្ចេកវិទ្យាឧស្សាហកម្ម ៤.0 នៅក្នុងវិស័យឧស្សាហកម្មផ្សេងៗអាចផ្តល់កាលានុវត្តភាពសេដ្ឋកិច្ចខ្ពស់ ហើយអាមេរិកនឹងក្លាយជាប្រទេស ដែលទំនងជាទទួលបានអត្ថប្រយោជន៍ច្រើនបំផុតពីការអភិវឌ្ឍនោះ និងតាមពីក្រោយដោយ ចិន អាល្លឺម៉ង់ និងចក្រភពអង់គ្លេស (Petrillo, Felice, Cioffi & Zomparelli, 2019)។ សម្រាប់សហគ្រាសខ្នាតតូច និងមធ្យម ក៏នឹងទទួលបាននូវឱកាសក្នុងការបង្កើនផលិតភាព និងប្រសិទ្ធភាពពីបច្ចេកវិទ្យាថ្មីៗ ដូចជាឧបករណ៍កំណត់សញ្ញា (Sensors) និងប្រព័ន្ធវិភាគទិន្នន័យធំ (Big Data Analytics) ដែលអាចជួយឲ្យមានការយល់ដឹងកាន់តែច្បាស់អំពីសេចក្តីលម្អិតនៃដំណើរការផលិតកម្ម និងជួយពួកគេស្វែងរកជម្រើសដែលត្រូវការពេលវេលា និងធនធានតិចជាងមុនសម្រាប់ផលិតកម្មរបស់ខ្លួន (Smith, 2018)។

ទោះបីជាយ៉ាងនេះក្តី បដិវត្តន៍ឧស្សាហកម្មទី៤ ក៏បាននាំមកនូវការព្រួយបារម្ភមួយចំនួនផងដែរ ដែលក្នុងនោះរួមមាន ការកើនឡើងនៃបញ្ញាសប្បនិម្មិត និងប្រព័ន្ធស្វ័យប្រវត្តិកម្មនៅក្នុងវិស័យការងារដែលអាចនឹងជំនួសកម្លាំងពលកម្មរបស់មនុស្ស ហើយអាចនាំឲ្យឈានទៅដល់ការបាត់បង់ការងារ និងនាំឲ្យមានកំណើននៃនិកម្មភាពកាន់តែខ្ពស់ជាមុន។ យោងតាមរបាយការណ៍របស់ធនាគារពិភពលោកនៅឆ្នាំ២០១៦ ការងារក្នុងប្រទេសចិនប្រមាណ៧៧% ស្ថិតនៅក្រោមហានិភ័យនៃការជំនួសដោយស្វ័យប្រវត្តិកម្ម (Citi and Oxford Martin School, 2016)។ ទោះបីជាបម្លាស់ប្តូរការងាររបស់កម្មករ ពឹងផ្អែកលើសន្ទុះនៃការចាប់យកបច្ចេកវិទ្យាមកប្រើប្រាស់ដោយស្ថាប័នជំនួញ និងសេដ្ឋកិច្ចក៏ដោយ កម្មករប្រមាណ ៣៧៥ លាននាក់ នឹងនៅតែត្រូវការផ្លាស់ប្តូរមុខរបររបស់ខ្លួននៅឆ្នាំ ២០៣០ ដដែល (McKinsey Global Institute, 2017)។ ដូច្នេះជំនាញ និងចំណេះដឹងថ្មីៗ ឬការសម្របខ្លួនជាមួយនឹងបច្ចេកវិទ្យាហើយនិងម៉ាស៊ីនទំនើបៗ គួរតែជាអាទិភាពចម្បង។

មួយវិញទៀត កំណើននៃវិសមភាពសង្គម ក៏ជាផលអវិជ្ជមានមួយទៀតរបស់អនាគតនៃឧស្សាហកម្ម ៤.0។ ដូចបានរៀបរាប់ខាងលើ បដិវត្តន៍ឧស្សាហកម្មទី៤ នឹងមានសក្តានុពលខ្លាំងក្លាក្នុងការលើកកម្ពស់គុណភាពជីវិតរបស់មនុស្ស ប៉ុន្តែនៅមានមនុស្សច្រើនណាស់ ដែលមិនទាន់សូម្បីតែមានឱកាសទទួលបានអត្ថប្រយោជន៍ពីបដិវត្តន៍ឧស្សាហកម្មជំនាន់មុនៗនៅឡើយ។ ជាក់ស្តែង មនុស្សយ៉ាងហោចណាស់ ៦០០ លាននាក់ ដែលរកស៊ីចិញ្ចឹមជីវិតដោយការធ្វើស្រែចម្ការ គ្មានលទ្ធភាពប្រើប្រាស់យន្តកម្ម ដែលជាបច្ចេក

វិទ្យាបង្កើតឡើងក្នុងជំនាន់បដិវត្តន៍ឧស្សាហកម្មទី១ ហើយមនុស្សប្រហែល ៤ ពាន់លាននាក់ នៅទូទាំងពិភពលោក នៅតែគ្មានលទ្ធភាពប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត (Trailhead, n.d.)។ លើសពីនេះ អ្នកដែលអាចទទួលផលច្រើនបំផុតពីបច្ចេកវិទ្យា និងនវានុវត្តន៍នៃឧស្សាហកម្ម ៤.០ នេះ ច្រើនបំផុត ភាគច្រើនគឺជាអ្នកផ្គត់ផ្គង់មូលធន រួមមានអ្នកធ្វើនវានុវត្តន៍ ម្ចាស់ភាគហ៊ុន និងវិនិយោគិនជាដើម (Schwab, 2016b)។ ដូច្នេះហើយ ស្ថានភាពនេះអាចនាំឲ្យមានការបាត់បង់ទំនុកចិត្តលើសង្គម ដោយសារតែគម្លាតនៃប្រាក់ចំណូលរវាងម្ចាស់មូលធន និងកម្មករកាន់តែធំទៅ។

ក្រៅពីនេះ សន្តិសុខប្រព័ន្ធអ៊ីនធឺណិត ក៏ជាអ្វីដែលប្រទេស និងជំនួញជាច្រើន កំពុងមានការព្រួយបារម្ភយ៉ាងខ្លាំងក្នុងយុគសម័យឌីជីថល។ ការគំរាមកំហែង និងហានិភ័យនៅក្នុងសន្តិសុខប្រព័ន្ធអ៊ីនធឺណិត បានកើតមានកាន់តែខ្លាំង នៅពេលដែលទិន្នន័យរបស់អ្នកប្រើប្រាស់រាប់លាននាក់ រួមមានទាំងព័ត៌មានផ្ទាល់ខ្លួន គណនីធនាគារ និងព័ត៌មានអំពីសកម្មភាពប្រចាំថ្ងៃ ត្រូវបានបញ្ជូនពីបច្ចេកវិទ្យាទំនើបៗ ជាពិសេសបច្ចេកវិទ្យាកំណត់សញ្ញា ដែលភ្ជាប់ជាមួយឧបករណ៍ប្រើប្រាស់ផ្សេងៗ ក្នុងជីវិតប្រចាំថ្ងៃរបស់មនុស្ស។ ដើម្បីការពារទិន្នន័យរសើប និងទ្រព្យមានតម្លៃនានាពីការលួចរបស់ Hackers លើប្រព័ន្ធអ៊ីនធឺណិត រដ្ឋាភិបាល និងស្ថាប័នជំនួញ ត្រូវមានវិធានការ និងយន្តការឆ្លើយតបដែលមានភាពឿនលឿន និងមានបច្ចុប្បន្នភាព សម្រាប់បញ្ហាសន្តិសុខដែលកើតមានឡើងជាបន្តបន្ទាប់លើប្រព័ន្ធអ៊ីនធឺណិត។ ព្រឹត្តិការណ៍នៃការវាយប្រហារមេរោគតាមកម្មវិធីកុំព្យូទ័រឈ្មោះ "WannaCry" ដែលកើតមានទូទាំងពិភពលោកនៅឆ្នាំ២០១៧ គឺជាការកត់សម្គាល់ និងជាឧទាហរណ៍នៃការវាយលុករបស់ក្រុម Hackers ចូលកុំព្យូទ័រប្រហែល ២សែនគ្រឿង នៅតាមបណ្តាទីតាំងនានាដល់ទៅជាង១០០ប្រទេស (Comptroller and Auditor, 2017)។ ការវាយលុកនេះ បានបង្ហាញយ៉ាងច្បាស់ថា ការប្រុងប្រយ័ត្នខ្ពស់ចំពោះសន្តិសុខឌីជីថលគឺជាកត្តាចាំបាច់បំផុតមួយ ដោយសារគេមិនអាចព្យាករទុកជាមុនបាននូវការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិត ជាពិសេសក្នុងពេលដែលអ្វីៗស្ទើរតែទាំងអស់ ត្រូវបានកែប្រែឲ្យក្លាយជាឌីជីថល។ ក្នុងករណីផ្សេងទៀត សង្គ្រាមតាមប្រព័ន្ធអ៊ីនធឺណិតក៏បានបង្កការព្រួយបារម្ភដល់បណ្តាប្រទេសក្នុងសកលលោកដែរ ដោយមានការប្រើប្រាស់បច្ចេកវិទ្យាជឿនលឿន និងទំនើបៗបំផុតនេះ ដើម្បីស៊ើបការណ៍លួចយកព័ត៌មានសម្ងាត់ ឬបង្កភាពវឹកវរផ្នែកនយោបាយនៅក្នុងប្រទេសរបស់ពួកគេ។

## ❖ និន្នាការនៃបដិវត្តន៍ឧស្សាហកម្មទី៤

បណ្តាប្រទេសជាច្រើនក្នុងតំបន់ និងពិភពលោក បានបង្ហាញពីកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនលើការត្រៀមខ្លួន ឬសឹងតែកំពុងស្ថិតក្នុងដំណាក់កាលនៃការអនុវត្តគោលនយោបាយរបស់ខ្លួនសម្រាប់ការចូលមកដល់នៃឧស្សាហកម្ម ៤.០ ដើម្បីធានាថាសង្គមរបស់ពួកគេនឹងអាចសម្របខ្លួន និងចាប់យកឱកាស និងអត្ថប្រយោជន៍ដ៏ច្រើនលើសលប់ ដែលអាចទទួលបានពីបច្ចេកវិទ្យាទំនើបៗក្នុងបដិវត្តន៍ឧស្សាហកម្មទី៤។ ឧទាហរណ៍៖ រដ្ឋាភិបាលក្រុងប៉េកាំងបានបង្កើតគំនិតផ្តួចផ្តើមមួយឈ្មោះថា "ផលិតនៅប្រទេសចិនឆ្នាំ២០២៥ (Made in China ២០២៥)" ដើម្បីផ្លាស់ប្តូរប្រទេសចិនឲ្យទៅជាមហាអំណាចបច្ចេកវិទ្យា និងបង្កើនការអភិវឌ្ឍបច្ចេកវិទ្យាសម្រាប់បដិវត្តន៍ឧស្សាហកម្មទី៤ (Kania, ២០១៩)។ រីឯក្នុងតំបន់អាស៊ីអាគ្នេយ៍វិញ សិង្ហបុរី គឺជាប្រទេសសកម្មបំផុតមួយដែលបានលើកកម្ពស់ការផ្លាស់ប្តូរផ្នែកបច្ចេកវិទ្យា និងឌីជីថលនៅក្នុងសង្គមរបស់ខ្លួន។ ក្រៅពីចក្ខុវិស័យនៃការសាងសង់ទីក្រុងវៃឆ្លាត សិង្ហបុរីបានខិតខំប្រឹងប្រែងជួយដល់ក្រុមហ៊ុនក្នុងស្រុក ក្នុងការបង្កើតយុទ្ធសាស្ត្រ ដើម្បីធ្វើការផ្លាស់ប្តូរបែបឌីជីថលនៃគំរូធុរកិច្ចរបស់ពួកគេ តាមរយៈការដាក់ឲ្យប្រើប្រាស់សន្ទស្សន៍វាស់ស្ទង់ភាពត្រៀមខ្លួនសម្រាប់ឧស្សាហកម្ម (Smart Industry Readiness Index) – ដើម្បីកំណត់ និងផ្តោតលើទិដ្ឋភាពសំខាន់ៗ ក្នុងការផ្លាស់ប្តូរគំរូធុរកិច្ច – និងតារាងសម្រាប់ការវាយតម្លៃ (Assessment Matrix) – ដើម្បីដាក់ចេញនូវផែនការសកម្មភាពសម្រាប់ការផ្លាស់ប្តូរ

និងវាយតម្លៃលើភាពពេញលក្ខណៈផ្នែកឌីជីថលរបស់ពួកគេ (Singapore Economic Development Board, 2018) ។

នៅក្នុងបរិបទកម្ពុជា និន្នាការនៃការផ្លាស់ប្តូរផ្នែកឌីជីថល ត្រូវបានយកមកអនុវត្តជាបន្តបន្ទាប់ ដោយរដ្ឋាភិបាលកម្ពុជា ក៏ដូចជាវិស័យឯកជនផងដែរ។ ឧទាហរណ៍៖ កម្ពុជាមានគំនិតផ្តួចផ្តើមជាច្រើនត្រូវបានបង្កើតឡើង ដែលគាំទ្រដោយក្រុមហ៊ុនឯកជន ដើម្បីលើកទឹកចិត្តដល់សហគ្រិនវ័យក្មេង ក្នុងការបង្កើតធុរកិច្ចឌីជីថលផ្ទាល់ខ្លួន។ មិនតែប៉ុណ្ណោះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានផ្តួចផ្តើមបង្កើតឲ្យមាន ធនាគារ SMEs ដើម្បីផ្តល់លទ្ធភាពដល់សហគ្រាសធុនតូច និងមធ្យមក្នុងការស្វែងរកមូលនិធិជំនួយ និងលើកកម្ពស់ការបង្កើតធុរកិច្ចឌីជីថលនៅក្នុងប្រទេស។ ថ្មីៗនេះ នាយករដ្ឋមន្ត្រីកម្ពុជា បានផ្តល់អនុសាសន៍ដល់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឲ្យបង្កើតក្របខណ្ឌសេដ្ឋកិច្ចឌីជីថលដើម្បីលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ដោយផ្តោតលើទិដ្ឋភាពសំខាន់ៗចំនួន៣៖ ទី១) ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសម្រាប់វិស័យឌីជីថល និងការរៀបចំប្រព័ន្ធទូទាត់ប្រាក់អេឡិចត្រូនិក, ទី២) ការបង្កើតថ្នាលឌីជីថល និងការអភិវឌ្ឍប្រព័ន្ធធុរកិច្ចឌីជីថល, និង ទី៣) ការលើកកម្ពស់ឌីជីថលូបនីយកម្មរដ្ឋាភិបាល សហគ្រិនភាព និងទិន្នន័យបើកចំហ។ ជាងនេះទៅទៀត រដ្ឋាភិបាលកម្ពុជាក៏បានខិតខំលើកកម្ពស់សន្តិសុខឌីជីថលនៅក្នុងប្រទេស តាមរយៈការបង្កើតគោលនយោបាយ បទប្បញ្ញត្តិច្បាប់ និងស្តង់ដាររួមផ្សេងៗ ដើម្បីធានាសុវត្ថិភាពនៃបរិយាកាសនៃការធ្វើធុរកិច្ចក្នុងសេដ្ឋកិច្ចឌីជីថល។ តែទោះជាយ៉ាងណាក៏ដោយ កិច្ចខិតខំប្រឹងប្រែងទាំងនេះនៅតែមិនអាចផ្តល់ភាពច្បាស់លាស់មួយថា តើវាគ្រប់គ្រាន់ហើយឬនៅ សម្រាប់រាជរដ្ឋាភិបាល ស្ថាប័នជំនួញ សង្គម និងជាពិសេសប្រជាជនទូទៅ អាចត្រៀមខ្លួនរួចរាល់សម្រាប់ការចូលមកដល់នៃឧស្សាហកម្ម៤.០៕

## ឯកសារយោង


Castro, D. (2019). *5G can enable smart cities – if policymakers allow it*. Retrieved from https://www.govtech.com/fs/infrastructure/5G-Can-Enable-Smart-Cities-If-Policymakers-Allow-It.html

Chen, J. (2019). *Industrial Revolution*. Retrieved from https://www.investopedia.com/terms/i/industrial-revolution.asp

Citi & Oxford Martin School. (2016). *Technology at work: The future is not what it used to be.* Retrieved from https://www.oxfordmartin.ox.ac.uk/downloads/reports/Citi_GPS_Technology_Work_2.pdf

Comptroller and Auditor General. (2017). *Investigation: WannaCry cyber attack and the NHS.* Retrieved from https://www.nao.org.uk/wp-content/uploads/2017/10/Investigation-WannaCry-cyber-attack-and-the-NHS.pdf

History. (2019). *Industrial Revolution*. Retrieved from https://www.history.com/topics/industrial-revolution/industrial-revolution

Kania, E. B. (2019, February 01). Made in China 2025, Explained. *The Diplomat.* Retrieved from https://thediplomat.com/2019/02/made-in-china-2025-explained/

Low, I. (2018). *The benefits of smart cities*. Retrieved from https://www.globalsign.com/en/blog/the-benefits-of-smart-cities/

McKinsey Global Institute. (2017). *Jobs Lost, Jobs Gained: Workforce Transitions in a Time of Automation*. Retrieved from https://www.mckinsey.com/~/media/mckinsey/featured%20insights/Future%20of%20Organizations/What%20the%20future%20of%20work%20will%20mean%20for%20jobs%20skills%20and%20wages/MGI-Jobs-Lost-Jobs-Gained-Report-December-6-2017.ashx

Petrillo, A., Felice, F. D., Cioffi, R., & Zomparelli, F. (2018). Fourth industrial revolution: current practices, challenges, and opportunities. Retrieved from https://api.intechopen.com/chapter/pdf-download/58010

Schwab, K. (2016a). *The fourth industrial revolution.* Geneva, Switzerland: World Economic Forum.

Schwab, K. (2016b). *The fourth industrial revolution: what it means, how to respond.* Retrieved from https://www.weforum.org/agenda/2016/01/the-fourth-industrial-revolution-what-it-means-and-how-to-respond/

Singapore Economic Development Board. (2018). *The Singapore Smart Industry Readiness Index*. Retrieved from https://www.edb.gov.sg/en/news-and-resources/news/advanced-manufacturing-release.html

Smith, J. (2018). *The Fourth Industrial Revolution: Challenges and Opportunities*. Retrieved from https://business.leeds.ac.uk/research-and-innovation/blog/article/the-fourth-industrial-revolution-challenges-and-opportunities/

Trailhead. (n.d.). *Understand the impact of the fourth industrialization on society and individuals.* Retrieved from https://trailhead.salesforce.com/content/learn/modules/impacts-of-the-fourth-industrial-revolution/understand-the-impact-of-the-fourth-industrial-revolution-on-society-and-individuals

Cambodia Development Center

Cambodia Development Center (@cdcenter_kh)

Cambodia Development Center (@cd.centerkh)

Cambodia Development Center

Cambodia Development Center

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

Building E, University of Puthisastra, #55, Street 180-184, Sangkat Boeung Raing, Khan Daun Penh

info@cd-center.com | (+855) 16 616 951

# ឯកសារជំនួយស្មារតី៖ ស្វែងយល់ពីសេដ្ឋកិច្ចឌីជីថល

ជំនួយស្មារតី

*វ៉ុល១ លេខទី៥ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩*

# ស្វែងយល់ពីសេដ្ឋកិច្ចឌីជីថល

គង់ រតនធីតា*

ការផ្លាស់ប្តូរបែបឌីជីថល បាននិងកំពុងកើតឡើងដំណាលគ្នានឹងបដិវត្តន៍ឧស្សាហកម្មទី៤។ និន្នាការនៅទូទាំងពិភពលោកនាពេលបច្ចុប្បន្ននេះ បានស្វាគមន៍យ៉ាងក្លៀវក្លានូវបដិវត្តន៍ជំនាន់ថ្មី រាប់បញ្ចូលទាំងអ៊ីនធឺណិត ប្រព័ន្ធទិន្នន័យធំ (Big Data) ប្រព័ន្ធ Cloud Computing បច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech) និងបច្ចេកវិទ្យាឌីជីថលជាច្រើនទៀតនាពេលថ្មីៗនេះ ហើយបានចោទជាចម្ងល់ទាក់ទិននឹងពាក្យថា «*សេដ្ឋកិច្ចឌីជីថល*»។ ឧបករណ៍តភ្ជាប់ទៅប្រព័ន្ធអ៊ីនធឺណិត (Internet of Things) និងបណ្តាញទំនាក់ទំនងជាប្រចាំលើប្រព័ន្ធអ៊ីនធឺណិត (Hyper-connectivity) រវាងមនុស្ស ពាណិជ្ជកម្ម និងទិន្នន័យ បានក្លាយជាផ្នែកមួយដ៏មានសារសំខាន់នៃជីវិតរបស់យើងដែលមិនធ្លាប់មានពីមុនមក។ រាប់ពីការទិញម្ហូបអាហារតាមអនឡាញដល់ការរៀនសូត្រ និងធ្វើការតាមអនឡាញ ការផ្លាស់ប្តូរតាមទម្រង់នៃប្រព័ន្ធឌីជីថលបានវិវត្តទៅជាគុណប្រយោជន៍បន្ថែមថ្មីដល់វិស័យពាណិជ្ជកម្ម ដែលបានជំរុញឲ្យការរស់នៅកាន់តែមានភាពងាយស្រួល។ ក្រុមហ៊ុនបច្ចេកវិទ្យាដូចជា Apple, Huawei, Microsoft និងវេទិកាអនឡាញដ៏មានឥទ្ធិពលជាច្រើនផ្សេងទៀតដូចជា Google, Amazon, Alibaba, Airbnb, Uber និង Facebook ជាដើម គឺជាឧទាហរណ៍នៃការងារវៃឆ្លាតនិងភាពជោគជ័យនៃប្រព័ន្ធ និងបរិស្ថានរបស់សេដ្ឋកិច្ចឌីជីថល។ ក្នុងន័យនេះ សំណួរដ៏សំខាន់ដែលគេចោទសួរគឺថា តើអ្វីទៅគឺជាសេដ្ឋកិច្ចឌីជីថល? តើបច្ចេកវិទ្យាឌីជីថលនេះបាន និងកំពុងមានឥទ្ធិពលបែបណាខ្លះមកលើយើង? តើអ្វីទៅជាឥទ្ធិពលពិតប្រាកដដែលកើតចេញពីការរីកដុះដាលយ៉ាងគំហុករបស់ប្រព័ន្ធឌីជីថលនៅសតវត្សរ៍ទី២១នេះ? អ្វីដែលយើងបានដឹងពីសេដ្ឋកិច្ចឌីជីថលគឺភាពមិនអាចប្រកែកបានថា វាជ្រាបចូលស្ទើរតែគ្រប់ជ្រុងនៃជីវិតរស់នៅ និងសង្គមមនុស្ស ដោយរាប់បញ្ចូលទាំងរបៀបរបបធ្វើការតាមបែបឌីជីថល និងរបៀបដែលមនុស្សប្រាស្រ័យទាក់ទងគ្នា។ ប៉ុន្តែមែនទែនទៅ អ្វីដែលយើងពុំបានដឹងឲ្យច្បាស់នោះ គឺថាតើការផ្លាស់ប្តូរដ៏ធំធេងនេះ នឹងកើតឡើងដោយរបៀបណា? អត្ថបទនេះនឹងផ្តល់ការស្វែងយល់ដោយសង្ខេបអំពីសេដ្ឋកិច្ចឌីជីថលជារួម និងដំណើររបស់វានៅក្នុងបរិបទកម្ពុជា។

## តើអ្វីទៅជាសេដ្ឋកិច្ចឌីជីថល?

បដិវត្តន៍ឧស្សាហកម្មទី១ — បានលេចរូបរាងឡើងដោយតាមរយៈការបង្កើតឧស្សាហកម្មដែក និងដែកថែប ព្រមទាំងម៉ាស៊ីនដើរដោយចំហាយទឹក — ហើយបដិវត្តន៍ឧស្សាហកម្មទី២ — ដែលដំណើរការដោយរបកគំហើញថាមពលអគ្គិសនី ប្រព័ន្ធទូរគមនាគមន៍ និងការបង្កើតខ្សែសង្វាក់ផលិតកម្មនៅក្នុងរោងចក្រ បានត្រួសត្រាយផ្លូវសម្រាប់សន្ទុះយ៉ាងខ្លាំងខ្លានៃការរីកចម្រើនផ្នែកផលិតកម្ម។ នៅក្នុងទសវត្សរ៍៦០ បដិវត្តន៍ឧស្សាហកម្មទី៣ ដែលត្រូវបានគេស្គាល់ផងដែរថាជា បដិវត្តន៍ឌីជីថល បានបង្ហាញវត្តមាននៃយុគសម័យព័ត៌មាន រួមមានការអភិវឌ្ឍប្រព័ន្ធអ៊ីនធឺណិត ព័ត៌មានវិទ្យា (IT) ស៊ីមីកុងឌុចទ័រ (Semiconductor) កុំព្យូទ័រភាវូបនីយកម្ម និងបច្ចេកវិទ្យាជាច្រើនទៀត។ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) ក្នុងយុគសម័យឌីជីថល បានតម្រង់ទិសដៅឆ្ពោះទៅកាន់

*__គង់ រតនធីតា__ ជាអ្នកសម្របសម្រួលគម្រោងទទួលបន្ទុកទំនាក់ទំនងសាធារណៈនៅមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

© *រក្សាសិទ្ធដោយ មអក | ខ្លឹមសារនៃអត្ថបទនេះគឺជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។*

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

បដិវត្តន៍ឧស្សាហកម្មទី៤ ហើយបានបង្កើតជាមូលដ្ឋានសម្រាប់ការមកដល់នៃបច្ចេកវិទ្យាទំនើបបំផុតសម្រាប់ការធ្វើពាណិជ្ជកម្មក្នុងយុគសម័យថ្មី ដែលគេស្គាល់ជាទូទៅថា «សេដ្ឋកិច្ចឌីជីថល»។

សេដ្ឋកិច្ចឌីជីថល គឺជាទម្រង់នៃសកម្មភាព និងដំណើរការសេដ្ឋកិច្ចដែលចរាចរនៅលើប្រព័ន្ធអ៊ីនធឺណិតដោយមានជំនួយពីបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដែលជំរុញឲ្យមានការតភ្ជាប់កាន់តែទូលំទូលាយបំផុត រវាងនិងក្នុងចំណោមមនុស្ស ពាណិជ្ជកម្ម ឧបករណ៍ និងទិន្នន័យ។ ព័ត៌មាន និងចំណេះដឹងត្រូវបានប្រើប្រាស់ដើម្បីពង្រឹង និងពង្រីកសកម្មភាពផលិតកម្ម។ សេដ្ឋកិច្ចឌីជីថល ក៏ត្រូវបានគេហៅថា សេដ្ឋកិច្ចអ៊ីនធឺណិត (Internet Economy) ឬសេដ្ឋកិច្ចថ្មី (New Economy) ឬសេដ្ឋកិច្ចវេបសាយ (Web Economy) ផងដែរ ដោយសារតែពំនឹងផ្អែកយ៉ាងខ្លាំងលើបណ្តាញភ្ជាប់ទៅនឹងប្រព័ន្ធអ៊ីនធឺណិត។ ពាក្យ «សេដ្ឋកិច្ចឌីជីថល» ត្រូវបានបង្កើតឡើងដំបូងដោយលោក Don Tapscott ក្នុងឆ្នាំ១៩៩៥ នៅក្នុងសៀវភៅរបស់លោកដែលមានចំណងជើងថា *«សេដ្ឋកិច្ចឌីជីថល៖ ការសន្យា និងគ្រោះថ្នាក់នៅក្នុងយុគសម័យបណ្តាញនៃភាពវៃឆ្លាត»*។ តែទោះជាយ៉ាងណា និយមន័យរបស់សេដ្ឋកិច្ចឌីជីថលមានភាពទូលំទូលាយ និងមិនជាក់លាក់ដែលមិនត្រូវបានកំណត់ដោយសកម្មភាព និងដំណើរការតែមួយនោះឡើយ។ ដោយសារបែបនេះហើយ ទើបមានការយល់ឃើញផ្សេងៗគ្នាអំពីថា អ្វីទៅជាសេដ្ឋកិច្ចឌីជីថល។ ខាងក្រោមនេះ គឺជានិយមន័យសេដ្ឋកិច្ចឌីជីថលដែលត្រូវបានកំណត់ដោយអង្គការធំៗនៅលើពិភពលោក។

## ទស្សនទាននានាអំពីសេដ្ឋកិច្ចឌីជីថល

Australian Government

"បណ្តាញនៃសកម្មភាពសេដ្ឋកិច្ច និងសង្គមជាសកល ដែលត្រូវបានដំណើរការដោយបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដូចជាអ៊ីនធឺណិត ទូរស័ព្ទចល័ត និងប្រព័ន្ធ Sensor ជាដើម។"

ADB

"សកម្មភាពសេដ្ឋកិច្ចដែលប្រើប្រាស់លើព័ត៌មាន និងចំណេះដឹងឌីជីថល ជាកត្តាគន្លឹះនៃផលិតកម្មផ្អែកលើអ៊ីនធឺណិត ប្រព័ន្ធ Cloud Computing ទិន្នន័យធំ និងបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីប្រមូល រក្សាទុក វិភាគ និងចែករំលែកព័ត៌មានឌីជីថល និងផ្លាស់ប្តូរអន្តរកម្មសង្គម។"

OECD

"ទីផ្សារមួយមានមូលដ្ឋានលើបច្ចេកវិទ្យាឌីជីថល ដែលជួយសម្រួលដល់ការធ្វើពាណិជ្ជកម្មនៃទំនិញ និងសេវាកម្មតាម រយៈពាណិជ្ជកម្មអេឡិចត្រូនិក។"

UNCTAD

"ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលផ្អែកលើអ៊ីនធឺណិតសម្រាប់ផលិតកម្ម និងការធ្វើពាណិជ្ជកម្មទំនិញ និងសេវាកម្ម។"

Oxford Dictionaries

"សេដ្ឋកិច្ចដែលដំណើរការជាចម្បងដោយបច្ចេកវិទ្យាឌីជីថល ជាពិសេសប្រតិបត្តិការអេឡិចត្រូនិកដែលត្រូវបានធ្វើឡើងផ្អែកលើប្រព័ន្ធអ៊ីនធឺណិត។"

THE WORLD BANK

"ប្រព័ន្ធទំនាក់ទំនងសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដោយផ្អែកលើការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានឌីជីថល។"

## ធាតុស្នូលនៃសេដ្ឋកិច្ចឌីជីថល

ចំណុចស្នូលនៃសេដ្ឋកិច្ចឌីជីថលក្នុងយុគសម័យទំនើប គឺការរួមបញ្ចូលនៃ ១) បច្ចេកវិទ្យារ៉ូបូតទំនើប ឧបករណ៍ដ្រូន (Drones) និងស្វ័យប្រវត្តិកម្មរោងចក្រ; ២) ឧបករណ៍តភ្ជាប់ទៅប្រព័ន្ធអ៊ីនធឺណិត; ៣) ប្រព័ន្ធ Cloud Computing; ៤) ប្រព័ន្ធវិភាគទិន្នន័យធំ; និង ៥) បញ្ញាសិប្បនិម្មិត (AI) (UNCTAD, 2017)។ បច្ចេកវិទ្យាទាំងនេះ គឺជាលក្ខណៈពិសេសនៃគំរូពាណិជ្ជកម្មទំនើបថ្មី ដែលត្រូវបានគេសម្គាល់ខុសពីសេដ្ឋកិច្ចធម្មតា។ លោក Thomas Mesenbourg បានកំណត់សមាសធាតុសំខាន់ចំនួន៣របស់សេដ្ឋកិច្ចឌីជីថល រួមមាន ហេដ្ឋារចនាសម្ព័ន្ធអាជីវកម្មអេឡិចត្រូនិក (e-business infrastructure) អាជីវកម្មអេឡិចត្រូនិក (e-business) និងពាណិជ្ជកម្មអេឡិចត្រូនិក (e-commerce) (Mesenbourg, 2001) ។

ហេដ្ឋារចនាសម្ព័ន្ធដែលអាចដំណើរការតាមបែបឌីជីថល/អាជីវកម្មអេឡិចត្រូនិក គឺជាគ្រឹះនៃសេដ្ឋកិច្ចឌីជីថលដែលឈរលើមូលដ្ឋាននៃបណ្តាញដែលគ្រប់គ្រង និងសម្របសម្រួលដោយប្រព័ន្ធកុំព្យូទ័រ។ ក្នុងនោះរួមមានសម្ភារូបវន្តមូលដ្ឋាន និងការរៀបចំប្រព័ន្ធ ដើម្បីធ្វើការគាំទ្រដល់ដំណើរការអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយរាប់បញ្ចូលទាំងផ្នែករឹង (Hardware) ផ្នែកទន់ (Software) បរិក្ខារ និងសេវាទូរគមនាគមន៍ រចនាសម្ព័ន្ធ ឧបករណ៍តភ្ជាប់ទៅប្រព័ន្ធអ៊ីនធឺណិត និងសេវាគាំទ្រ។ ម៉្យាងវិញទៀត ពាណិជ្ជកម្មអេឡិចត្រូនិក គឺជាដំណើរការណាមួយនៃការលក់ ឬផ្គត់ផ្គង់ទំនិញរាយតាមអនឡាញ និងប្រតិបត្តិការបែបអេឡិចត្រូនិក តាមរយៈការបញ្ជាទិញ ដឹកជញ្ជូនតាម ឬធ្វើប្រតិបត្តិការតាមប្រព័ន្ធឌីជីថល។ ទាំងនោះរួមមាន៖

- អាជីវកម្ម-ទៅ-អាជីវកម្ម (Business-to-business-B2B)៖ ប្រតិបត្តិការទំនិញ និងសេវាកម្មរវាងអាជីវកម្មមួយទៅកាន់អាជីវកម្មមួយផ្សេងទៀត តាមរយៈប្រព័ន្ធអ៊ីនធឺណិត ឬតាមមធ្យោបាយអេឡិចត្រូនិកផ្សេងទៀត។
- អាជីវកម្ម-ទៅ-អតិថិជន (Business-to-consumer-B2C)៖ ការលក់ទំនិញ និងសេវាកម្មដោយអាជីវកម្មមួយទៅអតិថិជន ឬការធ្វើពាណិជ្ជកម្មអេឡិចត្រូនិក ដូចជាការទិញ លក់រាយតាមប្រព័ន្ធអ៊ីនធឺណិត ឬមធ្យោបាយ អេឡិចត្រូនិកផ្សេងទៀត។
- អ្នកប្រើប្រាស់-ទៅ-អ្នកប្រើប្រាស់ (Peer-to-peer-P2P)៖ "សេដ្ឋកិច្ចចែករំលែក" ឬពាណិជ្ជកម្មអេឡិចត្រូនិកតាមអនឡាញ (platform-based e-commerce) រួមមានការផ្លាស់ប្តូរទំនិញ និងសេវាកម្មរវាងអ្នកប្រើប្រាស់តាមរយៈកម្មវិធីឌីជីថល។
- អាជីវកម្មអេឡិចត្រូនិក៖ ជាដំណើរការដែលអង្គភាពអាជីវកម្មមួយធ្វើអាជីវកម្មខ្លួនលើបណ្តាញគ្រប់គ្រងសម្របសម្រួលដោយប្រព័ន្ធកុំព្យូទ័រ។ ទោះបីមានភាពស្រដៀងគ្នាទៅនឹងពាណិជ្ជកម្មអេឡិចត្រូនិក វាលើសពីការលក់ និងទិញសេវាកម្ម និងផលិតផលតាមអនឡាញ។ អាជីវកម្មអេឡិចត្រូនិក គ្របដណ្តប់យ៉ាងទូលំទូលាយលើដំណើរការអាជីវកម្ម ដូចជាការគ្រប់គ្រងខ្សែសង្វាក់ផ្គត់ផ្គង់ ការលក់និងទីផ្សារ ការគ្រប់គ្រងទំនាក់ទំនងអតិថិជន និងការរៀបចំផែនការធនធានសហគ្រាសជាដើម។

លើសពីនេះ Barefoot et al., (2018) បានរៀបរាប់ស្រដៀងគ្នានេះដែរ ប៉ុន្តែបានបន្ថែមសមាសធាតុមួយទៀត គឺប្រព័ន្ធផ្សព្វផ្សាយឌីជីថល ជាធាតុផ្សំសំខាន់នៃសេដ្ឋកិច្ចឌីជីថល។ ប្រព័ន្ធផ្សព្វផ្សាយឌីជីថល គឺជាខ្លឹមសារដែលមនុស្សបង្កើតឡើង បើកឲ្យមានការចូលមកយករក្សាទុក ឬមើលតាមឧបករណ៍ឌីជីថល រួមមានប្រព័ន្ធផ្សព្វផ្សាយឌីជីថលលើការលក់ដោយផ្ទាល់ (ផលិតផលឌីជីថលត្រូវបានលក់ដោយផ្ទាល់ទៅអ្នកប្រើប្រាស់ក្នុងតម្លៃមួយ); ប្រព័ន្ធផ្សព្វផ្សាយឌីជីថលឥតគិតថ្លៃ (ប្រាក់ចំណូលទទួលបានពីការផ្សាយពាណិជ្ជកម្មនៃផលិតផលឌីជីថល); និង ទិន្នន័យធំ (ជាយន្តការសម្រាប់ប្រមូលព័ត៌មានអំពីឥរិយាបថ និងចំណូលចិត្តអ្នកប្រើប្រាស់) ។

## ឥទ្ធិពលរបស់សេដ្ឋកិច្ចឌីជីថល

វត្តមានរបស់បច្ចេកវិទ្យាទំនើបចុងក្រោយបង្អស់ដូចជាប្រព័ន្ធ Cloud Computing បច្ចេកវិទ្យា Augmented និង Virtual reality ការបោះពុម្ព 3D ការប្រាស្រ័យទាក់ទងពីម៉ាស៊ីនមួយទៅម៉ាស៊ីនមួយ បច្ចេកវិទ្យា Sensor ខ្សែសង្វាក់ផលិតកម្ម ទិន្នន័យធំ ឧបករណ៍តភ្ជាប់ទៅប្រព័ន្ធអ៊ីនធឺណិត បញ្ញាសិប្បនិម្មិត ប្រព័ន្ធ 5G និងបច្ចេក

វិទ្យាចែកចាយទិន្នន័យ (Distributed Ledger Technologies) ជាដើម បានបង្ហាញពីតួនាទីរបស់ឌីជីថលូបនីយកម្មក្នុងការជួយជ្រោមជ្រែងបរិស្ថានមួយ ដែលផ្តល់អត្ថប្រយោជន៍ដល់ទាំងសេដ្ឋកិច្ចនិងសង្គម។ ការអនុវត្តបច្ចេកវិទ្យាជឿនលឿនទាំងនោះ បានជួយឲ្យដំណើរការផលិតកម្មនាពេលបច្ចុប្បន្ន និងប្រព័ន្ធគ្រប់គ្រងអាជីវកម្មអាចបង្កើននូវផលចំណេញបានល្អប្រសើរជាមុន និងលឿនជាងអ្វីដែលត្រូវបានផ្តល់ជូនដោយវិធីប្រពៃណីក្នុងប្រតិបត្តិការអាជីវកម្ម។ សេដ្ឋកិច្ចឌីជីថលបានរៀបចំរចនាសម្ព័ន្ធអាជីវកម្មថ្មី ដោយផ្អែកលើប្រព័ន្ធអ៊ីនធឺណិតផ្ទៃក្នុង (intranet) និងប្រព័ន្ធអ៊ីនធឺណិតខាងក្រៅ (internet) ដែលជំរុញឲ្យមានសមិទ្ធផល និងប្រសិទ្ធផលខ្ពស់។ អ្វីដែលសំខាន់ជាងនេះទៀតនោះ គឺដំណើរការអន្តរកម្ម និងការចូលរួមកាន់តែច្រើនរវាងអ្នកលក់ និងអ្នកប្រើប្រាស់ ដែលធ្វើឲ្យអតិថិជនទទួលបានអត្ថប្រយោជន៍ជាច្រើនដូចជា តម្លាភាព តម្លៃជម្រើស ការវាយតម្លៃ និងភាពងាយស្រួល។ ដោយសារការទាមទារឲ្យមានការប្រើប្រាស់គំនិត និងជំនាញខ្ពស់ សេដ្ឋកិច្ចឌីជីថលដើរតួយ៉ាងសំខាន់ក្នុងការពង្រឹង និងពង្រីកសកម្មភាពឧស្សាហកម្ម និងជំរុញផលិតភាព និងភាពប្រកួតប្រជែងឲ្យកាន់តែធំឡើង។ ក្រៅពីនេះ សេដ្ឋកិច្ចឌីជីថលក៏រួមចំណែកដល់នវានុវត្តន៍ ព្រមទាំងការបង្កើតសេវាកម្ម និងការងារថ្មីសម្រាប់ប្រជាជនដែលមានសមត្ថភាពនិងទេពកោសល្យ ហើយអាចសម្របខ្លួនទៅនឹងវាបាន។

លោកនៃការផ្លាស់ប្តូរបែបឌីជីថលនេះក៏បាន និងកំពុងផ្លាស់ប្តូរ និងជះឥទ្ធិពលយ៉ាងខ្លាំងលើវឌ្ឍនភាព និងដំណើរជីវិតរស់នៅប្រចាំថ្ងៃរបស់យើង ក្នុងការបង្កើតនូវសង្គមឌីជីថលដែលគេរំពឹងទុកថានឹងជាបរិស្ថានមួយកាន់តែមានបរិយាបន្ន និរន្តរភាព សុវត្ថិភាព និងនវានុវត្តន៍បន្ថែមទៀត តាមរយៈការកាត់បន្ថយ និងដោះស្រាយបញ្ហាសង្គមនានា ដូចជាវិសមភាពនៃការបែងចែកផលប្រយោជន៍សេដ្ឋកិច្ចដែលមានពីមុន។ ដើម្បីដោះស្រាយវិសមភាព និងកង្វះនៃបរិយាបន្ននៃការអភិវឌ្ឍ ឌីជីថលូបនីយកម្មមានសក្តានុពលក្នុងការបង្កើនវិសាលភាពទូលំទូលាយឲ្យបានទៅដល់ ក្រុមដែលពុំទទួលបានឱកាសនៅក្នុងទីផ្សារតាមរយៈការបញ្ចុះតម្លៃប្រតិបត្តិការ និងកាត់បន្ថយវិសមភាពនៃការទទួលបានព័ត៌មាន។ ការរីកដាលបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដែលនាំមកដោយឌីជីថលូបនីយកម្ម អាចផ្តល់ភាពអង់អាចដល់បុគ្គល និងក្រុមហ៊ុននានា ហើយសម្រួលបរិយាកាសរស់នៅឲ្យកាន់តែប្រសើរ តាមរយៈការបង្កើនលទ្ធភាពទទួលបានឱកាសនៃការធ្វើពាណិជ្ជកម្មដោយសេរី និងយុត្តិធម៌ ការដឹកជញ្ជូននិងភ័ស្តុភារ សេវាហិរញ្ញវត្ថុ កម្មន្តសាល និងកសិកម្ម ការអប់រំ សេវាសុខាភិបាល និងប្រព័ន្ធផ្សព្វផ្សាយជាដើម។ សេដ្ឋកិច្ចឌីជីថល បាននាំមកនូវអត្តសញ្ញាណឌីជីថល ដែលគេជឿជាក់ថា នឹងត្រួសត្រាយផ្លូវសម្រាប់អនាគតឌីជីថលប្រកបដោយសុវត្ថិភាព និងភាពធន់ជាងមុនសម្រាប់គ្រប់ទិដ្ឋភាពនៃជីវិត។

ដោយគួរឲ្យកត់សម្គាល់ ខណៈពេលដែលឌីជីថលូបនីយកម្មបាននាំយកមកនូវអត្ថប្រយោជន៍ប្រកបដោយសក្តានុពលជាច្រើន ដល់សេដ្ឋកិច្ច និងសង្គម វាក៏បានបង្កឲ្យមានការព្រួយបារម្ភមួយចំនួនដូចគ្នា។ ទោះបីជាមានការកើនឡើងនៃនិន្នាការឌីជីថលូបនីយកម្មក្តី ការបែងចែកឌីជីថលនៅតែជាបញ្ហាប្រឈម ដោយសារការចែកចាយមិនស្មើភាពគ្នានៃការទទួលបាន ការប្រើប្រាស់ និងផលប៉ះពាល់នៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានក្នុងចំណោមប្រជាជន។ ឧទាហរណ៍ ជំនួសឲ្យការប្រើប្រាស់បច្ចេកវិទ្យាដ៏កាន់តែទូលំទូលាយ បញ្ហាដូចជាការចំណាយខ្ពស់ក្នុងការទិញទូរស័ព្ទស្មាតហ្វូន និងលទ្ធភាពក្នុងការទទួលបានអ៊ីនធឺណិតប្រើប្រាស់នៅតែនៅឆ្ងាយពីបុគ្គលមួយចំនួនធំនៅឡើយ ដែលជាកត្តារាំងស្ទះដល់ការទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចឌីជីថលដោយស្មើភាពគ្នា។ នៅពេលដែលបច្ចេកវិទ្យាឌីជីថលត្រូវបានទទួលយកទាំងស្រុង វានឹងទាមទារឲ្យមានជាចាំបាច់នូវជំនាញឌីជីថល ហើយដំណើរការឌីជីថលនឹងធ្វើឲ្យរំខានដល់ទីផ្សារការងារ និងផ្លាស់ប្តូរសមាសភាពការងារដែលមានស្រាប់។ មិនត្រឹមតែប៉ុណ្ណោះ បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ត្រូវខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីពង្រឹងកម្រិតហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ព្រមទាំងចូលរួមក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ ដើម្បីទទួលបាន និងចាប់យកអត្ថប្រយោជន៍ឌីជីថលជាអតិបរមា។




*ប្រភព៖ វេទិកាសេដ្ឋកិច្ចពិភពលោក*

## តើកម្ពុជានាពេលបច្ចុប្បន្នស្ថិតក្នុងចំណុចណានៃសេដ្ឋកិច្ចឌីជីថល?

ជាមួយនឹងការរីកលូតលាស់នៃបដិវត្តន៍ឧស្សាហកម្មទី៤ ការផ្លាស់ប្តូរបែបឌីជីថល នឹងក្លាយជាគំរូថ្មីនៃក្បាលម៉ាស៊ីនសម្រាប់កំណើនសេដ្ឋកិច្ចដ៏សំខាន់បំផុតមួយដែលមិនអាចចៀសបាន ប្រសិនបើកម្ពុជាត្រូវការសម្រេចចក្ខុវិស័យរយៈពេលវែងរបស់ខ្លួន ក្នុងការក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០។ ក្នុងការកសាងមូលដ្ឋានដើម្បីសម្រេចនូវក្តីស្រមៃនេះ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសផែនការដើម្បីប្រែក្លាយកម្ពុជាទៅជាសេដ្ឋកិច្ចឌីជីថលត្រឹមឆ្នាំ២០២៣។ អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានមានប្រសាសន៍ថា៖

*សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ដូចកម្ពុជា បច្ចេកវិទ្យាថ្មីផ្តល់នូវឱកាសក្នុងការលោតផ្លោះដំណាក់កាលបែបប្រពៃណីនៃការអភិវឌ្ឍ... វាត្រូវការរយៈពេលយ៉ាងតិច១០ឆ្នាំ ដើម្បីផ្លាស់ប្តូរទៅរកសេដ្ឋកិច្ចឌីជីថលពេញលេញមួយ (ខែឧសភា ២០១៩)។*

អ្វីដែលសំខាន់បំផុតគឺ ដើម្បីត្រៀមសម្រាប់បដិវត្តន៍ឧស្សាហកម្មទី៤ រាជរដ្ឋាភិបាលបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ អំពីខ្លឹមសារស្តីពីការធ្វើពិពិធកម្មសេដ្ឋកិច្ចក្នុងចតុកោណទី២។ ការត្រៀមខ្លួនរួចរាល់សម្រាប់ឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល និងឧស្សាហកម្ម៤.០ ក៏ត្រូវបានទទួលស្គាល់ក្នុងមុំទី៣ នៃយុទ្ធសាស្ត្រដែលបានចែង។ រាជរដ្ឋាភិបាលកម្ពុជា បានទទួលស្គាល់ពីសារសំខាន់នៃសេដ្ឋកិច្ចឌីជីថល ថាជាកម្លាំងស្នូលក្នុងរុញច្រានកំណើនសេដ្ឋកិច្ច ដែលជាលទ្ធផលនឹងបង្កើតឲ្យមានការងារ និងអាជីវកម្មថ្មីៗកាន់តែច្រើនឡើង ហើយទាំងនេះសុទ្ធសឹងតែជាឱកាសល្អបំផុតសម្រាប់កម្ពុជាក្នុងការកែលម្អរចនាសម្ព័ន្ធសេដ្ឋកិច្ចរបស់ខ្លួន (យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ឆ្នាំ២០១៨)។ ដោយឈរលើមូលដ្ឋាននេះ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើត និងដាក់ឲ្យ

ប្រើប្រាស់នូវក្របខណ្ឌយុទ្ធសាស្ត្រសេដ្ឋកិច្ចឌីជីថលរយៈពេលវែង និងគោលនយោបាយពាក់ព័ន្ធមួយចំនួនផ្សេងទៀត ដូចជា គោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ផែនការមេបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ច្បាប់ស្តីពីទូរគមនាគមន៍ និងក្របខណ្ឌយុទ្ធសាស្ត្របច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានរយៈពេលវែង។ លើសពីនេះ ក្របខណ្ឌគតិយុត្តនានាដូចជារដ្ឋាភិបាលឌីជីថល និងយុទ្ធសាស្ត្រសន្តិសុខព័ត៌មាន ច្បាប់ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិក និងច្បាប់ស្តីពីសន្តិសុខតាមអ៊ីនធឺណិត ត្រូវបានផ្សព្វផ្សាយដើម្បីជួយដល់ប្រព័ន្ធបរិស្ថានឌីជីថល ក៏ដូចជាគាំទ្រដល់ការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថលជារួមផងដែរ។

នៅកម្ពុជា សេវាកម្មតាមតម្រូវការដូចជា BookMeBus, PassApp និងNham24 ជាដើម បាន និងកំពុងស្ថិតក្នុងចំណោមសេវាកម្មបច្ចេកវិទ្យាដែលមានឥទ្ធិពលបំផុតនាពេលថ្មីៗនេះ ដែលផ្តល់ជូននូវសេវាកម្មតាមតម្រូវការជាច្រើន រាប់ចាប់ពីការដឹកជញ្ជូនដល់ការចែកចាយអាហារ និងសេវាកម្មផ្សេងទៀតដែលប្រជាជនកម្ពុជាត្រូវការ។ ក្រៅពីនេះបច្ចេកវិទ្យាហិរញ្ញវត្ថុដែលហៅថា ហ្វីនតិចក៏បានដើរតួនាទីដ៏សំខាន់ដូចគ្នា ក្នុងជីវិតប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជាក្នុងរយៈពេលមួយដ៏ខ្លីប៉ុណ្ណោះ។ ជាក់ស្តែង កម្មវិធីធនាគារចល័តរបស់ធនាគារ ABA និង PiPay គឺជាឧទាហរណ៍បង្ហាញយ៉ាងជាក់លាក់ពីឥទ្ធិពលនៃសេវាកម្មទូទាត់តាមអ៊ីនធឺណិតក្នុងការលើកកម្ពស់បរិយាកាសនៃការចំណាយមិនត្រូវការសាច់ប្រាក់នៅកម្ពុជា។ ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបានបង្ហាញខ្លួនមកជំនួសរបៀបនៃការដើរទិញឥវ៉ាន់តាមបែបប្រពៃណីនៅក្នុងទីផ្សារជាក់ស្តែង។ ចំនួនហាងលក់តាមអនឡាញបន្តពង្រីកខ្លួនទៅតាមការផ្គត់ផ្គង់ប្រភេទផលិតផលផ្សេងៗចាប់ពីអាហារភេសជ្ជៈ រហូតដល់សម្លៀកបំពាក់ និងគ្រឿងបន្លាស់នានា តាមរយៈប្រព័ន្ធអ៊ីនធឺណិត និងប្រព័ន្ធផ្សព្វផ្សាយសង្គម ជាពិសេសហ្វេសប៊ុក និងអ៊ីនស្តាក្រាម ក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ។ និន្នាការដែលកំពុងរីកលូតលាស់ទាំងនេះ បានបង្ហាញពីរបៀបដែលឌីជីថលធ្វើឲ្យប៉ះពាល់ដល់ឥរិយាបថរបស់អ្នកប្រើប្រាស់កម្ពុជានិងរបៀបរស់នៅរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ ការបែងចែកឌីជីថលក្នុងចំណោមប្រជាជនកម្ពុជា ជាពិសេសរវាងមនុស្សវ័យចំណាស់ និងយុវជនជំនាន់ក្រោយនៅតែបន្តជាបញ្ហាប្រឈមដែលធ្វើឲ្យរដ្ឋាភិបាលពិបាកក្នុងការធ្វើយ៉ាងណា ដើម្បីឲ្យមនុស្សម្នាក់ៗ ទទួលបានសមភាពនៃការចែកចាយយ៉ាងពេញលេញ។ ដូច្នេះ វាជារឿងចាំបាច់ណាស់ក្នុងការដោះស្រាយបញ្ហាបែបនេះ ដោយធានាថាមនុស្សគ្រប់គ្នាអាចមានលទ្ធភាពទទួលបានសមភាពនៃការប្រើប្រាស់បច្ចេកវិទ្យាទំនើប និងប្រព័ន្ធអ៊ីនធឺណិត។ អ្វីដែលសំខាន់ជាងនេះ និងជាផ្នែកមួយនៃការទាញយកប្រយោជន៍ជាអតិបរមាពីការផ្លាស់ប្តូរបែបឌីជីថលនោះ គឺការយកចិត្តទុកដាក់ជំរុញនូវអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ (Media Literacy) តាមរយៈការបង្កើត និងអភិវឌ្ឍកម្មវិធីអប់រំ និងបណ្តុះបណ្តាល ដែលផ្តោតលើការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលឲ្យបានទូលំទូលាយ ដើម្បីបង្កើនការយល់ដឹងរបស់ប្រជាជន។ ការធ្វើដូច្នេះ នឹងមិនត្រឹមតែជួយជំរុញឲ្យមានបរិស្ថានឌីជីថលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ឲ្យមនុស្សនូវជំនាញថ្មីដែលត្រូវការជាចាំបាច់សម្រាប់យុគសម័យបច្ចេកវិទ្យាទំនើប និងបដិវត្តន៍ឧស្សាហកម្មទី៤។

## ឯកសារយោង

(2019). *G20 Ministerial Statement on Trade and Digital Economy.* Retrieved from https://g20trade-digital.go.jp/dl/Ministerial_Statement_on_Trade_and_Digital_Economy.pdf

(2018). *Rectangular Strategy Phase IV.* Phnom Penh.

(2018). *World Trade Report .* https://www.wto.org/english/res_e/publications_e/wtr18_2_e.pdf.

ADB. (2018). *Understanding the Digital Economy: What Is It and How Can It Transform Asia?* Retrieved from Asia Development Bank : https://www.adb.org/news/events/understanding-digital-economy-what-it-and-how-can-it-transform-asia

Ahmad, N. (2018). *Towards a Framework for Measuring the Digital Economy.* Paper prepared for the 16th Conference of IAOS, OECD, Paris.

Alina, N. (2016 ). *Trend and Dimension of Digital Economy .* Univeristy of Petrosani .

Australian Government. (n.d.). *The Concept of Digital Economy*. Retrieved from Australian Government: https://www.alrc.gov.au/publications/3-policy-context-inquiry/concept-digital-economy

Barefoot, K., Curtis, D., Jolliff, W., Nicholson, J. R., & Omohundro, R. (2018). *Defining and Measuring the Digital Economy.* Working Paper, U.S. Department of Commerce , Bureau of Economic Analysis , Washington. Retrieved from https://www.bea.gov/sites/default/files/papers/defining-and-measuring-the-digital-economy.pdf

Bukht, R., & Heeks, R. (2017). *Defining, Conceptualising and Measuring the Digital Economy.* Centre for Development Informatics, Global Development Institute, SEED. Retrieved from http://www.gdi.manchester.ac.uk/research/publications/working-papers/di/

Council of the European Union. (2018). *Council Conclusion on Cambodia.* Brussels.

*Electronic Business (E-Business)*. (n.d.). Retrieved from Technopedoa : https://www.techopedia.com/definition/1493/electronic-business-e-business

European Commission. (2013). *Revised EU trade scheme to help developing countries applied on 01 January 2014.* Brussels: European Commission.

European Union. (2012). Regulations (EU) No. 978/2012 of the European Parliament and of the council of 25 october 2012. 10.

Heng, P. (n.d.). *Embracing the Digital Economy: Policy Considerations for Cambodia.* Enrich Institute.

IMF. (2018). *Measuring Digital Economy.* Washington, D.C. : International Monetary Fund.

Manet, S. (2018, March 7). *Cambodia to be a digital economy by 2023*. Retrieved from Khmer Times : https://www.khmertimeskh.com/112147/cambodia-to-be-a-digital-economy-by-2023/

May, K. (2019, 03 13). *Full-fledged digital economy not likely in the next decade: Minister*. Retrieved from Khmer Times: https://www.khmertimeskh.com/50586102/full-fledged-digital-economy-not-likely-in-the-next-decade-minister/

Mesenbourg, T. L. (2001). *Measuring the Digital Economy .* Retrieved from https://www.census.gov/content/dam/Census/library/working-papers/2001/econ/umdigital.pdf

OECD. (2012). *The Digital Economy 2012.*

OECD. (2017). *OECD Digital Economy Outlook 2017.* Paris: OECD Publishing. Retrieved from https://www.oecd-ilibrary.org/science-and-technology/oecd-digital-economy-outlook-2017_9789264276284-en

Oxford, D. (n.d.). *Digital Economy*. Retrieved from Oxford Dictionary: https://en.oxforddictionaries.com/definition/us/digital_economy

Ramos, M., & Steiner, A. (2019, 01 16). *How the digital finance revolution can drive sustainable development*. Retrieved from World Economic Forum: https://www.weforum.org/agenda/2019/01/digital-finance-can-help-sustainable-development-goals

Sirimanne, S. N. (2017). *The Development Dimension of e-Commerce and Digital Economy.* Intergovernmental Group of Experts on e-Commerce and Digital Economy, United Nations Conference on Trade and Development, Geneva. Retrieved from https://unctad.org/meetings/en/Presentation/tdb_ede2017p01_SSirimanne_en.pdf

Smith, J., & Amour, L. S. (2019, Jan 18). *This is the digital future we need*. Retrieved from World Economic Forum: https://www.weforum.org/agenda/2019/01/the-digital-future-we-need

UNCTAD. (2016). *The Least Developed Countries Report 2016: The Path to Graduation and Beyong-Making the Most of the Process.* UNCTAD.

UNCTAD. (2017). *The New Digital Economy and Development.* Retrieved from https://unctad.org/en/PublicationsLibrary/tn_unctad_ict4d08_en.pdf

*What is Digital Economy?* (2017, June 28). Retrieved from Youtube : https://www.youtube.com/watch?v=kQPs__9WT9k

WTO. (2018). *The Future of World Trade: How digital economies are transforming global commerce?* World Trade Report 2018, WTO. Retrieved from https://www.wto.org/english/res_e/publications_e/world_trade_report18_e.pdf



Cambodia Development Center

Cambodia Development Center (@cd.centerkh)

Cambodia Development Center

Building E, University of Puthisastra, #55, Street 184, Sangkat Boeung Raing, Khan Daun Penh

info@cd-center.com | (+855) 10 950 456

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

# ឯកសារជំនួយស្មារតី៖
# សារៈប្រយោជន៍នៃសាយ
# បើស្បៀសក្តុខដំណើការ
# អតិចឡ្យនៅកម្ពុជា

ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧

# ប្រធានបទ៖ សារប្រយោជន៍នៃសាយប៊ើស៊ែរក្នុងដំណើរការអភិវឌ្ឍនៅកម្ពុជា

ប៉ាវី សុភារ័ត្ន *

ជ័យលាភីលេខ ២ ក្នុងការប្រកួតសំណេរឆ្នាំ ២០១៧

កម្ពុជាគឺជាប្រទេសកំពុងអភិវឌ្ឍមួយនៅអាស៊ី ដែលកំពុងតែមានសន្ទុះសេដ្ឋកិច្ច និងបានក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៦។ ការអភិវឌ្ឍនេះកើតចេញពីកត្តាជម្រុញជាច្រើន ក្នុងនោះរួមមានការជួយជម្រុញដោយប្រយោលពីវត្តមានរបស់សាយប៊ើស៊ែរផងដែរ។ សាយប៊ើស៊ែរសំដៅដល់ការប្រើប្រាស់ពិភពនិមិត្ត ដែលបង្កើតឡើងដោយប្រព័ន្ធកុំព្យូទ័រ បច្ចេកវិទ្យាដើម្បីបង្កើតបណ្តាញ ទូទាំងពិភពលោក ដើម្បីសម្រួលដល់ការទំនាក់ទំនង។ តាមរយៈការសម្របសម្រួលរបស់សាយប៊ើស៊ែរនេះ វាក៏បានសម្រួលដល់ដំណើរការអភិវឌ្ឍនៅកម្ពុជា។ សារសំខាន់៣ចម្បងដែលសាយប៊ើស៊ែរ បានចូលរួមចំណែកក្នុងដំណើរការអភិវឌ្ឍនៅកម្ពុជានោះគឺ បង្កើតច្រកនៃឱកាស, វេទិកាសម្រាប់ធ្វើការរិះគន់ និងសម្រួលដល់ការសិក្សាស្រាវជ្រាវ។

សារសំខាន់ទី១គឺ សាយប៊ើស៊ែរបង្កើតច្រកនៃឱកាសសម្រាប់ការអភិវឌ្ឍ។ យើងសង្កេតឃើញថា បច្ចុប្បន្នមានការផ្សព្វផ្សាយព័ត៌មានជាច្រើន នៅក្នុងសាយប៊ើស៊ែរ និងតាមរយៈបណ្តាញសង្គមនានាជាច្រើន។ យោងតាមគេហទំព័រ "តើនរណាជាម្ចាស់ប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា?" ដែលជាគម្រោងរបស់អង្គការអ្នករាយការណ៍គ្មានព្រំដែន និងអង្គការCCIM បានសម្គាល់ថា "៣៩% នៃប្រជាជនកម្ពុជា បានចូលទៅក្នុងប្រព័ន្ធផ្សព្វផ្សាយអនឡាញ ដែលធ្វើឱ្យប្រព័ន្ធអ៊ីនធឺណេត ក្លាយជាវិស័យដែលមានប្រជាប្រិយភាពបំផុតលំដាប់ទី២ នៅក្នុងប្រទេស"។[1] គេហទំព័រដដែលនេះបានបង្ហាញផងដែរថា ប្រជាជនកម្ពុជាប្រើប្រាស់អ៊ីនធឺណេតដើម្បីទទួលបានព័ត៌មាន។ ជាក់ស្តែងព័ត៌មានទាំងនោះរួមមាន ព័ត៌មានទាន់ហេតុការណ៍ ព័ត៌មានអន្តរជាតិ និងព័ត៌មានអាហារូបករណ៍ ឬការប្រកួតប្រជែងថ្នាក់អន្តរជាតិ និងថ្នាក់តំបន់ជាដើម។ លំហូរនៃព័ត៌មានទាំងនេះ គឺជាច្រកនៃឱកាស សម្រាប់ប្រជាជនកម្ពុជា។ ឧទាហរណ៍ អ្នកជំនួញវ័យក្មេងអាចបង្កើតជំនួញថ្មីៗ និងផ្សព្វផ្សាយផលិតផលរបស់ខ្លួន ទៅកាន់អតិថិជនរបស់ខ្លួន តាមរយៈប្រព័ន្ធអនឡាញ។ លើសពីនេះទៅទៀត យើងឃើញថា មុនពេលដែលសាយប៊ើស៊ែរ ឬអ៊ីនធើណេតមានប្រជាប្រិយភាពនៅកម្ពុជា ការផ្សព្វផ្សាយព័ត៌មាននានា ជាពិសេសព័ត៌មានអាហារូបករណ៍ ឬការប្រកួតប្រជែងអន្តរជាតិនៅមានកម្រិត ពោលគឺមានតែការបិទផ្សាយនៅនាយកដ្ឋានអាហារូបករណ៍នៅជិតប៉ុស្តិ៍អប្សរា ឬតាមសាកលវិទ្យាល័យមួយចំនួនប៉ុណ្ណោះ ដែលជាហេតុបង្អាក់ឱកាសអភិវឌ្ឍខ្លួនរបស់យុវជន សិស្ស និងនិស្សិត។ ដោយសារសាយប៊ើស៊ែរនេះ ទើបសិស្សនិស្សិតអាចស្វែងរកឱកាស ដើម្បីទៅសិក្សានៅប្រទេសអភិវឌ្ឍនានាបានងាយស្រួល និងប្រសើរជាងមុន ព្រោះ

[1] http://mom-kh.com/kh/online_media

*ប៉ាវី សុភារ័ត្ន គឺជានិស្សិតដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

© រក្សាសិទ្ធដោយ មអក | ខ្លឹមសារនៃអត្ថបទនេះគឺជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

ការដាក់អាហារូបករណ៍ ឬការប្រកួតប្រជែងនានាភាគច្រើន អាចប្រព្រឹត្តទៅបាន តាមការដាក់ពាក្យស្នើសុំតាមអនឡាញ។ កត្តាដែលបានរៀបរាប់ខាងលើនេះ បានជម្រុញឱ្យមាន ការអភិវឌ្ឍធនធានមនុស្សមួយផ្នែកដល់ប្រជាជនកម្ពុជា។

សារសំខាន់ទី២គឺ សាយប៊ើស៊្បែសបង្កើតជាវេទិការសម្រាប់ធ្វើការរិះគន់ជូនដល់សាធារណជនទូទៅ។ ដោយសារការផ្សព្វផ្សាយបញ្ចេញមតិ ក្នុងបណ្តាញសង្គមមានភាពឆាប់រហ័ស ហើយទូលំទូលាយ យើងឃើញថាមានការរិះគន់មួយចំនួនដល់កិច្ចការរបស់រដ្ឋាភិបាលដើម្បីស្តាបនា និងទាមទារការបកស្រាយផ្សេងៗ។ ជាក់ស្តែង ការរិះគន់លើការសាងសង់ផ្លូវថ្មើរជើងអាកាសឆ្លងកាត់ផ្លូវនៅជិតសាលារៀន និងវិទ្យាល័យជំពូវន្ត ការរិះគន់ ទៅលើច្បាប់ចរាចរណ៍ផ្លូវគោក និងការរិះគន់ពីការស្ថាបនាភ្លោងទ្វាតុបតែងនៅក្នុងទីក្រុងថាដូចជាមិនមានការច្នៃប្រឌិតជាដើម។ តាមរយៈប្រព័ន្ធសាយប៊ើស៊្បែសនេះហើយ សាធារណជនអាចដើរតួជា អ្នកឃ្លាំមើល និងធ្វើការរិះគន់ដល់ភាពអវិជ្ជមានក្នុងសង្គម ដើម្បីឱ្យការអភិវឌ្ឍមានភាពប្រសើរឡើង ជាពិសេសជួយឱ្យរាជរដ្ឋាភិបាលក៏ដូចជាអ្នកបង្កើតច្បាប់នានាបានលឺ និងមើលឃើញ ពីតម្រូវការមូលដ្ឋានរបស់ប្រជាជន។ ក្រៅពីនេះ សាយប៊ើស៊្បែសអាចធ្វើឱ្យសាធារណជនមើលឃើញពិភពលោកខាងក្រៅ (ប្រទេសអភិវឌ្ឍនានាក្រៅពីកម្ពុជា) ដើម្បីបង្កើតជាគំនិតប្រៀបធៀបថា កម្ពុជាបានអភិវឌ្ឍនខ្លួន ឬបានដើរដល់ចំណុចណាមួយហើយ នៅក្នុងតំបន់ និងពិភពលោក។

សារសំខាន់ចុងក្រោយគឺជាប្រភពនៃការសិក្សាស្រាវជ្រាវ។ យើងសង្កេតឃើញថា កម្ពុជានៅខ្វះខាតឯកសារស្រាវជ្រាវ ឬបណ្ណាល័យដែលជាប្រភពឯកសារដ៏សំខាន់ ដើម្បីធ្វើការស្រាវជ្រាវនានា នៅឡើយ។ ជាសក្ខីភាព នៅទីក្រុងភ្នំពេញមានបណ្ណាល័យសាធារណៈមិនច្រើនប៉ុន្មានទេ។ ការស្វែងរកឯកសារបោះពុម្ព ពេលខ្លះផ្តល់ផលវិបាកដល់ការស្រាវជ្រាវរបស់សាធារណជន ជាពិសេសសិស្សនិងនិស្សិត។ ដូច្នេះ សាយប៊ើស៊្បែសបានដើរតួជាបណ្ណាល័យគ្មានរូបមួយ ដែលជួយសម្រួលដល់ស្វែងរកឯកសារចាំបាច់នានា ក្នុងការបំពេញការងារ និងការសិក្សារបស់និស្សិតបានប្រសើរជាងមុន។

សរុបមក ការបង្កើតច្រកនៃឱកាស, បង្កើតជាវេទិការរិះគន់ដើម្បីស្ថាបនា និងជាកន្លែងសម្រួលដល់ការស្រាវជ្រាវនេះហើយ ដែលជាសារសំខាន់គោលរបស់សាយប៊ើស៊្បែស ក្នុងការចូលរួមចំណែកអភិវឌ្ឍប្រទេសកម្ពុជាទៅកាន់កម្រិតមួយ។ កត្តាទាំង៣ដែលបានរៀបរាប់ខាងលើនេះ បានជួយជម្រុញឱ្យមាន ការអភិវឌ្ឍលើសមត្ថភាព ធនធានមនុស្ស បង្កើតជាកញ្ចក់ឆ្លុះសង្គមតាមរយៈការបើកចំហទទួលការរិះគន់ស្ថាបនា ការបង្ហាញកិច្ចការងាររបស់រាជរដ្ឋាភិបាល និងជាបណ្ណាល័យដើម្បីជម្រុញឱ្យមានការកែប្រែភាពអវិជ្ជមាន មកជាលទ្ធផលវិជ្ជមានដើម្បីកិច្ចអភិវឌ្ឍប្រទេសជាតិ។

Cambodia Development Center
Cambodia Development Center (@cdcenter_kh)
Cambodia Development Center (@cd.centerkh)
Cambodia Development Center
Cambodia Development Center
មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center
Building E, University of Puthisastra, #55, Street 180-184, Sangkat Boeung Raing, Khan Daun Penh
info@cd-center.com | (+855) 16 616 951

# INTRODUCTION

# E-COMMERCE

INTRODUCTION

# E-COMMERCE

Jenifer Mitra
April 14, 2010

# Table of Contents


1. E-Commerce overview
   1.1 Definition of e-commerce
   1.2 Brief history of e-commerce

2. E-Commerce categories
   2.1 Two major categories
   2.2 Other categories

3. Benefits of e-commerce
   3.1 Benefits to organizations
   3.2 Benefits to consumers

4. Business applications

6. Online shopping

8. Interesting facts and figures

10. Summary and Conclusion

12. References

# E-Commerce Overview

- Definition of E-Commerce
- Brief History of E-Commerce



## Definition of E-Commerce

- *E-Commerce or Electronic commerce is* a process of buying, selling, transferring, or exchanging products, services, and/or information via electronic networks and computers

# Brief History of E-Commerce

- 1970s
  - E- commerce meant the facilitation of commercial transactions electronically, using technology such as Electronic Data Interchange (EDI) and Electronic Funds Transfer (EFT), allowing businesses to send commercial documents like purchase orders or invoices electronically.

# Brief History of E-Commerce (cont)..

- 1980s
  - The growth and acceptance of credit cards
  - Automated teller machines (ATM)
  - Telephone banking
  - Airline reservation system



# Brief History of E-Commerce (cont)..

- 1990s
  - The Internet commercialized and users flocked to participate in the form of *dot-coms*, or *Internet start-ups*
  - Innovative applications ranging from online direct sales to e-learning experiences

# Brief History of E-Commerce (cont)..

- 2000s
  - Many European and American business companies offered their services through the World Wide Web.
  - Since then, People began to associate a word “e-commerce”

# E-Commerce Categories

- Two major categories
- Other categories



# Two Major Categories

- **Business-to-consumer (B2C)** :

  Online transactions are made between businesses and individual consumers. E.g. Amazon.com, eBay.com.

- **Business-to-business (B2B):**

  Businesses make online transactions with other businesses.

# Other Categories

- *Consumer-to-consumer (C2C)*
- Mobile commerce (m-commerce)
- *E-learning*
- *E-government*



# Benefits of E-Commerce

- Benefits to organizations
- Benefits to consumers



# Benefits to organizations

- Global reach
- Cost reduction
- Supply chain improvements
- Extended hours: 24/7/365
- Customization
- Improved customer relations

# Benefits to consumers

- More products and services
- Cheaper products and services
- Instant delivery
- Information availability
- Participation in auctions

## Business applications

- Email
- Instant messaging
- Online shopping and order tracking
- Online banking
- Shopping cart software
- Teleconferencing
- Electronic tickets

# Online Shopping

- Online shopping is the process of buying goods and services from merchants who sell on the Internet
- Online consumers are evenly split between men and women and tend to be better educated, younger, and more affluent than the general population

# Online Shopping (cont)..



- Advantages:
  - 24-hour access
  - Ability to comparison shop
  - The in-home privacy
  - Variety

## Online Shopping (cont)..

- Favourite websites for shopping include those featuring:
  - Event tickets
  - Online periodicals subscription
  - Flowers and gifts
  - Consumer electronics
  - Travel

# Online Shopping (cont)..




7

**How do you buy something**

# Interesting Facts and Statistics



- Every 1.2 seconds, a Canadian makes a purchase with their PayPal account
- Almost 20 per cent of Canadians make three or more online purchases per month (comScore 2009).

## Interesting Facts and Statistics (cont..)

- Ninety per cent of Canadians do their online shopping exclusively from home and only one per cent of Canadians shop online exclusively from work (comScore 2009).
- Experts predict that online sales will reach US$328 billion by 2010

## Summary and Conclusion

- The Internet has lead to the birth and evolution E-commerce. E-commerce has now become a key component of many organizations in the daily running of their business.

- As the Internet and in turn E-commerce has developed, and continues to evolve and grow, it is vital that any organization, in any particular industry, must base its strategic planning around such a rapidly growing medium.

# References (pictures)


1. Web. 14 Apr. 2010. http://www.siennawebdesigns.com/images/new-ecommerce.jpg
2. Web. 13 Apr. 2010. http://www.capitalbanknj.com/images/splash_images/products/telephone_
3. Web. 13 Apr. 2010. http://zunia.org/typo3temp/pics/427d6f0cb0.jpg
4. Web. 12 Apr. 2010. http://elearningeduc.files.wordpress.com/2009/02/elearning2.jpg
5. Web. 12 Apr. 2010. http://www.microinfoware.com/images/E_comm.jpg
6. Web. 13 Apr. 2010. http://www.zealousweb.com/img/ecommerce_development.jpg
7. Web. 13 Apr. 2010. http://images.google.ca/imgres?imgurl=http://www.teach-ict.com/ecdl/mod
8. Web. 13 Apr. 2010. http://www.duck-design.com/images/paypal_logo-2.gif

# References (content)


- Web. 10 Apr. 2010. www.rogeliodavila.com/tie/TIE%20notas/EC2004_ch01.ppt
- Web. 10 Apr. 2010. http://en.wikipedia.org/wiki/E-commerce
- Web. 10 Apr. 2010. http://wiki.media-culture.org.au/index.php/E-commerce_-_Ov
- Web. 10 Apr. 2010. http://www.exampleessays.com/viewpaper/19642.html
- Web. 12 Apr. 2010. http://www.newswire.ca/en/releases/archive/October2009/3(
- Kerin, Roger A., Steven William. Hartley, and William Rudelius. "Retailing and Wholesaling." *Marketing: the Core*. Boston, Mass.: McGraw-Hill/Irwin, 2009. 217-19. Print.

Thank You

☺

Are there any questions?